Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized





# កម្ពុជា៖ ឆ្ពោះទៅសម្រេចសក្ដានុពលរបស់នគរូបនីយកម្ម

ក្រុមធនាគារពិភពលោក

ខែសីហា ២០១៨

# មាតិកា

**សេចក្តីថ្លែងអំណរគុណ** ........ ៤
**សេចក្តីសង្ខេប** ........ ៥
**ផ្នែកទី ១៖ សេចក្តីផ្តើម និងបរិបទ** ........ ១១
១.១ សេចក្តីផ្តើម ........ ១១
១.២ លំនាំនគរូបនីយកម្ម និងសក្តានុពលសេដ្ឋកិច្ចរបស់ទីក្រុង ........ ១២
*១.២.១ ទីក្រុងក្នុងប្រទេសកម្ពុជា* ........ ១២
*១.២.២ សេចក្តីផ្តើមស្តីពីសន្ទស្សន៍សក្តានុពលសេដ្ឋកិច្ច* ........ ១៣
*១.២.៣ កត្តាមានឥទ្ធិពលលើសក្តានុពលសេដ្ឋកិច្ច* ........ ១៣
*១.២.៤ វិធីសាស្ត្រសម្រាប់បង្កើតកម្រងទិន្នន័យសូចនាករនីមួយៗ* ........ ១៤
*១.២.៥ ការបង្កើត និងការចាត់ថ្នាក់សន្ទស្សន៍សក្តានុពលសេដ្ឋកិច្ច (EPI)* ........ ១៦
*១.២.៦ លទ្ធផល* ........ ១៧
១.៣ ការពណ៌នាលក្ខណៈប្រភេទផ្សេងៗរបស់ទីក្រុង និងសក្តានុពលសេដ្ឋកិច្ច ........ ១៩
*១.៣.១ សេចក្តីផ្តើម* ........ ១៩
*១.៣.២ ទីក្រុងច្រករបៀងសេដ្ឋកិច្ចតំបន់* ........ ២១
*១.៣.៣ ទីក្រុងច្រកឆ្លងកាត់* ........ ២៣
*១.៣.៤ ទីក្រុង ឬទីប្រជុំជនជាប់ព្រំដែន* ........ ២៦
*១.៣.៥ រដ្ឋធានី* ........ ២៧
**ផ្នែកទី ២៖ ឧបសគ្គដល់ការឈានទៅសម្រេចឱ្យបានពេញលេញនូវសក្តានុពលសេដ្ឋកិច្ចរបស់នគរូបនីយកម្ម** ........ ២៩
២.១ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសម្រាប់ការអភិវឌ្ឍទីក្រុង ........ ២៩
២.២ ស្ថាប័ន អភិបាលកិច្ច និងហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងទីក្រុង ........ ៤៤
*២.២.១ សេចក្តីផ្តើម* ........ ៤៤
*២.២.២ ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយ* ........ ៤៤
*២.២.៣ សមត្ថភាពផ្នែករដ្ឋបាល* ........ ៤៦
*២.២.៤ ការផ្តល់ហិរញ្ញប្បទាន* ........ ៥០
២.៣ ការធ្វើផែនការប្រើប្រាស់ដីធ្លីឱ្យមានចីរភាពសម្រាប់ការរីកចម្រើនទីក្រុងមានប្រសិទ្ធផល ........ ៥៥
*២.៣.១ សេចក្តីផ្តើម* ........ ៥៥
*២.៣.២ ប្រព័ន្ធរៀបចំផែនការជាតិ* ........ ៥៥
*២.៣.៣ បញ្ហាប្រឈមចំពោះការអភិវឌ្ឍ និងការអនុវត្តផែនការរៀបចំក្រុង* ........ ៥៨
*២.៣.៤ ការធ្វើផែនការរៀបចំក្រុងនៅក្រុងបាត់ដំបង និងក្រុងព្រះសីហនុ* ........ ៦២
*២.៣.៥ សន្និដ្ឋាន* ........ ៦៩
**ផ្នែកទី ៣៖ កាលានុវត្តភាពសម្រាប់ឈានទៅសម្រេចឱ្យបានពេញលេញនូវសក្តានុពលរបស់នគរូបនីយកម្ម** ........ ៧០
៣.១ សេចក្តីផ្តើម ........ ៧០
*៣.១.១ អាទិភាពសម្រាប់ពង្រឹងការអភិវឌ្ឍទីក្រុងរបស់កម្ពុជា* ........ ៧១
៣.២ ការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព ........ ៧៤
៣.៣ លើកកម្ពស់ការអភិវឌ្ឍដែនដីដោយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ឱ្យមានរបាយជាលក្ខណៈយុទ្ធសាស្ត្រ

ទាំងនៅតាមវិស័យ និងទាំងនៅតាមភូមិសាស្ត្រ ..... ៧៤
៣.៤ ការពង្រឹងស្ថាប័ន និងហិរញ្ញប្បទាន ..... ៧៦
៣.៥ ធ្វើឱ្យប្រសើរឡើងនូវការធ្វើផែនការប្រើប្រាស់ដីធ្លីប្រកបដោយចីរភាព សម្រាប់ការរីកចម្រើនទីក្រុងមានប្រសិទ្ធផល ..... ៨២
៣.៦ ធានាឱ្យមានអភិក្រមបែបបរិយាប័ន្ន ..... ៨៥
៣.៧ សំណើកម្មវិធីដើម្បីធ្វើអាទិភាពការអភិវឌ្ឍក្រុង ..... ៨៦
*៣.៧.១ សកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ ..... ៨៦*
*៣.៧.២ បទពិសោធន៍របស់ធនាគារពិភពលោកក្នុងគម្រោងផ្នែករៀបចំក្រុង ..... ៨៩*
**ផ្នែកទី ៤៖ ឧបសម្ព័ន្ធ ..... ៩២**
ឧបសម្ព័ន្ធ ៤.១៖ ទីក្រុង និងតំបន់មិនមែនជាក្រុងទីប្រជុំជននៅប្រទេសកម្ពុជា ..... ៩២
ឧបសម្ព័ន្ធ ៤.២៖ លទ្ធផលនៃការគណនាសន្ទស្សន៍ EPI និងចំណាត់ថ្នាក់ស្រុក ..... ៩៣
ឧបសម្ព័ន្ធ ៤.៣៖ លទ្ធផលនៃការវិភាគតម្លៃលេខទិន្នន័យក្នុងកន្សោម និងក្រៅកន្សោម ..... ១០៦

# មាតិកាតារាង

តារាង ១.១៖ កត្តាធាតុចូលសម្រាប់ការវិភាគសន្ទស្សន៍សក្តានុពលសេដ្ឋកិច្ច (EPI) កម្ពុជា ..... ១៤
តារាង ១.២៖ ចំណាត់ថ្នាក់តម្លៃលេខ EPI របស់ស្រុក ..... ១៧
តារាង ១.៣៖ យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍនក្រុង (NUDS) - ប្រភេទទីក្រុងដែលអាចមាននៅកម្ពុជា ..... ២០
តារាង ១.៤៖ សំណើប្រភេទរបស់ទីក្រុងក្នុងប្រទេសកម្ពុជា ..... ២០
តារាង ១.៥៖ ច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ ..... ២២
តារាង ២.១៖ ភាពខុសៗគ្នានៃចំណាយជាក់ស្តែង(ជាប្រាក់រៀល)របស់បណ្តាក្រុង ខណ្ឌ រាជធានីភ្នំពេញ សម្រាប់ពលរដ្ឋម្នាក់ៗ ក្នុងឆ្នាំ២០១៦ ..... ៤៧
តារាង ២.២៖ កម្រិតភាពពេញចិត្តជាមួយការផ្តល់សេវារបស់ស្រុក/ក្រុង ..... ៤៨
តារាង ២.៣៖ ការចំណាយជាក់ស្តែងរបស់ថ្នាក់ក្រោមជាតិ តាមប្រភេទ គិតជាមធ្យមភាគ(%) រវាងឆ្នាំ២០១៤-២០១៦ ..... ៥០
តារាង ២.៤៖ ចំណូលរបស់ក្រុងទៅតាមប្រភព (២០១៧) ..... ៥១
តារាង ២.៥៖ ការប៉ាន់ទុកជាមុននូវតម្រូវការមូលនិធិសម្រាប់ស្រុក/ក្រុង ឆ្នាំ២០១៨-២០២៤ ..... ៥៣
តារាង ២.៦៖ ស្ថានភាពនៃការរៀបចំប្លង់ភូមិសាស្ត្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ..... ៥៧
តារាង ៣.១៖ សេចក្តីសង្ខេបអនុសាសន៍គោលនយោបាយអាទិភាព ..... ៧១

# មាតិការូបភាព

រូបភាព ១.១៖ រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិរបស់កម្ពុជា ..... ១២
រូបភាព ១.២៖ ឯកតានៃការវាយតម្លៃ EPI ..... ១៣
រូបភាព ១.៣៖ លទ្ធភាពចូលទៅកាន់ទីផ្សារ ..... ១៥
រូបភាព ១.៤៖ តំណភ្ជាប់ជាមួយបណ្តាញផ្លូវដឹកជញ្ជូន ..... ១៥
រូបភាព ១.៥៖ ដង់ស៊ីតេសេដ្ឋកិច្ច ..... ១៥
រូបភាព ១.៦៖ កម្រិតនគរូបនីយកម្ម ..... ១៦
រូបភាព ១.៧៖ មូលធនមនុស្ស ..... ១៦
រូបភាព ១.៨៖ ផែនទីប្រទេសកម្ពុជាអមដោយពិន្ទុឆៅរបស់ EPI ..... ១៨

រូបភាព ១.៩៖ ផែនទីប្រទេសកម្ពុជាអមដោយចំណាត់ថ្នាក់ EPI ..... ១៨
រូបភាព ១.១០៖ លទ្ធផលតាមខេត្ត និងចំណាត់ថ្នាក់ EPI ..... ១៩
រូបភាព ១.១១៖ ច្រករបៀងសេដ្ឋកិច្ច និងទីក្រុងក្នុងប្រទេសកម្ពុជា ..... ២២
រូបភាព ១.១២៖ តំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា ..... ២៦
រូបភាព ២.១៖ បណ្តាញផ្លូវអិចស្ព្រេសវ៉េដែលស្នើឡើងដោយប្រទេសចិន និងប្រទេសជប៉ុន ..... ៣០
រូបភាព ២.២៖ ចំណាយជាក់ស្តែងសរុប (ជាប៊ីលានរៀល) នៅថ្នាក់ក្រោមជាតិ ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៥ ..... ៥០
រូបភាព ២.៣៖ ទំនាក់ទំនងរវាងប្រភេទនៃការផ្តល់មូលនិធិ និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ..... ៥២
រូបភាព ២.៤៖ ឋានានុក្រមរបស់ផែនការភូមិសាស្ត្រនៅកម្ពុជា ..... ៥៦
រូបភាព ២.៥៖ រចនាសម្ព័ន្ធរៀបចំក្រុងបាត់ដំបង និងការិយាល័យក្រុង ..... ៥៩
រូបភាព ២.៦៖ ដ្យាក្រាមនៃចក្ខុវិស័យអភិវឌ្ឍន៍ក្រុងបាត់ដំបងដល់ឆ្នាំ២០២០ ..... ៦២
រូបភាព ២.៧៖ ប្លង់លម្អិតសម្រាប់រៀបចំប្រព័ន្ធលម្ហផ្ទៃបៃតងក្នុងក្រុងបាត់ដំបង ..... ៦៣
រូបភាព ២.៨៖ ដំណើរការអនុវត្តវិធានការកែលម្អលម្ហផ្ទៃបៃតងនៅតាមដងស្ទឹងសង្កែ ..... ៦៣
រូបភាព ២.៩៖ គោលការណ៍ណែនាំសម្រាប់ការការពារបេតិកភណ្ឌក្រុង ..... ៦៤
រូបភាព ២.១០៖ សេចក្តីព្រាងប្លង់គោលរបស់ទីភ្នាក់ងារ JICA សម្រាប់ក្រុងព្រះសីហនុ ..... ៦៩
រូបភាព ៣.១៖ ការវិភាគភូមិសាស្ត្រសម្រាប់ការផ្តល់មជ្ឈមណ្ឌលថែទាំកុមារ ..... ៨៤
រូបភាព ៣.២៖ ដីស្រុត ដង់ស៊ីតេប្រជាជន និងបណ្តាញផ្គត់ផ្គង់ទឹកស្អាតនៅទីក្រុង Semarang ..... ៩១

# មាតិកាប្រអប់

ប្រអប់ ១.១៖ តំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា ..... ២៥
ប្រអប់ ២.១៖ សមត្ថភាពមានកម្រិតរបស់ទីលានចាក់សំរាមនៅភ្នំពេញ ..... ៣៦
ប្រអប់ ២.២៖ ការគ្រប់គ្រងសំណល់រឹងនៅក្រុងសៀមរាប ..... ៣៧
ប្រអប់ ២.៣៖ ឧទាហរណ៍នៃការអភិវឌ្ឍអចលនទ្រព្យខ្វះការត្រួតពិនិត្យនៅក្រុងព្រះសីហនុ ..... ៤០
ប្រអប់ ២.៤៖ ការអភិវឌ្ឍបៃតងនៅកម្ពុជា ..... ៤៣
ប្រអប់ ២.៥៖ គម្រោងសាកល្បងប្រើតារាងសហគមន៍ដាក់ពិន្ទុក្រុមប្រឹក្សាស្រុក/ក្រុង របស់អង្គការ PACTs ..... ៤៩
ប្រអប់ ២.៥៖ ការកសាងសមត្ថភាពយូរអង្វែងសម្រាប់ការរៀបចំប្លង់ក្រុង - ករណីក្រុងបាត់ដំបង ..... ៦៥
ប្រអប់ ៣.១៖ ការប្រើអភិក្រមអភិវឌ្ឍន៍ដែនដី ..... ៧៥
ប្រអប់ ៣.២៖ ការធ្វើវិមជ្ឈការមុខងារផ្តល់សេវាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសហ្វីលីពីន តាមរយៈអភិក្រមសមាហរណកម្មខ្សែបណ្តោយ ..... ៧៧
ប្រអប់ ៣.៣៖ ការពង្រឹងសមត្ថភាពរដ្ឋាភិបាលមូលដ្ឋានដើម្បីបំពេញមុខងារវិមជ្ឈការ តាមរយៈការផ្តល់សម្បទានហិរញ្ញវត្ថុផ្អែកលើគុណផលការងារ នៅប្រទេសតង់សានី និងប្រទេសអ៊ូហ្គង់ដា ..... ៧៩
ប្រអប់ ៣.៤៖ ឧទាហរណ៍ជាសកលស្តីពីយន្តការយកពន្ធលើផលចំណេញពីការកើនតម្លៃដីដោយសារការបំពាក់ហេដ្ឋារចនាសម្ព័ន្ធ (Land Value Capture Schemes) ..... ៨១
ប្រអប់ ៣.៦៖ បទពិសោធន៍ប្រទេសសិង្ហបុរីក្នុងការរៀបចំនគរូបនីយកម្មដោយផ្អែកលើទិន្នន័យ ..... ៨៤
ប្រអប់ ៣.៧៖ គម្រោងទីក្រុងយុទ្ធសាស្ត្រនៅប្រទេសតង់សានី - ការកែលម្អហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងអភិបាលកិច្ចទីក្រុង ..... ៨៩
ប្រអប់ ៣.៨៖ គម្រោងកែលម្អសង្កាត់ក្នុងទីក្រុងកាំជី - ការវិនិយោគលើការអភិវឌ្ឍទីធ្លាសាធារណៈដោយប្រើអភិក្រមចូលរួម ..... ៩០
ប្រអប់ ៣.៩៖ មន្ទីរពិសោធន៍ធ្វើប្លង់រៀបចំក្រុង (ប្រទេសឥណ្ឌូណេស៊ី) - គម្រោងធនាគារពិភពលោក ដើម្បីបង្កើតហេដ្ឋារចនាសម្ព័ន្ធទិន្នន័យភូមិសាស្ត្រទីក្រុង ..... ៩០

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានរៀបចំឡើងដោយក្រុមការងារមួយ ដែលដឹកនាំដោយលោកស្រី Judy Baker (នាយក្រុមសេដ្ឋវិទូ) និងសមាជិកក្រុមដែលរួមមាន Sarah Xiyuan Lin (អ្នកឯកទេសទីក្រុង និងជាសហប្រធានផ្នែកនៃក្រុមការងារ), Huyen Thi Phuong Phan (អ្នកឯកទេសជាន់ខ្ពស់ផ្នែកទីក្រុង និងជាសហប្រធានផ្នែកនៃក្រុមការងារ), Natsuko Kikutake (អ្នកឯកទេសទីក្រុង), Erik Johnson (អ្នកឯកទេសជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍សង្គម), Frank Woerden (នាយវិស្វករផ្នែកបរិស្ថាន), ឡេង ប៊ុនឡុង (អ្នកឯកទេសជាន់ខ្ពស់ផ្នែកបរិស្ថាន), Katie McWilliams (មន្ត្រី IT), ទេព ម៉ាកាធី (អ្នកផ្តល់យោបល់ជាន់ខ្ពស់), សុខ ចំរើន (អ្នកផ្តល់យោបល់) និង អ៊ូ ណារីយ៉ា (ជំនួយការកម្មវិធី)។ Mark Roberts (សេដ្ឋវិទូជាន់ខ្ពស់ផ្នែកទីក្រុង) បានផ្តល់ឱ្យក្រុមការងារនេះនូវការណែនាំ មានប្រយោជន៍ស្តីពីសន្ទស្សន៍សក្តានុពលសេដ្ឋកិច្ច។ សហការីរួមការងារជាច្រើនបានពិនិត្យ និងផ្តល់អត្ថាធិប្បាយលើរបាយការណ៍នេះ ដែលក្នុងនោះមាន Joanna Mclean Masic (អ្នកឯកទេសជាន់ខ្ពស់ផ្នែកទីក្រុង), Uri Raich (អ្នកឯកទេសជាន់ខ្ពស់ផ្នែកទីក្រុង) និង កូវ ភីរម្យ (អ្នកឯកទេសផ្នែកទឹកស្អាត និងអនាម័យ)។

ការងារកម្មវិធីនេះត្រូវបានអនុវត្តក្រោមការណែនាំទូទៅរបស់ Abhas Jha អ្នកគ្រប់គ្រងកម្មវិធីការអនុវត្តជាសកលសម្រាប់ភាពធន់ផ្នែកសង្គម តំបន់ទីក្រុង និងតំបន់ជនបទ (GSURR), អ៊ីនហ្គូណា ដូប្រាចា នាយកគ្រប់គ្រងធនាគារពិភពលោកប្រចាំនៅកម្ពុជា (ក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក), Sameh Wahba (នាយកកម្មវិធី GSURR), Ellen Goldstein (នាយកប្រចាំប្រទេស) និង Ede Jorge Ijjasz-Vasquez (នាយកជាន់ខ្ពស់នៃកម្មវិធី GSURR)។

# សេចក្តីសង្ខេប



*ការរីកចម្រើនផ្នែកនគរូបនីយកម្មនៅកម្ពុជា ផ្តល់សក្តានុពលសម្រាប់ឱ្យមានកំណើនប្រកបដោយបរិយាប័ន្ន និងការកាត់បន្ថយភាពក្រីក្រ។ បច្ចុប្បន្ន សមាមាត្រនៃប្រជាជនរស់នៅក្នុងទីក្រុងកំពុងតែកើនឡើង ហើយទន្ទឹមគ្នានោះកត្តាជាច្រើនដែលជំរុញឱ្យមានកំណើនសម្រាប់ប្រទេស គឺជាវិស័យឧស្សាហកម្មដែលមានមូលដ្ឋាននៅទីក្រុង ដូចជាឧស្សាហកម្មផលិតកម្ម ទេសចរណ៍ និងពាណិជ្ជកម្ម ជាដើម។ ត្រង់នេះបង្កើតជាឱកាសដ៏សំខាន់មួយសម្រាប់ប្រទេសកម្ពុជា ពីព្រោះថា រាល់ការសម្រេចដែលបានធ្វើនាពេលបច្ចុប្បន្ន នឹងជះឥទ្ធិពលច្រើនបែបយ៉ាងទៅលើដំណើរការធ្វើនគរូបនីយកម្ម ជាច្រើនទសវត្សទៀតនាពេលខាងមុខ។*

*របាយការណ៍នេះ មានគោលបំណងបំពេញព័ត៌មានដល់គោលនយោបាយនគរូបនីយកម្មនៅកម្ពុជា ឈ្វេងយល់អំពីសក្តានុពលសេដ្ឋកិច្ចរបស់បណ្តាទីក្រុង និងឧបសគ្គធំៗដល់ការឈានទៅសម្រេចឱ្យបានសក្តានុពលនោះ ហើយបង្កើតអភិក្រមជាយុទ្ធសាស្រ្តមួយសម្រាប់កែលម្អការរីកចម្រើន និងភាពធន់របស់ទីក្រុងទាំងនោះ។ របាយការណ៍នេះមានបីផ្នែក គឺ៖ i) សេចក្តីផ្តើមអំពីលំនាំនគរូបនីយកម្ម និងសក្តានុពលសេដ្ឋកិច្ចរបស់ទីក្រុងនៅក្នុងដំណើរការនគរូបនីយកម្ម; ii) ការវិភាគបញ្ហាប្រឈមសំខាន់ៗ និង iii) ជម្រើសគោលនយោបាយ និងកម្មវិធី សម្រាប់ឈានទៅសម្រេចសក្តានុពលរបស់នគរូបនីយកម្ម ឱ្យបានពេញលេញ។*

## លំនាំនគរូបនីយកម្ម និងសក្តានុពលសេដ្ឋកិច្ចរបស់ទីក្រុង

នៅក្នុងកម្រិត ២១ភាគរយ ដំណើរនគរូបនីយកម្មរបស់កម្ពុជា នៅមានសម្ទុះទាបជាងអ្វីដែលគេរំពឹងទុកសម្រាប់ប្រទេសដែលមានកម្រិតផលិតផលក្នុងស្រុកសរុប (ផ.ស.ស/GDP) ប្រហាក់ប្រហែលគ្នានៅឡើយ។ បច្ចុប្បន្ននេះ ការរីកចម្រើនរបស់ទីក្រុងកំពុងវិវត្តទៅមិនស្មើគ្នាទេ ដោយក្នុងនោះមានទីក្រុងធំជាងគេមួយ (រាជធានីភ្នំពេញ) អមដោយទីក្រុងធំបន្ទាប់ និងទីក្រុងតូចៗជាច្រើនទៀត។ រាជធានីភ្នំពេញមានភាពគ្រប់ដណ្តប់លើសគេ ដោយមានប្រជាជនរស់នៅប្រមាណជាង ២លាននាក់ ខណៈដែលទីក្រុងលំដាប់ទី២ ដែលកំពុងលេចមុខឡើង ដូចជាក្រុងសៀមរាប ក្រុងបាត់ដំបង និងក្រុងប៉ោយប៉ែត ជាដើម មានប្រជាជនរស់នៅតែប្រមាណពី ១០០០០០នាក់ ទៅ ២៥០០០០នាក់ ប៉ុណ្ណោះ។ ការរីកចម្រើនទីក្រុងច្រើនតែគ្មានការគ្រោងទុកជាមុន ដែលអាចនាំឱ្យមានការលាតសន្ធឹងខ្វះរបៀបរៀបរយ និងភាពណែនណាន់ តំបន់សំណង់អនាធិបតេយ្យ ភាពងាយរងគ្រោះដោយសារទឹកជំនន់ ការបំពុល និងការផ្តល់សេវាមិនបានល្អ ហើយបង្កភាពរាំងស្ទះដល់កំណើនរយៈពេលយូរអង្វែងទៀតផង។

សន្ទស្សន៍សក្តានុពលសេដ្ឋកិច្ច (Economic Potential Index/EPI) មួយត្រូវបានបង្កើតឡើង ដើម្បីប្រើក្នុងការវាយតម្លៃសក្តានុពលសេដ្ឋកិច្ច នៅតាមស្រុកនានានៅក្នុងប្រទេសកម្ពុជា។ សន្ទស្សន៍នេះមានគោលដៅជួយតម្រែតម្រង់ទិសកិច្ចពិភាក្សាអំពីការបំពេញមុខងាររបស់បណ្តាស្រុក និងកត្តាដែលអាចនាំឱ្យមានផលប៉ះពាល់ដល់ការបំពេញមុខងារនោះ មិនមែនដើម្បីកំណត់អត្តសញ្ញាណថាតំបន់ណាខ្លះដើរក្រោយគេ ឬតំបន់ណាខ្លះដែលឈានមុខគេនោះទេ។ ការវិភាគនេះផ្អែកទៅលើកត្តាស្នូលចំនួន ៥ គឺ លទ្ធភាពចូលដល់ទីផ្សារ តំណភ្ជាប់ផ្លូវដឹកជញ្ជូន ដង់ស៊ីតេសេដ្ឋកិច្ច កម្រិតនគរូបនីយកម្ម និងមូលធនមនុស្ស ដោយប្រើប្រាស់ទិន្នន័យទាំងពីប្រទេសកម្ពុជា និងពីសំណុំទិន្នន័យដែលមាននៅទូទាំងពិភពលោក[១]។ ការយកទិដ្ឋភាពផ្សេងៗគ្នាទាំងនេះមកប្រើរួមគ្នា វាអាចឆ្លុះបញ្ចាំងឱ្យយល់ស៊ីជម្រៅបានអំពីសក្តានុពលផលិតភាពរបស់ស្រុកនីមួយៗ។

យោងតាមការវិភាគនេះ ស្រុកចំនួន២៧ លើស្រុកទាំង១៩២ (ត្រូវនឹង១៤%) ស្ថិតក្នុងលំដាប់ថ្នាក់មានសក្តានុពលសេដ្ឋកិច្ច «ខ្ពស់ណាស់»។ រាជធានីភ្នំពេញស្ថិតនៅលំដាប់ថ្នាក់នេះដែរ ដែលមិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលទេ ដោយសារទីក្រុងនេះមានលទ្ធភាពរកបានទីផ្សារខ្ពស់ ការតភ្ជាប់រឹងមាំជាមួយបណ្តាញផ្លូវដឹកជញ្ជូនសកម្មភាពនគរូបនីយកម្មខ្ពស់ ចំនួនក្រុមហ៊ុនធំច្រើន និងកម្រិតមូលធនមនុស្សខ្ពស់។ ស្ថានភាពភូមិសាស្ត្រនៅជិតរាជធានីភ្នំពេញ និងច្រករបៀងសេដ្ឋកិច្ច ជាចំណែកមួយធ្វើឱ្យស្រុកមួយចំនួននៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជាមានសន្ទស្សន៍ EPI រឹងមាំ សឹងតែស្មើគ្នាជាមួយនឹងបណ្តាស្រុកនៅតំបន់ឆ្នេរភាគខាងត្បូង ភាគពាយ័ព្យ និងជាមួយស្រុកមួយចំនួននាភាគកណ្តាលនៃប្រទេស ជាពិសេសតំបន់ដែលស្ថិតនៅតាមច្រករបៀងសេដ្ឋកិច្ច ដែលមានភាពអំណោយផលក្នុងការរកបានទីផ្សារបានងាយ បើទោះបីជាស្រុកទាំងនោះមានភូមិសាស្ត្រស្ថិតនៅក្នុងផ្ទៃប្រទេសឆ្ងាយពីតំបន់ឆ្នេរ ក៏ដោយ។

ការសិក្សានេះក៏បង្កើតផងដែរនូវប្រភេទដោយឡែកៗនៃទីក្រុង ដោយផ្អែកលើលទ្ធផលគណនា EPI លក្ខណសម្បត្តិរបស់ទីក្រុង និងយុទ្ធសាស្ត្រអភិវឌ្ឍថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីជួយវិភាគបន្ថែមលើតួនាទីរបស់វានៅក្នុងដំណើរការនគរូបនីយកម្មរបស់កម្ពុជា។ ចំណាត់ថ្នាក់ទាំងបួនរបស់ទីក្រុងមាន៖ ទីក្រុងច្រករបៀងសេដ្ឋកិច្ចតំបន់; ទីក្រុងច្រកឆ្លងកាត់; ទីក្រុង/ទីប្រជុំជនតាមព្រំដែន; និងរាជធានីភ្នំពេញ។ ក្រុងនីមួយៗនៅក្នុងក្រុមទាំងនេះមានកាលានុវត្តភាព និងបញ្ហាប្រឈមផ្ទាល់រៀងៗខ្លួន ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់នោះគឺសក្តានុពលនៅក្នុងច្រករបៀងសេដ្ឋកិច្ចតំបន់ ដោយសារតែលទ្ធភាពរឹងមាំក្នុងការចូលទៅដល់ទីផ្សារ និងលទ្ធភាពតភ្ជាប់ជាមួយទីផ្សារ និងកត្តាជំរុញលើកទឹកចិត្តខ្ពស់សម្រាប់កិច្ចសហប្រតិបត្តិការក្នុងតំបន់; សក្តានុពលនៅក្នុងទីក្រុងច្រកឆ្លងកាត់សម្រាប់វិស័យឯកជន និងចំណាប់អារម្មណ៍អន្តរជាតិ; សក្តានុពលនៃក្រុងជាប់ព្រំដែនសម្រាប់ការលើកទឹកចិត្តសម្រួលពាណិជ្ជកម្មឱ្យបានកាន់តែខ្លាំងក្លា និងក្នុងការបង្កើតតំបន់សេដ្ឋកិច្ច; និងសម្រាប់រាជធានីភ្នំពេញវិញ គឺជាសក្តានុពលសម្រាប់ការអភិវឌ្ឍវិស័យឯកជន និងការវិនិយោគបរទេស ឱ្យកាន់តែរឹងមាំ។

## ឧបសគ្គប៉ះពាល់ដល់ដំណើរការនគរូបនីយកម្ម

ទីក្រុងជាច្រើននៅក្នុងប្រទេសកម្ពុជា ជួបឧបសគ្គមួយចំនួនដែលធ្វើឱ្យគេមិនអាចទទួលបានផលប្រយោជន៍ពេញលេញ ពីនគរូបនីយកម្ម។ ក្នុងនោះហេដ្ឋារចនាសម្ព័ន្ធ និងសេវានៅមានកម្រិត និងសមត្ថភាពស្ថាប័នទន់ខ្សោយក្នុងការរៀបចំគោលនយោបាយ ក្នុងការផ្តល់ហិរញ្ញប្បទាន ក្នុងការរៀបចំផែនការ ក្នុងការអនុវត្ត និងក្នុងការរឹតបន្តឹងការអនុវត្តច្បាប់។

[១] សូមមើលសេចក្តីលម្អិតអំពីវិធីសាស្ត្រនៅក្នុងរបាយការណ៍ទាំងមូល។

**ហេដ្ឋារចនាសម្ព័ន្ធ និងសេវាមានកម្រិត។** នៅតាមវិស័យហេដ្ឋារចនាសម្ព័ន្ធទីក្រុងជាច្រើន គេឃើញមានឱនភាពគួរឱ្យកត់សម្គាល់ ដែលរារាំងដល់ការអភិវឌ្ឍទីក្រុង និងដល់ទស្សនវិស័យសម្រាប់ការរីកចម្រើនទីក្រុងទៅថ្ងៃមុខ។ ត្រង់នេះសំខាន់គឺ មួយផ្នែកធំបណ្តាលមកពីការវិនិយោគតិចតួចពេក ហើយទាក់ទិនជាមួយនឹងបញ្ហាអភិបាលកិច្ចទូទៅ ជុំវិញការផ្តល់ហិរញ្ញប្បទាន និងសមត្ថភាពស្ថាប័នផង។ សម្រាប់ផ្នែកដឹកជញ្ជូនវិញ កំណើនយ៉ាងក្រាស់ក្រែលនៃចំនួនយានយន្តនៅលើផ្លូវថ្នល់ និងសមត្ថភាពបណ្តាញផ្លូវថ្នល់នៅមានកម្រិត បានរួមចំណែកធ្វើឱ្យមានការកកស្ទះចរាចរណ៍កាន់តែខ្លាំង នៅតាមបណ្តាក្រុងក្នុងប្រទេស។ ការកើនឡើងនៃតម្រូវការទឹកក៏បានបន្ថែមសម្ពាធទៅលើប្រព័ន្ធចែកចាយដែលមានស្រាប់ដែរ ជាពិសេសនៅតាមទីក្រុងលំដាប់ទីពីរ។ ប្រព័ន្ធលូបង្ហូរទឹក និងប្រព័ន្ធការពារទឹកជំនន់ មានសារៈសំខាន់ជាពិសេសនៅតាមទីក្រុងនានា ដូចជាក្រុងបាត់ដំបង ក្រុងព្រះសីហនុ និងក្រុងកំពង់ចាម ដែលងាយរងគ្រោះខ្លាំងដោយសារទឹកជំនន់ ហើយតម្រូវឱ្យមានការវិនិយោគជាបន្ទាន់។

កាលណាគេនិយាយអំពីទឹកកខ្វក់វិញ បច្ចុប្បន្នមានស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ ក្នុងទីក្រុងដែលកំពុងដំណើរការតែ ៣ កន្លែងប៉ុណ្ណោះ (នៅក្រុងសៀមរាប ក្រុងព្រះសីហនុ និងក្រុងបាត់ដំបង) រីឯរាជធានីភ្នំពេញអត់មានប្រព័ន្ធប្រព្រឹត្តិកម្មទឹកស្អុយជាផ្លូវការទេ។ ទឹកកខ្វក់ដែលមិនបានឆ្លងកាត់ប្រព្រឹត្តិកម្ម និងទឹកស្អុយក្នុងប្រព័ន្ធលូ ត្រូវបានបង្ហូរចាក់ចូលត្រង់តែម្តងទៅក្នុងប្រភពទឹក ដូចជាប្រឡាយ ស្រះ ទន្លេ បឹង និងតំបន់ដីសើម ហើយបង្កការគំរាមកំហែងដល់បរិស្ថានក្នុងទីក្រុង ក៏ដូចជាហានិភ័យដល់សុខភាពផងដែរ។ ការគ្រប់គ្រងកាកសំណល់រឹងក៏នៅមានការអភិវឌ្ឍតិចតួចមែនទែននៅឡើយ ហើយស្រដៀងគ្នានេះដែរ វាជះផលវិបាកយ៉ាងធ្ងន់ធ្ងរលើសុខភាពសាធារណៈ បរិស្ថាន និងសេដ្ឋកិច្ច។ សម្រាប់ទីក្រុងភាគច្រើនបំផុត ការគ្រប់គ្រងកាកសំណល់រឹង ត្រូវបានប្រគល់តាមការដេញថ្លៃទៅឱ្យក្រុមហ៊ុនឯកជនជាអ្នកចាត់ចែង ដោយមានការគ្របដណ្តប់របស់សេវានៅមានកម្រិត និងស្តង់ដាសេវាខុសៗគ្នា ហើយក្នុងនោះប្រហែលជា ៤២ភាគរយ នៃប្រជាជនរស់នៅក្នុងទីក្រុងមិនបានទទួលសេវាគ្រប់គ្រងសំណល់រឹងទេ។ កម្ពុជាគ្មានទីលានចាក់សំរាមប្រកបដោយលក្ខណៈអនាម័យទេ ហើយក្រុមហ៊ុនភាគច្រើនចាក់សំរាមនៅទីធ្លាកណ្តាលវាល ឬមានការគ្រប់គ្រងខ្លះៗប៉ុណ្ណោះ។

ជាមួយនឹងលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស ជាពិសេសការផ្តល់ហិរញ្ញប្បទានរបស់ប្រទេសចិន ផ្នែកអចលនទ្រព្យកំពុងមានការរីកដុះដាលគគ្រឹកគគ្រេងនៅតាមទីក្រុង ដូចជារាជធានីភ្នំពេញ និងក្រុងព្រះសីហនុ ជាដើម។ ខណៈពេលដែលការរីកដុះដាលនេះបានបង្កើនយ៉ាងខ្លាំងនូវការផ្គត់ផ្គង់លំនៅដ្ឋាន និងអចលនទ្រព្យពាណិជ្ជកម្ម វាក៏មានហានិភ័យដែរនៅត្រង់ថាវាធ្វើឱ្យមាន «ពពុះអចលនទ្រព្យ» សម្រាប់ទីផ្សារអចលនទ្រព្យថ្លៃខ្ពស់ ហើយបើងាកមកមើលខាងក្រោមវិញ គេឃើញថាលំនៅដ្ឋានក្នុងតំលៃសមរម្យនៅមានចំនួនតិចតួចនៅឡើយ ដែលធ្វើឱ្យពលរដ្ឋមានចំណូលទាបគ្មានជម្រើសណាក្រៅតែពីទៅរស់នៅតាមតំបន់ សំណង់អនាធិបតេយ្យ។ គេបានប៉ាន់ស្មានថាមានមនុស្សប្រមាណជា១,៧ លាននាក់ រស់នៅក្នុងតំបន់អនាធិបតេយ្យ[២]។

**សមត្ថភាពស្ថាប័ន និងការផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍទីក្រុង។** ថ្វីបើក្របខណ្ឌសម្រាប់ការគ្រប់គ្រងទីក្រុងនៅប្រទេសកម្ពុជាត្រូវបានកំណត់ដោយច្បាប់ជាបន្តបន្ទាប់ និងនៅក្នុងកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រដ្ឋាភិបាលហើយក្តី ទិដ្ឋភាពសំខាន់ៗនៃក្របខណ្ឌគោលនយោបាយនេះនៅមិនទាន់បានអនុវត្តតាមការចង់បាននៅឡើយទេ ហើយនៅមានការខ្វះចន្លោះច្រើន។ នៅក្នុងភាពជាក់ស្តែង អភិបាលកិច្ចថ្នាក់មូលដ្ឋាននៅមានកម្រិត ដោយសារតែសមត្ថភាពទាប និងកង្វះអ្នកជំនាញដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ។ ពាក់ព័ន្ធជាមួយនឹងការផ្តល់ហិរញ្ញប្បទានទីក្រុងវិញ ភាពលម្អៀងមួយចំនួននៅក្នុងរចនាសម្ព័ន្ធជះផលប៉ះពាល់ទៅតាមកន្លែងផ្សេងៗគ្នា ហើយជារួម ធនធានដែលមានគឺនៅមានកម្រិតទាបណាស់។ ប្រាក់ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានកម្រិតស្តួចស្តើង ជាពិសេសសម្រាប់ស្រុក/ក្រុង/ខណ្ឌ ហើយមិនអាចបំពេញតាមតម្រូវការដែលចេះតែកើនឡើងរបស់ទីក្រុងលំដាប់ទីពីរបានទេ[៣]។ ក្នុងនាមជារាជធានី ភ្នំពេញមានភាពលេចធ្លោលើសគេបើប្រៀបទៅនឹងទីក្រុងលំដាប់ទីពីរ ដែលក្នុងនោះបណ្តាខណ្ឌនៅក្នុងរាជធានីទទួលបានហិរញ្ញប្បទានក្នុងមនុស្សម្នាក់ ក្រាស់ក្រែលជាងហិរញ្ញប្បទានផ្តល់ឱ្យក្រុង/ទីក្រុងផ្សេងទៅទៀត។ ខណៈពេលដែលមានច្បាប់ និងគោលនយោបាយដោយឡែកៗគ្នាជាច្រើនមែន គេនៅមិនទាន់មានក្របខណ្ឌទូទៅមួយនៅឡើយទេសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ដែលមានន័យថា រដ្ឋបាលមូលដ្ឋានមានរចនា

២ 2014, MDG data set: http://mdgs.un.org/unsd/mdg/Data.aspx

៣ យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ឆ្នាំ២០០៨ បណ្តាក្រុង ស្រុក និងខណ្ឌមានតួនាទី និងការទទួលខុសត្រូវប្រហាក់ប្រហែលគ្នា។ ជាទូទៅ ស្រុក និងក្រុងត្រូវបានបែងចែកទៅតាមដែនភូមិសាស្ត្រជនបទ និងទីប្រជុំជន រីឯខណ្ឌវិញគឺមានតែនៅក្នុងរាជធានីភ្នំពេញទេ។

សម្ព័ន្ធនៅមានកម្រិតសម្រាប់គណនេយ្យភាពនៅក្នុងរបៀបគ្រប់គ្រងហិរញ្ញវត្ថុ។ រីឯផ្នែកប្រភពចំណូលវិញ វាមានភាពលម្អៀងទៅរកក្រុងតូចៗ ហើយធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់ក្រុងទាំងនោះនៅក្នុងការធ្វើហិរញ្ញប្បទានដល់ការអភិវឌ្ឍទីក្រុង។ ភាគច្រើនភាពលម្អៀងនេះកើតចេញពីរូបមន្តចែករំលែកប្រាក់ចំណូលពន្ធរវាងបណ្តាខេត្ត និងក្រុង ដែលចែកឱ្យស្មើៗគ្នានូវទឹកប្រាក់ ៥០% នៃមូលនិធិដែលត្រូវបានផ្ទេរឱ្យ ហើយសល់ពីនោះ៥០% ទៀត ត្រូវបានបែងចែកដោយផ្អែកចំនួនប្រជាជននៅក្នុងខេត្ត/ក្រុងនីមួយៗ។

**ការធ្វើប្លង់ប្រើប្រាស់ដីធ្លីសម្រាប់ ការរីកចម្រើនប្រកបដោយសមិទ្ធផលនៃទីក្រុង។** បើទោះជាប្លង់ជារូបវន្ត ជាទម្រង់ភូមិសាស្ត្រ (spatial) និងប្លង់ផ្នែកសង្គម-សេដ្ឋកិច្ចហើយក្តី ជាក់ស្តែងមានការរៀបចំប្លង់ក្រុងតិចតួចណាស់ ដែលធ្វើឱ្យក្រុងជាច្រើនគ្មានលទ្ធភាពតាមឱ្យទាន់ល្បឿននៃការរីកលាតសន្ធឹងរបស់ក្រុង ហើយជាលទ្ធផលវាបង្កើតឱ្យមានលំនាំគ្មានរបៀបរៀបរយ នៅក្នុងការអភិវឌ្ឍក្រុង។ បញ្ហាធំៗដែលជះឥទ្ធិពលទៅលើកិច្ចខិតខំធ្វើផែនការរួមមាន សមត្ថភាពបច្ចេកទេសទាប និងកង្វះបុគ្គលិកនៅតាមផ្នែកដែលតម្រូវឱ្យមានជំនាញឯកទេស និងក្របខណ្ឌអនុវត្តច្បាប់ និងបទបញ្ញត្តិនៅទន់ខ្សោយ ដែលនាំឱ្យមានគម្លាតមួយរវាងផែនការដែលបានលើកស្នើឡើង និងការអនុវត្តផែនការទាំងនោះ ការខ្វះខាតហិរញ្ញវត្ថុ ក៏ដូចជាកង្វះការអនុវត្តឱ្យមានប្រសិទ្ធភាពនូវការធ្វើផែនការនៅកម្រិតក្រុង។ ភាគច្រើននៃបញ្ហាទាំងនេះពាក់ព័ន្ធទៅនឹងសមត្ថភាពរបស់ស្ថាប័ន។

## កាលានុវត្តភាពសម្រាប់ឈានទៅសម្រេចសក្តានុពលនៃនគរូបនីយកម្មឱ្យបានពេញលេញ

ក្នុងពេលដែលកម្ពុជាបន្តមានការលូតលាស់ផ្នែកទីក្រុង នៅមានកាលានុវត្តភាពសន្ធឹកសន្ធាប់ណាស់សម្រាប់ធានាយ៉ាងណាឱ្យនគរូបនីយកម្មប្រព្រឹត្តទៅក្នុងដំណើរការមួយ មានភាពប្រកួតប្រជែង មានចីរភាព និងប្រកបដោយបរិយាប័ន្ន។ ការសម្រេចទាំងឡាយនៅពេលនេះនឹងជះឥទ្ធិពលយូរអង្វែងទៅលើការថាតើទីក្រុងនឹងវិវត្តដូចម្តេចទៅថ្ងៃមុខ។ ជម្រើសគោលនយោបាយនៅក្នុងរបាយការណ៍ «ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ឆ្នាំ២០១៧» ជារួម មានសង្គតិភាពជាមួយនឹងភាពចាំបាច់សម្រាប់ក្រុងដទៃទៀតដែរ ហើយនឹងតម្រូវឱ្យមានការយកចិត្តទុកដាក់ទាំងនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន។ អាស្រ័យហេតុនេះ អនុសាសន៍ទាំងឡាយដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះមានមូលដ្ឋានលើរបាយការណ៍កាលពីឆ្នាំមុន ហើយត្រូវបានសម្រួលដើម្បីបញ្ចូលធាតុផ្សំទាំងឡាយដែលកើតចេញពីការវិភាគ និងច្របាច់បញ្ចូលទិដ្ឋភាពទូលំទូលាយថែមទៀតនៃទីប្រជុំជនក្នុងប្រទេសកម្ពុជា។

***ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព។*** បច្ចុប្បន្ននេះ កម្ពុជាមានតម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធជាអាទិភាពក្នុងទំហំធំធេង ហើយដែលជាភាពចាំបាច់សម្រាប់កែលម្អលទ្ធភាពទទួលបានសេវាជាមូលដ្ឋាននិងបង្កើនគុណភាពរបស់វា កែលម្អលក្ខខណ្ឌជីវភាពរស់នៅរបស់ប្រជាជន បង្កើតការងារ លើកកម្ពស់បរិយាប័ន្ន និងធានាឱ្យមានចីរភាពនិងភាពធន់បានយូរផងដែរ។ នៅក្នុងចំណោមការវិនិយោគទាំងនោះគឺ មានតម្រូវឱ្យមានការវិនិយោគទៅលើបណ្តាញផ្លូវដឹកជញ្ជូនរវាងទីក្រុង និងក្នុងរង្វង់ទីក្រុង ប្រព័ន្ធលូបង្ហូរទឹកនិងប្រព័ន្ធការពារទឹកជំនន់ ការធ្វើប្រព្រឹត្តិកម្មទឹកស្អុយនិងទឹកកខ្វក់ ការគ្រប់គ្រងសំណល់រឹង ការផ្គត់ផ្គង់ទឹកស្អាត លំនៅដ្ឋានមានតម្លៃសមរម្យ និងការកែលម្អសហគមន៍ជាពិសេសនៅតាមតំបន់អ្នកមានចំណូលទាប។ តម្រូវការនេះអាចមានភាពខុសគ្នាពីក្រុងមួយទៅក្រុងមួយ ប៉ុន្តែវាមានសារៈសំខាន់ជាសារវន្ត ដោយមិនគិតអំពីប្រភេទរបស់ទីក្រុង ឬទំហំរបស់វាទេ។ ដោយសារតែធនធានហិរញ្ញវត្ថុមានកម្រិត និងឧបសគ្គផ្នែកសមត្ថភាព គេចាំបាច់ធ្វើការបែងចែកការវិនិយោគឱ្យមានលក្ខណៈយុទ្ធសាស្ត្រ - ទាំងតាមផ្នែក និងទាំងខាងភូមិសាស្ត្រ (spatial) - ដើម្បីធានាយ៉ាងណា ឱ្យការរីកលូតលាស់ទីក្រុងនៅទូទាំងប្រទេសកម្ពុជាប្រព្រឹត្តទៅប្រកបដោយចីរភាព មានបរិយាប័ន្ន មានភាពធន់ និងមានភាពប្រកួតប្រជែង។ សម្រាប់តំបន់ជាយុទ្ធសាស្ត្រមួយចំនួននៅក្នុងប្រទេស ការវិនិយោគទៅលើបណ្តាញផ្លូវគមនាគមន៍រវាងទីក្រុង ដោយប្រើអភិក្រមអភិវឌ្ឍដែនដី អាចជួយលើកកម្ពស់ថែមទៀតនូវកាលានុវត្តភាពសម្រាប់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែង។

**ការពង្រឹងស្ថាប័ន និងការផ្តល់ហិរញ្ញប្បទាន។** ការវាយតម្លៃបានកំណត់ឃើញនូវបញ្ហាប្រឈមសំខាន់ៗមួយចំនួន សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិយកទៅលៃលកជាមួយការរីកចម្រើនយ៉ាងលឿននៃនគរូបនីយកម្ម និងដើម្បីធានាឱ្យមានការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាពនៅក្នុងដែនដីសមត្ថកិច្ចរៀងៗខ្លួន។ ជារួម នៅមានភាពចាំបាច់ជាអាទិភាពក្នុងការស្រាយបំភ្លឺតួនាទី និងការទទួលខុសត្រូវរវាងក្រសួងខ្សែបណ្តោយ និងរដ្ឋបាលថ្នាក់ក្រោម ដើម្បីធានាយ៉ាងណាឱ្យការរៀបចំផែនការក្រុង និងការផ្តល់សេវាមានសមាហរណកម្មជាមួយគ្នា និងមានចីរភាព។ ត្រង់នេះតម្រូវឱ្យមានការកសាងសមត្ថភាពដល់ស្ថាប័ននៅមូលដ្ឋាន ទាំងផ្នែកបច្ចេកទេស

និងទាំងផ្នែកសមត្ថភាពអនុវត្ត។ នៅកម្រិតទីក្រុងធំ ពិសេស រាជធានីភ្នំពេញ នៅមានឱកាសច្រើនដើម្បីកែលម្អកិច្ចសម្រប សម្រួលការងារផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាសំខាន់ៗ នៅក្នុងរង្វង់ និងរវាងទីប្រជុំជនពាក់ព័ន្ធនៅក្នុងរាជធានី។

បើនិយាយអំពីការផ្តល់ហិរញ្ញប្បទានដល់ទីក្រុងវិញ គំនិតផ្តួច ផ្តើមរបស់រដ្ឋាភិបាលថ្នាក់ជាតិក្នុងការផ្ទេរមូលនិធិបន្ថែមទៅឱ្យរដ្ឋ បាលថ្នាក់ក្រោមជាតិ មានន័យថាខណ្ឌនិងក្រុង តាមរយៈការ បង្កើនចំនួនមូលនិធិផ្ទេរទៅឱ្យស្រុក/ក្រុងនៅក្នុងអំឡុងពេលប្រាំឆ្នាំ ខាងមុខ និងតាមរយៈ មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ (Subnational Investment Facility) ដែលនឹងត្រូវបានដាក់ ចេញក្នុងពេលឆាប់ៗនេះ គឺជាការបោះជំហានឈានឡើងទៅធ្វើ ការពង្រឹងសមត្ថភាពរបស់ស្រុក/ក្រុងសម្រាប់រៀបចំផែនការ និង ការអនុវត្តផែនការ សម្រាប់ផ្តល់ជូនពលរដ្ឋនូវសេវា និងហេដ្ឋារចនា សម្ព័ន្ធទ្រទ្រង់ចាំបាច់នានា និងសម្រាប់ធានាឱ្យមានការអភិវឌ្ឍ ក្រុង និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ អភិក្រមជា សារវន្តសម្រាប់ការផ្តល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍទីក្រុង គឺ ធានាឱ្យមានក្របខណ្ឌសារពើពន្ធមួយមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានតម្លាភាព នឹងមានភាពអាចទាយទុកមុនបាន។ លើសពីនេះ ផ្នែកជាក់លាក់មួយចំនួនដែលអាចបង្កើនការផ្តល់និងការប្រើប្រាស់ ហិរញ្ញប្បទានសម្រាប់ទីក្រុងលំដាប់ទីពីរ រួមបញ្ចូលការបញ្ជាក់ឱ្យ បានច្បាស់នូវប្រភេទសេវាក្រុងដែលត្រូវផ្តល់ក្រោមអាណត្តិទូទៅ របស់ស្រុក/ក្រុង/ខណ្ឌ ការពង្រឹងសមត្ថភាពបច្ចេកទេសសម្រាប់ ការផ្តល់សេវាទាំងនោះ (ឧ. ដូចជាអគ្គិសនីបំភ្លឺតាមផ្លូវ សួន សាធារណៈ ទីផ្សារ ជាដើម) ការពង្រីកការប្រើប្រាស់ប្រភពចំណូល ផ្ទាល់ក្នុងមូលដ្ឋាន និងការផ្តួចផ្តើមផ្ទេរមូលនិធិជាប់លក្ខខណ្ឌទៅ ឱ្យគណនីក្រុងសម្រាប់បំពេញមុខងារវិមជ្ឈការ ដោយផ្តើមពីការ បំពេញតាមការប្តេជ្ញាចិត្តក្នុងការគ្រប់គ្រងសំណល់រឹង។ ការអនុវត្ត ក្របខណ្ឌគណនេយ្យភាពសង្គម (Social Accountability Framework) ចំពោះក្រុមប្រឹក្សាក្រុងទាំងអស់ នឹងការដាក់ឱ្យ ប្រើប័ណ្ណស្រង់យោបល់របស់ពលរដ្ឋ (Citizen Report Cards) នៅតាមក្រុងធំៗមួយចំនួន នឹងជួយកែលម្អភាពឆ្លើយតប និង គុណភាពរបស់សេវាដែលក្រុងផ្តល់ជូនពលរដ្ឋក្នុងដែនសមត្ថកិច្ច របស់ខ្លួន។

***កែលម្អការធ្វើប្លង់ប្រើប្រាស់ដីធ្លីសម្រាប់ការរីកចម្រើនប្រកបដោយ សមិទ្ធផលនៃទីក្រុង។*** ការធ្វើប្លង់រៀបចំក្រុងមួយដែលមានលក្ខណៈ សមាហរណកម្មល្អ និងផ្នែកលើភ័ស្តុតាង នឹងជួយធានាឱ្យដំណើរ នគរូបនីយកម្មប្រព្រឹត្តទៅមានប្រសិទ្ធផល ហើយរួមបញ្ចូល ទិដ្ឋភាពនានារបស់ចីរភាព និងភាពធន់ដែលអាចនាំឱ្យមាន កំណើនសេដ្ឋកិច្ចកាន់តែខ្ពស់ និងបង្កើនគុណភាពនៃភាពរស់នៅ បានរបស់ពលរដ្ឋក្នុងក្រុង។ អ្វីដែលសំខាន់ជាពិសេសសម្រាប់ ប្រទេសកម្ពុជានោះគឺ ការធ្វើអាទិភាពសមាហរណកម្មនៃដំណើរ ការរៀបចំផែនការ ដែលនៅក្នុងបរិបទបច្ចុប្បន្នដំណើរការនេះត្រូវ បានធ្វើនៅច្រើនកម្រិត ប៉ុន្តែមិនសូវមានការសម្របសម្រួលគ្នាឱ្យ បានល្អទេ។ ជាមួយគ្នានេះ មានឱកាសច្រើនទៀតដើម្បីពង្រឹង តំណភ្ជាប់ទំនាក់ទំនងរវាងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ធ្វើសមាហរណកម្មខ្សែបណ្តោយ កសាងសមត្ថភាពថ្នាក់ មូលដ្ឋានដើម្បីរៀបចំធ្វើផែនការប្រើប្រាស់ដី និងផែនការ ហេដ្ឋារចនាសម្ព័ន្ធមានចីរភាពនិងការសម្របសម្រួលគ្នា ក្នុងនោះ រួមមានទាំងផែនការជាដំណាក់កាលសម្រាប់ការវិនិយោគ និងការ អនុវត្តគម្រោង ការដាក់ចេញនូវច្បាប់ និងក្រមនានាចាំបាច់សម្រាប់ សម្រួលដល់ការអនុវត្តផែនការប្រើប្រាស់ដីលម្អិត ការបញ្ចូល គោលគំនិតភាពធន់ទៅក្នុងការធ្វើផែនការរៀបចំក្រុងសំដៅកាត់បន្ថយ ហានិភ័យ កសាង និងពង្រឹងការអនុវត្តគោលការណ៍ណែនាំពិនិត្យ លើការអភិវឌ្ឍ និងក្រមសំណង់ និងបង្កើតក្របខណ្ឌមួយសម្រាប់ ប្រមូល ចែករំលែក និងវិភាគទិន្នន័យទីក្រុង។ ក្នុងនាមជារាជធានី/ ទីក្រុងច្រកឆ្លងកាត់មួយ យកល្អគួរតែមានអនុសាសន៍ជាក់លាក់ មួយសំណុំសម្រាប់ភ្នំពេញ ដោយសារថាមានភាពស្មុគស្មាញច្រើន ថែមទៀតនៃការរៀបចំផែនការ នៅតាមផ្នែកដែលមានលក្ខណៈ ពហុយុត្តាធិការ ដូចមានលើកឡើងនៅក្នុងរបាយការណ៍«ការ អភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ឆ្នាំ២០១៧»[៤]។

***ធានាឱ្យមានអភិក្រមប្រកបដោយបរិយាប័ន្នមួយ នៅក្នុង ដំណើរការនគរូបនីយកម្ម។*** បញ្ហាបរិយាប័ន្នមិនទាន់ត្រូវបានវិភាគ ឱ្យបានសព្វគ្រប់ទេនៅក្នុងរបាយការណ៍នេះ យ៉ាងណាក៏ដោយនៅ មានសារៈសំខាន់ក្នុងការទទួលស្គាល់ថា បើទោះជានគរូបនីយកម្ម នាំមកនូវផលចំណេញច្រើន ដូចគេធ្លាប់បានដឹងរួចមកហើយក្តី ការរីកលូតលាស់ទីក្រុងលឿនពេកក៏អាចបង្កើតឱ្យមានវិសមភាព ដែរ ប្រសិនបើវាខ្វះការរៀបចំផែនការ និងការគ្រប់គ្រងឱ្យបានល្អ។ របាយការណ៍ផ្សេងទៀតរបស់ធនាគារពិភពលោក ដូចជារបាយ ការណ៍ «ទីក្រុងនៅតំបន់អាស៊ីបូព៌ា៖ ពង្រីកកាលានុវត្តភាពដល់ ជនក្រីក្រក្នុងទីក្រុង» (East Asia Cities: Expanding Opportunities for the Urban Poor) បានធ្វើការឆ្លុះបញ្ចាំង

៤ ធនាគារពិភពលោក ឆ្នាំ២០១៧ «ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ»

បញ្ហាទាំងនេះយ៉ាងទូលំទូលាយ ពីជ្រុងទស្សនៈបរិយាប័ន្នផ្នែកសេដ្ឋកិច្ច ភូមិសាស្ត្រ និងសង្គម[៥]។ កង្វះការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ លើការបង្កើតការងារ និងសេវា អាចពង្រីកវិសមភាពនានាឱ្យកាន់តែធំ រារាំងដល់កំណើនសេដ្ឋកិច្ច និងនាំឱ្យមានការបែងចែកនៅក្នុងសង្គមទៀតផង។ មានកិច្ចការជាច្រើនដែលរដ្ឋាភិបាលថ្នាក់ជាតិ ឬរដ្ឋបាលថ្នាក់មូលដ្ឋានអាចធ្វើបាន ដើម្បីឆ្លើយតបទៅនឹង ឬក៏បញ្ចៀសបញ្ហានេះ។ ក្នុងនោះមានការរៀបចំផែនការសម្រាប់ការពង្រីកទីក្រុង ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជននៃគ្រប់កម្រិតចំណូលទាំងអស់ តាមរយៈការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានសម្រាប់ទាំងអស់គ្នា, ការផ្តល់លទ្ធភាពទទួលបានសេវាដឹកជញ្ជូនសាធារណៈក្នុងតម្លៃសមរម្យ ដើម្បីឱ្យពលរដ្ឋនៃគ្រប់កម្រិតចំណូលទាំងអស់អាចមានលទ្ធភាពស្វែងរកការងារបាន, ការបង្កើនការចូលរួមរបស់សហគមន៍ដើម្បីកំណត់ភាពចាំបាច់ជាអាទិភាព, និងការវិនិយោគទៅលើការអប់រំប្រកបដោយគុណភាព ដើម្បីធានាឱ្យមានពលកម្មប្រកបដោយជំនាញសម្រាប់ការរីកលូតលាស់ទីក្រុង នាពេលអនាគត។

## កម្មវិធីមួយដើម្បីធ្វើអាទិភាពការអភិវឌ្ឍទីក្រុង

ករណីសិក្សាមួយស្តីពីការវិនិយោគលើទីក្រុង ត្រូវបានលើកយកមកបង្ហាញជាលក្ខណៈសកលយ៉ាងទូលំទូលាយ ហើយវាក៏ជាគន្លងផ្លូវមួយសំខាន់ដែរសម្រាប់នាំមកនូវកំណើន និងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា។ ការរីកចម្រើននគរូបនីយកម្មរបស់កម្ពុជាដែលកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយ កាន់តែគូសបញ្ជាក់ថែមទៀតលើសារៈសំខាន់ក្នុងការធានាឱ្យបានថា សមាសភាគផ្សេងៗសំខាន់ៗចាំបាច់ត្រូវតែមានជាស្រេចសម្រាប់ធ្វើផែនការ កសាង និងថែទាំទីក្រុង។ សក្តានុពលសេដ្ឋកិច្ចរបស់ទីក្រុងជាក់លាក់មួយចំនួន រួមទាំងក្រុងនៅតាមច្រករបៀងសេដ្ឋកិច្ចស្នូលផង ត្រូវបានគូសរំលេចនៅក្នុងរបាយការណ៍នេះ ហើយបង្ហាញថាទីក្រុងខ្លះក្នុងចំណោមនោះ មានឱកាសច្រើនសម្រាប់ទទួលបានការរីកចម្រើននាពេលអនាគត។ ភ័ស្តុតាងជាសកលក៏បង្ហាញដែរនូវសារៈសំខាន់នៃការវិនិយោគលើការពង្រឹងសមត្ថភាពរបស់ស្ថាប័នសម្រាប់ធ្វើផែនការ ការរៀបចំហិរញ្ញវត្ថុ និងការគ្រប់គ្រងក្រុង ដែលការណ៍នេះ នឹងជួយកាត់បន្ថយមកនៅកម្រិតអប្បបរមានូវបញ្ហាណែនណាន់ បញ្ហាសំណង់អនាធិបតេយ្យ បញ្ហាបំពុលបរិយាកាស បញ្ហាវិសមភាព និងឧក្រិដ្ឋកម្មនៅក្នុងទីក្រុង។

ជាមួយនឹងតម្រូវការជាច្រើនឱ្យមានការវិនិយោគ និងជំនួយបច្ចេកទេសដែលត្រូវបានរំលេចនៅក្នុងរបាយការណ៍នេះ ជាសំណើ គួរមានកម្មវិធីមួយសម្រាប់ពង្រឹងការអភិវឌ្ឍទីក្រុងក្នុងប្រទេសកម្ពុជា ដើម្បីបំពេញបន្ថែមទៅឱ្យកិច្ចខិតខំនានាដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន។ ខណៈពេលដែលបែបបទជាក់លាក់របស់កម្មវិធីនេះកំពុងស្ថិតក្រោមការពិភាក្សានៅឡើយ អាទិភាពគួរតែតម្រង់ទិសទៅរកការពង្រឹងសមត្ថភាពក្នុងការធ្វើផែនការ រៀបចំហិរញ្ញវត្ថុ និងអនុវត្តគម្រោងវិនិយោគអភិវឌ្ឍន៍ក្រុង និងដើម្បីគាំទ្រដល់តម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធក្រុង នៅតាមបណ្តាទីក្រុងអាទិភាព។ ដៃគូអភិវឌ្ឍន៍មួយចំនួនកំពុងសកម្មជួយកម្ពុជា ប៉ុន្តែការផ្តោតរបស់ពួកគេទៅលើការអភិវឌ្ឍទីក្រុងនៅមានកម្រិតនៅឡើយ ហើយដូច្នេះ វាក៏ជាឱកាសមួយសម្រាប់ពួកគេធ្វើភាពជាដៃគូក្នុងដំណើរនគរូបនីយកម្មទៅមុខទៀតដែរ[៦]។

---

៥ Baker and Gadgil, 2017, East Asia and the Pacific, Expanding Opportunities for the Urban Poor, World Bank.

៦ មានតែវិទ្យាស្ថានកំណើនបៃតងសកល (Global Green Growth Initiative/GGGI) ទេដែលផ្តោតការយកចិត្តជាក់លាក់ទៅលើតម្រូវការចាំបាច់ដោយឡែករបស់ក្រុងលំដាប់ទីពីរ។

# ផ្នែកទី ១ សេចក្តីផ្តើម និងបរិបទ



## ១.១ សេចក្តីផ្តើម

នៅក្នុងកម្រិត ២០% សម្ទុះនគរូបនីយកម្មរបស់កម្ពុជានៅទាបជាងអ្វីដែលគេអាចរំពឹងទុកពីប្រទេសមួយដែលមានផលិតផលក្នុងស្រុកសរុប (ផ.ស.ស/GDP) សម្រាប់ពលរដ្ឋម្នាក់ៗក្នុងកម្រិតប្រហាក់ប្រហែលគ្នា ដែលជាតម្រុយឱ្យដឹងថាសម្ទុះនគរូបនីយកម្មលឿនជាងនេះនឹងកើតមាន នៅក្នុងប៉ុន្មានឆ្នាំខាងមុខ។ បច្ចុប្បន្នការរីកចម្រើនទីក្រុងនៅទូទាំងប្រទេសកំពុងប្រព្រឹត្តទៅមិនស្មើគ្នាទេ ដោយវាច្រើនតែប្រមូលផ្តុំនៅក្នុងរាជធានីភ្នំពេញ និងទីប្រជុំជនមួយចំនួនក្បែររាជធានី ដែលជាប្រវត្តិសាស្ត្រ ជាទីតាំងទាក់ទាញឱ្យមានការលូតលាស់ផ្នែកឧស្សាហកម្ម ដោយសារភ្នំពេញជាចំណុចតភ្ជាប់បណ្តាញជាមួយអន្តរជាតិ និង ភាពងាយក្នុងលទ្ធភាពស្វែងរកសេវារបស់រដ្ឋាភិបាល និងមុខងាររដ្ឋបាល ដែលទីក្រុងនេះ អាចផ្តល់ជូនដល់សាធារណជន។

លំនាំនៃរបាយទីក្រុងមានទំហំខុសគ្នា - ក្នុងនេះគឺទីក្រុងធំមួយមានប្រជាជនរស់នោះច្រើន អមដោយទីក្រុងលំដាប់ទីពីរ និងទីប្រជុំជនតូចៗច្រើន - គឺជាទិដ្ឋភាពទូទៅមួយនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ហើយជាធម្មតា ច្រើនតែអមដោយវិសមភាពតាមតំបន់ធំៗច្រើន។ នៅឆ្នាំ២០១៥ ទីក្រុងភ្នំពេញមានមនុស្សរស់នៅប្រហែលជា២លាននាក់ (ក្នុងនោះប្រហែល ១,៥លាននាក់ ចុះបញ្ជី) ខណៈដែលទីប្រជុំជនផ្សេងៗទៀតមានប្រជាជនរស់នៅសរុប ១,១៨លាននាក់[៧] ប៉ុណ្ណោះ។ ទីក្រុងលំដាប់ទីពីរដែលកំពុងតែលេចមុខឡើង ដូចជាក្រុងព្រះសីហនុ ក្រុងសៀមរាប ក្រុងបាត់ដំបង និងក្រុងប៉ោយប៉ែត ជាដើម មានទំហំតូចជាងរាជធានីទេ ដោយក្រុងនីមួយៗមានប្រជាជនរស់នៅប្រមាណពី ១០០០០០នាក់ ទៅ ២០០០០០នាក់ ប៉ុណ្ណោះ។

កាលណាគេធ្វើការឆ្លុះបញ្ចាំងនូវតួនាទីរបស់វិស័យផលិតកម្មសម្រាប់នាំចេញ វិស័យទេសចរណ៍ និងវិស័យពាណិជ្ជកម្មតាមព្រំដែនថាជាកត្តាជំរុញកំណើនសេដ្ឋកិច្ច បណ្តាទីក្រុងលំដាប់ទីពីរនៅកម្ពុជាកំពុងតែបង្កើតបានជាលំនាំគន្លងផ្លូវសេដ្ឋកិច្ចរៀងៗខ្លួន និងទទួលបានការរីកចម្រើនផ្នែកនគរូបនីយកម្មក្នុងអត្រាពី ៣ ទៅ

៧ Global Green Growth Institute, 2017. Cambodia Green Urban Development Program, Phase Two (2017-2018) - Program Update.

៥ ភាគរយ[៨]។ យ៉ាងណាក៏ដោយ ការរីកចម្រើននេះកំពុងតែប្រព្រឹត្តទៅដោយមិនទាន់មានក្របខណ្ឌយុទ្ធសាស្ត្រថ្នាក់ជាតិណាមួយដើម្បីតម្រង់ទិសការអភិវឌ្ឍទីក្រុងជាតិ និងដើម្បីធានាយ៉ាងណាឱ្យមានប្រព័ន្ធ ប្រកបដោយតុល្យភាពមួយសម្រាប់កំណើនតាមភូមិសាស្ត្រនៅឡើយទេ។

ទីក្រុងគឺជាក្បាលម៉ាស៊ីនជំរុញឱ្យមានកំណើន និងវិបុលភាពដែលសម្រួលឱ្យឧស្សាហកម្មលូតលាស់ទៅបង្កើតការងារ សេវា និងនវានុវត្តភាព។ ទីក្រុងដើរតួសំខាន់ក្នុងការស្ទូចប្រជាជនឱ្យចេញផុតពីភាពក្រីក្រ តាមរយៈការបង្កើនឱកាសការងារ និងរកចំណូលដល់ពលរដ្ឋ។ ក៏ប៉ុន្តែ ប្រសិនបើគ្មានការគ្រប់គ្រង និងរៀបចំផែនការបានល្អទេ អត្ថប្រយោជន៍របស់នគរូបនីយកម្មនឹងមិនអាចសម្រេចបានតាមការរំពឹងទុកទេ ហើយផ្ទុយទៅវិញវាអាចទឹងបង្កើតឱ្យមានវិសមភាព ភាពណែនណាន់ សំណង់អនាធិបតេយ្យ ក៏ដូចជាចិញ្ចឹមឱ្យមានភាពតានតឹងនានា ដូចជាអំពើឧក្រិដ្ឋ និងអំពើហិង្សា ជាដើម។ សម្ពុះនគរូបនីយកម្មលឿនពេកអាចដាក់សម្ពាធទៅលើហេដ្ឋារចនាសម្ព័ន្ធរបវន្ត ការប្រើប្រាស់ដីធ្លី បណ្តាញដឹកជញ្ជូន សេវាមូលដ្ឋានរបស់ក្រុង តម្រូវការលំនៅដ្ឋាន និងបរិស្ថានថែមទៀត។

របាយការណ៍នេះ មានគោលបំណងជួយបំពេញព័ត៌មានដល់គោលនយោបាយនគរូបនីយកម្មនៅកម្ពុជា ឱ្យកាន់តែយល់អំពីសក្តានុពលសេដ្ឋកិច្ចរបស់ទីក្រុង ឧបសគ្គរាំងដល់ការសម្រេចសក្តានុពលនោះ ហើយរៀបចំឱ្យមានអភិក្រមយុទ្ធសាស្ត្រមួយសម្រាប់ការរីកលូតលាស់ និងភាពធន់ របស់ទីក្រុង។ ផ្នែកទី ១ នៃរបាយការណ៍នេះប្រើ «សន្ទស្សន៍សក្តានុពលសេដ្ឋកិច្ច» (Economic Potential Index/EPI) ដែលវិភាគលំនាំភូមិសាស្ត្រ (spatial patterns) របស់កំណើន និងតំបន់សក្តានុពលសេដ្ឋកិច្ច ដើម្បីធ្វើចំណាត់ថ្នាក់ប្រភេទរបស់ក្រុង។ ផ្នែកទី ២ រួមមានការវិភាគទីក្រុងលម្អិត ដើម្បីឈ្វេងយល់អំពីឧបសគ្គដល់ការកែលម្អភាពប្រកួតប្រជែងរបស់ក្រុង ការរៀបចំផែនការក្រុងប្រកបដោយចីរភាព និងភាពបរិយាប័ន្នសម្រាប់នាំឱ្យមានសមធម៌ធំជាងមុន។ ដំណើរទស្សនកិច្ចទៅកាន់ក្រុងព្រះសីហនុ ក្រុងសៀមរាប ក្រុងប៉ោយប៉ែត ក្រុងបាត់ដំបង និងក្រុងច្បារមន ក៏បានជួយបំពេញព័ត៌មានសម្រាប់ការវិភាគ ដែរ។ ការវិភាគនេះបានឈរលើមូលដ្ឋានរបាយការណ៍មានប្រធានបទស្រដៀងគ្នានេះ របស់ធនាគារពិភពលោក ដោយផ្តោតជាក់លាក់ទៅលើរាជធានីភ្នំពេញ[៩]។ ផ្នែកទី ៣ ពិភាក្សាអំពីជម្រើសគោលនយោបាយ និងអាទិភាពសម្រាប់ជួយកម្ពុជាក្នុងដំណើរឆ្ពោះទៅសម្រេចឱ្យបានពេញលេញនូវសក្តានុពលរបស់នគរូបនីយកម្ម។

## ១.២ លំនាំនគរូបនីយកម្ម និងសក្តានុពលសេដ្ឋកិច្ចរបស់ទីក្រុង

### ១.២.១ ទីក្រុងក្នុងប្រទេសកម្ពុជា

ទីក្រុងក្នុងប្រទេសកម្ពុជា ត្រូវបានចាត់ចំណាត់ថ្នាក់ផ្អែកលើរចនាសម្ព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិ និងរៀបចំជារដ្ឋបាលបីជាន់ (រូប ១.១)[១០]។ ខេត្តមានចំនួន២៤ និងអង្គភាពរដ្ឋបាលពិសេសមួយរបស់រាជធានីភ្នំពេញ ដែលទាំងអស់នេះបង្កើតបានជារដ្ឋបាលជាន់ទី១។ រដ្ឋបាលជាន់បន្ទាប់មកទៀតមានក្រុងចំនួន ២៦ និងស្រុក/ខណ្ឌចំនួន១៧១។ ទីក្រុងសំដៅលើតំបន់រាជធានីភ្នំពេញ ឬក្រុងទាំង២៦ (ភាគច្រើនមានតួនាទីជាទីរួមខេត្តដែរ)[១១]។ ចុងក្រោយគេគឺរដ្ឋបាលជាន់ទាបបំផុត ដែលមានឃុំ/សង្កាត់ចំនួន ១២៧៣[១២]។ តំបន់រាជធានីភ្នំពេញគឺជាអង្គភាពរដ្ឋបាលពិសេសមានឋានៈស្មើនឹងខេត្តដែរ។

**រូបភាព ១.១៖** រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិរបស់កម្ពុជា




៨ The Urban Initiative, 2012. Growing Pains: Urbanization and Informal Settlements in Cambodia's Secondary Cities.
៩ ធនាគារពិភពលោក ឆ្នាំ២០១៧ «ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ»
១០ Based on the Organic Law on Administrative Management of Capital, Provinces, Municipalities, Districts and Khans (2008).
១១ Annex Section 4.1 includes a table with main cities and population from the 2008 Census. This data is outdated but the only official numbers available.
១២ GGGI, Sustainable City Strategic Plan 2018-2030 (Draft), 2017.

## ១.២.២ សេចក្តីផ្តើមស្តីពីសន្ទស្សន៍សក្តានុពលសេដ្ឋកិច្ច

សន្ទស្សន៍សក្តានុពលសេដ្ឋកិច្ច (EPI) វិភាគសក្តានុពលសេដ្ឋកិច្ចនៅតាមក្រុង និងស្រុក (ពីនេះតទៅហៅជារួមថា **«ស្រុក»**) នៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានឱ្យនិយមន័យថាជា «វិសាលភាពដែលស្រុកមួយមានកត្តានានា ដែលជាការកំណត់សំខាន់ៗអំពីសមត្ថភាពក្នុងការសម្រេចបានផលិតភាពកម្រិតខ្ពស់» (Roberts 2016)។ សន្ទស្សន៍នេះគឺជាការវិភាគសមាសធាតុ ផ្អែកលើសូចនាករដែលត្រូវបានគេចាត់ទុកជាទូទៅថាមានឥទ្ធិពលទៅលើកម្រិតរបស់ផលិតភាព។ សូចនាករទាំងនោះ រួមមាន លទ្ធភាពចូលទៅកាន់ទីផ្សារ តំណភ្ជាប់បណ្តាញផ្លូវដឹកជញ្ជូន ដង់ស៊ីតេសេដ្ឋកិច្ច កម្រិតនគរូបនីយកម្ម និងមូលធនមនុស្ស។ កាលណាផ្គុំចូលគ្នា កត្តាទាំងនេះអាចផ្តល់នូវការយល់ស៊ីជម្រៅអំពីសក្តានុពលផលិតភាពរបស់ស្រុកមួយបាន។

ឯកតាប្រើសម្រាប់ការវាយតម្លៃ EPI កម្ពុជា គឺជាលំដាប់ថ្នាក់រដ្ឋបាលអន្តរការី ដែលក្នុងនោះសក្តានុពលសេដ្ឋកិច្ចត្រូវបានវាស់វែងនៅកម្រិតក្រុង និងស្រុក (រូប ១.២)។ ក្នុងចំណោមក្រុងនិងស្រុកទាំងអស់១៩៧ សន្ទស្សន៍ EPI យកក្រុងនិងស្រុកតែ១៩៣ ទេមកវិភាគ ដោយផ្អែកលើទិន្នន័យដែលមាន។

**រូបភាព ១.២៖** ឯកតានៃការវាយតម្លៃ EPI




EPI ជាឧបករណ៍មួយជួយឱ្យអ្នកធ្វើសេចក្តីសម្រេច និងរៀបចំគោលនយោបាយ យល់អំពីការបែងចែកភូមិសាស្ត្រនៃសក្តានុពលនៅក្នុងប្រទេស។ សន្ទស្សន៍ EPI តែឯងមិនគួរដើរតួជាកត្តាក្នុងការកំណត់ថាតំបន់ណាមានភាពអត់ថយ ឬតំបន់ណាមានភាពឈានមុខគេក៏ពិតមែន ប៉ុន្តែវានៅតែអាចជួយក្នុងការតម្រង់ទិសការពិភាក្សាអំពីស្រុកដែលមានសមត្ថភាពដំណើរការខ្ពស់ ឬទាប និងកំណត់សូចនាករដែលមានឥទ្ធិពលលើតម្លៃសន្ទស្សន៍ចុងក្រោយរបស់ស្រុកនីមួយៗ។ តាមរយៈការរកឃើញចំណុចខ្លាំង និងចំណុចខ្សោយនៃស្រុកនីមួយៗហើយ EPI អាចប្រើបានក្នុងកម្រិតជាតិដើម្បីកំណត់អត្តសញ្ញាណថាតើកត្តាណាខ្លះដែលគួរតែត្រូវលៃលកដោះស្រាយ ដើម្បីជួយឱ្យស្រុកនីមួយៗសម្រេចបានសក្តានុពលពេញលេញ។

ផ្នែកបន្ទាប់ៗមកទៀតនេះ បង្ហាញពីស្រទាប់ភូមិសាស្ត្រ (spatial layers) និងប្រភពដែលត្រូវបានយកមកប្រើប្រាស់សម្រាប់ការបង្កើត EPI នៅកម្ពុជា, ការពន្យល់លម្អិតអំពីប្រភពនៃស្រទាប់/លំដាប់ទាំងនោះនីមួយៗ, វិធីសាស្ត្រនៅពីក្រោយការបង្កើតសន្ទស្សន៍ ហើយបន្ទាប់មកគឺលទ្ធផលនៃការវិភាគតែម្តង។

## ១.២.៣ កត្តាមានឥទ្ធិពលលើសក្តានុពលសេដ្ឋកិច្ច

អាស្រ័យទៅតាមប្រទេស និងដំណាក់កាលពេលវេលា មានកត្តាច្រើនដែលអាចជះឥទ្ធិពលដល់ការវាស់វែងផលិតភាពនៃតំបន់មួយ។ ប៉ុន្មានឆ្នាំមកនេះ ឯកសារស្រាវជ្រាវសំខាន់ៗបានលេចឡើងដោយបានធ្វើការសាកល្បងនូវកត្តាសក្តានុពលផ្សេងៗ និងសារៈសំខាន់នៃស្ថិតិរបស់វាក្នុងការកំណត់ (ឬវាស់វែង) ផលិតភាព។ បញ្ហាប្រឈមមួយនៅត្រង់ថា កត្តាមួយចំនួនតូចបង្ហាញឱ្យឃើញនូវសង្គតិភាពនៅតាមកាលវេលា និងកន្លែងផ្សេងគ្នា។ ដូច្នេះ EPI ដូចត្រូវបានគណនានៅក្នុងរបាយការណ៍នេះ ពឹងផ្អែកទៅលើសំណុំទិន្នន័យដែលត្រូវបានគេរកឃើញថាអាចទុកចិត្តបាននៅក្នុងឯកសារស្រាវជ្រាវមុនៗ ដោយមិនគិតពីទីតាំងភូមិសាស្ត្រ ឬរយៈកាលនៃការវិភាគទេ៖

១) ***លទ្ធភាពចូលទៅកាន់ទីផ្សារ៖*** វាស់មើលថាតើស្រុកស្ថិតនៅជិតប៉ុណ្ណាទៅនឹងផ្សារធំៗក្នុងស្រុក ដែលជាទូទៅធ្វើឱ្យមានការបង់ថ្លៃចំណាយទាបក្នុងការជួញដូរ និងលទ្ធភាពល្អសម្រាប់ការស្វែងរកជាវទំនិញ ឬការផ្គត់ផ្គង់នានា។

២) ***តំណភ្ជាប់ជាមួយបណ្តាញផ្លូវដឹកជញ្ជូន៖*** កំណត់អត្តសញ្ញាណតំណភ្ជាប់រវាងទីតាំងប្រជុំជន និងទីជនបទ ដោយធ្វើការវាស់មើលភាពងាយស្រួលនៃការធ្វើដំណើរ និងចរាចរណ៍ទំនិញចេញពីទីប្រជុំជន និងចលនាផ្លាស់ទីរបស់ជំនាញទៅកាន់ទីប្រជុំជនវិញ។

៣) ***ដង់ស៊ីតេសេដ្ឋកិច្ច៖*** ផ្តោតលើសក្តានុពលរបស់មនុស្ស និងក្រុមហ៊ុន/ធុរកិច្ចដើម្បីទទួលអត្ថប្រយោជន៍ពីការផ្តុំសកម្មភាពសេដ្ឋកិច្ចចូលគ្នា។

៤) ***កម្រិតនគរូបនីយកម្ម៖*** ស្រដៀងគ្នាទៅនឹងដង់ស៊ីតេសេដ្ឋកិច្ច ដែរនៅត្រង់ថា អត្រានគរូបនីយកម្មវាស់លទ្ធភាពរបស់ស្រុកមួយ ក្នុងការទទួលអត្ថប្រយោជន៍ពីការផ្តុំសកម្មភាពសេដ្ឋកិច្ច

ចូលគ្នា។ ជាងនេះទៅទៀត នគូបនីយកម្មមានការពាក់ព័ន្ធជាមួយកម្រិតខ្ពស់របស់ផលិតភាពនៅក្នុងផ្នែកសេវាកម្ម និងផ្នែកផលិតកម្ម ដែលដើរតួសំខាន់នៅក្នុងសក្តានុពលសេដ្ឋកិច្ច។

៥) ***មូលធនមនុស្ស៖*** លទ្ធភាពទទួលបានកម្លាំងពលកម្មមានជំនាញជះឥទ្ធិពលជាវិជ្ជមានទៅលើសក្តានុពលរកចំណូលរបស់ពលករ និងផលិតភាពរបស់ក្រុមហ៊ុន ឬធុរកិច្ច។

តារាង ១.១ ខាងក្រោមរៀបរាប់បន្ថែមពីលើហេតុផលសម្រាប់បញ្ចូលកត្តានីមួយៗក្នុងការវិភាគ EPI កម្ពុជា និងសូចនាករ ដែលត្រូវបានជ្រើសយកធ្វើជាតំណាងរបស់កត្តានីមួយៗ។ អ្វីដែលគួរកត់សម្គាល់សំខាន់នោះគឺថា ភាគច្រើននៃប្រភពទិន្នន័យមានជាសាធារណៈ រួមទាំងសំណុំទិន្នន័យសកលជាច្រើនផងដែរ។ ដូច្នេះគេអាចយកវិធីសាស្ត្រដែលមាននៅក្នុងការវិភាគនេះទៅធ្វើសាជាថ្មីនៅក្នុងភូមិសាស្ត្រផ្សេងៗទៀត។

**តារាង ១.១៖** កត្តាធាតុចូលសម្រាប់ការវិភាគសន្ទស្សន៍សក្តានុពលសេដ្ឋកិច្ច (EPI) កម្ពុជា

| កត្តា | ហេតុផល | សូចនាករដែលជ្រើសយក | ប្រភពទិន្នន័យ |
|---|---|---|---|
| **លទ្ធភាពចូលទៅកាន់ទីផ្សារ** | លទ្ធភាពខ្ពស់ក្នុងការរកបានទីផ្សារជាទូទៅមានន័យថាការបង់ថ្លៃចំណាយទាបលើការជួញដូរ និងលទ្ធភាពល្អសម្រាប់ការស្វែងរកជាវទំនិញ ឬការផ្គត់ផ្គង់នានា | លទ្ធភាពរកបានទីផ្សារគឺវាស់ដោយពេលវេលាធ្វើដំណើរជាមធ្យមទៅកាន់ទីផ្សារក្នុងទីប្រជុំជន ហើយចែកដោយចំនួនប្រជាជននៅក្នុងទីប្រជុំជន | ព័ត៌មានស្រង់ចេញពីផ្លូវ នៅក្នុងផែនទីផ្លូវទូទៅ |
| **តំណភ្ជាប់ជាមួយបណ្តាញផ្លូវដឹកជញ្ជូន** | វាស់មើលភាពងាយស្រួលនៃការធ្វើដំណើរ និងចរាចរណ៍ទំនិញចេញពីមជ្ឈមណ្ឌលទីប្រជុំជន និងចលនាផ្លាស់ទីរបស់ជំនាញទៅកាន់មជ្ឈមណ្ឌលទីប្រជុំជនវិញ | ដង់ស៊ីតេរបស់ផ្លូវមេលំដាប់ទីមួយ ផ្លូវលំដាប់ទីពីរ និងផ្លូវលំដាប់ទីបី នៅក្នុងស្រុកនីមួយៗ | ព័ត៌មានស្រង់ចេញពីផ្លូវ នៅក្នុងផែនទីផ្លូវទូទៅ |
| **ដង់ស៊ីតេសេដ្ឋកិច្ច** | ផ្តោតលើសក្តានុពលរបស់មនុស្ស និងក្រុមហ៊ុន/ធុរកិច្ចដើម្បីទទួលអត្ថប្រយោជន៍ពីការផ្តុំសកម្មភាពសេដ្ឋកិច្ចចូលគ្នា | ចំនួនគ្រឹះស្ថាននៅក្នុងស្រុកនីមួយៗ | ជំរឿនសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០១៤ វិទ្យាស្ថានជាតិស្ថិតិ |
| **កម្រិតនគូបនីយកម្ម** | នគូបនីយកម្មមានការពាក់ព័ន្ធជាមួយកម្រិតខ្ពស់របស់ផលិតភាពនៅក្នុងផ្នែកសេវាកម្ម និងផ្នែកផលិតកម្ម | ភាគរយនៃប្រជាជនរស់នៅក្នុងតំបន់ទីប្រជុំជនមួយ | Landscan 2012 population grid, European Commission's urban cluster algorithm ក្បួនគណនាទីប្រជុំជនជាកន្សោមអាលហ្គោរីតរបស់គណៈកម្មការអឺរ៉ុប |
| **មូលធនមនុស្ស** | លទ្ធភាពទទួលបានកម្លាំងពលកម្មមានជំនាញជះឥទ្ធិពលជាវិជ្ជមានទៅលើសក្តានុពលរកចំណូលរបស់ពលករ និងផលិតភាពរបស់ក្រុមហ៊ុន ឬធុរកិច្ច | អត្រាបញ្ចប់ការសិក្សា, ២០១៤ | ស្ថិតិអប់រំ និងសូចនាករ ឆ្នាំ ២០១៦-២០១៧ ក្រសួងអប់រំ យុវជន និងកីឡា កម្ពុជា |

*ប្រភព៖ ក្រុមការងារធនាគារពិភពលោក*

## ១.២.៤ វិធីសាស្ត្រសម្រាប់បង្កើតកម្រងទិន្នន័យសូចនាករនីមួយៗ

ផ្នែកបន្ទាប់នេះសង្ខេបជូននូវវិធីសាស្ត្រនៅពីក្រោយការបង្កើតកម្រងទិន្នន័យ ដែលត្រូវបានយកមកប្រើនៅក្នុងការវិភាគ EPI ដែលមានសារៈសំខាន់ក្នុងការយល់អំពីសន្ទស្សន៍ទូទៅបាន៖

**លទ្ធភាពចូលទៅកាន់ទីផ្សារ៖** លទ្ធភាពចូលទៅកាន់ទីផ្សារត្រូវបានបង្កើតចេញពីព័ត៌មានដែលបានស្រង់ចេញពីផ្លូវនៅក្នុងផែនទីផ្លូវទូទៅ (Open Street Map), ទីតាំងរបស់ក្រុងទីផ្សារធំៗ (ជាមួយព័ត៌មានប្រជាជន), និងចំណុចក្រឡាមង (ចម្ងាយ ៣គ.ម ពីចំណុចមួយទៅចំណុចមួយ) គ្របដណ្តប់លើផ្ទៃប្រទេសទាំងមូល។ លទ្ធភាពចូលទៅដល់របស់ចំណុចក្រឡានីមួយៗត្រូវបានវាស់ដោយប្រើរូបមន្ត Origin Grid Point X = Population of Market Town Y *e [(-Time between X and Y) / (2* a2)], ដោយក្នុងនោះអក្សរ a = ចំនួនរយៈពេលសរុបគិតជាម៉ោងនៃការធ្វើដំណើរឆ្លងកាត់ប្រទេស។ សម្រាប់ប្រទេសកម្ពុជា តម្លៃលេខនៃរយៈពេលធ្វើដំណើរនេះត្រូវបានប៉ាន់ស្មានថាមានប្រហែល ១២ម៉ោង។ ចំណុចនៅលើក្រឡាណាមួយនៅលើផែនទីដែលស្ថិតនៅចម្ងាយជាង ១០គ.ម ពីផ្លូវធំ ជាស្វ័យប្រវត្តិ ត្រូវបានឱ្យតម្លៃលេខលទ្ធភាពចូលទៅដល់ទីផ្សារស្មើសូន្យ (0)។ លទ្ធភាពចូលទៅកាន់ទីផ្សាររបស់ស្រុកច្រុងក្រោយគេត្រូវបានគណនា ដោយធ្វើមធ្យមភាគនៃលទ្ធភាពចូលចូលទៅកាន់ទីផ្សារនៅលើក្រឡាទាំងអស់ក្នុងរង្វង់ស្រុកមួយនោះ។

**រូបភាព ១.៣៖** លទ្ធភាពចូលទៅកាន់ទីផ្សារ




**តំណភ្ជាប់ជាមួយបណ្តាញផ្លូវដឹកជញ្ជូន៖** ប្រវែងសរុបរបស់ផ្លូវ (ដែលត្រូវបានកំណត់ថាជា ផ្លូវធំ /'Trunk,' ផ្លូវលំដាប់ទីមួយ /'Primary,' ផ្លូវលំដាប់ទីពីរ/'Secondary,' ឬផ្លូវលំដាប់ទីបី/ 'Tertiary' នៅក្នុងទិន្នន័យផែនទី Open Street Map ឆ្លងកាត់ស្រុកនីមួយៗត្រូវបានគណនា ហើយយកមកចែកជាមួយផ្ទៃសរុបរបស់ស្រុក ដើម្បីបង្កើតបានជាដង់ស៊ីតេផ្លូវ (ប្រវែងគិតជាគីឡូម៉ែត្រក្នុងទំហំផ្ទៃដីមួយគីឡូម៉ែត្រការ៉េ)។

**រូបភាព ១.៤៖** តំណភ្ជាប់ជាមួយបណ្តាញផ្លូវដឹកជញ្ជូន




**ដង់ស៊ីតេសេដ្ឋកិច្ច៖** ដង់ស៊ីតេសេដ្ឋកិច្ចត្រូវបានតំណាងដោយចំនួនគ្រឹះស្ថាននៅក្នុងស្រុកនីមួយៗ។ ទិន្នន័យអំពីដង់ស៊ីតេនេះបានមកពីជំរឿនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៤ របស់វិទ្យាស្ថានជាតិស្ថិតិកម្ពុជា។

**រូបភាព ១.៥៖** ដង់ស៊ីតេសេដ្ឋកិច្ច



**កម្រិតនគរូបនីយកម្ម៖** សម្រាប់ស្រុកនីមួយៗ ចំនួនភាគរយនៃប្រជាជនរស់នៅក្នុងតំបន់ទីប្រជុំជន ត្រូវបានគណនា ដោយប្រើទិន្នន័យប្រជាសាស្ត្រផ្អែកលើគំនូសក្រឡាសំណាញ់ នៅក្នុងរបាយការណ៍ Landscan 2012។ តំបន់ទីប្រជុំជនត្រូវបានកំណត់ដោយប្រើ ក្បួនគណនាទីប្រជុំជនជាកន្សោមអាលហ្គោរីតរបស់គណៈកម្មការអឺរ៉ុប (European Commission's clustering algorithm) ដែលចែងថាទីប្រជុំជនគឺជាកន្សោមនៃក្រុមភូមិដ្ឋានតូចច្រើនក្បែរគ្នារាងជាក្រឡាចក្រតុរង្គ (clusters of contiguous grid cells) ដោយមានដង់ស៊ីតេ «យ៉ាងហោចណាស់ ៣០០នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ និងប្រជាជនសរុបតិចបំផុត ៥០០០នាក់»[១៣]។ ដោយប្រើលក្ខខណ្ឌវិនិច្ឆ័យទាំងនេះ កន្សោមទីប្រជុំជន (មានន័យថា លំនាំ/footprints) ត្រូវបានបង្កើតចេញពីក្រឡាសំណាញ់ប្រជាសាស្ត្រ Landscan 2012។ បន្ទាប់មក គេធ្វើការគណនាចំនួនប្រជាជនសរុបនៅតាមកន្សោមភូមិដ្ឋាននីមួយៗ។ ក្រោយមកទៀត ចំនួនប្រជាជនជាកន្សោមត្រូវបានយកមកបូកបញ្ចូលគ្នានៅតាមស្រុកនីមួយៗ ហើយចែកនឹងចំនួនប្រជាជនសរុបនៅក្នុងស្រុកនោះ (ដែលត្រូវបានគណនាចេញពី Landscan 2012 ដែរ) ដើម្បីបង្កើតជា សូចនាករ «ភាគរយទីប្រជុំជន»[១៤]។

**រូបភាព ១.៦៖** កម្រិតនគរូបនីយកម្ម




**មូលធនមនុស្ស៖** មូលធនមនុស្សត្រូវបានវាស់ដោយប្រើ «អត្រាបញ្ចប់ការសិក្សា» ដែលត្រូវបានដកស្រង់ចេញពីសៀវភៅ «ស្ថិតិ និងសូចនាករវិស័យអប់រំ ឆ្នាំ២០១៤-២០១៥»[១៥]។ ប្រសិនបើស្រុកណាមួយអត់មានទិន្នន័យ ស្រុកនោះទទួលបានអត្រាមធ្យមភាគនៃការបញ្ចប់ការសិក្សារបស់ស្រុកទាំងអស់ក្នុងរង្វង់ខេត្តតែមួយ។

**រូបភាព ១.៧៖** មូលធនមនុស្ស




## ១.២.៤ ការបង្កើត និងការចាត់ថ្នាក់សន្ទស្សន៍សក្តានុពលសេដ្ឋកិច្ច (EPI)

ដំបូង គេបង្កើតឱ្យបានអ៊ីស្តូក្រាមមួយសិនសម្រាប់ចុះពិន្ទុនៅនីមួយៗរបស់សូចនាករ ដើម្បីវាយតម្លៃមើលថារបាយបែងចែកមានសភាពប្រក្រតីឬទេ។ សម្រាប់ប្រទេសកម្ពុជា ពិន្ទុនៅពាក់ព័ន្ធស្តីពីអត្រាលទ្ធភាពចូលដល់ទីផ្សារ តំណភ្ជាប់ជាមួយបណ្តាញផ្លូវដឹកជញ្ជូន និងនគរូបនីយកម្ម ត្រូវបានកំណត់ឃើញថាមានរបាយបែងចែកជាប្រក្រតីគួរសម។ សម្រាប់ដង់ស៊ីតេសេដ្ឋកិច្ច (ក្រុមហ៊ុន) និងអត្រាបញ្ចប់ការសិក្សា ទិន្នន័យដើមត្រូវបានស្រង់ចេញពីពិន្ទុនៅ ដើម្បីបង្កើតបានជារបាយបែងចែកមួយមានភាពប្រក្រតីគ្រាន់បើបន្តិច។

១៣ Dijkstra and Poelman.

១៤ សម្រាប់ព័ត៌មានបន្ថែម សូមមើលវិធីសាស្ត្រកំណត់កន្សោមទីប្រជុំជនរបស់គណៈកម្មការអឺរ៉ុប៖ http://ec.europa.eu/regional_policy/sources/docgener/work/2014_01_new_urban.pdf

១៥ «សៀវភៅស្ថិតិ និងសូចនាករវិស័យអប់រំ ឆ្នាំ២០១៦-២០១៧» ផ្តល់ព័ត៌មានជាមូលដ្ឋានស្តីពីសាលារៀនសាធារណៈ រួមទាំងកម្រិតមត្តេយ្យ បឋមសិក្សា និងអនុវិទ្យាល័យនៅកម្ពុជា។ ទិន្នន័យត្រូវបានប្រមូលដោយសាលា និងយកមកពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញដោយមន្ទីរអប់រំ យុវជន និងកីឡាស្រុក និងខេត្ត។

កាលណារបាយនេះមានលំនឹងហើយ ពិន្ទុឆៅត្រូវបានគេបំប្លែងទៅជាឯកតាប្រៀបធៀប ដោយគណនាពិន្ទុ Z-scores។ លេខពិន្ទុ Z-Scores សម្រាប់សូចនាករទាំងប្រាំត្រូវបានយកទៅគណនាចេញជាមធ្យមភាគ ដើម្បីបង្កើតលេខពិន្ទុសន្ទស្សន៍មួយសម្រាប់ស្រុកមួយ។ លេចពិន្ទុឆៅត្រូវបានយកមករៀបតាមថ្នាក់ (ដោយប្រើរូបមន្ត EPIi = 50 + [50 /Max (IZiI)]*Zi ; ដែល Zi ជាតំណាងឱ្យពិន្ទុ Z-score មធ្យម) ដើម្បីធ្វើឱ្យតម្លៃលេខ EPI ចុងក្រោយមានភាពងាយនឹងបកស្រាយ ដោយក្នុងនោះលេខពិន្ទុសម្រាប់ស្រុកទាំងអស់រត់នៅក្នុងចន្លោះសូន្យ ០ (មានន័យថាសក្តានុពលទាប) និង ១០០ (មានន័យថាសក្តានុពលខ្ពស់)។

បន្ទាប់មក ស្រុកទាំងអស់ត្រូវបានដាក់បញ្ចូលជាក្រុមមានប្រាំថ្នាក់ អាស្រ័យទៅតាមចម្ងាយពីកម្រិតមធ្យម។ សម្រាប់កម្ពុជា លេខពិន្ទុ EPI ជាមធ្យមគឺ ៤៩,៩៩ ដោយមានគម្លាតប្រែប្រួលជាស្តង់ដាចំនួន ១០,៥៨។

**តារាង ១.២៖** ចំណាត់ថ្នាក់តម្លៃលេខ EPI របស់ស្រុក

| ចំណាត់ថ្នាក់ | តម្លៃ | ចម្ងាយពិន្ទុ | ចំនួនស្រុក |
|---|---|---|---|
| **ខ្ពស់ណាស់** | > ១ ជាគម្លាតស្តង់ដាលើសពីកម្រិតមធ្យម | ៦០,៥៨ - ១០០ | ២៧ |
| **ខ្ពស់** | រវាង ១,៥ និង ១ ជាគម្លាតស្តង់ដាលើសពីកម្រិតមធ្យម | ៥៥,២៩ - ៦០,៥៧ | ២៦ |
| **មធ្យម** | ក្នុងរង្វង់ ០,៥ ជាគម្លាតស្តង់ដានៃកម្រិតមធ្យម | ៤៤,៧១ - ៥៥,២៨ | ៧៩ |
| **ទាប** | រវាង ០,៥ និង ១ ជាគម្លាតស្តង់ដាក្រោមកម្រិតមធ្យម | ៣៩,៤២ - ៤៤,៧០ | ២៧ |
| **ទាបណាស់** | > ១ ជាគម្លាតស្តង់ដាក្រោមកម្រិតមធ្យម | ០ - ៣៩,៤១ | ៣៤ |

កាលណាពិចារណាអំពីលទ្ធផល ជាយោបល់គួរផ្តោតទៅលើចំណាត់ថ្នាក់ទូទៅរបស់ស្រុកនីមួយៗ។ ការណ៍នេះនឹងជួយកុំឱ្យផ្តោតការសង្កត់ធ្ងន់ខ្លាំងពេកទៅលេខតម្លៃ ហើយផ្ទុយទៅវិញជួយរក្សាការផ្តោតទៅលើការវាយតម្លៃសក្តានុពលទូទៅរបស់ស្រុកវិញ។

សំខាន់ដែរក្នុងចងចាំថា EPI មានគោលដៅវាស់សក្តានុពលសម្រាប់ការបំពេញមុខងារផ្នែកសេដ្ឋកិច្ច មិនមែនជាការបំពេញមុខងារនៃសក្តានុពលជាក់ស្តែង នោះទេ។ ខណៈដែលយើងរំពឹងចង់ឱ្យបានពិន្ទុ EPI មានភាពប្រទាក់ប្រទងគ្នាជាវិជ្ជមានជាមួយសូចនាករដែលមិនមែនតំណាងឱ្យការបំពេញមុខងារ សេដ្ឋកិច្ច (ដូចជា ផ.ស.ស ជាដើម) លទ្ធផលដែលទទួលបានអាចមានលក្ខណៈផ្ទុយទៅវិញ។ ស្រុកមួយដែលមានសក្តានុពលខ្ពស់ ប៉ុន្តែបើមិនចេះទាញយកអានុភាពពីវាឱ្យបានប្រយោជន៍ល្អ អាចទទួលបានចំណាត់ថ្នាក់ EPI ខ្ពស់មែន ប៉ុន្តែមាន ផ.ស.ស ទាបទៅវិញក៏មានដែរ។

## ១.២.៦ លទ្ធផល

លទ្ធផលជាពិន្ទុឆៅរបស់ការវិភាគសន្ទស្សន៍ EPI ត្រូវបានរៀបនៅក្នុងរូប ១.៦ រីឯលទ្ធផលចំណាត់ថ្នាក់ EPI មាននៅក្នុងរូប ១.៧។ តារាងគណនាលទ្ធផល EPI អាចមើលបាននៅក្នុងឧបសម្ព័ន្ធ ៣.១។ លទ្ធផលបង្ហាញដូចតទៅ៖

**រាជធានីភ្នំពេញនិងតំបន់ជាប់ជាយក្រុង។** គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេដែលរាជធានីភ្នំពេញនិងតំបន់ជាប់ជាយក្រុង មានសក្តានុពលសេដ្ឋកិច្ចខ្ពស់បំផុត អមដោយបណ្តាខណ្ឌនិងស្រុកមាន EPI ខ្ពស់ព័ទ្ធជុំវិញទីក្រុងផង។ លទ្ធភាពចូលទៅកាន់ទីផ្សារ តំណភ្ជាប់បណ្តាញផ្លូវដឹកជញ្ជូន ភាគរយទីប្រជុំជន និងចំនួនក្រុមហ៊ុនតាមតំបន់ក្នុងក្រុង ទាំងអស់មានកម្រិតខ្ពស់ ដែលធ្វើឱ្យរាជធានីនេះជាកន្សោមធំមួយប្រមូលផ្តុំសុទ្ធតែពិន្ទុ EPI ខ្ពស់ៗ។ ខណ្ឌប្រជុំជនធំៗនៅភ្នំពេញ ដែលរួមមានខណ្ឌ៧មករា ខណ្ឌចម្ការមន ខណ្ឌដូនពេញ និងខណ្ឌទួលគោក ទទួលបានពិន្ទុ EPI ខ្ពស់ជាងគេ គឺរវាង ៨០ និង ១០០។ ខណ្ឌដង្កោ ខណ្ឌពោធិសែនជ័យ ខណ្ឌឫស្សីកែវ ខណ្ឌសែនសុខ និងខណ្ឌមានជ័យ ទទួលបានចំណាត់ថ្នាក់ «ខ្ពស់ណាស់» ប៉ុន្តែមានពិន្ទុ EPI ទាបបន្តិច គឺជាង ៦០ សំខាន់គឺដោយសារតែខណ្ឌទាំងនេះមានតួលេខតម្លៃខ្សោយផ្នែកមូលធនមនុស្ស។ ក្រៅពីនេះ មានស្រុកមួយចំនួនដែលទទួលបានពិន្ទុ EPI «ខ្ពស់ណាស់» ដែលប្រមូលផ្តុំនៅជុំវិញជាយខាងក្រៅរាជធានីភ្នំពេញ រួមមានស្រុកច្បារមនក្នុងខេត្តកំពង់ស្ពឺ ក្រុងព្រៃវែង ស្រុកមុខកំពូល ស្រុកកៀនស្វាយ និងស្រុកអង្គស្នួលក្នុង

ខេត្តកណ្ដាល។ ស្រុកដទៃទៀតក្នុងខេត្តកណ្ដាល ដូចជាស្រុកកណ្ដាលស្ទឹង ស្រុកខ្សាច់កណ្ដាល ស្រុកពញាឮ ស្រុកកោះធំ ស្រុកល្វាឯម និងស្រុកពាមរក្នុងខេត្តព្រៃវែង ជាប់ចំណាត់ថ្នាក់ជាស្រុកមាន EPI «ខ្ពស់» ជាមួយនឹងពិន្ទុពី ៥៥ ដល់ ៦០។

**ប៉ែកអាគ្នេយ៍៖** ស្ថានភាពភូមិសាស្ត្រនៅកៀករាជធានីភ្នំពេញ និងច្រករបៀងសេដ្ឋកិច្ចក៏រួមចំណែកផងដែរដល់ការនាំឱ្យស្រុកមួយចំនួនមាន EPI រឹងមាំនៅប៉ែកអាគ្នេយ៍នៃប្រទេសកម្ពុជា ដូចជាស្រុកក្នុងខេត្តស្វាយរៀង និងស្រុកដូនកែវ ខេត្តតាកែវ ជាដើម។

**តំបន់ឆ្នេរប៉ែកខាងត្បូង៖** តំបន់ឆ្នេរប៉ែកខាងត្បូងនៃប្រទេសកម្ពុជាប្រមូលផ្ដុំដោយស្រុកដែលមានពិន្ទុ EPI រឹងមាំ រួមទាំងស្រុកមួយចំនួនមាន EPI «ខ្ពស់ណាស់» នៅក្នុងខេត្តកំពត និងក្រុងខេមរភូមិន្ទនៃខេត្តកោះកុងផងដែរ។ ក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ និងស្រុកដំណាក់ចង្អើរក្នុងខេត្តកែប ទទួលបានពិន្ទុ EPI «ខ្ពស់»។

**ប៉ែកពាយ័ព្យ៖** នៅប៉ែកខាងនេះក៏មានស្រុកមួយចំនួនដែលទទួលបានពិន្ទុ EPI រឹងមាំដែរ។ ក្នុងនោះមានស្រុកមួយចំនួនដែលជាស្រុកមានសក្ដានុពល «ខ្ពស់ណាស់» នៅក្នុងខេត្តបាត់ដំបង និងខេត្តសៀមរាប និងក្រុងមានសក្ដានុពល «ខ្ពស់» ដូចជាក្រុងសិរីសោភ័ណ ក្រុងប៉ៃលិន និងក្រុងប៉ោយប៉ែត ជាដើម។

**ភូមិភាគកណ្ដាល៖** ក្រុងកំពង់ចាម ក្រុងកំពង់ឆ្នាំង ក្រុងពោធិសាត់ និងក្រុងស្ទឹងសែននៃខេត្តកំពង់ធំ ទទួលបានពិន្ទុ EPI ពី «ខ្ពស់» ដល់ «ខ្ពស់ណាស់»។ ភាគច្រើននៃទីក្រុងលំដាប់ទីពីរទាំងនេះមានទីតាំងភូមិសាស្ត្រ ស្ថិតនៅតាមច្រករបៀងសេដ្ឋកិច្ច ដែលបង្កភាពងាយស្រួលដល់ពួកគេនូវលទ្ធភាពល្អក្នុងចូលទៅរកទីផ្សារ បើទោះជាក្រុងទាំងនេះស្ថិតនៅក្នុងផ្ទៃក្នុងប្រទេសក៏ដោយ។

**ប៉ែកខាងជើង និងប៉ែកឦសាន៖** អ្វីដែលគួរឱ្យភ្ញាក់ផ្អើលគឺស្រុកមួយចំនួននៅប៉ែកខាងជើង និងប៉ែកឦសានប្រទេសកម្ពុជារួមមានស្រុកក្នុងខេត្តក្រចេះ ព្រះវិហារ ក្រុងបានលុងខេត្តរតនគីរី និងក្រុងស្ទឹងត្រែង មានសក្ដានុពលសេដ្ឋកិច្ច «ខ្ពស់ណាស់» ឬ «ខ្ពស់»។ ត្រង់នេះប្រហែលជាអាចមកពីអត្ថិភាព និងការរីកចម្រើននៃការធ្វើសម្បទានដីសេដ្ឋកិច្ច សម្រាប់យកទៅធ្វើចម្ការកសិកម្ម និងកសិឧស្សាហកម្មកែច្នៃ ទេដឹង?

ស្រុក និងកន្សោមស្រុកមានសក្ដានុពល «ខ្ពស់» ដែលត្រូវបានកំណត់តាមរយៈការដាក់ពិន្ទុ EPI ត្រូវបានឆ្លងកាត់ការវិភាគថែមទៀតនៅក្នុង «ការវិភាគលម្អិតទីក្រុង» នៅផ្នែកខាងក្រោមបន្តបន្ទាប់ទៀត។

**រូបភាព ១.៨៖** ផែនទីប្រទេសកម្ពុជាអមដោយពិន្ទុឆៅរបស់ EPI




**រូបភាព ១.៩៖** ផែនទីប្រទេសកម្ពុជាអមដោយចំណាត់ថ្នាក់ EPI



លទ្ធផលការវិភាគ EPI បង្ហាញថា លើកលែងតែខេត្តមណ្ឌលគិរី និងខេត្តឧត្តរមានជ័យចេញ ជាទូទៅ ខេត្តដទៃទៀតក្នុងប្រទេសកម្ពុជាមានយ៉ាងហោចណាស់ស្រុកមួយដែលមានពិន្ទុ EPI «ខ្ពស់ណាស់» ឬ «ខ្ពស់»។ ស្រុកមានសក្តានុពលខ្ពស់ទាំងនោះច្រើនតែជាទីក្រុងរបស់ខេត្ត ដែលដើរតួជាមជ្ឈមណ្ឌលរដ្ឋបាលនិងសេដ្ឋកិច្ចរបស់ខេត្ត និងតំបន់ជុំវិញ។ ចំនួនរបស់ស្រុកនៅក្នុងរង្វង់ខេត្តនីមួយៗ និងចំណាត់ថ្នាក់ពិន្ទុ EPI របស់វាមានបង្ហាញនៅក្នុងរូប ១.១០។

**រូបភាព ១.១០៖** លទ្ធផលតាមខេត្ត និងចំណាត់ថ្នាក់ EPI




## ១.៣ ការពណ៌នាលក្ខណៈប្រភេទផ្សេងៗរបស់ទីក្រុង និងសក្តានុពលសេដ្ឋកិច្ច

### ១.៣.១ សេចក្តីផ្តើម

នៅក្នុងបរិបទមួយដែលទីប្រជុំជនក្នុងប្រទេសចេះតែបន្តរីកលូតលាស់ ការរៀបចំឱ្យមាន «យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍតំបន់ក្រុងនិងទីប្រជុំជន» (National Strategy on Development of Municipal and Urban Areas) ស្ថិតនៅក្នុងចំណោមអាទិភាពជាច្រើនរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិសភាទីប្រាំ។ «យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍនក្រុង» (National Urban Development Strategy/NUDS) ដែលត្រូវបានរៀបចំឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺជាការឆ្លើយតបមួយទៅនឹងយុទ្ធសាស្ត្រជាតិដែលបានលើកឡើងនៅខាងលើ។ វាក៏ស្របគ្នាដែរ ទៅនឹងបញ្ហាគោលនយោបាយនគរូបនីយកម្មសំខាន់ៗដែលបានរំលេចឡើងនៅក្នុង«យុទ្ធសាស្ត្រចតុកោណ៖ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព - ដំណាក់កាលទី៣» របស់រាជរដ្ឋាភិបាលកម្ពុជា, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨, និងគោលនយោបាយពាក់ព័ន្ធដទៃទៀត ដូចជា គោលនយោបាយជាតិស្តីពីដីធ្លី, គោលនយោបាយជាតិស្តីពីផែនការរៀបចំភូមិសាស្ត្រ (National Policy on Spatial Planning), គោលនយោបាយជាតិស្តីពីលំនៅដ្ឋាន, និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម[១៦]។ ក្របខណ្ឌយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍនគរូបនីយកម្ម (សេចក្តីព្រាងឆ្នាំ២០១៥) បានកំណត់តំបន់មួយចំនួនដែលអាចជាប្រភេទទីប្រជុំជននៅក្នុងប្រទេសកម្ពុជា ដូចមានសង្ខេបជូននៅក្នុងតារាង ១.៣ ខាងក្រោម។

---

១៦ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្របខណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍នគរូបនីយកម្ម (សេចក្តីព្រាង ឆ្នាំ២០១៥)

**តារាង ១.៣៖** យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍនក្រុង (NUDS) - ប្រភេទទីក្រុងដែលអាចមាននៅកម្ពុជា

| កម្រិត | ការចាត់តាំង | ទីតាំងដែលអាចជាបេក្ខភាព | លក្ខណៈវិនិច្ឆ័យ | សម្គាល់ |
|---|---|---|---|---|
| ១ | រាជធានីជាតិ | ភ្នំពេញ | > លើស ១លាននាក់ | ទាំងអស់នេះត្រូវបានប្រកាសដោយច្បាប់រួចហើយ ក្នុងឋានៈជារាជធានីរបស់ប្រទេស ឬជារាជធានីរបស់ខេត្ត |
| ២ | ទីក្រុងលំដាប់ទីពីរ | សៀមរាប, បាត់ដំបង, ប៉ោយប៉ែត, សិរីសោភ័ណ | > លើស ១០០០០០នាក់ | |
| ៣ | ទីក្រុងលំដាប់ទីបី | កំពង់ចាម, តាខ្មៅ, ស្វាយរៀង, ច្បារមន, ពោធិសាត់, ស្ទឹងសែន, បាវិត, កំពត, សំរោង, ខេមរភូមិន្ទ, ដូនកែវ, ក្រចេះ, ប៉ៃលិន, សួង, ស្ទឹងត្រែង, បានលុង | > លើស ៣០០០០នាក់ | |
| ៤ | មជ្ឈមណ្ឌលក្រុង | ព្រះវិហារ, កែប, សែនមនោរម្យ | > លើស ១០០០០នាក់ | |
| ៥ | មជ្ឈមណ្ឌលទីប្រជុំជនផ្សេងទៀត (មិនមែនជាមជ្ឈមណ្ឌលក្រុង) | ១១ | > លើស ២០០០០នាក់ | |
| | | ១៨ | > លើស ១០០០០នាក់ | |
| | | ១១ | > ២០០០ - ១០០០០នាក់ | |

*ប្រភព៖ ក្របខណ្ឌយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍនគរូបនីយកម្ម (សេចក្តីព្រាង ឆ្នាំ២០១៥)*

ក្របខណ្ឌយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍនគរូបនីយកម្ម បានកំណត់ប្រភេទទីប្រជុំជន និងទីក្រុងបេក្ខភាព ដោយផ្អែកជាបឋមលើចំនួនប្រជាជន និងឋានៈដែលមានការប្រកាសតាមផ្លូវច្បាប់រួចហើយ។ ប៉ុន្តែ ជាប្រការសំខាន់ដែលគួរកត់សម្គាល់ថា ទីក្រុង (និងតំបន់ទីប្រជុំជន) មានទំហំខុសគ្នាច្រើន។ ការស្រាវជ្រាវរបស់របាយការណ៍ក្រោមចំណងជើងថា «ទីក្រុងប្រកួតប្រជែងដើម្បីការងារ និងកំណើន» “Competitive Cities for Jobs and Growth” បានឱ្យដឹងថាទីក្រុងមានភាពខុសគ្នាចម្រុះច្រើនទិដ្ឋភាព ខាងទំហំ (ចំនួនប្រជាជន ផ្ទៃ ដង់ស៊ីតេ), និន្នាការសេដ្ឋកិច្ច (ឧស្សាហកម្ម និងសេវា), ទីតាំងភូមិសាស្ត្រ និងលទ្ធភាពចេញចូលបាន (មានក្រុងនៅជាប់ឆ្នេរសមុទ្រ ក្រុងនៅឆ្ងាយពីឆ្នេរសមុទ្រ ក្រុងដែលឥតមានជាប់នឹងសមុទ្រសោះតែម្តង), ទយជ្ជទានធម្មជាតិផ្តល់ឱ្យ (សម្បូរធនធាន ឬក៏ដីទទេ), កម្រិតចំណូល (គិតជា ផ.ស.ស ឬ ចំណូលសរុបជាតិ), ប្រវត្តិ (ថ្មី ចាស់ មានផែនការ គ្មានផែនការ), ប្រព័ន្ធនយោបាយ, សមត្ថភាពនិងស្វ័យភាពរបស់ស្ថាប័ន និងទិដ្ឋភាពផ្សេងទៀត[១៧]។ ទីក្រុងភាគច្រើនមានកន្សោមបញ្ហាខ្វល់ខ្វាយរៀងៗខ្លួនពាក់ព័ន្ធនឹងការអភិវឌ្ឍ អាស្រ័យទៅលើលក្ខណសម្បត្តិក្រុង បញ្ហាប្រឈម និងមុខងារ (ចក្ខុវិស័យ និងគោលបំណង) ដោយឡែកៗពីគ្នា។

យោងតាមលទ្ធផល EPI, លក្ខណសម្បត្តិទីក្រុង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងតំបន់ ទីក្រុងរបស់កម្ពុជាអាចត្រូវបានចាត់ចំណាត់ថ្នាក់ជាបួនប្រភេទផ្សេងគ្នា អាស្រ័យទៅតាមមុខងារ និងសក្តានុពល ដូចមានសង្ខេបជូនក្នុងតារាង ១.៤ នៅខាងក្រោម។ ប្រភេទរបស់ទីក្រុងនឹងមានការពន្យល់លម្អិតនៅផ្នែកបន្ទាប់ៗមកទៀត។

**តារាង ១.៤៖** សំណើប្រភេទរបស់ទីក្រុងក្នុងប្រទេសកម្ពុជា

| | ទីក្រុងច្រករបៀងសេដ្ឋកិច្ចតំបន់ | ទីក្រុងច្រកឆ្លងកាត់ | ទីក្រុង/ទីប្រជុំជនជាប់ព្រំដែន | ទីក្រុងរាជធានី |
|---|---|---|---|---|
| **ទីក្រុងក្នុងប្រទេសកម្ពុជា** | បាត់ដំបង, កំពង់ចាម, ស៊ីសុផុន, កំពង់ឆ្នាំង, កំពត, កែប, និងផ្សេងទៀត | ភ្នំពេញ, សៀមរាប, ក្រុងព្រះសីហនុ | ប៉ោយប៉ែត, បាវិត | ភ្នំពេញ |

១៧ ធនាគារពិភពលោក - ទីក្រុងប្រកួតប្រជែងដើម្បីការងារ និងកំណើន, ២០១៥

| | | | | |
|---|---|---|---|---|
| **សក្តានុពលសេដ្ឋកិច្ច** | ជាទីក្រុងនៅតាមច្រករបៀងសេដ្ឋកិច្ចតំបន់ ដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ ដោយសារតែទីតាំងយុទ្ធសាស្ត្ររបស់វា និងលទ្ធភាពផ្លូវចេញចូលភ្ជាប់ជាមួយពាណិជ្ជកម្មអន្តរតំបន់ (សកល) និងឧស្សាហកម្មតម្លៃបន្ថែម។ ទីក្រុងប្រភេទនេះក៏ទទួលផលចំណេញផងដែរពីការអភិវឌ្ឍរវាងតំបន់ (ក្នុងមូលដ្ឋាន) តាមរយៈសេដ្ឋកិច្ចមាត្រដ្ឋាន និងភាពបរិយាប័ន្ន ឬសមាហរណកម្ម។ | ជាទីក្រុងដែលមានតួនាទីចម្បងជាចំណុចច្រកឆ្លងកាត់ («ខ្លោងទ្វារ») ទៅកាន់ប្រទេស ឬតំបន់មួយទៀត។ ទីក្រុងច្រកឆ្លងកាត់មានអាកាសយានដ្ឋាន/កំពង់ផែសមុទ្រ ថ្នាក់ជាតិ/អន្តរជាតិ (មុខងារចម្បងរបស់វាសម្រាប់ដំណើរមកដល់ ឬដំណើរចេញ របស់ភ្ញៀវ) ហើយមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ ដោយបម្រើតួនាទីជាយុថ្កា ឬជាមជ្ឈមណ្ឌលសេដ្ឋកិច្ចតំបន់។ | ជាទីក្រុងដែលស្ថិតនៅតាមច្រករបៀងសេដ្ឋកិច្ច និងព្រំដែនអន្តរជាតិ។ ទីក្រុង/ទីប្រជុំជនទាំងនេះមានសក្តានុពលខ្ពស់ដើម្បីបម្រើជាខ្លោងទ្វារឆ្លងកាត់សម្រាប់សកម្មភាពពាណិជ្ជកម្មឆ្លងដែន សកម្មភាពទេសចរណ៍ និងការអភិវឌ្ឍតំបន់សេដ្ឋកិច្ច។ | ជាទីក្រុងដែលដើរតួនាទីចម្បងជាមជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ បញ្ញវន្ត (និងជារឿយៗផ្នែកនយោបាយដែរ) របស់ជាតិ។ នៅក្នុងករណីជាច្រើន រដ្ឋធានី/រាជធានីមានមនុស្សរស់នៅច្រើនជាងគេ ហើយក៏ផ្តល់ឱកាសការងារទាក់ទាញជាងគេដែរ។ |
| **បញ្ហាប្រឈម** | ចំនួនយានយន្តដែលមានសក្តានុពលនឹងកើនឡើងថែមទៀតអាចបណ្តាលឱ្យមានសម្ពាធកាន់តែខ្លាំងទៅលើហេដ្ឋារចនាសម្ព័ន្ធដែលនៅមានកម្រិត | ដីនៅទំនេរ/តម្លៃដី; ការផ្លាស់ប្តូរទីលំនៅ; ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ; ឱកាសតម្លៃសម្រាប់ទីក្រុងដទៃទៀត | តម្រូវការនិងចំណាប់អារម្មណ៍កាន់តែតិច, ភាពសាំញ៉ាំនៃបញ្ហាឆ្លងដែន រួមមានការហូរចូលគំហុករបស់ពលករពេលថ្ងៃ ឬយប់ | ដីនៅទំនេរ/តម្លៃដី; ការផ្លាស់ប្តូរទីលំនៅ; ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ; ឱកាសតម្លៃសម្រាប់ទីក្រុងដទៃទៀត |
| **កាលានុវត្តភាពសំខាន់ៗ** | លទ្ធភាពខ្ពស់ក្នុងការចូលដល់ទីផ្សារ និងក្នុងការភ្ជាប់ជាមួយបណ្តាញផ្លូវដឹកជញ្ជូន, ប្រការលើកទឹកចិត្តខ្លាំងសម្រាប់កិច្ចសហប្រតិបត្តិការតំបន់ | វិស័យឯកជនរឹងមាំ និងវត្តមានចំណាប់អារម្មរបស់អ្នកផ្តល់ជំនួយអន្តរជាតិ | ប្រការជំរុញលើកទឹកចិត្តខ្លាំងឱ្យមានការសម្របសម្រួលពាណិជ្ជកម្មឆ្លងដែន និងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ច | វិស័យឯកជនរឹងមាំ និងវត្តមានចំណាប់អារម្មរបស់អ្នកផ្តល់ជំនួយអន្តរជាតិ |

## ១.៣.២ ទីក្រុងច្រករបៀងសេដ្ឋកិច្ចតំបន់

ច្រករបៀងសេដ្ឋកិច្ចតំបន់ដើរតួនាទីសំខាន់ណាស់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសមាហរណកម្មតំបន់។ ច្រករបៀងសេដ្ឋកិច្ចក្នុងមហាអនុតំបន់ទន្លេមេគង្គ, ច្រករបៀងឧស្សាហកម្មដេលី-បុមបៃនៃប្រទេសឥណ្ឌា, គំនិតផ្តួចផ្តើមផ្លូវមួយខ្សែក្រវាត់មួយរបស់ចិន, និងច្រករបៀងអភិវឌ្ឍសេដ្ឋកិច្ចទ្វីបអាហ្វ្រិក ជាឧទាហរណ៍ខ្លះៗនៃច្រករបៀងសេដ្ឋកិច្ច ដែលទទួលបានជោគជ័យនៅក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចឱ្យទៅមុខ តាមរយៈយុទ្ធសាស្ត្រសហប្រតិបត្តិការដែនដី និងតំបន់។ ដោយតភ្ជាប់មជ្ឈមណ្ឌលនិងខ្នែងផ្នែកសេដ្ឋកិច្ចសំខាន់ៗជាមួយគ្នា (ទីក្រុង ផ្សារ កំពង់ផែ មជ្ឈមណ្ឌលឧស្សាហកម្ម) តាមរយៈបណ្តាញហេដ្ឋារចនាសម្ព័ន្ធមានប្រសិទ្ធភាព (មានហេដ្ឋារចនាសម្ព័ន្ធរឹង ដូចជា ផ្លូវថ្នល់ ផ្លូវរថភ្លើង និងហេដ្ឋារចនាសម្ព័ន្ធទន់ មានកិច្ចព្រមព្រៀងពាណិជ្ជកម្ម កិច្ចព្រមព្រៀងដឹកជញ្ជូន និងការធ្វើស្តង់ដានីយកម្ម ជាដើម) ច្រករបៀងសេដ្ឋកិច្ចជួយពង្រឹងថែមទៀតដល់ការសម្រួលពាណិជ្ជកម្មអន្តរតំបន់ (សកល) និងពង្រីកខ្សែចង្វាក់តម្លៃបន្ថែម រួមចំណែកដល់ការអភិវឌ្ឍក្នុងរង្វង់តំបន់ (ក្នុងមូលដ្ឋាន) តាមរយៈសេដ្ឋកិច្ចមាត្រដ្ឋាន និងបរិយាប័ន្ន។

ប្រទេសកម្ពុជា ជាសមាសភាគដ៏សំខាន់មួយនៃកិច្ចព្រមព្រៀងច្រករបៀងសេដ្ឋកិច្ច ប៉ែកខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ (GMS Southern Economic Corridor/SEC) ដែលត្រូវបានបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គអនុម័តយល់ព្រមនៅ

ឆ្នាំ១៩៩៨ ដើម្បីជួយជំរុញល្បឿនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអនុតំបន់។ ច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូងនេះ ភ្ជាប់មហាអនុតំបន់ ដែលរួមមានប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និង វៀតណាម ជាមួយទីផ្សារ និងមជ្ឈមណ្ឌលសេដ្ឋកិច្ចធំៗ ឱ្យដើរតួនាទីជាកន្សោមមជ្ឈមណ្ឌលសម្រាប់ការអភិវឌ្ឍសហគ្រាស។ តារាង ១.៥ និងរូបភាព ១.៩ បង្ហាញអនុច្រករបៀងទាំងបួននៃច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូង ដែលរួមបញ្ចូលទីក្រុង/ទីប្រជុំជនកម្ពុជាមួយចំនួននៅតាមបណ្ដាញផ្លូវរបស់វាផង។

**តារាង ១.៥៖** ច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ

| អនុច្រករបៀង | បណ្ដាញផ្លូវ |
|---|---|
| អនុច្រករបៀងប៉ែកខាងជើងនៃច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូង (ពណ៌ស្វាយក្នុងរូបភាព ១.១១) | បាងកក (T) - ប៉ោយប៉ែត (C) - ស៊ីសុផុន (សិរីសោភ័ណ) (C) - សៀមរាប (C) - ស្ទឹងត្រែង (C) - រតនគិរី (C) - អូរយ៉ាដាវ (C) - ផ្លីគូ (V) - គុយញ៉ុន (V) (តាមផ្លូវជាតិលេខ៦ និង លេខ៦៨ ក្នុងប្រទេសកម្ពុជា) |
| អនុច្រករបៀងប៉ែកកណ្ដាលនៃច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូង (ពណ៌ខៀវក្នុងរូបភាព ១.១១) | បាងកក (T) - ប៉ោយប៉ែត (C) - ស៊ីសុផុន (សិរីសោភ័ណ) (C) - បាត់ដំបង (C) - កំពង់ឆ្នាំង (C) - ភ្នំពេញ (C) - បាវិត (C) - ក្រុងហូជីមិញ (V) - វ៉ុងតាវ (V) (តាមផ្លូវជាតិលេខ៥ និងលេខ១ ក្នុងប្រទេសកម្ពុជា) |
| អនុច្រករបៀងតាមតំបន់ឆ្នេរខាងត្បូងនៃច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូង (ពណ៌បៃតងក្នុងរូបភាព ១.១១) | ដាវ៉ី (M) - បាងកក (T) - ត្រាត (T) - កោះកុង (C) - កំពត (C) - កែប (C) - ហាទៀង (V) - កាម៉ៅ (V) - ណាមកាញ់ (V) (តាមផ្លូវជាតិលេខ៤៨ក្នុងប្រទេសកម្ពុជា) |
| តំណភ្ជាប់ផ្លូវអន្តរច្រករបៀង (ពណ៌ផ្កាឈូកក្នុងរូបភាព ១.១១) | ក្រុងព្រះសីហនុ (C) - ភ្នំពេញ (C) - កំពង់ចាម (C) - ក្រចេះ (C) - ស្ទឹងត្រែង (C) - ដុងក្រឡ (ត្រពាំងក្រៀល) (C) - ប៉ាក់សេ (L) - សុវណ្ណខេត្ត (L) (តាមផ្លូវជាតិលេខ៣ និងលេខ៧ ក្នុងប្រទេសកម្ពុជា ភ្ជាប់អនុច្រករបៀងបីនៃច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូងជាមួយច្រករបៀងសេដ្ឋកិច្ចកើត-លិច (EWEC)) |

*សម្គាល់៖ C = Cambodia, L = Laos, M = Myanmar, T = Thailand, V = Vietnam*

*ប្រភព៖ ADB, Review of Configuration of the Greater Mekong Sub-Region Economic Corridors, 2016.*

**រូបភាព ១.១១៖** ច្រករបៀងសេដ្ឋកិច្ច និងទីក្រុងក្នុងប្រទេសកម្ពុជា



*ប្រភព៖ World Bank Team based on Municipalities and Other Urban Areas (ADB, 2014)*

ទីក្រុងធំៗក្នុងប្រទេសកម្ពុជា រួមទាំងរាជធានីភ្នំពេញ (មានពិពណ៌នាបន្ថែមនៅក្នុងផ្នែករាជធានី) ក្រុងសៀមរាបនិងក្រុងព្រះសីហនុ (រៀបរាប់បន្ថែមនៅក្នុងផ្នែកទីក្រុងច្រកឆ្លងកាត់) និង ប៉ោយប៉ែតនិងបាវិត (មានពិពណ៌នាបន្ថែមនៅក្នុងផ្នែកទីក្រុង/ទីប្រជុំជន) ផងដែរ សុទ្ធតែស្ថិតនៅក្នុងទីតាំងយុទ្ធសាស្ត្រតាមបណ្ដោយច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូង។ ក៏ប៉ុន្តែ នៅមានក្រុង/ទីប្រជុំជនផ្សេងៗទៀតដែលមិនទាន់ទទួលបានឈានទៅទាញយកអត្ថប្រយោជន៍ឱ្យបានពេញលេញ ពីភូមិសាស្ត្រអំណោយផលរបស់ពួកគេនៅតាមច្រករបៀងសេដ្ឋកិច្ច នៅឡើយទេ។ បើកាលណាបរិស្ថានអំណោយផលចាំបាច់ត្រូវបានរៀបចំបង្កើតរួចហើយ រួមមានផែនការបច្ចុប្បន្នភាពអភិវឌ្ឍទីប្រជុំជន, ហេដ្ឋារចនាសម្ព័ន្ធសមស្របនិងការផ្ដល់សេវាជាមូដ្ឋាន, និងសមត្ថភាពស្ថាប័នសម្រាប់ផ្ដល់ហិរញ្ញប្បទានធ្វើផែនការ និងអនុវត្តគោលនយោបាយនិងគម្រោង ទីក្រុង/ទីប្រជុំជនទាំងនេះ ប្រហែលជាអាចនឹងដើរតួសំខាន់មួយជំរុញ

សកម្មភាពសង្គម-សេដ្ឋកិច្ច និងការអភិវឌ្ឍក្នុងមូលដ្ឋាន បាន ទៀតផង។ សូមជូនឧទាហរណ៍ខ្លះៗដូចខាងក្រោមនេះ។

**បាត់ដំបងៈ** ជាប្រពៃណី ក្រុងបាត់ដំបងជាមជ្ឈមណ្ឌលជួញដូរផលិតផលកសិកម្មមួយ ដែលដើរតួជាមជ្ឈមណ្ឌលពាណិជ្ជកម្ម សម័យអាណាព្យាបាលបារាំង (១៩០៧-១៩២៦) ហើយមានសក្តានុពលខ្ពស់ក្នុងការប្រែក្លាយខ្លួនទៅជាមជ្ឈមណ្ឌលកសិ-ឧស្សាហកម្មមួយ ទៅថ្ងៃមុខ។ ពិន្ទុ EPI របស់ក្រុងបាត់ដំបង ទទួលបានចំណាត់ថ្នាក់មានសក្តានុពល «ខ្ពស់ណាស់» សំខាន់ដោយសារតែមានតំណភ្ជាប់ជាមួយផ្លូវដឹកជញ្ជូន ដង់ស៊ីតេ កម្រិតនគរូបនីយកម្ម និងមូលធនមនុស្សខ្លាំង។ ថ្វីបើលទ្ធភាពចូលទៅកាន់ទីផ្សារ នៅខ្សោយជាងកត្តាបួនផ្សេងទៀតក៏ដោយ ទីក្រុងនេះមានឧត្តមភាពសំខាន់ៗផ្នែកភូមិសាស្ត្រនៅតាមអនុច្រករបៀងប៉ែកកណ្តាលនៃច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូង គឺផ្លូវជាតិលេខ៥ដែលភ្ជាប់ជាមួយរាជធានីភ្នំពេញ និងភូមិសាស្ត្រកៀករបស់ខ្លួនទៅនឹងព្រំប្រទល់អន្តរជាតិជាប់ជាមួយប្រទេសថៃ។ បាត់ដំបងស្ថិតក្នុងចំណោមក្រុងលំដាប់ទីពីរធំៗដោយមានប្រជាជនរស់នៅប្រមាណជា ១៥៥០០០នាក់ ក្នុងឆ្នាំ២០១៥ ដែលចំនួននេះកំពុងតែកើនបន្តិចម្តងៗ ហើយត្រូវបានគេរំពឹងទុកថា នឹងកើនថែម ៧០០០០នាក់ទៀត (ជិតពាក់កណ្តាលនៃចំនួនប្រជាជនរស់នៅក្នុងក្រុងនាពេលបច្ចុប្បន្ន) គិតត្រឹមឆ្នាំ២០៣០[១៩]។ ជាមួយផ្ទៃដីប្រមាណជា ៧៤% ក្នុងក្រុងបាត់ដំបងជាដីកសិកម្ម វិស័យមួយនេះបង្កើតការងារបានប្រមាណជា៧,៣% តែប៉ុណ្ណោះ (២០១៥)។ គិតត្រឹមឆ្នាំ២០១៥ ការងារចំនួន ៧០,៧% គឺជាការងារនៅក្នុងវិស័យសេវាកម្ម អាស្រ័យហេតុនេះវានៅមានសក្តានុពលច្រើនដើម្បីអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានថែមទៀត ពិសេសក្នុងផ្នែកជួញដូរពាណិជ្ជកម្ម សេវាកម្ម និងអប់រំ[១៨]។

បើទោះជាក្រុងបាត់ដំបងជួបប្រទះបញ្ហាប្រឈមមួយចំនួនក្នុងផ្នែករៀបចំក្រុងក៏ពិតមែន ពិសេស ភាពងាយរងគ្រោះកម្រិតមធ្យមរបស់ក្រុងដោយសារទឹកជំនន់ និងភាពងាយរងគ្រោះកម្រិតខ្ពស់ដោយសារភាពរាំងស្ងួត បាត់ដំបងស្ថិតក្នុងចំណោមទីក្រុងមួយចំនួនតូចក្នុងប្រទេសកម្ពុជាដែលមានប្លង់គោលស្តីពីការប្រើប្រាស់ដីធ្លី។ ក្រុងនេះត្រូវបានជ្រើសរើសធ្វើជាស្រុកគម្រោងសាកល្បងមួយក្រោមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៤៧ ស្តីពីការរៀបចំបង្កើតផែនការប្រើប្រាស់ដីធ្លី ក្រោមជំនួយបច្ចេកទេសពីទីភ្នាក់ងារ GIZ (Deutsche Gesellschaft fur Internationale Zusammenarbeit GmbH) នៃប្រទេសអាល្លឺម៉ង់។ តាមរយៈនេះ «ប្លង់គោលស្តីពីការប្រើប្រាស់ដីធ្លី ២០៣០» (Land Use Master Plan 2030) របស់ក្រុងបាត់ដំបង ស្ថិតនៅក្នុងចំណោមផែនការដំបូងគេមួយចំនួន ដែលត្រូវបានគណៈកម្មាធិការជាតិសម្រាប់រៀបចំដែនដីនិងនគរូបនីយកម្ម អនុម័តយល់ព្រមនៅក្នុងខែធ្នូ ឆ្នាំ២០១៥[២០]។ បច្ចុប្បន្ន ក្រុងបាត់ដំបងកំពុងមានបញ្ហាប្រឈមនៅក្នុងការស្វែងរកជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីអនុវត្តប្លង់គោលនេះ។ បើគ្មានជំនួយទេ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ក្រុងនឹងមិនអាចសម្រេចបានពេញលេញ តាមការណែនាំរបស់ប្លង់គោលនេះឡើយ។

### ១.៣.៣ ទីក្រុងច្រកឆ្លងកាត់

ទីក្រុងច្រកឆ្លងកាត់ គឺជាទីក្រុងដែលមានតួនាទីចម្បងជាចំណុចឆ្លងកាត់ ឬ«ខ្លោងទ្វារ» ទៅកាន់ប្រទេស ឬតំបន់មួយទៀត។ ទីក្រុងច្រកឆ្លងកាត់មានអាកាសយានដ្ឋាន ឬកំពង់ផែសមុទ្រថ្នាក់ជាតិឬអន្តរជាតិ ដែលមានមុខងារចម្បងសម្រាប់បម្រើការធ្វើដំណើរមកដល់ ឬការដំណើរចេញរបស់ភ្ញៀវ និងមានតួនាទីជាយុថ្កា ឬជាមជ្ឈមណ្ឌលសេដ្ឋកិច្ចតំបន់ ផងដែរ។

**សៀមរាបៈ** ជាទីក្រុងមួយដែលមានការរីកលូតលាស់យ៉ាងលឿនដោយសារតែកំណើនទេសចរណ៍អន្តរជាតិ ក្រុងសៀមរាបបម្រើជាច្រកទ្វារដ៏សំខាន់មួយទៅកាន់ឧទ្យានបុរាណវិទ្យាអង្គរ ដែលជារមណីយដ្ឋានបុរាណវិទ្យាដ៏ល្បីឈ្មោះជាអន្តរជាតិ និងជារមណីយដ្ឋានបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ ផងដែរ។ ក្នុងឆ្នាំ២០១៦ អាកាសយានដ្ឋានអន្តរជាតិក្រុងសៀមរាបទទួលបានភ្ញៀវទេសចរមកដល់ចំនួន១លាន ៥សែននាក់ ប្រៀបទៅនឹងចំនួន ១លាន ១សែននាក់ ដែលអាកាសយានដ្ឋានអន្តរជាតិភ្នំពេញទទួលបាន[២១]។ វិស័យសេវាកម្មក្នុងក្រុងសៀមរាប រួមទាំងផ្នែកទេសចរណ៍ផង ផ្តល់ការងារបាន ៦៨,៧% នៃការងារពីផ្នែកសេដ្ឋកិច្ចទាំងអស់នៅក្នុងក្រុង។ ក្រុងសៀមរាបជាទីក្រុងដែលមាន

១៨ ADB, Case Study 1: Building Urban Resilience in Battambang, Cambodia, 2015.

១៩ GGGI, Sustainable City Strategic Plan 2018-2030 (Draft), 2017.

២០ Phnom Penh Post - Battambang Approves Long Awaited Master Plan, 2016. http://www.phnompenhpost.com/real-estate/battambang-approves-long-awaited-master-plan

២១ ស្ថិតិទេសចរណ៍កម្ពុជា ឆ្នាំ២០១៦

ប្រជាជនរស់នៅច្រើនជាងគេលំដាប់ទីពីរក្នុងប្រទេសកម្ពុជា ដោយមានប្រជាជនចំនួនជាង២៤០០០០នាក់ក្នុងឆ្នាំ២០១៦ ជាមួយនឹងអត្រាកំណើនជាមធ្យម ៣%ក្នុងមួយឆ្នាំ ហើយចំនួននេះត្រូវបានគេរំពឹងទុកថានឹងកើនរហូតដល់ទៅ ៣៤៧០០០នាក់ ក្នុងឆ្នាំ២០៣០[២២]។ សន្ទស្សន៍ EPI របស់ខេត្តសៀមរាបមានសក្តានុពល «ខ្ពស់ណាស់» សំខាន់ ដោយសារតែមានតំណភ្ជាប់ជាមួយផ្លូវដឹកជញ្ជូន ដង់ស៊ីតេ កម្រិតនគរូបនីយកម្ម និងមូលធនមនុស្ស ជាចំណុចខ្លាំងរបស់ខ្លួន។ យ៉ាងណាក្តី លទ្ធភាពចូលដល់ទីផ្សាររបស់ក្រុងសៀមរាបនៅខ្សោយជាងកត្តាបួនផ្សេងទៀត ប៉ុន្តែនេះតាមមើលទៅប្រហែលជាមកពីដោយសារកត្តាលទ្ធភាពចេញចូលតាមផ្លូវអាកាសនេះ (ទាំងក្នុងស្រុកនិងអន្តរជាតិ) មិនត្រូវបានយកមកដាក់ចូលនៅក្នុងម៉ូដែលនៃការវិភាគសន្ទស្សន៍។

ដូចគ្នានឹងក្រុងបាត់ដំបងដែរ ក្រុងសៀមរាបស្ថិតក្នុងចំណោមក្រុងពីរដែលត្រូវបានរាជរដ្ឋាភិបាលជ្រើសរើសធ្វើជាគម្រោងសាកល្បងក្នុងអំឡុងឆ្នាំ ២០០១-២០០៨ ដើម្បីលើកកម្ពស់កំណែទម្រង់វិមជ្ឈការ និងពង្រឹងសមត្ថកិច្ចអាជ្ញាធរស្រុក។ ក្រោមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៤៧ «ផែនការមេចម្រុះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៃក្រុងសៀមរាប និងក្រុងអង្គរ» (Integrated Master Plan for Sustainable Development of Siem Reap and Angkor Town) ត្រូវបានរៀបចំរួចនៅឆ្នាំ២០០៦ (បន្តដោយបច្ចុប្បន្នភាពឆ្នាំ២០១០) ក្រោមជំនួយរបស់ទីភ្នាក់ងារជំនួយអន្តរជាតិប្រទេសជប៉ុន (JICA)។ ប៉ុន្តែ តាំងពីមានប្លង់គោលឆ្នាំ២០០៦ នោះមក ក្រុងសៀមរាបចេះតែបន្តមានការលូតលាស់គួរឱ្យកត់សម្គាល់ ក្រោមសម្ពាធកំណើនយ៉ាងខ្លាំងរបស់វិស័យទេសចរណ៍។ ក្រុងនេះមានចំនួនប្រជាជនកើនឡើងដង ហើយថែមស្រុកបីថ្មីទៀត (ស្រុកទឹកវិល ស្រុកក្របីរៀល និងស្រុកពួក) ទៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែអត់មានផែនទីកំណត់ហេដ្ឋារចនាសម្ព័ន្ធឱ្យបានសមស្របនៅឡើយទេ[២៣]។ ថ្នាក់ដឹកនាំក្រុងបានទទួលស្គាល់ភាពចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលរបស់ខ្លួនហើយបច្ចុប្បន្ននេះកំពុងតែដំណើរការរៀបចំធ្វើបច្ចុប្បន្នភាពប្លង់គោលនេះ ដោយសហការគ្នាជាមួយអាជ្ញាធរជាតិអប្សរា[២៤] ក្នុងភាពជាដៃគូជាមួយអង្គការ JICA និងអង្គការសេវាអភិវឌ្ឍន៍នៃប្រទេសអាល្លឺម៉ង់ (German Development Service/DED)[២៥]។

**ក្រុងព្រះសីហនុ៖** ក្រុងព្រះសីហនុជាមូលដ្ឋានកំពង់ផែសមុទ្រធំជាងគេរបស់កម្ពុជា អមដោយតំបន់សេដ្ឋកិច្ចពិសេសចំនួនបួនផង។ សន្ទស្សន៍ EPI របស់ក្រុងព្រះសីហនុជាប់ចំណាត់ថ្នាក់មានសក្តានុពល «ខ្ពស់» ហើយនៅលំដាប់បន្ទាប់គឺស្រុកស្ទឹងហាវដែលមានសក្តានុពល «មធ្យម»។ ពិន្ទុ EPI ខ្ពស់ក៏ដោយសារតែក្រុងនិងស្រុកពីរនេះមានតំណភ្ជាប់ផ្លូវដឹកជញ្ជូន ដង់ស៊ីតេសេដ្ឋកិច្ច និងអត្រានគរូបនីយកម្មល្អ។ ផ្ទុយទៅវិញ ក្រុងព្រះសីហនុមានលទ្ធភាពចូលទៅកាន់ទីផ្សារទាប ដោយសារតែទិន្នន័យមានកម្រិត (ពីព្រោះមិនរាប់បញ្ចូលតំណភ្ជាប់ជាមួយលទ្ធភាពចូលទៅផ្សារអន្តរជាតិ) ដែលប្រសិនជាបានរាប់បញ្ចូលវិញ វាអាចនឹងដំឡើងសន្ទស្សន៍ EPI របស់ក្រុងព្រះសីហនុឱ្យខ្ពស់គួរឱ្យកត់សម្គាល់ ជាមិនខាន។

ស្ថាប័នផ្តល់ជំនួយអន្តរជាតិជាច្រើន និងវិស័យឯកជន បានធ្វើការវិនិយោគមួយចំនួនទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសក្នុងក្រុងព្រះសីហនុ។ កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ (ក្នុងនោះ មានចំណតកុងតឺន័រមានសមត្ថភាពលើកដាក់កុងតេន័រទំហំ២០ហ្វីត បាន ៣៥០០០០ កុងតឺន័រក្នុងមួយឆ្នាំ, ចំណតលើកដាក់ទំនិញដុលមានសមត្ថភាពលើកដាក់ទំនិញដុលបាន៩សែនតោនក្នុងមួយឆ្នាំ និងចំណតអ្នកដំណើរដែលមានសមត្ថភាពទទួលអ្នកដំណើរបាន ២៧០០០០ នាក់ក្នុងមួយឆ្នាំ) គឺជាកំពង់ផែទឹកជ្រៅតែមួយគត់របស់កម្ពុជា[២៦] ត្រូវបានសាងសង់ឡើងនៅក្នុងឆ្នាំ ១៩៥៦ ហើយរ៉ាប់រងជាង ៦០% នៃការដឹកជញ្ជូនភ័ស្តុភារសរុបកម្រិតជាតិ។ នៅជាប់នឹងកំពង់ផែនោះ អង្គការ JICA បានវិនិយោគទៅលើការអភិវឌ្ឍបង្កើតតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ ដែលបច្ចុប្បន្នមានទំហំ ៧០ហិកតា ហើយកំពុងពិចារណាលទ្ធភាពពង្រីកវាដល់ទំហំ ១៦០ហិកតា សម្រាប់កំណើនសកម្មភាពទៅ

---

២២ GGGI, 2017.

២៣ Ibid.

២៤ អាជ្ញាធរជាតិអប្សរាគឺជាស្ថាប័នកម្ពុជាមួយដែលមានការទទួលខុសត្រូវលើការការពារឧទ្យានបុរាណវិទ្យាអង្គរ។

២៥ Phnom Penh Post - Siem Reap Expand City While Houses Downtown Remain Undeveloped, 2016. http://www.phnompenhpost.com/post-property/siem-reap-expand-city-while-houses-downtown-remain-undeveloped

២៦ ក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូននៃសាធារណរដ្ឋកូរ៉េ។ ការរៀបចំបង្កើតប្លង់គោល និងគម្រោងសាកល្បងសម្រាប់ក្រុងព្រះសីហនុ ប្រទេសកម្ពុជា (បទបង្ហាញនាកិច្ចប្រជុំចាប់ផ្តើមគម្រោង) ឆ្នាំ២០១៧។

ថ្ងៃអនាគត[២៧]។ ក្រៅពីនេះ ក្នុងឆ្នាំ២០១៧ អង្គការ JICA បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្ចីមួយសម្រាប់ធ្វើការពង្រីកទ្រង់ទ្រាយធំនៅកំពង់ផែព្រះសីហនុ ដោយក្នុងនោះថែមចំណតកុងតឺន័រថ្មីមួយទៀតផង[២៨]។

តំបន់សេដ្ឋកិច្ចពិសេសធំជាងគេនៅក្រុងព្រះសីហនុ មានឈ្មោះថា តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ជាទូទៅនៅក្នុងមូលដ្ឋានគេហៅថា តំបន់សេដ្ឋកិច្ចពិសេសបិតក្រាង) ដែលត្រូវបានគ្រោងថានៅពេលសង់រួចរាល់ នឹងមានទំហំផ្ទៃដីសរុប ១១១៣ ហិកតា មានសមត្ថភាពដាក់ស្នាក់ការក្រុមហ៊ុនបានចំនួន១១៨ (១០០មកពីប្រទេសចិន, ៦កម្ពុជា, និង១២មកពីប្រទេសផ្សេងទៀត) និងជួលកម្មករនិយោជិតចំនួន ២០០០០នាក់។ ដំណាក់កាលទី១ (៥២៨ហិកតា) នៃការអភិវឌ្ឍត្រូវបានបញ្ចប់ក្នុងឆ្នាំ ២០០៨ ហើយបច្ចុប្បន្នកំពុងតែប្រតិបត្តិការនៅក្រោមជំនួយរបស់ប្រទេសចិន។ ឧស្សាហកម្មសំខាន់ៗនៅទីនោះរួមមាន ការផលិតសំលៀកបំពាក់ វាយនភណ្ឌ គ្រឿងចក្រ និងគ្រឿងផ្សំឧបករណ៍អេឡិចត្រូនិក។ ដំណាក់កាលទី២កំពុងស្ថិតក្នុងដំណើរការសាងសង់។ ក្នុងរយៈពេល ៥ឆ្នាំខាងមុខ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ មានគោលដៅដាក់ក្រុមហ៊ុនឱ្យបានដល់ ៥០០ ក្រុមហ៊ុន ជាមួយនឹងកម្លាំងពលករនិយោជិតសរុបប្រមាណពី ៨០០០០ ទៅ ១០០០០០នាក់[២៩]។

ក្រៅពីសក្តានុពលផ្នែកឧស្សាហកម្ម ក្រុងព្រះសីហនុក៏ត្រូវបានចាត់ផងដែរថាជាប៉ូលមួយក្នុងចំណោមប៉ូលទេសចរណ៍ទាំងបួនរបស់កម្ពុជា រួមមាន ភ្នំពេញ សៀមរាប តំបន់ឆ្នេរ និងតំបន់ឦសាន។ ឆ្នេរធម្មជាតិ ជីវៈចម្រុះ រមណីយដ្ឋានធម្មជាតិ និងលទ្ធភាពផ្លូវចេញចូល (អាកាសយានដ្ឋានអន្តរជាតិ កំពង់ផែអន្តរជាតិ និងសេវាដឹកជញ្ជូនដោយរថភ្លើង) ធ្វើឱ្យក្រុងព្រះសីហនុជាគោលដៅទេសចរណ៍គួរឱ្យទាក់ទាញមួយ។ ក្នុងឆ្នាំ២០១៦ ភ្ញៀវទេសចរចំនួន២លាននាក់ បានទៅលេងក្រុងព្រះសីហនុ ដែលក្នុងនោះ ១,៧លាននាក់ជាអ្នកទេសចរក្នុងស្រុក។ វិស័យសេវាកម្មនៅក្នុងក្រុងព្រះសីហនុមានចំណែកធំជាងគេក្នុងការបង្កើតការងារ រហូតដល់ទៅ ៩០,១% ឯណោះ[៣០]។

**ប្រអប់ ១.១៖** តំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា

តាមរយៈក្រឹត្យមួយចេញក្នុងឆ្នាំ២០០៥ កម្ពុជាបង្កើតក្របខណ្ឌច្បាប់មួយសម្រាប់តំបន់សេដ្ឋកិច្ចពិសេស។ មកទល់បច្ចុប្បន្ននេះ មានតំបន់សេដ្ឋកិច្ចពិសេសប្រហែលជា ៣០ នៅទូទាំងប្រទេស (បួនក្នុងក្រុងព្រះសីហនុ, បីនៅបាវិត, មួយនៅភ្នំពេញ ប៉ោយប៉ែត កោះកុងកណ្តាល កំពត និងកន្លែងផ្សេងទៀត)។ ជាចម្បង តំបន់សេដ្ឋកិច្ចពិសេសទាំងនេះជាតំបន់កែច្នៃផលិតផលសម្រាប់ការនាំចេញ ដោយក្រុមហ៊ុនជាអ្នកនាំចូលធាតុចូលពាក់កណ្តាលសម្រេចដោយខ្លួនឯង យកមកធ្វើផលិតកម្មសម្រេចសម្រាប់នាំចេញទៅលក់នៅខាងក្រៅ។ អាស្រ័យហេតុនេះហើយបានជាតំបន់សេដ្ឋកិច្ចពិសេសជាច្រើនមានទីតាំងស្ថិតនៅជិតកំពង់ផែទឹកជ្រៅ ដើម្បីមានភាពងាយស្រួលក្នុងការដឹកជញ្ជូននាំចេញ។ សេវាច្រកចេញចូលតែមួយដែលភ្នាក់ងារនានារបស់រដ្ឋាភិបាលផ្តល់ មានគោលដៅធានាឱ្យមានបរិស្ថានធុរកិច្ចមានលំនឹង ហេដ្ឋារចនាសម្ព័ន្ធ ទឹកភ្លើង និងសេវា ព្រមទាំងឯកសិទ្ធិនានាទៀតដែរ (ដូចជា ការធានាមិនឱ្យមានការត្រួតត្រាទៅលើថ្លៃ ឬទៅលើការប្តូររូបិយបណ្ណអន្តរជាតិ ការផ្ទេរចេញរូបិយបណ្ណបរទេសដោយសេរី ការលើកលែងឱ្យរួចពន្ធគយនាំចូលនិងពីអាករលើតម្លៃបន្ថែម, រយៈពេលអនុគ្រោះពន្ធ និងអត្ថប្រយោជន៍ច្រើនទៀត) ដែលជាប្រការអាចទាក់ទាញការវិនិយោគផ្ទាល់ពីប្រទេស (FDI)[៣១]។

ខណៈដែលតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាធ្លាប់ទទួលបានជោគជ័យនៅក្នុងការបង្កើតការងារ (ពិសេសសម្រាប់នារីវ័យក្មេង) ដោយបម្រើជាចម្បងដល់តំបន់កែច្នៃសម្រាប់ការនាំចេញ តំបន់សេដកិច្ចពិសេសទាំងនេះមានតំណទាក់ទងខ្សោយណាស់ជាមួយសេដកិច្ចក្នុងស្រុក។ បើទោះតំបន់សេដ្ឋកិច្ចពិសេសភាគច្រើនស្ថិតនៅតាមច្រករបៀងសេដ្ឋកិច្ចនៃមហាអនុតំបន់ទន្លេមេគង្គមែនក្តី និងមានសក្តានុពលក្នុងការប្រែក្លាយជាទីក្រុងច្រកឆ្លងកាត់ ឬចំណុចប្រសព្វសេដ្ឋកិច្ចតំបន់ក៏ដោយ នៅក្នុងខណៈនេះ តំបន់សេដ្ឋកិច្ចទាំងនោះមិនសូវបានជួយសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងការធ្វើសមាហរណកម្មក្នុងតំបន់ប៉ុន្មានទេ។

---

២៧ Ibid

២៨ JICA Press Release: https://www.jica.go.jp/english/news/press/2017/170808_01.html

២៩ សម្ភាសន៍នៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ខែមីនា ឆ្នាំ២០១៨។

៣០ GGGI, 2017.

៣១ ADB, The Role of Special Economic Zones in Improving Effectiveness of GSM Economic Corridors, 2016.

**រូបភាព ១.១២៖** តំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា




*ប្រភព៖ ក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូននៃសាធារណរដ្ឋកូរ៉េ។ ការរៀបចំបង្កើតប្លង់គោល និងគម្រោងសាកល្បងសម្រាប់ក្រុងព្រះសីហនុ ប្រទេសកម្ពុជា (បទបង្ហាញនាកិច្ចប្រជុំចាប់ផ្ដើមគម្រោង) ឆ្នាំ ២០១៧។*

## ១.៣.៤ ទីក្រុង ឬទីប្រជុំជនជាប់ព្រំដែន

ដោយភាគច្រើនមានស្ថានភាពជាយុទ្ធសាស្ត្រស្ថិតនៅតាមច្រករបៀងសេដ្ឋកិច្ចស្រាប់ ទីក្រុង ឬទីប្រជុំជនជាប់ព្រំដែនប្រហែលជាអាចដើរតួនាទីបានច្រើននៅក្នុងការធ្វើជាច្រកឆ្លងកាត់ពាណិជ្ជកម្ម និងទេសចរណ៍ឆ្លងដែន ព្រមទាំងជាតំបន់សេដ្ឋកិច្ចតាមព្រំដែន (Border Economic Zones/BEZ) ផងដែរ ដើម្បីសម្រួលដល់ផ្នែកផលិតកម្ម និងការជួញដូរឆ្លងដែន។ ទីក្រុង ឬទីប្រជុំជនជាប់ព្រំដែនទាំងនេះ មានសក្ដានុពលសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ក៏ពិតមែន ប៉ុន្តែការសម្របសម្រួលខ្សោយនៅផ្ទៃក្នុងនិងក្រៅប្រទេស(រួមទាំងភាពស្មុគស្មាញនៅក្នុងការសម្របសម្រួលការឆ្លងដែន និងចម្ងាយឆ្ងាយពីបណ្ដាក្រសួង), ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងសេវាខ្សោយ, និងសមត្ថភាពស្ថាប័នខ្សោយ ជាឧបសគ្គរារាំងទីក្រុង ឬទីប្រជុំជនជាប់ព្រំដែនទាំងនេះមិនឱ្យឈានទៅសម្រេចសក្ដានុពលសេដ្ឋកិច្ចរបស់ខ្លួនបាន។ ក្នុងករណីកម្ពុជា ទីក្រុងជាប់ព្រំដែនជាមួយប្រទេសថៃ និងជាមួយប្រទេសវៀតណាម សុទ្ធជាព្រំដែនដីគោក ប្រហែលអាចជាមិនសូវជាគួរឱ្យទាក់ទាញប៉ុន្មានទេសម្រាប់អ្នកវិនិយោគ ដោយពួកគេច្រើនមើលឃើញកាលានុវត្តភាពច្រើនជាងនៅតាមទីក្រុងច្រកឆ្លងកាត់ ដូចជាក្រុងព្រះសីហនុជាដើម ដែលមានកំពង់ផែទឹកជ្រៅភ្ជាប់ទៅជាមួយនឹងផ្សារអន្តរជាតិ[៣២]។ យ៉ាងណាក៏ដោយ ប្រទេសថៃ និងប្រទេសវៀតណាមសុទ្ធតែជាទីផ្សារមានសារៈសំខាន់ អាស្រ័យហេតុនេះចាំបាច់ត្រូវបង្កលក្ខណៈឱ្យមានបរិស្ថានអំណោយផលដើម្បីបង្កើតសកម្មភាពឧស្សាហកម្មរស់រវើកនៅតាមច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូង។

**ក្រុងប៉ោយប៉ែត (ជាប់ព្រំដែនជាមួយស្រុកអារញ្ញក្នុងប្រទេសថៃ)៖** ដោយស្ថិតក្នុងភូមិសាស្ត្រតាមព្រំដែនកម្ពុជា-ថៃក្នុងអនុច្រករបៀងប៉ែកខាងជើងនៃច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូង (ផ្លូវជាតិលេខ៦) និងអនុច្រករបៀងភូមិភាគកណ្ដាលនៃច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូង (ផ្លូវជាតិលេខ៥) ប៉ោយប៉ែតជាក្រុងជាប់ព្រំដែនសំខាន់មួយ ដែលកំពុងតែរីកចម្រើនឈានទៅក្លាយជាច្រកឆ្លងកាត់សេដ្ឋកិច្ចមួយ សម្រាប់ប្រទេសកម្ពុជា។ ចាប់តាំងពីការបើកពាណិជ្ជកម្មឆ្លងដែនក្នុងឆ្នាំ១៩៩៣មក ប៉ោយប៉ែតបានលេចមុខជាគោលដៅទេសចរណ៍មួយសម្រាប់ពលរដ្ឋថៃ និងសម្រាប់ទេសចរបរទេសឯទៀតដែលធ្វើដំណើរទៅកាន់ខេត្តបាត់ដំបង និងខេត្តសៀមរាប។ ទីក្រុងនេះបានបង្កើតឱ្យមានសកម្មភាពសេដ្ឋកិច្ចជាច្រើន ដូចជាគ្រឹះស្ថានកំសាន្ត និងល្បែងស៊ីសង (កាស៊ីណូ) សណ្ឋាគារ និងភោជនីយដ្ឋាន សកម្មភាពធនាគារ និងតូបដូរលុយ ជាដើម។ តំបន់សេដ្ឋកិច្ចពិសេសដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១០ និងសួនឧស្សាហកម្មមួយចំនួនទៀត (កម្មន្តសាលធនស្រាល និងវេចខ្ចប់ រួមទាំងគ្រឿងបន្លាស់រថយន្តផង) ត្រូវបានគេរំពឹងទុកថានឹងជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មឆ្លងដែន[៣៣]។ ក្រុងប៉ោយប៉ែតត្រូវបានចាត់ចំណាត់ថ្នាក់ថាមានសក្ដានុពល «ខ្ពស់» សំខាន់ដោយសារតែវាមានដង់ស៊ីតេសេដ្ឋកិច្ច និងអត្រានគរូបនីយកម្មខ្លាំង។

នៅក្នុងបញ្ហាប្រឈមនានាដែលក្រុងប៉ោយប៉ែតជួបប្រទះ គឺមាន តម្រូវការខ្ពស់ក្នុងការរកដំណោះស្រាយលំនៅដ្ឋានសម្រាប់ពលករចំណាកស្រុកដែលបានមកធ្វើការនៅក្នុងសួនឧស្សាហកម្ម និងឱនភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធទីប្រជុំជន (អគ្គិសនី ការគ្រប់គ្រងកាកសំណល់រឹង និងទឹកស្អុយ)។ ផែនការមេមួយត្រូវបានរៀបចំរួចហើយ ប៉ុន្តែមិនទាន់ទទួលបានការអនុម័តលើនៅឡើយ ដែល

៣២ ដូចបានលើកឡើងក្នុងប្រអប់ ១.១ បច្ចុប្បន្ននេះតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជាដើរតួនាទីចម្បងជាតំបន់កែច្នៃផលិតផលសម្រាប់ការនាំចេញស្របគ្នាជាមួយនឹងការនិយមរបស់អ្នកវិនិយោគទៅលើទីតាំងនៅជិតកំពង់ផែទឹកជ្រៅ ជាជាងទីតាំងជាប់តំបន់ព្រំដែន ដូចជាក្រុងប៉ោយប៉ែត និងក្រុងបាវិត ជាដើម។

៣៣ GGGI, 2017.

ជាលទ្ធផលបណ្តាលឱ្យមានការអភិវឌ្ឍគ្មានរបៀបរៀបរយ ហើយទុកឱ្យផ្នែកខ្លះរបស់ទីក្រុងនេះងាយនឹងរងគ្រោះពីទឹកជំនន់ណាស់។

**បាវិត (ជាប់ព្រំដែនជាមួយម៉ុកបៃនៃប្រទេសវៀតណាម)៖** បាវិតគឺជាក្រុងជាប់ព្រំដែនសំខាន់មួយដែរ ដែលស្ថិតនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ក្នុងអនុច្រករបៀងភូមិភាគកណ្តាលនៃច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូង (ផ្លូវជាតិលេខ១)។ ស្រដៀងគ្នានឹងប៉ោយប៉ែតដែរ ស្ថានភាពភូមិសាស្ត្រជាយុទ្ធសាស្ត្ររបស់ក្រុងបាវិតនៅតាមព្រំដែន បាននាំឱ្យលេចចេញឡើងនូវសកម្មភាពមុខរបរកំសាន្តឬល្បែងស៊ីសង ដូចជាកាស៊ីណូ (១២ កន្លែង) ដែលហាមមិនឱ្យពលរដ្ឋកម្ពុជាចូលលេងទេ ហើយសម្រាប់តែភ្ញៀវបរទេស ជាពិសេសភ្ញៀវទេសចរមកពីវៀតណាម និងចិន។ ក្រៅពីវិស័យទេសចរណ៍ដែលដឹកនាំដោយកាស៊ីណូ ឧស្សាហកម្មផ្សេងៗទៀត ដូចជារោងចក្រវាយនភណ្ឌ ផលិតកង់ និងគ្រឿងអេឡិចត្រូនិក ត្រូវបានបង្កើតឡើងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមួយចំនួន ដែលដើរតួជាប្រភពធំមួយ ក្នុងការបង្កើតការងារ។ ក្រុងនេះមានផែស្ងួតចំនួនបីកន្លែងស្ថិតក្រោមប្រតិបត្តិការរបស់ផ្នែកឯកជន ដែលមិនបានបង្កើតចំណូលពន្ធ ឬអាករសម្រាប់រដ្ឋាភិបាលទេ។ សន្ទស្សន៍ EPI របស់ក្រុងបាវិតទទួលបានចំណាត់ថ្នាក់មានសក្តានុពល «មធ្យម» ជាចម្បងដោយសារតែវាមានលទ្ធភាពខ្លាំងក្នុងការភ្ជាប់ជាមួយបណ្តាញផ្លូវដឹកជញ្ជូន និងលទ្ធភាពមធ្យមក្នុងការចូលដល់ទីផ្សារ និងផ្នែកមូលធនមនុស្ស។ ប៉ុន្តែ ក្រៅពីកាស៊ីណូ និងតំបន់សេដ្ឋកិច្ចពិសេស ការអភិវឌ្ឍសេដ្ឋកិច្ចនៅមានភាពទន់ខ្សោយនៅឡើយ ហើយសក្តានុពលរបស់ទីក្រុងជាប់ព្រំដែនក៏មិនទាន់សម្រេចបាននៅឡើយដែរ។ បញ្ហាប្រឈមចំគឺហេដ្ឋារចនាសម្ព័ន្ធទីប្រជុំជន ដែលក្នុងនោះ ផ្លូវ ប្រឡាយ លូបង្ហូរទឹកស្អុយនៅមានកម្រិតនៅឡើយ។ ក្រុងនេះឥតមានស្ថានីយធ្វើប្រព្រឹត្តិកម្មទឹកស្អុយទេ ដែលបង្កើតឱ្យមានបញ្ហាបរិស្ថានច្រើន ដោយសារទឹកស្អុយនិងទឹកភ្លៀងហូរលាយឡំជាមួយគ្នាចាក់ចូលទៅក្នុងតំបន់ដីកសិកម្ម និងវាលស្រែ មុននឹងហូរចុះទៅដល់តំបន់ព្រំដែនជាមួយប្រទេសវៀតណាម។

## ១.៣.៤ រដ្ឋធានី

រដ្ឋធានីជាទីក្រុងដែលដើរតួនាទីជាមជ្ឈមណ្ឌលចម្បងផ្នែកសេដ្ឋកិច្ច វប្បធម៌ និងបញ្ញវន្តរបស់ប្រជាជាតិមួយ។ ក្នុងករណីភាគច្រើន រដ្ឋធានីក៏មានតួនាទីជាមជ្ឈមណ្ឌលនយោបាយរបស់ជាតិដែរ ដែលនៅទីនោះមានវត្តមានស្ថាប័នកំពូលរបស់រដ្ឋាភិបាល និងជាកន្លែងដែលគេធ្វើសេចក្តីសម្រេចនានាសម្រាប់ប្រទេស។ រដ្ឋធានីភាគច្រើនមានមនុស្សរស់នៅច្រើនជាងគេ ព្រមទាំងផ្តល់កាលានុវត្តភាពគួរឱ្យទាក់ទាញខ្លាំងច្រើនផ្នែកការងារទៀតផង។ តាមធម្មតា រដ្ឋធានីច្រើនតែដើរតួជាទីក្រុងច្រកឆ្លងកាត់។ លើសពីនោះ នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ រដ្ឋធានីភាគច្រើនស្ថិតក្នុងភូមិសាស្ត្រជាយុទ្ធសាស្ត្រនៅតាមច្រករបៀងសេដ្ឋកិច្ចតំបន់។

**ភ្នំពេញ៖** ជារាជធានីរបស់ប្រទេស ភ្នំពេញគឺជាមជ្ឈមណ្ឌលសេដ្ឋកិច្ច ឧស្សាហកម្ម និងវប្បធម៌របស់កម្ពុជា។ អាស្រ័យហេតុនេះ វាធម្មតាទេដែលភ្នំពេញមានសន្ទស្សន៍ EPI ខ្ពស់ជាងគេនៅក្នុងប្រទេស ដោយក្នុងនោះខណ្ឌភាគច្រើនទទួលបានពិន្ទុខ្ពស់នៅក្នុងចំណាត់ថ្នាក់ទាំងប្រាំ (បើទោះជាខណ្ឌមួយចំនួនតូចមានពិន្ទុផ្នែកមូលធនមនុស្សខ្សោយបន្តិចក្តី)។ ភ្នំពេញជាទីក្រុងមានមនុស្សរស់នៅច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា គឺប្រមាណជា ២លាននាក់ នៅក្នុងឆ្នាំ២០១៥ ហើយតាមការព្យាករទុកចំនួននេះនឹងកើនដល់ ២,៨៧លាននាក់ ក្នុងឆ្នាំ២០៣៥[៣៤]។ សម្ពុះនគរូបនីយកម្មយ៉ាងលឿន និងការហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស បាននាំឱ្យមានការអភិវឌ្ឍផ្នែកពាណិជ្ជកម្មគួរឱ្យកត់សម្គាល់ នៅក្នុងទីក្រុងភ្នំពេញ។ ការអភិវឌ្ឍផ្នែកឯកជនទ្រង់ទ្រាយធំបានបង្កើតឱកាសមានការងារ និងការផ្គត់ផ្គង់លំនៅដ្ឋានច្រើន រួមចំណែកដល់កំណើនសេដ្ឋកិច្ចរបស់ទីក្រុង។ យ៉ាងណាក្តី ការអភិវឌ្ឍទាំងនេះក៏បានបន្ថែមសម្ពាធទៅលើហេដ្ឋារចនាសម្ព័ន្ធក្រុង និងការផ្តល់សេវាដែរ។

ថ្វីបើស្ថាប័នផ្តល់ជំនួយអន្តរជាតិបានផ្តល់ជំនួយបច្ចេកទេស ជំនួយឥតសំណង ឬឥណទានច្រើនសន្ធឹកសន្ធាប់ដល់ទីក្រុងភ្នំពេញក៏ពិតមែន សមត្ថភាពនិងល្បឿនរបស់ក្រុងក្នុងការធ្វើហិរញ្ញប្បទាន ការធ្វើផែនការ និងការអនុវត្ត នៅមិនទាន់ដើរទាន់សម្ពុះនគរូបនីយកម្ម និងការអភិវឌ្ឍពាណិជ្ជកម្ម នៅឡើយទេ។ ការសម្របសម្រួលតាមវិស័យ និងផែនការគ្រប់គ្រងដីធ្លីចម្រុះមួយគឺជាភាពចាំបាច់ដើម្បីធានាយ៉ាងណាឱ្យមានផែនការរៀបចំក្រុងដើម្បីឆ្លើយតបទៅនឹងតម្រូវការដ៏ច្រើនរបស់ក្រុង។ ដីធ្លីត្រូវបម្រុងទុកដើម្បីបំពេញតម្រូវចាំបាច់ផ្សេងៗទៅថ្ងៃមុខ រួមទាំងការប្រើប្រាស់សម្រាប់ផ្នែកឧស្សាហកម្ម ផ្នែកពាណិជ្ជកម្ម ផ្នែកសង្គម ផ្នែកលំនៅដ្ឋាន និងផ្នែកលំហែកំសាន្ត ក៏ដូចជាសម្រាប់បម្រើតម្រូវការហេដ្ឋារចនាសម្ព័ន្ធធំៗ មានព្រលានយន្តហោះ និងផ្លូវ ជាដើម។ បើគ្មានផែនការលម្អិតគ្រប់គ្រងការប្រើប្រាស់ដីធ្លីនៅក្នុងកាលៈទេសៈ

៣៤ ធនាគារពិភពលោក ឆ្នាំ២០១៧ «ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ»

ដែលនគរូបនីយកម្មកំពុងតែមានសន្ទុះលឿនដូចសព្វថ្ងៃនេះទេ ភ្នំពេញនឹងជួបការលំបាក ហើយនៅក្នុងការសម្របសម្រួលតម្រូវការនៅតាមផ្នែកផ្សេងៗគ្នាក្នុងទីក្រុង។

**ភ្នំពេញរីកមាឌ (រួមទាំងខេត្តកណ្តាល)៖** សន្ទុះនគរូបនីយកម្ម និងការអភិវឌ្ឍដ៏លឿនរបស់ក្រុងភ្នំពេញនឹងបន្តបង្ខំឱ្យទីក្រុងនេះពង្រីកផ្ទៃទំហំដែនដី ទៅក្រសោបយកទីប្រជុំជនតូចៗមួយចំនួននៅជុំវិញមកបញ្ចូលក្រោមយុត្តាធិការរបស់ខ្លួន។ ក្រៅពីឃុំចំនួន២០របស់ខេត្តកណ្តាលដែលត្រូវបានធ្វើសមាហរណកម្មឱ្យមកនៅក្រោមយុត្តាធិការរបស់រាជធានីភ្នំពេញនៅក្នុងឆ្នាំ២០១០[៣៥] រួចមក ស្រុកមួយចំនួននៃខេត្តកណ្តាលនិងខេត្តផ្សេងទៀតនៅជុំវិញផ្តុំគ្នាបានជាតំបន់សេដ្ឋកិច្ចក្រុងធំមួយ របស់រាជធានីភ្នំពេញដែលកំពុងរីកមាឌ។ តំបន់ក្រុងភ្នំពេញរីកមាឌអាចសន្ធឹងរហូតដល់ទៅចម្ងាយ ១០០គ.ម. ព័ទ្ធជុំវិញរាជធានីបច្ចុប្បន្ន បើកាលណាគេពិចារណាមើលការប្រមូលផ្តុំរបស់ហេដ្ឋារចនាសម្ព័ន្ធ សេវាសាធារណៈ និងឱកាសការងារ (រាជធានីភ្នំពេញ, ២០១៧)។ បើទោះជាខណ្ឌភាគច្រើននៅក្នុងរាជធានីនេះទទួលបានចំណាត់ថ្នាក់ពិន្ទុ EPI ថាមានសក្តានុពល «ខ្ពស់» ឬ «ខ្ពស់ណាស់» មែន ខណ្ឌទាំងនោះកំពុងតែរងសម្ពាធ និងភាពតានតឹងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងផ្នែកផ្តល់សេវាក្រុង កាន់តែខ្លាំងឡើងដែរ។

៣៥ ការដាក់បញ្ចូលឃុំចំនួន២០ពីខេត្តកណ្តាលមកនៅក្រោមការគ្រប់គ្រងរដ្ឋបាលរបស់រាជធានីភ្នំពេញ បានធ្វើឱ្យខណ្ឌកើនចំនួនពី ៧ ដល់ ១២ ហើយពង្រីកទំហំដែនដីរបស់ក្រុងពី ៣៧៦,១៧គម២ ទៅដល់ ៦៧៨,៤៧គម២។

# ផ្នែកទី ២ ឧបសគ្គដល់ការឈានទៅសម្រេចឱ្យបានពេញលេញនូវសក្តានុពលសេដ្ឋកិច្ចរបស់នគរូបនីយកម្ម



ដូចបានរៀបរាប់នៅក្នុង «ផ្នែកទី ១» ខាងលើរួចហើយ ទីក្រុងជាច្រើនមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ ប៉ុន្តែក៏នៅមានឧបសគ្គមួយចំនួនដែលទីក្រុងទាំងនោះកំពុងតែជួបប្រទះនៅក្នុងការឈានទៅសម្រេចសក្តានុពលរបស់ខ្លួន។ ឧបសគ្គទាំងនោះរួមមាន កង្វះខាតបណ្តាញការដឹកជញ្ជូននៅក្នុងរង្វង់ទីក្រុងដើម្បីសម្រួលដល់ចរាចរណ៍ទំនិញនិងសេវា, ហេដ្ឋារចនាសម្ព័ន្ធនិងការផ្តល់សេវានៅមានកម្រិតនៅក្នុងក្រុង, និងសមត្ថភាពស្ថាប័ននៅខ្សោយនៅក្នុងការរៀបចំគោលនយោបាយ ការធ្វើហិរញ្ញប្បទាន និងរៀបចំផែនការ ការអនុវត្ត និងការរឹតបន្តឹងការអនុវត្តការផ្តល់សេវា ដូចមានរៀបរាប់ជូននៅខាងក្រោម។

## ២.១ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសម្រាប់ការអភិវឌ្ឍទីក្រុង

**ការដឹកជញ្ជូនក្នុងរវាងទីក្រុង (តំបន់)៖** ប្រទេសកម្ពុជាគឺជាមុខតំណភ្ជាប់សំខាន់មួយរបស់ច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូងរបស់មហាអនុតំបន់ទន្លេមេគង្គ។ អាស្រ័យហេតុនេះ បណ្តាញហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនមានប្រសិទ្ធផល ក្នុងការផ្សារភ្ជាប់ជាមួយមជ្ឈមណ្ឌលសេដ្ឋកិច្ច (ទីក្រុង ទីផ្សារ កំពង់ផែ តំបន់ឧស្សាហកម្មជាដើម) មានសារៈសំខាន់ជាសារវន្តសម្រាប់ការអភិវឌ្ឍតំបន់ និងសម្រាប់ភាពប្រកួតប្រជែងរបស់ទីក្រុងច្រករបៀង។ មកទល់បច្ចុប្បន្ននេះ តម្រូវការដឹកជញ្ជូននៅក្នុងប្រទេសកម្ពុជានៅតែបន្តពឹងផ្អែកទៅលើប្រព័ន្ធផ្លូវ ដែលនៅក្នុងឆ្នាំ២០១៥ ប្រវែង ២២០០ គ.ម. ជាផ្លូវជាតិលំដាប់ទីមួយ និង៥០០០គ.ម. ទៀតជាផ្លូវជាតិលំដាប់ទីពីរ។ នៅក្នុងនោះ ផ្លូវជាតិលំដាប់ទីមួយជាផ្លូវកៅស៊ូរាបស្មើ១០០ភាគរយ ហើយមានតែ៥៧ភាគរយទេនៃផ្លូវជាតិលំដាប់ទីពីរជាផ្លូវកៅស៊ូរាបស្មើ។ រវាងឆ្នាំ២០០៨ និងឆ្នាំ២០១៣ ចំនួនយានជំនិះចុះបញ្ជីក្នុងប្រទេសកម្ពុជាមានកំណើន ១៤%ក្នុងមួយឆ្នាំ (ក្នុងនោះម៉ូតូកើន២២%ក្នុងមួយឆ្នាំ)។ ចំនួនយានយន្តសរុបនៅក្នុងទូទាំងប្រទេសបានកើនដល់ប្រហែល ២,៥លានគ្រឿង

ក្នុងឆ្នាំ២០១៣[៣៦]។ ផ្លូវជាតិលំដាប់ទីមួយនិងលំដាប់ទីពីរ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរួមរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន បានទទួលការជួសជុលស្តារហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍ ក្រោមជំនួយពីធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងារជំនួយប្រទេសអូស្ត្រាលី ប្រទេសជប៉ុន ចិន សាធារណរដ្ឋកូរ៉េ ថៃ និងតួអង្គនានាក្នុងវិស័យឯកជន[៣៧]។ ប៉ុន្តែ ផ្លូវលំដាប់ទីបីនិងផ្លូវលំទីប្រជុំជនអាចធ្លាក់ទៅនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងអភិវឌ្ឍន៍ជនបទ អាជ្ញាធរខេត្ត ឬអាជ្ញាធរក្រុង ហើយដែលជារឿយៗតែងប្រឈមនឹងការខ្វះខាតហិរញ្ញប្បទាន ឬសមត្ថភាពសម្រាប់ធ្វើការថែទាំ និងជួសជុលផ្លូវទាំងនោះ។

ជាកិច្ចឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ចលឿនរបស់ប្រទេស និងការធ្វើសមាហរណកម្មអាស៊ាន ប្លង់គោលសម្រាប់គម្រោងផ្លូវអិចស្ប្រេសវ៉េកម្ពុជា (Master Plan for the Cambodia Expressway) ត្រូវបានបង្កើតឡើងក្រោមជំនួយរបស់ប្រទេសចិន ដែលក្នុងនោះមានសំណើអភិវឌ្ឍបណ្តាញផ្លូវអិចស្ប្រេសវ៉េប្រវែងសរុប ២២៣០គ.ម ត្រឹមឆ្នាំ២០៤០។ ចំនួនទឹកប្រាក់វិនិយោគសរុបសម្រាប់គម្រោងនេះត្រូវបានគេរំពឹងទុកថានឹងមានទំហំរហូតដល់ទៅប្រហែល ២៦ប៊ីលានដុល្លារអាមេរិក។ ស្រដៀងគ្នានេះដែរ ការសិក្សាមួយដែលធ្វើឡើងដោយអង្គការ JICA ក្នុងឆ្នាំ២០១៣ បានផ្តល់អនុសាសន៍ឱ្យអភិវឌ្ឍសង់បណ្តាផ្លូវអិចស្ប្រេសវ៉េជាតិ ដែលមានប្រវែងសរុប ២២០០គ.ម[៣៨]។ ភាពខុសគ្នារវាងបណ្តាញផ្លូវអិចស្ប្រេសវ៉េដែលស្នើឡើងដោយប្រទេសចិន និងប្រទេសជប៉ុន មានបង្ហាញជូននៅក្នុងរូបភាព ២.១។ ក្រសួងសាធារណការ និងដឹកជញ្ជូនរំពឹងទុកថា ផ្លូវអិចស្ប្រេសវ៉េនេះនឹងរួមចំណែកដល់ការជំរុញសេដ្ឋកិច្ចក្នុងស្រុក តាមរយៈការភ្ជាប់បណ្តាញផ្លូវ និងសម្រួលដល់ចរាចរណ៍ទំនិញ។ ទីក្រុងច្រករបៀង ដូចជាក្រុងច្បារមននៃខេត្តកំពង់ស្ពឺជាដើម ត្រូវបានគេរំពឹងទុកថានឹងលែងនៅជាទីក្រុងឆ្លងកាត់ទៀតហើយ ប៉ុន្តែនឹងមានតួនាទីមួយសំខាន់នៅក្នុងការអភិវឌ្ឍឧស្សាហកម្ម និងសេដ្ឋកិច្ចដែរ។ យ៉ាងណាក៏ដោយ មានការទទួលស្គាល់ថាទីក្រុងច្រករបៀងទាំងនោះចាំបាច់ត្រូវធ្វើការកែលម្អផ្លូវ ប្រព័ន្ធដឹកជញ្ជូនសាធារណៈ និងសុវត្ថិភាពចរាចរណ៍ ដើម្បីឈានទៅសម្រេចឱ្យបាននូវតួនាទីដែលបានរំពឹងទុកទាំងនេះ[៣៩]។

**រូបភាព ២.១៖** បណ្តាញផ្លូវអិចស្ប្រេសវ៉េដែលស្នើឡើងដោយប្រទេសចិន និងប្រទេសជប៉ុន







*ប្រភព៖ Infrastructure and Regional Integration Technical Working Group (IRITWB) and JICA, Overview of the Transport Infrastructure Sector in the Kingdom of Cambodia (5th Edition), 2015. Originally from MPWT.*

ក្រៅពីបណ្តាញផ្លូវជាតិ កម្ពុជានៅមានបណ្តាញផ្លូវរថភ្លើងដែលមានខ្សែរត់ទៅប៉ែកពាយ័ព្យនៃប្រទេស (មានប្រវែងសរុប ៣៨៦គ.ម ពីភ្នំពេញទៅប៉ោយប៉ែត ឆ្លងកាត់ខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង និងបន្ទាយមានជ័យ) និងខ្សែរត់ទៅប៉ែក

៣៦ World Bank, Cambodia Systematic Country Diagnostic - Sustaining Strong Growth for the Benefit of All, 2017.

៣៧ Infrastructure and Regional Integration Technical Working Group (IRITWB) and JICA, Overview of the Transport Infrastructure Sector in the Kingdom of Cambodia (5th Edition), 2015.

៣៨ Ibid.

៣៩ យោងតាមកិច្ចពិភាក្សាជាមួយអាជ្ញាធរក្រុងច្បារមនកាលពីខែមីនា ឆ្នាំ២០១៨។

ខាងត្បូងនៃប្រទេស (មានប្រវែងសរុប ២៦៤គ.ម ពីភ្នំពេញទៅក្រុងព្រះសីហនុ)[៤០]។ ការជួសជុលស្តារផ្លូវដែកនេះឡើងវិញដែលមានការខូចខាតយ៉ាងដំណំកន្លងមក កំពុងតែដំណើរការអនុវត្តនៅក្រោមជំនួយហិរញ្ញវត្ថុពីធនាគារអភិវឌ្ឍន៍អាស៊ី ហើយផ្លូវដែកនេះ ស្ថិតនៅក្រុមប្រតិបត្តិការជាឯកជនរបស់ក្រុមហ៊ុនអូស្ត្រាលីមួយ។ កន្លងមកធ្លាប់មានការចាប់អារម្មណ៍ថានឹងប្រើខ្សែផ្លូវដែកនេះសម្រាប់បម្រើសេវាដឹកជញ្ជូនអ្នកដំណើរដែរ ប៉ុន្តែគេមិនទាន់ឃើញមានការសិក្សាលម្អិតនៅឡើយទេ អំពីចំណុចនេះ[៤១]។ ខណៈដែលការដឹកជញ្ជូនតាមផ្លូវអាកាសទទួលបានកំណើនខ្លាំងជាពិសេសសម្រាប់វិស័យទេសចរណ៍ ប្រភេទដឹកជញ្ជូនផ្សេងទៀតមិនសូវជាទទួលបានកំណើនប៉ុន្មានទេ។

**ការដឹកជញ្ជូនរវាងទីក្រុង (ទីប្រជុំជន)៖** កំណើនអិចស្ប៉ូណង់ស្យែលនៃចំនួនយានយន្តចុះបញ្ជី និងសមត្ថភាពមានកម្រិតរបស់បណ្តាញផ្លូវ បានរួមចំណែកដល់ការកកស្ទះចរាចរណ៍នៅតាមទីក្រុងក្នុងប្រទេសកម្ពុជា។ ភាគច្រើននៃផ្លូវក្នុងទីប្រជុំជនមានភាពចាំបាច់ច្រើនឱ្យមានការស្តារជួសជុល និងកែលម្អ ប៉ុន្តែមិនអាចធ្វើទៅបានដោយសារតែឧបសគ្គផ្នែកហិរញ្ញវត្ថុ ឬសមត្ថភាពនៅក្នុងការថែទាំនិងជួសជុល។ នៅភ្នំពេញ រវាងឆ្នាំ១៩៩០ និងឆ្នាំ២០១២ ចំនួនរថយន្តធុនស្រាល និងធុនធ្ងន់កើនពី ៤០០០គ្រឿង ដល់ ២៦៨០០០គ្រឿង ហើយចំនួនម៉ូតូកើនពី ៤៤០០០គ្រឿង ដល់ ៩៥១០០០គ្រឿង ដែលបណ្តាលឱ្យមានការកកស្ទះកាន់តែខ្លាំងឡើងនៅទូទាំងទីក្រុង[៤២]។ លទ្ធផលនៃការស្ទង់មើលស្ថានភាពចរាចរណ៍ដែលអង្គការ JICA បានធ្វើ បានបង្ហាញថាល្បឿនក្នុងការធ្វើដំណើរនៅលើដងវិថីធំៗក្នុងទីក្រុងបានថយចុះពី ២២,៩ គ.ម/១ម៉ នៅឆ្នាំ២០០១ មកនៅជាមធ្យមត្រឹម ១៤,៦គ.ម/១ម៉ ក្នុងឆ្នាំ២០១២។

ប្រព័ន្ធដឹកជញ្ជូននៅតាមទីក្រុងកម្ពុជាមិនមានភាពសម្បូរបែប ឬមាលក្ខណៈសមាហរណកម្មទេ។ ជម្រើសក្នុងការប្រើប្រាស់សេវាដឹកជញ្ជូនសារធារណៈ មិនទាន់ឃើញថាមានលទ្ធភាពទៅរួចនៅឡើយទេនៅតាមទីក្រុងប្រទេសកម្ពុជា។ មានតែទីក្រុងភ្នំពេញទេដែលមានប្រព័ន្ធដឹកជញ្ជូនសាធារណៈសម្រាប់អ្នកដំណើរដែលជាគម្រោងសាកល្បង ប៉ុន្តែបរិមាណនៃអ្នកប្រើប្រាស់នៅទាបនៅឡើយ ដោយសារតែចរាចរណ៍មានសភាពណែនណាន់ពេកកាលវិភាគប្រតិបត្តិការមិនអាចទុកចិត្តបាន និងគុណភាពអន់របស់រថយន្តដែលយកមកប្រើក្នុងការដឹកអ្នកដំណើរ។ ជាងនេះទៅទៀត កង្វះមធ្យោបាយដឹកជញ្ជូនភ្ជាប់ពីចំណុចចេញដំណើរ (ឧ. ពីផ្ទះ) ទៅដល់ចំណតរថយន្តក្រុងនិងពីចំណតរថយន្តក្រុងទៅគោលដៅ (ឧ.កន្លែងធ្វើការ) (first-last mile connectivity) ជាកត្តាបន្ទុចបង្អាក់មួយដល់ការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈ ជាពិសេសនៅក្នុងបរិបទមួយដែលមានភាពងាយស្រួលជាងក្នុងការជិះម៉ូតូ ឬរ៉ឺម៉កពីកន្លែងមួយទៅកន្លែងមួយទៀត។ បណ្តាទីក្រុងខ្វះការគ្រប់គ្រងចរាចរណ៍បែបទំនើប ខ្វះការរឹតបន្តឹងការអនុវត្តបទបញ្ញត្តិចរាចរណ៍និងបទបញ្ញត្តិចតយានយន្តតាមផ្លូវ ខ្វះវិធានការសុវត្ថិភាពចរាចរណ៍ និងខ្វះបរិស្ថានមានមេត្រីភាពសម្រាប់អ្នកថ្មើរជើង។ ភ្នំពេញជាទីក្រុងតែមួយគត់ដែលមានផែនការមេគ្រប់ជ្រុងជ្រោយស្តីពីមធ្យោបាយដឹកជញ្ជូន ក្នុងក្រុង (Comprehensive Urban Transport Master Plan) ដែលត្រូវបានរៀបចំបង្កើតឡើងក្រោមជំនួយរបស់អង្គការ JICA។ យោងតាមផែនការមេនេះ គម្រោងបង្កើនការដឹកជញ្ជូនតាមរថយន្តក្រុង និងការគ្រប់គ្រងភ្លើងចរាចរណ៍បែបទំនើប (Public Bus Improvement and Modernized Traffic Management Projects) កំពុងត្រូវបានអនុវត្ត ស្របពេលដែលមានការគិតគូរពិចារណាអំពីជម្រើសនៃការដឹកជញ្ជូនផ្សេងៗទៀត ដូចជា ត្រាំវ៉េ កាណូតតាក់ស៊ី និង រថភ្លើងផ្លូវអាកាស ដើម្បីបន្ធូរបន្ថយការកកស្ទះនៅតាមដងផ្លូវ[៤៣]។

ជាមួយនឹងក្តីបារម្ភកាន់តែច្រើនឡើងអំពីការកកស្ទះចរាចរណ៍ និងអំពីកង្វះជម្រើសសម្បូរបែបក្នុងសេវាដឹកជញ្ជូនសាធារណៈ ទីក្រុងលំដាប់ទីពីរក៏កំពុងតែប្រឈមជាមួយបញ្ហាចំពោះមុខមួយចំនួនដែរ។ ឧទាហរណ៍ ទីក្រុងជាប់ព្រំដែនបាវិតមានរថយន្តដឹកកុងតឺន័រជិត៣០០ ឆ្លងកាត់រៀងរាល់ថ្ងៃ បន្ថែមពីលើដោយរថយន្តដឹកជញ្ជូនប្រហែល៧០០គ្រឿងផ្សេងទៀតដែលដឹកពលករ/កម្មករទៅមករោងចក្រ ដែលស្ថិតនៅជុំវិញទីក្រុងនោះ។ សន្ទឹកយានយន្តនៅលើផ្លូវដ៏តូចចង្អៀតរបស់ក្រុងបាវិត បង្កើតឱ្យមានការបំពុលសំឡេង និងការកកស្ទះចរាចរណ៍។ លើសពីនេះទៅទៀត រថយន្តដឹកជញ្ជូនដែលមានសភាពចាស់រខេករខាកបង្កើតឱ្យមានការបំពុលខ្យល់ និងបង្កគ្រោះថ្នាក់ចរាចរណ៍ជាច្រើន។ នៅឯជ្រុងម្ខាងទៀត ទីក្រុងសួងខ្វះហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដូចជាផ្លូវរាបស្មើជា

---

៤០ Ibid.

៤១ ធនាគារពិភពលោក ឆ្នាំ២០១៧ «ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ»។

៤២ JICA, The Project for Comprehensive Urban Transport Plan in Phnom Penh Capital City, 2014.

៤៣ ធនាគារពិភពលោក ឆ្នាំ២០១៧ «ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ»។

ដើម។ មានតែ១៦%នៃផ្លូវក្នុងក្រុងសួងប៉ុណ្ណោះដែលជាផ្លូវរាបស្មើ ដែលនាំឱ្យមានការលំបាកក្នុងការធ្វើដំណើររវាងភូមិនិងភូមិ[៤៤]។ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនតាមទីក្រុង ដូចជាក្រុងបាត់ដំបង និងក្រុងកំពង់ចាម និងក្រុងតំបន់ឆ្នេរ ដូចជាក្រុងព្រះសីហនុ និងកោះកុង ប្រឈមនឹងបញ្ហាប្រឈមនៃការលិចទឹកជំនន់ និងហានិភ័យនៃការឡើងកម្រិតទឹកសមុទ្រ។ និយាយជារួម ប្រព័ន្ធនិងបណ្តាញផ្លូវដឹកជញ្ជូនក្នុងប្រទេស (ទាំងរវាងទីក្រុង ទាំងក្នុងរង្វង់ទីក្រុង) ដែលភាគច្រើនលើសលុបជាសេវាផ្លូវដី នៅតែមិនទាន់ល្បឿននៃកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សនៅឡើយទេ ហើយដែលតម្រូវឱ្យមានការកែលម្អបង្កើនសមត្ថភាពកាន់តែខ្លាំងថែមទៀត។

**ការផ្គត់ផ្គង់ទឹកស្អាត៖** សេវាផ្គត់ផ្គង់ទឹកស្អាតនៅភ្នំពេញស្ថិតក្នុងចំណោមផ្នែកសេវាសាធារណៈមួយចំនួនតូចដែលទទួលបានជោគជ័យ។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥ ហើយទទួលបានស្វ័យភាពក្នុងឆ្នាំ១៩៩៧។ ឆ្លងតាមបីដំណាក់កាលនៃជំនួយហិរញ្ញប្បទានរបស់ម្ចាស់ជំនួយ មានអង្គការ JICA និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង AFD ស្ថានីយប្រព្រឹត្តិកម្មទឹកស្អាតទាំងបួន និងបណ្តាញចែកចាយទឹកស្អាតរបស់ខ្លួន បានធ្វើផ្គត់ផ្គង់ទឹកស្អាតដល់អ្នកប្រើប្រាស់ទូទាំងទីក្រុងភ្នំពេញ។ តាមរយៈការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំ និងការភាពអង់អាចដែលទទួលបានពីស្វ័យភាពរបស់អង្គភាពនេះ ប្រតិបត្តិការរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានភាពរឹងប៉ឹង ដោយមានលទ្ធភាពចំណេញរវាង ២៥ ទៅ ២៦% ហើយអត្រាប្រមូលថ្លៃសេវាមានលើស ៩៩%[៤៥]។ នៅក្រៅទីក្រុងភ្នំពេញឯណោះវិញ រដ្ឋាភិបាលជួបបញ្ហាប្រឈមច្រើនក្នុងការចម្លងជោគជ័យរបស់ក្រុងភ្នំពេញទៅអនុវត្តនៅតាមខេត្តផ្សេងទៀត ដោយសារខ្វះការប្តេជ្ញាចិត្តនយោបាយកម្រិតខ្ពស់ គ្មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ (រួមទាំងសមត្ថភាពផលិត និងបណ្តាញចែកចាយមានកម្រិតផង) និងសមត្ថភាពនៅទន់ខ្សោយនៃការផ្គត់ផ្គង់អគ្គិសនីតាមខេត្តផងដែរ។ ការសាងសង់ ឬការស្តារឡើងវិញនូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតត្រូវបានធ្វើកន្លងមកនៅតាមក្រុងមួយចំនួន មានក្រុងសៀមរាប ក្រុងព្រះសីហនុ ក្រុងកំពង់ចាម កំពង់ធំ ពោធិសាត់ ស្ទឹងត្រែង ស្វាយរៀង និងសួង ក្រោមជំនួយរបស់អង្គការ JICA ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក។ ទាំងអង្គការ JICA ទាំងធនាគារអភិវឌ្ឍន៍អាស៊ី ធ្លាប់បានផ្តល់ជំនួយកសាងសមត្ថភាពច្រើនក្រៃលែងដែរ ដោយចម្លងនិងយកគ្រាប់តាមគម្រោង និងបទពិសោធន៍មានជោគជ័យរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដើម្បីពង្រឹងពង្រីកសមត្ថភាពប្រតិបត្តិការ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធសម្រួលការផ្គត់ផ្គង់ទឹកស្អាតនៅតាមក្រុងលំដាប់ទីពីរ។ ប៉ុន្តែបញ្ហាប្រឈមនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងខ្វះស្ថិរភាពដល់ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់សេវា និងហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ នៅតែបន្តមាននៅតាមទីក្រុងលំដាប់ទីពីរ ដែលនាំឱ្យការគ្រប់ដណ្តប់ការផ្គត់ផ្គង់ទឹកស្អាតនៅមានកម្រិតទាបនៅឡើយ។ លើសពីនេះ ក្របខណ្ឌច្បាប់និងក្របខណ្ឌស្ថាប័ន គោលការណ៍ណែនាំ និងការកែលម្អសមត្ថភាពត្រួតពិនិត្យទូទៅ ចាំបាច់ត្រូវធ្វើការពង្រឹងឱ្យបានខ្លាំងឡើងនៅតាមទីក្រុងទាំងនោះ[៤៦]។

សម្ទុះល្បឿនរបស់នគរូបនីយកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច បានបន្ថែមផងដែរនូវសម្ពាធទៅលើប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទីក្រុងដែលមានស្រាប់។ នៅក្រុងព្រះសីហនុ ការអភិវឌ្ឍក្នុងជំហានមួយយ៉ាងលឿនបានបណ្តាលឱ្យហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានកាន់តែរងភាពតានតឹងឡើង រួមទាំងបណ្តាញផ្គត់ផ្គង់ទឹកផង។ នៅជិតកណ្តាលទីក្រុង ការដ្ឋានសាងសង់មួយក្នុងតម្លៃទឹកប្រាក់ ១ប៊ីលានដុល្លារអាមេរិក បានចាប់ផ្តើមកាលពីពេលថ្មីៗនេះ សម្រាប់គម្រោងអភិវឌ្ឍន៍សំណង់សម្រាប់ការប្រើប្រាស់ចម្រុះមួយនៅលើផ្ទៃដីទំហំ ១៦,៥ហិកតា ដែលក្នុងនោះមានអគារខ្ពស់ចំនួន៣០ និងសហគមន៍លំនៅដ្ឋានដោយឡែកមួយ។ គ្រឹះស្ថានជាច្រើននៅជុំវិញតំបន់គម្រោងនោះ - ភាគច្រើនជាភោជនីយដ្ឋាន និងតូបលក់ដូរ - បានរាយការណ៍ឱ្យដឹងថា ការផ្គត់ផ្គង់ទឹកត្រូវបានកាត់ផ្តាច់ពីកន្លែងរបស់ពួកគេ នៅពេលគម្រោងសាងសង់នោះចាប់ដំណើរការ ហើយពួកគេព្យាយាមមិនបានសម្រេចនៅឡើយទេក្នុងការសុំឱ្យអាជ្ញាធរផ្តល់ការផ្គត់ផ្គង់ទឹកឡើងវិញ។ ខណៈដែលសេវាផ្គត់ផ្គង់ទឹកមានជោគជ័យគួរឱ្យកត់សម្គាល់នៅទីក្រុងភ្នំពេញ ការពង្រីកបណ្តាញចែកចាយទឹកគឺជាតម្រូវការមួយសម្រាប់បម្រើគម្រោងអភិវឌ្ឍន៍ថ្មីៗនៅតាមតំបន់ជាយក្រុង ដែលនៅមិនទាន់មានការផ្គត់ផ្គង់ទឹកស្អាតទៅដល់នៅឡើយ។ នៅក្នុងសេចក្តីរាយការណ៍ព័ត៌មានមួយរបស់កាសែតភ្នំពេញប៉ុស្ត ម្ចាស់គ្រឹះស្ថានមួយចំនួននៅតាមផ្លូវកាវ៉ាអូខេនៅក្រុងព្រះសីហនុត្រូវបង្ខំចិត្តទិញទឹកពីការដ្ឋានសំណង់

---

៤៤ GGGI, 2017.

៤៥ ធនាគារពិភពលោក ឆ្នាំ២០១៧ «ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ»។

៤៦ JICA, The Project on Capacity Building for Urban Water Supply System (Phase 3), 2012.

ដែលទទួលបានការផ្គត់ផ្គង់ទឹកឥតអាក់ខានសោះ[៤៧]។ នៅពេលដែលមិនមានការពន្យល់ណាមួយច្បាស់លាស់ថា ហេតុអ្វីបានការផ្គត់ផ្គង់ទឹកត្រូវបានបង្វែរចេញពីអ្នកប្រើប្រាស់ទាំងនោះ តាមមើលទំនងជាបណ្ដាញដែលមានស្រាប់នេះ គ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទ្រទ្រង់ដល់បរិមាណនៃកំណើនរបស់ការប្រើប្រាស់ និងការដ្ឋានសាងសង់នៅទីនោះទេ។ ចំពោះមុខនៃទំហំវិសាលភាពរបស់គម្រោងអភិវឌ្ឍថ្មីៗនៅទីនោះ ការផ្គង់ផ្គង់ទឹកស្អាតនឹងកាន់តែជួបការលំបាកខ្លាំងថែមទៀតនៅពេលណាគម្រោងសាងសង់នោះត្រូវបានបញ្ចប់ ប្រសិនបើគ្មានវិធានការដើម្បីធានាយ៉ាងណាឱ្យមានការបង្កើនសមត្ថភាពរបស់បណ្តាញផ្គត់ផ្គង់ សម្រាប់បំពេញទៅតាមតម្រូវការថ្មី។

ក្រៅពីសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ផ្នែកសាធារណៈ ផ្នែកឯកជនក្នុងស្រុកក៏សកម្មដែរក្នុងការផ្ដល់សេវាទឹកស្អាតដល់អ្នកប្រើប្រាស់។ ការប៉ាន់ស្មានពីមុនរបស់ធនាគារពិភពលោកបង្ហាញឱ្យឃើញថា ផ្នែកឯកជនបានរ៉ាប់រងជិត៥០%ក្នុងការតភ្ជាប់បណ្ដាញផ្គត់ផ្គង់ទឹកនៅក្នុងប្រទេស[៤៨]។ យ៉ាងណាក៏ដោយ ភាគច្រើននៃអ្នកផ្គង់ផ្គង់ឯកជន បានផ្ដោតតែទៅលើតំបន់ណាដែលគេយល់ថាអាចនាំផលចំណេញដល់គេ និងតំបន់ណាដែលមានប្រភពទឹកស្រាប់ងាយស្រួលទាញយកមកចែកចាយបន្តប៉ុណ្ណោះ។ តំបន់ដទៃទៀតដែលទំនងជាមិនសូវនាំមកនូវផលចំណេញ ឬមានបញ្ហាប្រឈមផ្នែកបច្ចេកទេសពេក (សំខាន់ ដោយសារតែហានិភ័យផ្នែកប្រភពទឹក) នៅតែមិនទទួលបានសេវាទឹកប្រើប្រាស់ដដែល។

**ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងប្រព័ន្ធការពារទឹកជំនន់៖** ទីក្រុងធំៗមួយចំនួនក្នុងប្រទេសកម្ពុជា មានដូចជា ភ្នំពេញ បាត់ដំបង ព្រះសីហនុ និងកំពង់ចាម ដែលងាយរងគ្រោះខ្លាំងដោយសារទឹកជំនន់ ហើយតម្រូវឱ្យមានការវិនិយោគបន្ទាន់ទៅលើការសង់ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងប្រព័ន្ធការពារទឹកជំនន់។ ទីក្រុងភ្នំពេញ ដែលស្ថិតនៅជាប់មាត់ច្រាំងទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ហើយហ៊ុំព័ទ្ធដោយតំបន់ដីល្បាប់ និងតំបន់ទំនាបលិចទឹក គឺងាយរងគ្រោះដោយសារទឹកជំនន់ណាស់ ទាំងទឹកជំនន់ទឹកភ្លៀង និងទឹកជន់ពីព្រឹត្តិការណ៍លិចលង់ទ្រង់ទ្រាយធំនៅតាមតំបន់វាលទំនាបនៅជុំវិញ។ ក្នុងឆ្នាំ២០១១ និង២០១៣ ទីក្រុងទទួលរងការលិចទឹកជំនន់ដ៏ខ្លាំង ដោយសារតែភ្លៀងជោគជាំមានកម្រិតខ្ពស់ខុសធម្មតា ខ្យល់ព្យុះជាបន្តបន្ទាប់ និងកម្រិតទឹកឡើងខ្ពស់នៅក្នុងទន្លេមេគង្គ ទាំងអស់នេះគួបគ្នាក្នុងគ្រាតែមួយ ដែលនាំឱ្យមានផលប៉ះពាល់ដល់ ១៧០០០គ្រួសារ នៅក្នុងឆ្នាំ២០១១ និងជាង ៣៥០០គ្រួសារ នៅក្នុងឆ្នាំ២០១៣[៤៩]។ ចាប់តាំងពីឆ្នាំ១៩៩៨មក អង្គការ JICA និងធនាគារអភិវឌ្ឍន៍អាស៊ី បានជួយដល់ការកែលម្អស្ថានភាពលិចទឹកនៅផ្នែកកណ្ដាលរបស់ទីក្រុងភ្នំពេញ ដែលមានដង់ស៊ីតេខ្ពស់។ បណ្ដាខណ្ឌ នៅភាគកណ្ដាលក្រុងភ្នំពេញបានធ្វើការកែលម្អច្រើនគួរឱ្យកត់សម្គាល់ដល់ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងបច្ចេកវិទ្យា (មានដូចជា បណ្ដាញលូបង្ហូរ ទ្វារទឹក ស្ថានីយបូមទឹក និងអាងស្តុកទឹក ជាដើម) ហើយខណ្ឌទាំងនោះត្រូវបានការពារពីផលប៉ះពាល់របស់ទឹកជំនន់ដោយសារទំនប់ជាច្រើនខ្សែ។ ផ្ទុយទៅវិញ ខណ្ឌមួយចំនួននៅបន្ទាប់ពីភាគកណ្ដាលក្រុង និងនៅតាមជាយក្រុងវិញ បច្ចុប្បន្នអត់មានប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងប្រព័ន្ធការពារការលិចទឹកទេ ហើយដូច្នេះធ្វើឱ្យវាងាយរងហានិភ័យខ្ពស់ពីការលិចលង់ជាញឹកញាប់ ដែលស្ថានភាពនេះនឹងកាន់តែមានសភាពធ្ងន់ធ្ងរថែមទៀត ដោយសារតែការអភិវឌ្ឍន៍យ៉ាងលឿននៃគម្រោងទីក្រុងលំដាប់ទីពីរទ្រង់ទ្រាយធំនៅជុំវិញ[៥០]។

ស្រដៀងគ្នានេះដែរ ក្រុងបាត់ដំបង ដែលស្ថិតនៅជ្រុងពាយ័ព្យនៃបឹងទន្លេសាប ហើយភ្ជាប់ជាមួយនឹងបឹងនេះតាមរយៈស្ទឹងសង្កែ តែងតែរងការប៉ះពាល់ខ្លាំងគួរសមដែរពីទឹកភ្លៀងជារៀងរាល់ឆ្នាំ។ ខេត្តទាំងមូលវិញមានភាពងាយរងគ្រោះកម្រិតមធ្យមទេដោយសារទឹកជំនន់ ប៉ុន្តែមានភាពងាយរងគ្រោះខ្ពស់ណាស់ដោយសារភាពរាំងស្ងួត។ កំណត់ត្រាផ្លូវការបានបង្ហាញថា ទឹកជំនន់ក្នុងឆ្នាំ២០១១ ដែលកម្ពស់ទឹកឡើងដល់ ១៣,៩៥ម ប៉ះពាល់ប្រជាជន ៣១៩៥៨នាក់ (៧១១១គ្រួសារ ក្នុង ៣១ឃុំ ក្នុង៩ស្រុក) បានធ្វើឱ្យលិចលង់ផ្ទៃដីអស់ ៥២៥០៣ហិកតា និងបំផ្លាញស្រូវអស់ ៣៦២៦៦ហិកតា។ ទឹកជំនន់ឆ្នាំ២០១៣ ដែលឡើងកម្ពស់ជា

---

៤៧ McGrath, Cam (2018). “Chinese property hunters flood into Occheuteal Beach.” The Phnom Penh Post. 23 March 2018. https://www.phnompenhpost.com/supplements-post-property/chinese-property-hunters-flood-ochheuteal-beach

៤៨ Source: Tapping the Market: Opportunities for Domestic Investments in Water for the Poor, the World Bank, 2013

៤៩ ធនាគារពិភពលោក ឆ្នាំ២០១៧ «ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ»។

៥០ Ibid.

ប្រវត្តិសាស្ត្រដល់ ១៤,២ម ប៉ះពាល់ការរស់នៅរបស់ប្រជាជន ៣៤៦៤០៨នាក់ (៧៤១៦០គ្រួសារ ក្នុង១៣២ឃុំ)។ ភាពរាំងស្ងួតក្នុងឆ្នាំ២០១៥ ក៏បង្កផលប៉ះពាល់ខ្លាំងដែរទៅលើមុខរបរចិញ្ចឹមជីវិតរបស់ពលរដ្ឋ[៥១]។ នៅក្រោមគម្រោងអភិវឌ្ឍន៍ទីក្រុងតាមច្រករបៀងសេដ្ឋកិច្ច ប៉ែកខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ (Greater Mekong Subregion Southern Economic Corridor Towns Development Project) របស់ធនាគារអភិវឌ្ឍន៍អាស៊ី វិធានការគ្រប់គ្រងទឹកជំនន់នឹងត្រូវបានអភិវឌ្ឍឡើងនៅក្នុងក្រុងបាត់ដំបង បាវិត អ្នកលឿង និងប៉ោយប៉ែត[៥២]។

ក្រុងព្រះសីហនុ មានភាពងាយរងគ្រោះពីទឹកជំនន់ ការឡើងកម្ពស់ទឹកសមុទ្រ និងសំណឹកដីតំបន់ឆ្នេរ។ លំនៅដ្ឋាននៅតាមតំបន់ឆ្នេរប្រឈមខ្លាំងទៅនឹងហានិភ័យទឹកជំនន់ ហើយស្ថានភាពនេះ កាន់តែធ្ងន់ធ្ងរថែមទៀតដោយសារគុណភាពអន់ថយនៃសំណង់លំនៅដ្ឋាន និងកង្វះហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាននៅក្នុងទីប្រជុំជនផង។ បញ្ហាទឹកជន់លិចលង់នេះកាន់តែមានសភាពធ្ងន់ធ្ងរទៅទៀតនៅពេលដែលគ្មានប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងលូបង្ហូរទឹកស្អុយ និងការគ្រប់គ្រងសំណល់រឹងឱ្យបានគ្រប់គ្រាន់[៥៣]។ ក្រៅពីនេះ ក្រុងកំពង់ឆ្នាំងជាទីក្រុងមួយទៀតដែរដែលរងផលប៉ះពាល់ខ្លាំងពីការជន់លិចទឹកជំនន់ទន្លេមេគង្គ ជារៀងរាល់ឆ្នាំ។ ការកើនឡើងកម្ពស់ទឹកនាំមកនូវដីល្បប់ និងធ្វើឱ្យច្រាំងទន្លេបាក់ បណ្តាលឱ្យមានទឹកជំនន់ និងផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតនៅតាមដងទន្លេរងនូវការខូចខាត[៥៤]។

**អនាម័យ៖** បច្ចុប្បន្ន ប្រទេសកម្ពុជាមានស្ថានីយប្រព្រឹត្តិកម្មទឹកស្អុយក្រុងដែលដំណើរការតែបីកន្លែងទេ គឺនៅក្រុងសៀមរាប ក្រុងព្រះសីហនុ និងក្រុងបាត់ដំបង ដែលស្ថានីយនីមួយៗតាមលំដាប់លំដោយ មានសមត្ថភាពធ្វើប្រព្រឹត្តិកម្មទឹកស្អុយបាន ៣០០០ម$^{៣}$, ៦៩០០ម$^{៣}$, និង ១០០០ម$^{៣}$ ក្នុងមួយថ្ងៃ[៥៥]។ ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់សេវាទាំងនេះ មានសភាពកាន់តែចាស់គំរឹល ហើយមិនគ្រប់គ្រាន់នឹងឆ្លើយតបទៅនឹងតម្រូវការចេះតែកើនឡើងរបស់ទីក្រុង អ្វីដែលគួរឱ្យកាន់តែភ្ញាក់ផ្អើលទៅទៀតនោះគឺរាជធានីភ្នំពេញ មកទល់បច្ចុប្បន្ននេះ អត់មានប្រព័ន្ធប្រព្រឹត្តិកម្មទឹកស្អុយផ្លូវការណាមួយរបស់ខ្លួនទេ។ នៅភ្នំពេញ និងទីក្រុងដទៃទៀត (ដូចជាកំពង់ចាម សួង បាវិត និងកែប)[៥៦] ទឹកស្អុយ និងទឹកប្រើប្រាស់តាមផ្ទះ គ្រឹះស្ថានធុរកិច្ច និងឧស្សាហកម្មដែលមិនបានឆ្លងប្រព្រឹត្តិកម្ម ត្រូវបានបង្ហូរចូលត្រង់តែម្តងទៅក្នុងប្រភពទឹកនានា ដូចប្រឡាយ ស្រះ ទន្លេ បឹង និងតំបន់វាលទំនាប[៥៧]។ ប្រព័ន្ធលូបង្ហូរដែលអន់ថយ (ឬកង្វះនៃប្រព័ន្ធលូបង្ហូរ) និងហេដ្ឋារចនាសម្ព័ន្ធប្រព្រឹត្តិកម្មទឹកដែលអន់ថយ និងអវត្តមាននូវបទបញ្ញត្តិនិងការរឹតបន្តឹងការអនុវត្តច្បាប់ បានបណ្តាលឱ្យបរិមាណការហូរចាក់ទឹកស្អុយដើមកាន់តែច្រើនឡើងៗ ទៅក្នុងប្រភពទឹកធម្មជាតិ។ ស្ថានភាពនេះបង្កនូវការគម្រាមកំហែងដល់បរិស្ថានទីប្រជុំជន ជាពិសេសដល់ប្រជាជនរស់នៅតាមតំបន់មានចំណូលទាបក្បែរប្រឡាយ និងបឹងដែលជាប្រភពទឹកធម្មជាតិទាំងនោះ។

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់នូវផលវិបាកធ្ងន់ធ្ងរពីបញ្ហាទឹកស្អុយនេះ និងភាពចាំបាច់បន្ទាន់ក្នុងការរៀបចំឱ្យមានការគ្រប់គ្រងទឹកស្អុយ និងទឹកកង្វក់ឱ្យបានគ្រប់គ្រាន់ ប៉ុន្តែយ៉ាងណាក្តី គេឃើញមានវឌ្ឍនភាពនៅមានកម្រិត នៅឡើយនៅក្នុងការផ្តល់ហិរញ្ញប្បទាន សម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធប្រព្រឹត្តិកម្មទឹកស្អុយ។ អវត្តមានរបស់បទបញ្ញត្តិ និងការរឹងបន្តឹងការអនុវត្តច្បាប់ជាឧបសគ្គធំមួយ ហើយក្នុងបរិបទបែបនេះ ការរៀបចំឱ្យមាននិងការអនុម័តទៅលើច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អុយឱ្យបានឆាប់ៗនាពេលខាងមុខគឺជារឿងមានសារៈសំខាន់បំផុត[៥៨]។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់សភាពធ្ងន់ធ្ងរ និងភាពបន្ទាន់របស់បញ្ហានេះ ហើយកំពុងតែដំណើរការធ្វើសេចក្តីព្រាងអនុក្រឹត្យមួយស្តីពីការគ្រប់គ្រងទឹកស្អុយ និងទឹកកង្វក់ក្នុងទីក្រុង។

លើសពីនេះ នៅតាមតំបន់ទីប្រជុំជនក្នុងប្រទេសកម្ពុជា មានតែ ៤៤% នៃប្រជាជនប៉ុណ្ណោះដែលបានតភ្ជាប់បណ្តាញទៅនឹងបណ្តាញលូទឹកស្អុយក្នុងឆ្នាំ២០១៥ ហើយអ្នកក្រៅពីនោះមានតែ

---

៥១ Urban Climate Resilience in Southeast Asia Partnership (URCSEA), Report on Identification of Case Study Site: Battambang Municipality, Battambang Province, Cambodia. 2015

៥២ ADB, 2017. https://www.adb.org/projects/43319-033/main

៥៣ GGGI, 2017.

៥៤ Ibid

៥៥ Ibid

៥៦ Ibid

៥៧ Sahmakum Teang Tnaut, 2012. Phnom Penh: City of Water.

៥៨ ធនាគារពិភពលោក ឆ្នាំ២០១៧ «ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ»។

ពឹងផ្អែកលើអាងស្តុកទឹកលូ ដែលតម្រូវឱ្យមានសេវាបូមសំណល់លាមកជាទៀងទាត់ក្នុងកាលៈទេសៈដែលទីក្រុងចេះតែបន្តលូតលាស់ និងអភិវឌ្ឍ[៥៩]។ យោងតាមយុទ្ធសាស្ត្ររបស់ក្រសួងសាធារណការ និងដឹកជញ្ជូន អាងស្តុកលាមកតាមផ្ទះត្រូវបានគេរំពឹងទុកថា នឹងត្រូវបានភ្ជាប់បណ្តាញជាមួយអាងស្តុកលូធំត្រឹមឆ្នាំ២០៣០ ហើយការគ្រប់គ្រងទឹកកង្វក់ និងសេវាអនាម័យត្រូវបានគេរំពឹងទុកថានឹងមានផ្តល់ជូននៅត្រឹមឆ្នាំ២០៥០។ បើទោះជាមានចេតនាបែបនេះមែនហើយក្តី សំខាន់គួរកត់សម្គាល់ថា ដើម្បីឈានទៅសម្រេចបានគោលដៅខាងលើ ចាំបាច់ត្រូវមានឆន្ទៈនយោបាយខ្លាំង ការចូលរួមរបស់ភាគីពាក់ព័ន្ធ និងយុទ្ធសាស្ត្រការអនុវត្ត រួមទាំងកម្មវិធីធ្វើហិរញ្ញប្បទាន ការរឹងបន្តឹងការអនុវត្ត និងការយល់ដឹងរបស់សាធារណៈ ផងដែរ[៦០]។ បន្ថែមលើនេះ នៅមានអាទិភាពខ្ពស់មួយទៀត នៅក្នុងការបង្កើតឱ្យមានគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងលូទឹកស្អុយ និងលូទឹកភ្លៀងនៅតាមតំបន់អភិវឌ្ឍន៍ទ្រង់ទ្រាយធំ ពីព្រោះកំណើនការរស់នៅក្នុងតំបន់ក្រុងលំដាប់ទីពីរធំៗបានទៅហួសសមត្ថភាពធ្វើប្រព្រឹត្តិកម្មរបស់ទីក្រុងហើយ[៦១]។

សម្រាប់ភ្នំពេញ អង្គការ JICA បានបញ្ចប់ការរៀបចំរបាយការណ៍មួយមានចំណងជើងថា «ការសិក្សាអំពីគម្រោងកែលម្អប្រព័ន្ធលូទឹកភ្លៀងនិងលូទឹកស្អុយក្នុងតំបន់ក្រុងភ្នំពេញ» (Study on Drainage and Sewerage Improvement Project in Phnom Penh Metropolitan Area) កាលពីឆ្នាំ២០១៧។ ការសិក្សានេះបានកំណត់អត្តសញ្ញាណអំពីភាពបន្ទាន់ ក្នុងការបង្កើតឱ្យមាន «ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ និងទឹកស្អុយ» (Wastewater and Sewerage Treatment Plant/STP) នៅជើងឯក និងតម្លើងប្រព័ន្ធបង្ហូរទឹកស្អុយដោយបំពាក់នូវគ្រឿងប្រព្រឹត្តិកម្មនៅចំណុចមួយចំនួនផង[៦២]។ បន្ថែមលើនេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយកាលពីខែមករា ឆ្នាំ២០១៨ ដោយសន្យាជួយដល់គម្រោងកែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធលូទឹកស្អុយ និងស្ថានីយប្រព្រឹត្តិកម្មនៅក្រុងបាត់ដំបង កំពង់ចាម សៀមរាប និងក្រុងព្រះសីហនុដែរ។ កម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវបានអមដោយជំនួយឥតសំណងមួយទៀតពីប្រទេសជប៉ុន សម្រាប់សង់ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ដើរដោយថាមពលប្រកបដោយប្រសិទ្ធផលមួយ នៅក្រុងបាត់ដំបង[៦៣]។

**ការគ្រប់គ្រងសំណល់រឹង៖** នៅប្រទេសកម្ពុជា ការគ្រប់គ្រងសំណល់រឹងមានការអភិវឌ្ឍតិចតួចបំផុត នៅពេលដែលផលវិបាករបស់វានឹងមានសភាពធ្ងន់ធ្ងរមែនទែន ដល់សុខភាពសាធារណៈ បរិស្ថាន និងសេដ្ឋកិច្ច។ កំណើនប្រជាជន ស្តង់ដាជីវភាពកាន់តែខ្ពស់ជាងមុន សកម្មភាពសេដ្ឋកិច្ចក្នុងវិស័យទេសចរណ៍កាន់តែកើន ការអភិវឌ្ឍសំណង់ និងឧស្សាហកម្ម ទាំងអស់នេះបានបណ្តាលឱ្យកាកសំណល់ មានកំណើនយ៉ាងលឿន។ តាមការប៉ាន់ស្មាន នៅទូទាំងប្រទេស មានសំណល់រឹងកើតឡើងប្រមាណជា ២,៧លានតោន ក្នុងនោះ ៨៥០០០០តោននៅទីក្រុងភ្នំពេញ, ៦០០០០០តោននៅតំបន់ប្រជុំជនក្នុងក្រុងលំដាប់ទីពីរ ហើយនៅសល់ប៉ុន្មានកើតឡើង នៅក្នុងតំបន់ជុំវិញក្បែរៗនោះផ្សេងទៀត (ដែលមានប្រជាជនជាង ៨០%រស់នៅ)។ បរិមាណនេះត្រូវបានគេរំពឹងទុកថានឹងកើនដល់ទៅ ៣,៥តោនក្នុងមួយឆ្នាំ ត្រឹមឆ្នាំ២០៣០។ ការគ្រប់គ្រងនៅខ្សោយលើសំណល់រឹង កង្វះប្រព័ន្ធនិងប្រតិបត្តិការប្រមូលសំរាមឱ្យបានគ្រប់គ្រាន់ កង្វះវិធានការញែកសំរាមនិងការធ្វើប្រព្រឹត្តិកម្មសំរាម (ដូចជាធ្វើកំប៉ុស្ត) កង្វះការចូលរួមរបស់សហគមន៍ក្នុងយុទ្ធនាការ 3R (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃ) បានធ្វើឱ្យបរិមាណសំរាមជិតពាក់កណ្តាលត្រូវបានគេទុកចោលអត់មានការប្រមូលទេ។ មួយភាគដែលមានការប្រមូលនោះបានកើនពី ៣៩៧៣១១តោនក្នុងមួយឆ្នាំ នៅឆ្នាំ២០០៦ ដល់១,២តោនក្នុងមួយឆ្នាំ នៅឆ្នាំ២០១៦[៦៤]។ ប៉ុន្តែ សំរាមដែលត្រូវបានប្រមូលនោះ ត្រូវបានគេយកទៅចាក់ចោលនៅតាមកន្លែងដែលឥតមានវិធានការគ្រប់គ្រងជាមូលដ្ឋានទេ ដូចជាវិធានការត្រងទឹកស្អុយពីរណ្តៅសំរាម និងការការពារដីជាដើម។ កំណើនយ៉ាងឆាប់រហ័សនៃសំណល់រឹងគឺជាបញ្ហាធំមួយរបស់ក្រុងភ្នំពេញ ដែលត្រូវប្រឹងពុះពារក្នុងពេលមួយដែលថ្លៃដីចេះតែឡើង និងកង្វះហិរញ្ញវត្ថុសម្រាប់ធ្វើការអភិវឌ្ឍទីតាំងចាក់សំរាមឱ្យបានគ្រប់គ្រាន់។

---

៥៩ Source Joint Monitoring Programme for Water Supply, Sanitation and Hygiene, WHO/UNICEF 2017

៦០ GGGI, 2017.

៦១ JICA, 2017. Study on Drainage and Sewerage Improvement Project in Phnom Penh Metropolitan Area.

៦២ Ibid.

៦៣ Phnom Penh Post, 2018. https://www.phnompenhpost.com/business/adb-signs-180m-loans-cambodia

៦៤ GGGI, 2017. Based on Ministry of Environment, 2017.

**ប្រអប់ ២.១៖** សមត្ថភាពមានកម្រិតរបស់ទីលានចាក់សំរាមនៅភ្នំពេញ

កំណើនយ៉ាងឆាប់រហ័សនៃបរិមាណសំណល់រឹងក្នុងក្រុង គឺជាបញ្ហាប្រឈមសំខាន់មួយសម្រាប់រាជធានីភ្នំពេញ។ នៅឆ្នាំ២០០៩ ទីលានចាក់សំរាមដង្កោដែលមានទំហំ៣១ហិកតាត្រូវបានបើកឱ្យដំណើរការ ជាមួយអាយុកាលកំណត់ត្រឹម២៥ឆ្នាំ។ ប៉ុន្តែ គ្រាន់តែជាង៥ឆ្នាំនៃប្រតិបត្តិការប៉ុណ្ណោះ ដំណាក់កាលទី១ដែលមានផ្ទៃ១៤ហិកតាសម្រាប់ចាក់សំរាមនោះបានពេញសមត្ថភាពបាត់ទៅហើយ។ ដំណាក់កាលទី២ដែលមាន១៧ហិកតាបានដំណើរការតាំងពីឆ្នាំ២០១៥មកម្ល៉េះ ប៉ុន្តែការព្យាករក្នុងពេលបច្ចុប្បន្នបានប្រមើលថា សមត្ថភាពរបស់ទីចាក់សំរាមដែលនៅសេសសល់នេះនឹងគ្រប់គ្រាន់សម្រាប់តម្រូវការត្រឹមឆ្នាំ២០២០ តែប៉ុណ្ណោះ បានន័យថាវាសម្រេចបានតែពាក់កណ្តាលអាយុកាលដែលគេបានគ្រោងទុកទេ។ ទីក្រុងកំពុងតែប្រឹងតស៊ូប្រមូលសំរាមឱ្យទាន់ទំហំកំណើន (និងសមាសធាតុផ្សំ) របស់វាដែលមានជារៀងរាល់ថ្ងៃ ដែលកើនពី៨០០តោនក្នុងមួយថ្ងៃនៅឆ្នាំ២០០៩ មកដល់ ១៤៧៥តោនក្នុងមួយថ្ងៃនៅឆ្នាំ២០១៤ (ទន្ទឹមគ្នានេះមានការព្យាករទុកថាបរិមាណនេះនឹងកើនដល់ទៅ ២២០០តោនក្នុងមួយថ្ងៃនៅឆ្នាំ២០២០)[៦៥]។

បច្ចុប្បន្ន ឥតមានទីលានចាក់សំរាមប្រកបដោយអនាម័យទេនៅកម្ពុជា។ ការគ្រប់គ្រង់សំណល់រឹងនៅតាមទីក្រុងលំដាប់ទីពីរមួយចំនួនត្រូវបានប្រគល់ទៅឱ្យក្រុមហ៊ុនឯកជនចាត់ចែង ដោយមានកម្រិតសមត្ថភាពគ្របដណ្តប់ និងស្តង់ដាសេវាខុសៗគ្នាអាស្រ័យតាមដំណើរការថ្លៃសេវាប្រមូលផ្សេងៗគ្នា ទៅតាមសេដ្ឋកិច្ចមាត្រដ្ឋាន លទ្ធភាពផ្លូវចូលប្រមូលសំរាម និងចេតនារបស់សហគមន៍ក្នុងការបង់ថ្លៃសេវាប្រមូលសំរាម។ បច្ចេកវិទ្យាគ្រប់គ្រងសំណល់រឹង និងសមត្ថភាពគ្រប់គ្រងនៅខ្សោយ ដោយភាគច្រើននៃទីលានចាក់សំរាមប្រតិបត្តិការជាទីលានកណ្តាលវាល ដោយគ្រាន់តែមានរចនាសម្ព័ន្ធគ្រប់គ្រងបន្តិចបន្តួចនៅនឹងកន្លែង ប៉ុន្តែវិធានការគ្រប់គ្រងបរិស្ថានអន់ និងការរៀបចំបច្ចេកទេសមានកម្រិត (ដូចជាការធ្វើប្រព្រឹត្តិកម្មទឹកស្អុយចេញពីសំរាម ក្លិន សត្វចង្រៃ ឧស្ម័ន ជាដើម)។ អ្នករស់នៅទីក្រុងដែលមិនមានសេវាប្រមូលសំរាមទៅដល់ ដែលគេស្មានថាមានប្រហែលជា៤២ភាគរយ ជាទូទៅច្រើនតែទម្លាប់ដុតសំរាមចោលមុននឹងធ្វើការញែកប្រភេទសំរាមចេញពីគ្នា ហើយការដុតនៅក្នុងសីតុណ្ហភាពមួយទាបបានបញ្ចេញឧស្ម័ន និងផង់ធូលីតូចៗមានគ្រោះថ្នាក់ទៅក្នុងបរិយាកាស[៦៦]។ សំរាមដទៃទៀតដែលមានការប្រមូលត្រូវបានគេយកទៅចាក់ចោលនៅតាមទីសាធារណៈ ឬមួយក៏យកទៅគ្រវែងចោលដោយខុសច្បាប់ទៅក្នុងផ្លូវទឹក។

អនុក្រឹត្យលេខ១១៣ ដែលត្រូវបានចេញនៅខែសីហា ឆ្នាំ២០១៥ គឺជាការប៉ុនប៉ងមួយសម្រាប់ធ្វើវិមជ្ឈការការគ្រប់គ្រងកាកសំណល់ និងផ្តល់អាណត្តិមួយល្អនិងច្បាស់លាស់ជាងមុនស្តីពីការគ្រប់គ្រងសំណល់រឹង។ អនុក្រឹត្យនេះមានគោលបំណងពង្រឹងការទទួលខុសត្រូវរបស់ភ្នាក់ងាររដ្ឋាភិបាល ចាត់តាំងកិច្ចការគ្រប់គ្រងសំណល់រឹង នៅក្នុងទីប្រជុំជនទៅឱ្យអង្គភាពរដ្ឋបាលថ្នាក់មូលដ្ឋាន បង្កើនប្រសិទ្ធភាព និងសុវត្ថិភាពនៅក្នុងការគ្រប់គ្រងសំណល់រឹងក្នុងក្រុង និងបង្កើនការយល់ដឹងនិងការចូលរួមរបស់សាធារណជននៅក្នុងការគ្រប់គ្រង់សំណល់ក្នុងមូលដ្ឋាន រួមទាំងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ការញែកប្រភេទសំរាមចេញពីគ្នា និងការប្រើគោលការណ៍ 3R (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃ)។ បើទោះជាអនុក្រឹត្យនោះ មានចេតនាល្អក៏ដោយ ការអនុវត្តរបស់វានៅមានកម្រិតនៅឡើយ ចម្បងដោយសារតែឧបសគ្គផ្នែកហិរញ្ញវត្ថុ ធនធានមនុស្ស និងសមត្ថភាពរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ សម្រាប់ការតាមដាន និងរឹតបន្តឹងការអនុវត្តការគ្រប់គ្រងសំណល់រឹង[៦៧]។

៦៥ World Bank, 2017. Based on The Asia Foundation, Overseas Development Institute, 2016. Reforming Solid Waste Management in Phnom Penh

៦៦ GGGI, 2017.

៦៧ Ibid.

**ប្រអប់ ២.២៖** ការគ្រប់គ្រងសំណល់រឹងនៅក្រុងសៀមរាប

ខេត្តសៀមរាបទាំងមូលមានប្រជាជន ១,០៦លាននាក់ ហើយទទួលបានភ្ញៀវទេសចរជិត ៣លាននាក់ ក្នុងមួយឆ្នាំ។ រីឯនៅក្នុងក្រុងសៀមរាបវិញមានប្រជាជនរស់ ៣៥០០០០នាក់។ ការប្រមូលសំរាមជាប្រព័ន្ធផ្លូវការមានប្រមូលផ្តុំតែនៅក្នុងក្រុងសៀមរាបទេ ជាពិសេសនៅក្នុងស្រុកចំនួនបួននាភាគកណ្តាលដែលគ្រប់ដណ្តប់លើមួយភាគបីនៃផ្ទៃដីរបស់ទីក្រុង ហើយដែលត្រូវបានចាត់ទុកថាជាតំបន់មានការអភិវឌ្ឍនគរូបនីយកម្មពេញលេញនៅក្នុងរង្វង់ខ្សែក្រវាត់ដែនរបស់ក្រុង ដែលមានប្រជាជនប្រហែលពីរភាគបីនៃប្រជាជនសរុប ឬជាង ២០០០០០នាក់ រស់នៅ។ ស្រុកដែលនៅជាងខាងក្រៅ ដែលមានសភាពជាទីជនបទច្រើនជាង ជាមួយនឹងប្រជាជនជាង ១០០០០០នាក់រស់នៅ អត់មានការប្រមូលសំរាមជាផ្លូវការទេ។ ការប្រមូលសំរាមត្រូវបានប្រគល់ទៅឱ្យក្រុមហ៊ុន GAEA ដែលប្រតិបត្តិការតែនៅតាមស្រុកជាទីប្រជុំជនក្រុងទេ។ ក្រុមហ៊ុនប្រមូលសំរាមភាគច្រើនតែនៅតាមផ្លូវណាដែលមានប្រជាជនបង់ថ្លៃសេវាប្រមូលសំរាមទៅឱ្យក្រុមហ៊ុននេះដោយផ្ទាល់តែប៉ុណ្ណោះ។ បន្ថែមលើនេះ ក្រុមហ៊ុន GAEA ជាប់កាតព្វកិច្ចក្រោមកិច្ចសន្យាប្រមូលសំណល់ទាំងអស់នៅតាមដងផ្លូវធំៗរបស់ក្រុង និងតាមដងស្ទឹងសៀមរាបផងដែរ។ ដោយមានផ្ទះតែប្រហែល២០០០០គ្រួសារ (ឬ១០០០០០នាក់) ប៉ុណ្ណោះបង់ថ្លៃសេវាប្រមូលសំរាម សំរាមត្រូវបានគេចោលពាសវាលពាសកាលច្រើនណាស់។ ប្រជាជនចំនួនពាក់កណ្តាលផ្សេងទៀតដែលមិនបង់ថ្លៃសេវានៅតែទុកសំរាមឱ្យគេប្រមូលបានពីព្រោះពួកគេរស់នៅតាមវិថី និងផ្លូវដែលត្រូវមានសេវាមកប្រមូលស្រាប់ៗ។ បើមិនដូច្នោះទេ អ្នកទាំងនោះយកសំរាមរបស់ខ្លួនមកដាក់តាមផ្លូវដែលមានសេវាមកប្រមូល ឬក៏យកទៅចោលម្តុំណានៅក្នុងស្រុកដែលគ្មានសេវាប្រមូលសំរាមទៅដល់។ ក្នុងមួយថ្ងៃ សំរាមដែលប្រមូលបានមានរហូតដល់ទៅ ១៥០តោន ហើយបរិមាណប្រហែលគ្នានេះដែរផ្សេងទៀតមិនត្រូវបានគេប្រមូលទេ។ សំរាមដែលមិនត្រូវបានប្រមូលនេះត្រូវបានគេគ្រវាត់ចោលនៅតាមទីសាធារណៈ (នៅតាមច្រាំងស្ទឹង និងតាមលើចិញ្ចើមផ្លូវ) នៅពេលយប់ ឬក៏ត្រូវមនុស្សយកទៅទម្លាក់ចោលនៅតាមដីនៅទំនេរគ្មានមនុស្សនៅ។

ជារួម ជិត ៦៥%នៃប្រជាជនក្នុងទីក្រុងទទួលបានសេវាប្រមូលសំរាមដោយផ្ទាល់ ឬដោយប្រយោល ដែលក្នុងនោះចំនួនជិតពាក់កណ្តាល (៣៥% នៃចំនួនប្រជាជនសរុបក្នុងក្រុង) បង់ថ្លៃសេវាប្រមូលសំរាម។ នៅក្នុងកិច្ចសន្យារបស់ក្រុមហ៊ុន GAEA រដ្ឋបាលមូលដ្ឋានចែងថាថ្លៃសេវាប្រមូលសំរាមនេះអាចយកបានតាមវិក្កយបត្រអគ្គិសនី ដែលបន្ទាប់មកត្រូវរដ្ឋបាលមូលដ្ឋានផ្ទេរទៅឱ្យក្រុមហ៊ុន។ ប៉ុន្តែ រដ្ឋបាលមូលដ្ឋានមិនដែលបានចាត់វិធានការឱ្យមានការបង់ថ្លៃសេវាប្រមូលសំរាមតាមវិក្កយបត្រភ្លើងទេ ដោយប្រជាជនធ្វើការតវ៉ា។ អាស្រ័យហេតុនេះ រដ្ឋបាលមូលដ្ឋានអនុញ្ញាតឱ្យក្រុមហ៊ុន GAEA ប្រមូលថ្លៃសេវាពីអតិថិជនដោយផ្ទាល់តែម្តង។ កាលណាគ្មានការបង់ប្រាក់ពីសំណាក់រដ្ឋបាលមូលដ្ឋាន វាក៏នឹងមិនមានការប៉ះប៉ូវសងសម្រាប់សំរាមដែលក្រុមហ៊ុន GAEA ត្រូវប្រមូលពីតាមចិញ្ចើមផ្លូវ និងពីទីសាធារណៈដែរ។ ក្រុងមិនមានសមត្ថភាពប៉ុន្មានទេសម្រាប់ការគ្រប់គ្រងសំណល់។ ខេត្តសៀមរាបមានកម្មករជាប់កិច្ចសន្យារបស់ខ្លួនដើរប្រមូលសំរាមពីក្នុងស្ទឹង។ ជារួម ការចោលនិងប្រមូលសំរាមនៅមានភាពអន់ថយនៅឡើយ។ បន្ថែមលើនេះ ដោយសារតែទំហំរបស់ក្រុមហ៊ុន កិច្ចសន្យាប្រមូលសំរាមរបស់ GAEA ត្រូវបានចុះជាមួយរដ្ឋបាលខេត្តដោយ អាស្រ័យហេតុនេះមានកិច្ចសន្យាទីពីរដែលត្រូវបានចុះរវាងសាលាខេត្ត និងក្រុមហ៊ុន WeGreen សម្រាប់ប្រមូលសំរាមពីឧទ្យានអង្គរ ព្រលានយន្តហោះ និងសារមន្ទីរ។ ដូចគ្នាដែរជាមួយក្រុមហ៊ុននេះ អតិថិជនត្រូវបង់ថ្លៃសេវាប្រមូលសំរាម។ ផ្ទះនីមួយៗត្រូវបង់ ១ដុល្លារក្នុងមួយខែ ២ដុល្លារទៅ៥ដុល្លារក្នុងមួយខែសម្រាប់ធុរកិច្ចខ្នាតតូច ហើយសេវាថ្លៃជាងនេះសម្រាប់សណ្ឋាគារ (សណ្ឋាគារមានលើសពី ២០បន្ទប់ឡើងទៅត្រូវបង់ ៣០ដុល្លារក្នុងមួយខែ)។ តារាងថ្លៃត្រូវបានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអ្នកកំណត់។ តារាងថ្លៃសម្រាប់សំរាមតាមផ្ទះមានសមាមាត្រស្មើនឹង ១០ដុល្លារក្នុងមួយតោន ដែលមិនគ្រប់គ្រាន់សម្រាប់ទូទាត់បង់ថ្លៃទេ រាប់ទាំងថ្លៃលើការទុកដាក់សំរាមឱ្យមានអនាម័យផង។ ប្រជាពលរដ្ឋដែលមិនបង់ថ្លៃសេវាសំរាមកាន់តែធ្វើឱ្យមានភាពស្មុគស្មាញផ្នែកហិរញ្ញវត្ថុមួយផ្នែកទៀត។ ប៉ុន្តែតារាងថ្លៃសេវាសម្រាប់អតិថិជនផ្សេងទៀតមានខ្ពស់ជាងក្នុងមួយតោន ដូច្នេះវាជួយប៉ះប៉ូវឱ្យការខាតដោយសារអ្នកមិនបង់ថ្លៃសេវា បានខ្លះដែរ។ ក្រសួងសុខាភិបាលជាអ្នកគ្រប់គ្រងសំណល់មន្ទីរពេទ្យដោយឡែក ប៉ុន្តែសំណល់នេះនៅទីបំផុតត្រូវបានក្រុម GAEA ជាអ្នកប្រមូលទៅចាក់ចោលនៅទីលានសំរាមរបស់គេដដែល។

ក្រុមហ៊ុន GAEA ប្រើរថយន្តមានម៉ាស៊ីនគាបកម្លាំង៥តោនក្នុងការប្រមូលសំរាមហើយផ្ទេរទៅដាក់តាមស្ថានីយ រថយន្តមានម៉ាស៊ីនគាបកម្លាំង១០តោនសម្រាប់សណ្តោងកន្ទុយរទេះសំរាម និងរថយន្តប្រើគ្រឿងគាបកម្លាំង២០តោនសម្រាប់ដឹកជញ្ជូនសំរាមពីស្ថានីយផ្ទេរទៅចាក់នៅទីលានសំរាម ដែលស្ថិតនៅចម្ងាយ៣៥គ.ម. ក្រៅក្រុងសៀមរាប។ ក្រុមហ៊ុនបានច្បាប់ផ្តើមការសាកល្បងដាក់ធុងសំរាមចំណុះ ៨ម៣ នៅតាមភូមិហើយធ្វើការប្រមូលមួយដងក្នុងមួយសប្តាហ៍ ជាមួយនឹងថ្លៃសេវា១ដុល្លារក្នុងមួយខែ សម្រាប់ផ្ទះនីមួយៗ។ ការចាក់សំរាម តាមទម្លាប់ គឺគេចាក់នៅទីកណ្តាលវាល ពីរកន្លែង ដោយមានវិធានការគ្រប់គ្រងនៅនឹងកន្លែងតិចតួចណាស់។ មានមនុស្សជិត២០០នាក់ដើររើសសំរាមនៅនឹងទីលាននោះរៀងរាល់ថ្ងៃ។ ទីលានដែលក្រុមហ៊ុន GAEA មានទំហំ ៨ហិកតា ហើយនៅមានសមត្ថភាពដាក់សំរាមបាន ៥ ទៅ ៦ឆ្នាំទៀត។

ក្នុងខែមីនា ឆ្នាំ២០១៥ រដ្ឋាភិបាលបានបង្កើតមូលនិធិមួយមានទឹកប្រាក់ ៥លានដុល្លាអាមេរិក ដើម្បីអនុញ្ញាតឱ្យអង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ចាប់ការខុសត្រូវក្នុងការគ្រប់គ្រងសំរាមតាមទីក្រុងរបស់ខ្លួន។ គំនិតផ្តួចផ្តើមនេះស្ថិតក្រោមការសម្របសម្រួលរវាងក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រុងទីរួមខេត្ត។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗទទួលអំណាចក្នុងការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជនប្រមូលសំរាម។ ជាមួយនឹងគំនិតផ្តួចផ្តើមនេះ នៅខែវិច្ឆិកា ឆ្នាំ២០១៥ អនុក្រឹត្យលេខ១១៣ ស្តីពីការគ្រប់គ្រងសំរាមនិងសំណល់រឹងត្រូវបានដាក់ចេញ។ គោលបំណងរបស់វាគឺដើម្បីពង្រឹង និងធ្វើប្រតិភូកម្មការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រងសំរាម និងសំណល់ផ្សេងៗនៅក្នុងទីក្រុងរបស់ខ្លួន។ អនុក្រឹត្យនោះបានចែងលម្អិតការទទួលខុសត្រូវរបស់អាជ្ញាធរពាក់ព័ន្ធ រួមទាំងក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ និងអង្គភាពអភិបាលកិច្ចថ្នាក់ក្រោមជាតិ។

ពីមូលនិធិនេះដែរ រដ្ឋាភិបាលបានផ្តល់ថវិកាអនាម័យបរិស្ថានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបំពេញការខ្វះខាតថវិកាមួយផ្នែកណាមួយនោះជាបណ្តោះអាសន្នសិន (ចំនួន ១,២៥លានដុល្លារក្នុងឆ្នាំ២០១៥ និង ២លានដុល្លារក្នុងឆ្នាំ២០១៦)។ ក្រុងសៀមរាបទទួលបាន ២០០០០០ដុល្លារក្នុងឆ្នាំ២០១៧ ហើយប្រើប្រាស់វាសម្រាប់សេវាប្រមូលសំរាមនៅតាមស្រុកមួយចំនួន ដែលស្ថិតនៅខាងក្រៅកណ្តាលទីក្រុង ហើយក្រោយពីទទួលបានហិរញ្ញប្បទានថ្មីចំនួន ១៩០០០០ដុល្លារពីមូលនិធិ អាជ្ញាធរក្រុងឥឡូវកំពុងចុះកិច្ចសន្យាថ្មីជាមួយក្រុមហ៊ុនសម្រាប់ឆ្នាំ២០១៨ ដើម្បីបន្តសេវានេះតទៅមុខទៀត។

នៅពេលដែលសួរថា តើមានភាពចាំបាច់អ្វីខ្លះពេលនេះដើម្បីកែលម្អការគ្រប់គ្រងសំណល់រឹងឱ្យបានល្អឡើង តំណាងរបស់អាជ្ញាធរក្រុងបានលើកឡើងសំណើចំនួនពីរ។ ទីមួយ គឺសំណើសុំឱ្យផ្តោតការយកចិត្តទុកដាក់លើការចូលរួមរបស់សហគមន៍ឱ្យមានការឯកភាពលើការទទួលខុសត្រូវ និងកាតព្វកិច្ចបង់ថ្លៃសេវាប្រមូលសំរាម និងដើម្បីលើកកម្ពស់ការយល់ដឹងតាមផ្ទះអំពីការញែកសំរាម ដែលជាទម្លាប់បច្ចុប្បន្ននេះប្រជាជនដាក់សំរាមគ្រប់ប្រភេទចូលគ្នាក្នុងថង់។ ទីពីរ គឺសំណើសុំឱ្យមានការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធប្រមូល និងចាក់សំរាម។ ជាមួយគ្នានេះ មានការលើកឡើងអំពីចំណាប់អារម្មណ៍របស់ក្រុមហ៊ុនអន្តរជាតិធ្វើការនិយោគទ្រង់ទ្រាយតូចមួយដើម្បីបង្កើតរោងចក្រយកសំណល់ផលិតថាមពល ដោយគេសម្លឹងឃើញអត្រាតម្លៃអគ្គិសនីខ្ពស់នៅកម្ពុជា។

*ប្រភព៖ ក្រុមការងារធនាគារពិភពលោក*

**លំនៅដ្ឋាន៖** សម្ទុះលឿនរបស់ការរីកចម្រើនផ្នែកនគរូបនីយកម្ម និងរំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស ជាពិសេសហិរញ្ញប្បទានពីប្រទេសចិន បាននាំឱ្យមានការអភិវឌ្ឍវិស័យអចលនទ្រព្យក្នុងរូបភាពមួយគ្មានរបៀបរៀបរយ និងការលាតសន្ធឹងទីប្រជុំជនទៅច្រើនមុខព្រួញនៅក្នុងផ្ទៃប្រទេស រួមទាំងក្រុងភ្នំពេញ និងក្រុងព្រះសីហនុ ផងដែរ។ នៅភ្នំពេញ ការអភិវឌ្ឍវិស័យឯកជនទ្រង់ទ្រាយធំបានបង្កើនគួរឱ្យកត់សម្គាល់នូវបរិមាណនៃការផ្គត់ផ្គង់លំនៅដ្ឋាន និងអចលនទ្រព្យពាណិជ្ជកម្មទៅលើទីផ្សារ។ ជាមួយនឹងកំណើនរឹងមាំនៅក្នុងការផ្តល់ឥណទានដល់អនុផ្នែកកម្ចីលំនៅដ្ឋានក្នុងពេលប៉ុន្មានឆ្នាំមកនេះ តម្រូវការលំនៅដ្ឋានក៏មានការកើនឡើងដែរ[៦៨]។ នៅក្រុងព្រះសីហនុះឯណោះវិញ ការវិនិយោគផ្ទាល់របស់ចិន និងការអភិវឌ្ឍអចលនទ្រព្យមានការស្ទុះឡើងយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ២០១៧មក ធ្វើឱ្យតម្លៃដីនិងតម្លៃជួលអចលនទ្រព្យក៏ឡើងខ្ពស់យ៉ាងគំហុកចាប់តាំងពីពេលនោះមកដែរ។ ប្រឈមមុខនឹងទិដ្ឋភាពនេះមានការយល់ឃើញអំពីភាពបន្ទាន់ត្រូវរៀបចំបង្កើនផែនការប្រើប្រាស់ដីធ្លីលម្អិតមួយ ប៉ុន្តែ នៅខ្វះធនធានហិរញ្ញវត្ថុ និងបច្ចេកទេសម្រាប់យកទៅអនុវត្តទៅវិញ[៦៩]។

កំណើនយ៉ាងឆាប់រហ័សរបស់វិស័យសំណង់ និងអចលនទ្រព្យនៅទីក្រុងភ្នំពេញ និងក្រុងព្រះសីហនុ បង្កនូវហានិភ័យថាវាអាចបង្កើតទៅជាកំណើន«ពពុះផ្សារអចលនទ្រព្យ»។ បទពិសោធន៍ពីប្រទេសជិតខាង មានចិន និងវៀតណាម បានឱ្យដឹងថាកំណើន«ពពុះជាគំរូ» ចេញមកពីការផ្គត់ផ្គង់លើសតម្រូវការ ពិសេសតម្រូវការរបស់ខុនដូមានថ្លៃខ្ពស់ និងមកពីការកំណត់ថ្លៃខ្ពស់ហួសហេតុដើម្បីកេងយកចំណេញ។ ហានិភ័យមួយទៀតគឺទៅលើផ្នែកហិរញ្ញប្បទាន និងធនាគារ ដូចមានវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៨-២០០៩ ជាភ័ស្តុតាងស្រាប់ ដែលកាលនោះ វាបានជះឥទ្ធិពលអាក្រក់ទៅលើវិស័យអចលនទ្រព្យនៅកម្ពុជា និងប្រទេសជិតខាង។ ទាំងធនាគារពិភពលោក ទាំងធនាគារអភិវឌ្ឍន៍អាស៊ី បានព្រមានឱ្យមានការប្រុងប្រយ័ត្នជាមួយការកើនឡើងក្នុងការផ្តល់ឥណទានដល់វិស័យសំណង់ និងអចលនទ្រព្យ ដោយលើកសំណើឱ្យមានការត្រួតត្រាមើល និងការពិនិត្យតាមដានការផ្តល់កម្ចីឱ្យបានល្អិតល្អន់។ ការឡើងតម្លៃដីបានទុកឱ្យក្រុមប្រជាជនមានចំណូលទាបប្រទះជាមួយបញ្ហាប្រឈមច្រើន នៅក្នុងការស្វែងរកលំនៅដ្ឋានមានតម្លៃសមរម្យ ហើយការណ៍ដែលតម្លៃចេះតែឡើងនេះអាចបណ្តាលឱ្យទីលំនៅអនាធិបតេយ្យរីកកាន់តែធំថែមទៀត។ បច្ចុប្បន្ននេះ តាមការប៉ាន់ស្មានមានមនុស្សប្រមាណជា ១,៧លាននាក់កំពុងរស់នៅតាមតំបន់សំណង់អនាធិបតេយ្យ ដែលលក្ខខណ្ឌនៃការរស់នៅមានហានិភ័យច្រើនដល់ផ្នែកសុខភាព និងសុវត្ថិភាព[៧០]។

នៅក្នុងឆ្នាំ២០១៤ កម្ពុជាបានអនុម័តលើ«គោលនយោបាយលំនៅដ្ឋានជាតិ» ដើម្បីលើកកម្ពស់ការអភិវឌ្ឍលំនៅដ្ឋាន ហើយបច្ចុប្បន្នគោលនយោបាយមួយទៀតស្តីពីលំនៅដ្ឋានតម្លៃសមរម្យកំពុងត្រូវបានរៀបចំឡើងដោយ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិជាមួយជំនួយបច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ តាមការរំពឹងទុក គោលនយោបាយស្តីពីលំនៅដ្ឋានតម្លៃសមរម្យ នឹងបង្កើតឱ្យមានយន្តការពិសេសមួយសម្រាប់ផ្តល់ហិរញ្ញប្បទានដល់គ្រួសារមានចំណូលទាប ដើម្បីជួយឱ្យពួកគេអាចមានកម្មសិទ្ធិផ្ទះរបស់ខ្លួនបាន។ ក្នុងឆ្នាំ២០១៧ ក្រុមហ៊ុនឯកជនអភិវឌ្ឍន៍សំណង់មួយចំនួន រួមទាំងក្រុមហ៊ុនពិភពថ្មីផង (បុរីពិភពថ្មី) និងក្រុមហ៊ុន VTrust បានចាប់ផ្តើមបង្វែរទិសនៅក្នុងតម្រូវការ ពីការផ្គត់ផ្គង់លំនៅដ្ឋានប្រណីត/មានតម្លៃខ្ពស់ ទៅជាលំនៅដ្ឋានមានតម្លៃសមល្មមជាងមុនវិញ សម្រាប់គ្រួសារមានចំណូលទាបមធ្យម ជាពិសេស គឺទីផ្សារក្នុងស្រុកតែម្តង។ គួរកត់សម្គាល់ដែរថា «ដោយសារតែមានការធ្លាក់ចុះនូវតម្រូវការរបស់លំនៅដ្ឋានប្រណីត អ្នកអភិវឌ្ឍន៍សំណង់បានបង្ហាញចំណាប់អារម្មណ៍ទៅលើទីផ្សារក្នុងស្រុកវិញ ហើយធ្វើការឆ្លើយតបដោយធ្វើការផ្គត់ផ្គង់លំនៅដ្ឋានមានតម្លៃទាប»[៧១]។

---

៦៨ ធនាគារពិភពលោក ២០១៧។

៦៩ យោងតាមបទសម្ភាសន៍ក្នុងអំឡុងពេលចុះធ្វើការស្រាវជ្រាវ។

៧០ 2014, MDG data set: http://mdgs.un.org/unsd/mdg/Data.aspx

៧១ 2017, Housing Market Outlook Report.

### ប្រអប់ ២.៣៖ ឧទាហរណ៍នៃការអភិវឌ្ឍអចលនទ្រព្យខ្វះការត្រួតពិនិត្យនៅក្រុងព្រះសីហនុ

ក្រុងព្រះសីហនុបានឆ្លងកាត់ការផ្លាស់ប្តូរមុខមាត់ខុសស្រឡះពីមុន ពីទីក្រុងឆ្នេរមួយធ្លាប់តែលង់លក់ស្ងាត់និងជាទីពេញនិយមរបស់ទេសចរស្ពាយបង្វិច ទៅជាទីក្រុងលំដាប់ទីពីរធំមួយក្នុងចំណោមទីក្រុងលំដាប់ទីពីរជាច្រើននៃប្រទេសកម្ពុជា។ ជាមូលដ្ឋានសម្រាប់កំពង់ផែទឹកជ្រៅតែមួយគត់របស់ប្រទេស និងតំបន់សេដ្ឋកិច្ចពិសេសមួយចំនួន ទីក្រុងនេះបានក្លាយជាគោលដៅធំមួយសម្រាប់ការវិនិយោគលើអចលនទ្រព្យ ជាពិសេសសម្រាប់ជនបរទេស។ ជួនកាលត្រូវបានគេហៅថាជា «កូនម៉ាកាវ» ឬ «ម៉ាកាវទីពីរ» ទីក្រុងនេះតែមួយរំពេចសោះ ស្រាប់តែសម្បូរទៅដោយការអភិវឌ្ឍកាស៊ីណូ។ គ្រាន់តែក្នុងរយៈពេលជាងពីរឆ្នាំសោះ មានកាស៊ីណូជាង៣០កន្លែងទទួលបានអាជ្ញាបណ្ណធ្វើការសាងសង់ អមដោយសណ្ឋាគារ ភោជនីយដ្ឋាន ហាង និងកន្លែងលក់វត្ថុផ្ចាប់ចិត្តជាច្រើនទៀតសម្រាប់ទេសចរ និងកម្មករដែលរស់នៅនិងធ្វើការនៅទីនោះ[៧២]។ អាជ្ញាបណ្ណសង់អគារត្រូវបានគេចេញឱ្យក្រុមហ៊ុនដែលប្រកបមុខរបរល្បែងស៊ីសងអនឡាញ ធ្វើឱ្យមុខរបរបើកកាស៊ីណូជាវិធីមួយងាយរកចំណេញសម្រាប់វិនិយោគិនក្នុងការឈានជើងចូលមកក្នុងទីផ្សារអចលនទ្រព្យកម្ពុជា។ សណ្ឋាគារលំដាប់កំពូលៗ មានដូចជា Marriott International, AccorHotels និង Intercontinental Hotels & Resorts ពេលនេះកំពុងបោះជើងឈានចូលក្នុងផ្សារអចលនទ្រព្យក្រុងព្រះសីហនុដែរហើយ ដើម្បីឆ្លើយតបទៅនឹងកំណើនខ្ពស់នៃការមកដល់របស់ភ្ញៀវទេសចរស្របពេលនឹងទីក្រុងនេះនៅជួបប្រទះកង្វះខាតរុំព័ន្ធនូវបន្ទប់សណ្ឋាគារសម្រាប់ដាក់ភ្ញៀវ[៧៣]។

ក្រៅពីកាស៊ីណូ ការវិនិយោគលើអលនទ្រព្យនៅតែបន្តកើនក្នុងសម្ទុះមួយលឿនយ៉ាងគំហុក ពិសេសក្នុងចំណោមវិនិយោគិនចិន។ ការវិនិយោគមានតម្លៃ ២០០លានដុល្លារ ក្នុងការសាងសង់អគារប្រណីតលំដាប់កំពូលមាន ៣៨ជាន់ ឈ្មោះថា Blue Bay Resort បានចាប់ផ្តើមលេចចេញជារូបរាងហើយនៅតាមឆ្នេរមួយចំនួនដែលធ្លាប់តែស្ងប់ស្ងាត់ ដែលក្នុងនោះមានអាផាតមិនក្នុងតម្លៃពី ១២៥០០០ដុល្លារទៅ៥០០០០០ដុល្លារ ក្នុងមួយឯកតា[៧៤]។ ក្នុងពេលដែលតម្លៃដីនិងអចលនទ្រព្យចេះតែបន្តឡើងនៅភ្នំពេញ - ដែលការវិនិយោគបរទេសក្នុងវិស័យអចលនទ្រព្យក៏ទទួលបានកំណើនខ្លាំងណាស់ដែរ - ក្រុងព្រះសីហនុត្រូវបានគេចាត់ទុកថាជាគោលដៅជម្រើសមួយទៀត សម្រាប់អ្នកដែលមានបំណងចង់ក្លាយជាកម្មសិទ្ធិករលើខុនដូ។ វិនិយោគិនចិនហ៊ានខែងរ៉ឹងណាស់នៅក្រុងព្រះសីហនុ ដែលត្រូវបានអ្នកអភិវឌ្ឍអចលនទ្រព្យធ្វើម៉ាឃីតធិងថាជាកំពង់ចំណតទីមួយរបស់គម្រោង «ខ្សែក្រវាត់មួយ ផ្លូវមួយ» របស់ចិន។ ទស្សនៈនេះត្រូវបានពង្រឹងថែមទៀតដោយផែនការពង្រីកបណ្តាញផ្លូវថ្នល់ ផ្លូវហោះហើរ និងផ្លូវដែកពីភ្នំពេញទៅប្រទេសចិន និងផែនការដែលកំពុងដំណើរការឈានទៅពង្រីកតំបន់សេដ្ឋកិច្ចដ៏ធំជាងគេរបស់ទីក្រុងនេះ។ រូបភាពប្រអប់ ២.៣ បង្ហាញចំនួនកាស៊ីណូដែលមានស្រាប់និងដែលនឹងកើតឡើងថ្មីទៀត និងទីតាំងអចលនទ្រព្យនានានៅភាគកណ្តាលក្រុងព្រះសីហនុ និងនៅតាមឆ្នេរពេញនិយមអូរឈើទាល។

---

៧២ McGrath, 2018.

៧៣ Vin, Vat (2018). “International hotel chains moving into Sihanoukville.” The Phnom Penh Post. 30 March 2018. https://www.phnompenhpost.com/supplements-post-property/international-hotel-chains-moving-sihanoukville

៧៤ Tostevin, Matthew and Prak Chan Thul (2017). “Cambodia goes all-in on China in casino port city.” Reuters, 7 December 2017. https://www.reuters.com/article/us-cambodia-politics-china-insight/cambodia-goes-all-in-on-china-in-casino-port-city-idUSKBN1E101E

**ប្រអប់រូបភាព ២.៣៖** ការអភិវឌ្ឍអចលនទ្រព្យនៅក្រុងព្រះសីហនុ




*ប្រភព៖ Phnom Penh Post (2018)*

យ៉ាងណាក្តី ការអភិវឌ្ឍអចលនទ្រព្យក្នុងសម្ទុះយ៉ាងលឿននាពេលបច្ចុប្បន្នមិនមែនចេះតែបន្តទៅដោយគ្មានការខាតបង់ណាមួយទេ។ ជាមួយនឹងអវត្តមាននៃផែនការគ្រប់គ្រងការប្រើប្រាស់ដីធ្លីសម្រាប់ផ្តល់ការណែនាំការអភិវឌ្ឍ ទេសភាពទីក្រុងមានការប្រែប្រួលមុខមាត់ខុសពីមុនឆ្ងាយណាស់ ដោយក្នុងនោះមានអគារខ្ពស់ៗលេចត្រដែតទៅលើស្មោកស្មុះ នៅក្នុងទីក្រុងមួយដែលជាប្រពៃណីធ្លាប់តែបរិស្ថានមានសំណង់កំពស់ទាប ឬមធ្យម។ នៅក្នុងបរិការណ៍បែបនេះ ការអនុញ្ញាតការសាងសង់ត្រូវបានផ្តល់លើមូលដ្ឋានមួយករណីម្តងៗ ដែលនៅទីនោះគេច្រើនស្គាល់ថាជាវិធី «សង់សិន អាជ្ញាបណ្ណតាមក្រោយ» "built first, license later"។ សិទ្ធិអំណាចក្នុងការចេញអាជ្ញាបណ្ណសាងសង់ និងការត្រួតត្រាសំណង់ ស្ថិតនៅហួសពីសមត្ថកិច្ចរបស់មន្ទីរខេត្តនីមួយៗ ឬរបស់អាជ្ញាធរក្រុងទៅទៀត។ ឥឡូវនេះពេលវេលាចាំតែមើលទេថាតើ ទីតាំងឆ្នេរសំខាន់ៗរបស់ក្រុងនេះនឹងនៅបើកចំហសម្រាប់ឱ្យការអភិវឌ្ឍគម្រោងប្រណីតៗដាច់មុខ ដែលកំពុងមាននៅទីនោះឬទេ។ ការសម្រុកចូលរបស់អគារថ្មីៗ ភ្ញៀវទេសចរ និងចំនួនប្រជាជនរស់នៅទីនោះ បានបង្កើនភាពតានតឹងទៅលើហេដ្ឋារចនាសម្ព័ន្ធក្រុង ដែលបណ្តាលឱ្យមានការកកស្ទះកាន់តែខ្លាំងឡើង និងការផ្តល់សេវាមិនបានល្អ។ ភាពតានតឹងរវាងពាណិជ្ជករកម្ពុជា និងពាណិជ្ជករចិនក៏មានការកើនឡើងដែរ ដោយក្នុងនោះពលរដ្ឋមួយចំនួនបានបន្ទោសការឡើងថ្លៃដី និងការលក់ដូរមិនសូវដាច់ដូចមុន ទៅលើអ្នកវិនិយោគចិន។ ខណៈដែលតម្លៃដីឡើងជារឿងមួយល្អសម្រាប់ម្ចាស់ដី អ្នកជួលអចលនទ្រព្យជាអ្នករងទម្ងន់នៃការឡើងចំណាយក្នុងការរកស៊ីទៅវិញ។ ហេតុនេះ គេរំពឹងថានឹងមានផលប៉ះពាល់អាក្រក់ផ្នែកសេដ្ឋកិច្ចរយៈពេលយូរអង្វែង ពីព្រោះការជួលបន្ទប់ (សណ្ឋាគារ កន្លែងស្នាក់នៅ ផ្ទះ) វានឹងទៅហួសពីលទ្ធភាពដែលពលរដ្ឋក្នុងមូលដ្ឋានអាចបង់ថ្លៃបាន។ មន្ទីរនានាក្នុងក្រុងបានលើកឡើងនូវក្តីកង្វល់ថា ការបំពុលបរិស្ថាននឹងមានការកើនឡើងដល់កម្រិតអាសន្នមួយក្នុងពេលដែលហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងបរិស្ថានក្នុងក្រុង (សំណល់រឹង ការត្រងនិងការធ្វើប្រព្រឹត្តិកម្មទឹកកង្វក់ ជាដើម) នៅខ្វះសមត្ថភាព។ ភាពណែនតាន់តាប់ក្នុងក្រុងកាន់តែឃើញច្បាស់ជាងមុនហើយ នៅពេលដែលស្ថានីយចំណតរថយន្តដឹកអ្នកដំណើរធុនធំនៅមានកម្រិត ហើយខ្វះការរៀបចំឱ្យបានត្រឹមត្រូវ។

*ប្រភព៖ ក្រុមការងារធនាគារពិភពលោក*

**ហេដ្ឋារចនាសម្ព័ន្ធបៃតង៖** មានភាពចាំបាច់កាន់តែច្រើនឡើងសម្រាប់ទីក្រុងធំក្នុងប្រទេសកម្ពុជា ធ្វើការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធបៃតង មានដូចជា ទីធ្លាបៃតង ទីធ្លាសាធារណៈ និងធ្លាសម្រាប់អ្នកថ្មើរជើង។ ទឹកជន់លិចបានកាន់តែក្លាយជាបញ្ហាធ្ងន់ធ្ងរនៅតាមទីក្រុងធំៗ មានក្រុងភ្នំពេញ ក្រុងបាត់ដំបង និងក្រុងព្រះសីហនុ ដែលមានគម្រោងសាងសង់ផុរកិច្ចរបស់វិស័យឯកជនត្រូវបានគេអភិវឌ្ឍនៅលើទីតាំងដែលពីដើមឡើយ ជាទីធ្លាបៃតងសាធារណៈ បឹងធម្មជាតិ ឬតំបន់ដីសើម ដែលជាប្រវត្តិសាស្ត្រមានតួនាទីជាប្រព័ន្ធធម្មជាតិសម្រាប់គ្រប់គ្រងទឹកជំនន់ និងទឹកកង្វក់[៧៥]។ ជាងនេះទៅទៀត កង្វះធ្លាសម្រាប់អ្នកថ្មើរជើង និងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ពីចំណុចចេញដំណើរទៅកាន់ចំណតរថយន្តសាធារណៈនិងពីចំណតរថយន្តសាធារណៈទៅកាន់គោលដៅបានក្លាយជាបញ្ហាប្រឈមមួយដល់ការព្យាយាមធ្វើឱ្យលទ្ធភាពធ្វើដំណើរក្នុងទីក្រុង និងភាពរស់នៅបានរបស់ទីក្រុង កាន់តែមានភាពងាយស្រួលជាងមុន។ ទោះជាផ្នែកជាច្រើននៃក្រុងភ្នំពេញនៅមានសល់សាច់ចិញ្ចើមផ្លូវដើរធំគួរសមក៏ដោយ (ទំហំ២ទៅ៣ម៉ែត្រនៅតាមផ្លូវតូច និង៥ម៉ែត្រនៅតាមផ្លូវធំៗ) ដែលជាកេរដំណែលនៃការអភិវឌ្ឍសម័យអាណានិគមបារាំង ចិញ្ចើមថ្នល់ទាំងនោះត្រូវបានគេកាន់កាប់សម្រាប់ធ្វើចំណតរថយន្ត ឬធ្វើទីតាំងសម្រាប់សកម្មភាពលក់ដូរ ដោយបង្ខំឱ្យអ្នកថ្មើរជើងចុះមកដើរនៅតាមលើសាច់ទ្រូងថ្នល់ទៅវិញ[៧៦]។

នៅក្នុងប៉ុន្មានឆ្នាំមកនេះ មានវឌ្ឍនភាពជាច្រើនត្រូវបានសម្រេចនៅក្នុងការតស៊ូមតិលើកកម្ពស់កំណើនបៃតងនៅកម្ពុជា ដូចត្រូវបានរៀបរាប់ជូនលម្អិតនៅក្នុងប្រអប់ ២.៤ ខាងក្រោម។ ក្រោមការជួយឧបត្ថម្ភពីម្ចាស់ជំនួយ ភាគច្រើននៃទីក្រុងកម្ពុជាបាន ឬកំពុងតែដំណើរការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍទីក្រុងបៃតងនិងប្រកបដោយចីរភាព។ យ៉ាងណាក្តី នៅមានកិច្ចខិតខំច្រើនទៀតដែលចាំបាច់ត្រូវធ្វើដើម្បីធានាឱ្យមានការវិនិយោគគ្រប់គ្រាន់ទៅលើហេដ្ឋារចនាសម្ព័ន្ធបៃតង។ សំខាន់គឺហេដ្ឋារចនាសម្ព័ន្ធបៃតងត្រូវមានការគិតគូរតាក់តែង ព្រមគ្នាជាមួយនឹងវិធានការគ្រប់គ្រងទឹកជំនន់ ហានិភ័យគ្រោះមហន្តរាយ និងគោលបំណងក្នុងសកម្មភាពការប្រែប្រួលអាកាសធាតុ ឬអំពីអត្ថប្រយោជន៍របស់វា តាំងពីដើមទីឱ្យហើយ ពីព្រោះថាវាអាចអស់ចំណាយច្រើនក្នុងការរុះរើបំពាក់ ឬសង់ហេដ្ឋារចនាសម្ព័ន្ធបៃតងឡើងវិញ នៅក្រោយពេលដែលតម្រូវការសេវាជាមូលដ្ឋានត្រូវបានបំពេញរួច។ លើសពីនេះទៅទៀត សក្តានុពលសេដ្ឋកិច្ចរបស់ទីក្រុងកម្ពុជា (ដូចជាវិស័យទេសចរណ៍ និងឧស្សាហកម្ម ជាដើម) អាចត្រូវបានយកមកបញ្ចូលបន្ថែម ដើម្បីធ្វើជាគំរូក្នុងការអភិវឌ្ឍសេដ្ឋកិច្ចបៃតងឱ្យមានសន្ទុះទៅមុខកាន់តែខ្លាំងថែមទៀត។

---

៧៥ GGGI, Phnom Penh Green City Strategic Plan 2017-2026, 2017.

៧៦ ធនាគារពិភពលោក ឆ្នាំ២០១៧។

**ប្រអប់ ២.៤៖** ការអភិវឌ្ឍបៃតងនៅកម្ពុជា

អនុលោមតាមយុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់សារៈសំខាន់លើបញ្ហាបរិស្ថាននិងការប្រែប្រួលអាកាសធាតុក្នុងការសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចមានចីរភាព រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តលើគោលការណ៍កំណើនបៃតង កាលពីប៉ុន្មានឆ្នាំមុននេះ។ យោងតាមផែនទីបង្ហាញផ្លូវជាតិសម្រាប់កំណើនបៃតង ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១០ កំណើនបៃតងនៅកម្ពុជា និងការអភិវឌ្ឍក្រុងបៃតងនិងប្រកបដោយចីរភាព បានក្លាយជាគោលនយោបាយអាទិភាពសំខាន់មួយរបស់នាយកដ្ឋានសេដ្ឋកិច្ចបៃតងនៃឧត្តមក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍដោយចីរភាព របស់ក្រសួងបរិស្ថាន។

ក្នុងបរិបទនេះ ឧត្តមក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍដោយចីរភាព ក្រសួងបរិស្ថាន និងរដ្ឋបាលមូលដ្ឋានពាក់ព័ន្ធ ដោយមានការគាំទ្រពីវិទ្យាស្ថានកំណើនបៃតងសកល (GGGI) បានរៀបចំឡើងនូវផែនការយុទ្ធសាស្ត្រទីក្រុងបៃតងមួយ។ នៅឆ្នាំ២០១៧ ផែនការយុទ្ធសាស្ត្រទីក្រុងបៃតងរបស់រាជធានីភ្នំពេញ ២០១៧-២០២៦ និងសេចក្តីព្រាងផែនការយុទ្ធសាស្ត្រទីក្រុងមានចីរភាព ២០១៨-២០៣០ - ដែលគ្របដណ្តប់លើទីក្រុងចំនួន៧ មានក្រុងសៀមរាប ក្រុងបាត់ដំបង ក្រុងព្រះសីហនុ ក្រុងកែប ក្រុងកំពង់ចាម ក្រុងបាវិត និងក្រុងសួង - ត្រូវបានបង្កើតឡើង។ ជាមួយចក្ខុវិស័យអភិវឌ្ឍទីក្រុងនានាក្នុងប្រទេសកម្ពុជាឱ្យក្លាយជា «ទីក្រុងមានភាពធន់ មានធនធានប្រកបដោយប្រសិទ្ធផល និងទទួលបានភាពចម្រុងចម្រើនអមដោយមេត្រីភាពផ្នែកបរិស្ថាន ដែលផ្តល់ជូនពលរដ្ឋនូវសេវាសាធារណៈមានគុណភាពខ្ពស់ ឱកាសការងារសមរម្យ ជីវភាពរស់នៅមានគុណភាពល្អ ភាពសុខដុមសង្គម និងការចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច» កិច្ចប្រឹងប្រែងរបស់កំណើនបៃតងមានគោលដៅ i) អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងមានចីរភាព, ii) កែលម្អសេដ្ឋកិច្ចក្នុងមូលដ្ឋាន, iii) លើកកម្ពស់បរិយាប័ន្នសង្គម និងលទ្ធភាពទទួលបានសេវា និងការងារសម្រាប់ទាំងអស់គ្នា, និង iv) កែលម្អអភិបាលកិច្ចរបស់ទីក្រុង។ ផែនការយុទ្ធសាស្ត្រទាំងនេះព្យាយាមឆ្លើយតបទៅនឹងបញ្ហាផ្តល់សេវាក្នុងទីក្រុងមួយចំនួន ដូចបានពិភាក្សារួចហើយនៅខាងលើ ដោយឈរលើជ្រុងទស្សនៈរបស់ចីរភាពបរិស្ថាន និងកំណើនបៃតង ហើយវាបានលើកឡើងនូវបញ្ជីយ៉ាងវែងមួយ ស្តីពីគម្រោងបៃតងមានសក្តានុពលនៅក្នុងការរៀបចំធ្វើផែនការ ភាពងាយរងគ្រោះរបស់ទីក្រុង (រួមមានបញ្ហាអនាម័យ ការការពារទឹកជំនន់ ការការពារបរិស្ថាន) ផ្នែកថាមពល ផ្នែកដឹកជញ្ជូន បរិស្ថានសំណង់ ការគ្រប់គ្រងសំណល់រឹងរបស់ឧស្សាហកម្ម ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌។

ជាងនេះទៅទៀត កំណើនបៃតង និងការអភិវឌ្ឍទីក្រុងបៃតង មានភាពស៊ីគ្នាជាមួយនឹងកម្មវិធីទីក្រុងបៃតងរបស់រាជរដ្ឋាភិបាល ដែលមានគោលដៅកែលម្អសោភ័ណភាព អនាម័យ បរិស្ថានល្អ និងស្តង់ដារស់នៅក្នុងទីក្រុង ហើយទាក់ទាញភ្ញៀវទេសចរឱ្យបានកាន់តែច្រើនថែមទៀត។ ទីក្រុងកម្ពុជាមានឱកាសច្រើនក្នុងការទាញយកផលចំណេញពី«សេដ្ឋកិច្ចបៃតង» ពិសេសពីការបង្កើតការងារបៃតងថ្មីៗនៅក្នុងវិស័យទេសចរណ៍ និងឧស្សាហកម្ម។ គោលបំណងរបស់សេដ្ឋកិច្ចបៃតងគឺដើម្បីកែលម្អសុខុមាលភាពមនុស្ស និងសមធម៌សង្គម ដោយកាត់បន្ថយឱ្យបានច្រើននូវបញ្ហាបរិស្ថានសង្គម និងភាពអត្តខាត់ផ្នែកអេកូឡូហ្ស៊ី។ គំរូសេដ្ឋកិច្ចបៃតងត្រូវបានគេយកទៅអនុវត្តបានជោគជ័យនៅប្រទេសមួយចំនួន ដូចជាប្រទេសកូស្តារីកា ជាដើម ដែលជាប្រទេសឈានមុខគេក្នុងការអភិវឌ្ឍបៃតងតាមរយៈវិស័យទេសចរណ៍ធម្មជាតិ។

*ប្រភព៖ Source: GGGI, ផែនការយុទ្ធសាស្ត្រទីក្រុងបៃតងរបស់រាជធានីភ្នំពេញ ២០១៧-២០២៦ ឆ្នាំ២០១៧។ សេចក្តីព្រាងផែនការយុទ្ធសាស្ត្រទីក្រុងមានចីរភាព ២០១៨-២០៣០។ ធនាគារពិភពលោក ឆ្នាំ២០១៧។*

## ២.២ ស្ថាប័ន អភិបាលកិច្ច និងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងទីក្រុង

### ២.២.១ សេចក្ដីផ្ដើម

តួនាទីរបស់ស្ថាប័នមានសមត្ថភាពរឹងមាំ អភិបាលកិច្ចល្អ និងការផ្ដល់ហិរញ្ញប្បទានមានចីរភាពមានសារៈសំខាន់ជាសារវន្តសម្រាប់ការគ្រប់គ្រងទីក្រុងឱ្យមានប្រសិទ្ធភាព និងការផ្ដល់សេវាទីក្រុងមានចីរភាព ហើយវាជាភាពចាំបាច់ផងសម្រាប់នាំមកនូវបរិស្ថានមួយមានអំណោយផលសម្រាប់ធុរកិច្ច និងការបង្កើតការងារ។ នៅកម្ពុជា មានក្របខណ្ឌកំពុងវិវត្តជានិច្ចសម្រាប់កសាងរដ្ឋបាលក្រុងមួយដែលប្រតិបត្តិការទៅមុខក្រោមកន្សោមច្បាប់ និងកម្មវិធីកំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការរបស់រដ្ឋាភិបាល ប៉ុន្តែនៅក្នុងភាពជាក់ស្ដែង អភិបាលកិច្ចមូលដ្ឋានត្រូវបានជួបឧបសគ្គទៅវិញ ដោយសារតែមានការអនុវត្តតិចតួចនូវគោលនយោបាយដែលមានស្រាប់ និងធនធាន ការទទួលខុសត្រូវ និងចំនួនបុគ្គលិកមានជំនាញនៅមានកម្រិត។

ជារួម ការផ្ទេរអំណាចទៅឱ្យថ្នាក់ក្រោមជាតិ នៅមានកម្រិតទាបនៅឡើយ ហើយមិនទាន់បំពេញសេចក្ដីត្រូវការរបស់ទីក្រុងលំដាប់ទីពីរបាននៅឡើយទេ។ ជាពិសេស ទីក្រុងលំដាប់ទីពីរមិនទាន់អាចយកមកប្រៀបបានទេជាមួយទីក្រុងភ្នំពេញ ដែលទទួលបានហិរញ្ញប្បទាន គិតក្នុងពលរដ្ឋម្នាក់ ក្នុងចំនួនច្រើនគួរឱ្យកត់សម្គាល់ ជាងក្រុងលំដាប់ទីពីរផ្សេងៗទៀត។ ក្នុងឆ្នាំ២០១៧ ទីក្រុងសៀមរាបទទួលបានហិរញ្ញប្បទានតិចជាងពាក់កណ្ដាលនៃចំនួនហិរញ្ញប្បទានជាមធ្យម ដែលខណ្ឌក្នុងទីក្រុងភ្នំពេញ ទទួលបានទៅទៀត។ ទោះជាមានច្បាប់និងគោលនយោបាយដោយឡែកៗជាច្រើនមែន គេនៅមិនទាន់មានក្របខណ្ឌសម្រាប់ការផ្ដល់ហិរញ្ញវត្ថុដល់ថ្នាក់ក្រោមជាតិនៅឡើយទេ ដែលមានន័យថារដ្ឋបាលថ្នាក់ក្រោមជាតិមានរចនាសម្ព័ន្ធនៅមានកម្រិតសម្រាប់គណនេយ្យភាពនៅក្នុងការថាតើគួរគ្រប់គ្រងហិរញ្ញវត្ថុរបៀបណា។ បើនិយាយពីប្រភពចំណូលវិញ គេឃើញមានភាពលម្អៀងទៅរកទីក្រុងតូចៗ ហើយធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់ក្រុងទាំងនោះនៅក្នុងការធ្វើហិរញ្ញប្បទានដល់ការអភិវឌ្ឍទីក្រុង។ ភាគច្រើន ភាពលម្អៀងនេះកើតចេញពីរូបមន្តចែករំលែកប្រាក់ចំណូលពន្ធរវាងបណ្ដាខេត្ត និងក្រុងដែលចែកឱ្យស្មើៗគ្នានូវទឹកប្រាក់ ៥០% នៃមូលនិធិដែលត្រូវបានផ្ទេរ ហើយសល់ពីនោះ៥០%ទៀត ត្រូវបានបែងចែកដោយផ្អែកតាមចំនួនប្រជាជននៅក្នុងក្រុងនីមួយៗ។ គំនិតផ្ដួចផ្ដើមនានាដូចជា ច្រកសេវាចេញចូលតែមួយ ជាដើម ដែលមានគោលដៅធ្វើឱ្យសេវារដ្ឋបាលជាមូលដ្ឋាន (ឧ. លិខិតបញ្ជាក់ ឬលិខិតអនុញ្ញាតនានា) ឱ្យមានភាពងាយស្រួលសម្រាប់ពលរដ្ឋទទួលបាន ឃើញថាមានប្រសិទ្ធភាព ប៉ុន្តែគេមិនទាន់ដឹងច្បាស់ថាតើនិរន្តរភាពរបស់ការិយាល័យទាំងនេះនឹងមានកម្រិតណាទេ នៅពេលដែលចំណូលដែលប្រមូលបានពីការផ្ដល់សេវាទាំងនោះ មិនអាចគ្របដណ្ដប់ទៅលើការចំណាយបានផង។ ផ្នែកឯកជនបានឈានមកបំពេញការខ្វះចន្លោះខ្លះ នៅក្នុងការធ្វើហិរញ្ញប្បទានដល់ការអភិវឌ្ឍក្រុង ប៉ុន្តែភាគច្រើននៃសកម្មភាពទាំងនោះមិនបានអនុលោមតាមផែនការរៀបចំក្រុងទេ ហើយត្រូវបានអនុវត្តតាមរបៀបមួយរញ៉េរញ៉ៃ ដែលបណ្ដាលឱ្យមានបញ្ហាប្រឈមជាច្រើន (ដូចមានក្រុងព្រះសីហនុជាឧទាហរណ៍ស្រាប់)។ ផ្នែកនេះនៃរបាយការណ៍ធ្វើការពិនិត្យទៅលើបញ្ហាគន្លឹះមួយចំនួនពាក់ព័ន្ធទៅនឹងក្របខណ្ឌស្ថាប័ន និងការផ្ដល់ហិរញ្ញប្បទានសម្រាប់ផ្នែកកិច្ចការរដ្ឋបាល និងការផ្ដល់សេវារបស់ទីក្រុង។

### ២.២.២ ក្របខណ្ឌច្បាប់ និងក្របខណ្ឌគោលនយោបាយ

ទីក្រុង អមដោយស្រុកនិងខណ្ឌផង ស្ថិតនៅចំកណ្ដាលរចនាសម្ព័ន្ធរដ្ឋបាលនៃរដ្ឋាភិបាលកម្ពុជា។ ឋានានុក្រមហូរពីពីថ្នាក់កំពូលជាតិចុះដល់ថ្នាក់ខេត្ត រាជធានី រហូតដល់ស្រុក ក្រុង និងខណ្ឌ (ខណ្ឌសម្រាប់តែរាជធានីភ្នំពេញមួយទេ) និងឃុំ-សង្កាត់ដែលជាឋានានុក្រមទាបជាងគេបង្អស់។ ថ្នាក់រដ្ឋបាលនីមួយៗត្រូវបានគ្រប់គ្រងអភិបាលដោយក្រុមប្រឹក្សាដែលមានការជ្រើសតាំងដែលក្នុងនោះរដ្ឋបាលថ្នាក់ជាតិ និងក្រុមប្រឹក្សា ឃុំ-សង្កាត់ត្រូវបានជ្រើសតាំងដោយផ្ទាល់ដោយប្រជាជនតាមរយៈការបោះឆ្នោត រីឯក្រុមប្រឹក្សារាជធានី ខេត្ត ស្រុក ក្រុងនិងខណ្ឌ ត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់តាមរយៈការបោះឆ្នោតអសកល។

ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ឆ្នាំ២០០៨) ផ្ដល់ក្របខណ្ឌរួមផ្នែកច្បាប់និងស្ថាប័នសម្រាប់ការគ្រប់គ្រងក្រុង។ ច្បាប់នេះរៀបរាប់អំពីរចនាសម្ព័ន្ធរដ្ឋបាល និងហិរញ្ញវត្ថុរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងទំនាក់ទំនងរបស់ពួកគេទៅនឹងរដ្ឋបាលថ្នាក់ក្រោមជាតិនៃរដ្ឋាភិបាល។ ច្បាប់ស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨ កសាងឡើង

នៅលើ ច្បាប់ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសកម្មរបស់ខេត្ត និងក្រុង (ឆ្នាំ១៩៩៨) ហើយមានវិសាលភាពគ្រប់ដណ្តប់លើគ្រប់ទិដ្ឋភាពហិរញ្ញវត្ថុរបស់រដ្ឋ (ពន្ធដារ ថវិកា ទ្រព្យសកម្ម និងបំណុល) រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិផង (ឧ. ចំណូលថ្នាក់ក្រោមជាតិ និងថវិកា)។ ក៏ប៉ុន្តែ គ្មានច្បាប់ណាមួយជាក់លាក់ស្តីពីហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ដែលអាចរៀបរាប់លម្អិតបានថាតើអាជ្ញាធរថ្នាក់ក្រោមជាតិគួរប្រើប្រាស់ហិរញ្ញវត្ថុដូចម្តេច ចាត់ចែងចំណូលរបស់ខ្លួនដោយរបៀបណា ហើយតើមានតម្រូវការអ្វីខ្លះសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ។

មានលិខិតុបករណ៍ច្បាប់ និងគោលនយោបាយជាច្រើនដែលចែងលម្អិតអំពីសកម្មភាពរបស់អាជ្ញាធរក្រុង ដែលមានឋានានុក្រមតាមលំដាប់លំដោយពីលើចុះក្រោមថាជា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស។ អ្វីដែលសំខាន់ជាងគេនៅក្នុងចំណោមលិខិតុបករណ៍ទាំងនេះ សម្រាប់ថ្នាក់ក្រុងគឺផ្តោតទៅលើការផ្ទេរមុខងាររដ្ឋាភិបាលពីថ្នាក់កណ្តាលទៅឱ្យថ្នាក់ក្រោមជាតិ និយាយឱ្យចំភាគច្រើនគឺថ្នាក់ ស្រុក និងថ្នាក់ក្រុង។ ជាឧទាហរណ៍មានអនុក្រឹត្យលេខ៦៨ ដែលគ្របដណ្តប់លើដំណើរការទូទៅសម្រាប់ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានការរៀបចំមុខងារ ការពិនិត្យឡើងវិញ និងដំណើរអនុវត្តការចាត់តាំងមុខងារ (ឆ្នាំ២០១២); អនុក្រឹត្យលេខ២៨៥ ស្តីពីការគ្រប់គ្រងមុខងារជាជម្រើសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយកំណត់នីតិវិធីសម្រាប់ធ្វើនិយតកម្មមុខងារជាជម្រើសតាមរយៈការពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធ (ឆ្នាំ២០១៤); ព្រមទាំងអនុក្រឹត្យ និងប្រកាសរបស់ក្រសួងផងដែរស្តីពីការធ្វើប្រតិភូកម្ម និងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រសួងទេសចរណ៍ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច និងក្រសួងបរិស្ថាន)។

មានលិខិតុបករណ៍ជាច្រើនទៀតដែលកំណត់ធនធានហិរញ្ញវត្ថុសម្រាប់ស្រុក/ក្រុង ដូចជា៖ អនុក្រឹត្យលេខ៣៦ស្តីពីការបង្កើតមូលនិធិស្រុក/ក្រុង និងកំណត់នីតិវិធីប្រតិបត្តិការរបស់មូលនិធិ ដោយក្នុងនោះរួមមានកម្រិតមូលនិធិ និងរូបមន្តបែងចែកមូលនិធិ (២០១២); អនុក្រឹត្យលេខ៣២ស្តីពីការបង្កើត និងការគ្រប់គ្រងមូលនិធិវិនិយោគថ្នាក់ក្រោមជាតិ ដែលក្នុងនោះរួមមានការផ្តល់ហិរញ្ញប្បទានស្ថាប័ននិងការបង្កើតកញ្ចប់មូលនិធិសម្រាប់កម្មវិធីវិនិយោគ (២០១៦) ដែរ; និងអនុក្រឹត្យលេខ៦ស្តីពីការគ្រប់គ្រងសម្បទានថវិកាជាប់លក្ខខណ្ឌ ដែលក្នុងនោះមាននីតិវិធីអនុវត្តលើការធ្វើអត្តសញ្ញាណកម្ម ការចាត់តាំង និងការធ្វើហិរញ្ញប្បទានដល់មុខងារដែលត្រូវទ្រទ្រង់ដោយសម្បទានថវិកាជាប់លក្ខខណ្ឌ (២០១៧)។

ដំណើរវិវត្តន៍នៃតួនាទីរបស់ស្រុក/ក្រុងនៅកម្ពុជា ជាទូទៅ ត្រូវបានជំរុញដោយការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រដ្ឋាភិបាល ដែលមានឈ្មោះថា កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ២០០៩-២០១៩ (National Program for Subnational Democratic Development, 2009 - 2019/NP-SNDD)។ កម្មវិធីជាតិ NP-SNDD បានអនុវត្តតាមរយៈផែនការបីឆ្នាំអស់បីដំណាក់កាលមកហើយ ដែលផែនការចុងក្រោយគេត្រូវបានអនុម័តនៅខែវិច្ឆិកា ឆ្នាំ២០១៧ ហើយមានឈ្មោះថា «ផែនការអនុវត្តបីឆ្នាំ ដំណាក់កាលទី៣ (ផអ៣ទី៣)» ២០១៨-២០២០។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ជាអង្គភាពទទួលខុសត្រូវសម្រាប់អនុវត្តយុទ្ធសាស្ត្រ និងផែនការនេះ។

**អាទិភាពធំៗរបស់ «ផអ៣ទី៣» រួមមាន៖**

- ពង្រីកធនធានដែលមានឆន្ទានុសិទ្ធិសម្រាប់ស្រុក/ក្រុងយកទៅប្រើប្រាស់ ពីព្រោះថាធនធានដែលគេទទួលបានកន្លងមកសម្រាប់តែចំណាយលើផ្នែកបុគ្គលោក និងផ្នែករដ្ឋបាលតែប៉ុណ្ណោះ ឬមួយក៏មិនបានទ្រទ្រង់ដល់ការផ្តល់សេវាឱ្យបានពេញលេញទេ រួមទាំងសេវាផ្នែកសង្គមផង។ កង្វះខាតធនធាននេះបានរួមចំណែកធ្វើអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ គ្មានលទ្ធភាពដាក់ចេញគំនិតផ្តួចផ្តើមរឹងមាំណាមួយដើម្បីដោះស្រាយបញ្ហាក្នុងមូលដ្ឋានរបស់ខ្លួនឡើយ។

- បង្កើនល្បឿននៃការផ្ទេរមុខងារ ដោយប្រែក្លាយការធ្វើសេចក្តីសម្រេចផ្ទេរមុខងារសំខាន់ឱ្យទៅជាការផ្ទេរមុខងារជាក់ស្តែង រួមទាំងការបញ្ចេញធនធានដែលជាតម្រូវការចាំបាច់សម្រាប់យកទៅអនុវត្តលើមុខងារទាំងនោះទៅជាមួយផង។

- បង្កើតគោលនយោបាយ និងចក្ខុវិស័យច្បាស់លាស់សម្រាប់ការផ្តល់សេវាបែបវិមជ្ឈការ ដើម្បីដាក់ឱ្យប្រតិបត្តិនូវស្តង់ដាផ្តល់សេវា (តាមរយៈវិធានការអធិការកិច្ច ទណ្ឌកម្ម និងរង្វាន់លើកទឹកចិត្ត) ប៉ុន្តែក៏ផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវស្វ័យភាពក្នុងការចាត់ចែងគ្រប់គ្រងកិច្ចការប្រចាំថ្ងៃដែរ។

- ពង្រឹងសមត្ថភាពរបស់អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសផ្នែកភាពជាអ្នកដឹកនាំ និងជំនាញអាជីពផ្សេងៗទៀត។

## ២.២.៣ សមត្ថភាពផ្នែករដ្ឋបាល

អំណាចក្នុងការតែងតាំង ផ្ទេរ និងបញ្ឈប់ពីការងារដល់បុគ្គលិកស៊ីវិលដែលធ្វើការនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើប្រតិភូកម្មទៅឱ្យថ្នាក់ក្រោមជាតិរួចហើយ ប៉ុន្តែបុគ្គលិកស៊ីវិលទាំងនោះនៅតែរក្សាខ្សែចាត់តាំងរបៀបរបបការងាររបស់ពួកគេជាមួយក្រសួងរៀងៗខ្លួនដដែលនៅឡើយ។ នៅឆ្នាំ២០១៦ ក្រសួង២៤ក្នុងចំណោមក្រសួងសរុបចំនួន៣៥ មានតំណាងរបស់ខ្លួនធ្វើការនៅតាមខេត្ត និងស្រុក ស្របពេលដែលមាននិន្នាការទៅរកការធ្វើវិសហមជ្ឈការបុគ្គលិករបស់ខ្លួនច្រើនថែមទៀត ឱ្យទៅនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ក្រោមជាតិវិញ។ រវាងឆ្នាំ២០១០ និង២០១៦ ចំនួនប្រាក់បៀវត្សដែលក្រសួងចំណាយទៅលើមន្ទីរតាមខេត្ត (និងនៅតាមស្រុក/ក្រុងមួយចំនួន) បានកើនពី ៣៩,៨% ទៅដល់ ៤៨,២% (ADB, 2018)។ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច ក្រសួងសុខាភិបាល តំណាងឱ្យ៨៨,៩% នៃចំណាយសរុបលើប្រាក់បៀវត្សនៅតាមខេត្ត។ បុគ្គលិកសរុបរបស់ក្រុងបច្ចុប្បន្នស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ ប៉ុន្តែកិច្ចពិភាក្សាកំពុងតែដំណើរការក្នុងគោលដៅផ្ទេរ ឬធ្វើវិមជ្ឈការមនុស្សជិត ៩០០០ នាក់ ក្នុងចំណោមបុគ្គលិករបស់ក្រសួងដែលបម្រើការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ចេញពីការគ្រប់គ្រងផ្ទាល់របស់ក្រសួង ឱ្យទៅនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិវិញ។ ជំហាននេះបង្ហាញនូវការផ្លាស់ប្ដូរយ៉ាងធំមួយនៅក្នុងបែបបទអំណាចគ្រប់គ្រងដោយអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការសម្រេចនានាបានលើវចនាសម្ព័ន្ធបុគ្គលិក និងការប្រើប្រាស់ធនធានរៀងៗខ្លួន។ ក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈ ក៏កំពុងពិចារណាដែរនូវការណ៍ថាតើមន្ត្រីស៊ីវិលដែលធ្វើការក្រោមឱវាទរបស់ក្រសួងនៅតាមការិយាល័យស្រុក/ក្រុង គួរត្រូវបានដាក់បញ្ចូលទៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរបៀបណា។

ដោយសារតែមានអតុល្យភាពនៅក្នុងការបែងចែកចំណូលពន្ធរួមគ្នា និងរូបមន្តបែបអសមធម៌ក្នុងការធ្វើហិរញ្ញប្បទានសម្បទានថវិកាជាប់លក្ខខណ្ឌទៅឱ្យថ្នាក់ក្រោមជាតិ ជាលទ្ធផល ក្រុងធំៗច្រើនតែមានចំនួនបុគ្គលិកតិចបើគិតតាមអត្រាប្រជាជន ហើយមានលទ្ធភាពមានកម្រិតណាស់ក្នុងការសម្រួលតម្រូវការក្នុងស្ថានភាពការងាររបស់គេ[៧៧]។ តារាង ២.១ នៅខាងក្រោមបង្ហាញក្រុងសៀមរាប ដែលជាក្រុងធំជាងគេទីពីរ មានអត្រាចំណាយសម្រាប់ពលរដ្ឋម្នាក់ទាបជាងគេ ហើយក្រុងដែលមានអត្រាចំណាយទាបបន្ទាប់គឺក្រុងបាត់ដំបង ដែលជាក្រុងធំទីបីក្នុងប្រទេស (ADB, Dunn, 2016)។ ការណ៍ដែលបណ្ដាក្រុងចំណាយជិត ៤៥%នៃថវិការបស់ខ្លួនទៅលើបៀវត្ស និងប្រាក់ឧបត្ថម្ភ (ដូចមានបង្ហាញក្នុងតារាង ២.៣) ក៏ជាការឆ្លុះបញ្ចាំងឱ្យឃើញផងដែរនូវកម្រិតសមត្ថភាពរបស់បុគ្គលិក និងរដ្ឋបាល គិតជាអត្រាក្នុងមនុស្សម្នាក់។ បន្ថែមលើនេះ ឧបសគ្គរឹងកំព្រឹសៗដែលបណ្ដាក្រុងកំពុងប្រឈមពាក់ព័ន្ធទៅនឹងចំនួនថវិកាសម្រាប់បុគ្គលិក និងភាពស្មុគស្មាញនៃបទបញ្ញត្តិហិរញ្ញវត្ថុ និងលទ្ធកម្ម កាន់តែធ្វើឱ្យក្រុងមានការលំបាកក្នុងជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាមកបំពេញតម្រូវការជាអាទិភាព ដែលលេចឡើងនៅក្នុងអង្គភាពរបស់ខ្លួន។ អាស្រ័យហេតុនេះ ចាំបាច់ត្រូវមានការខិតខំច្រើនថែមទៀតក្នុងការសម្រួលបែបបទឱ្យកាន់តែសាមញ្ញ និងដើម្បីកសាងភាពជឿទុកចិត្ត និងសមត្ថភាពបុគ្គលិករបស់រដ្ឋបាលក្រុង ក្នុងការរកជួលបុគ្គលិកជាប់កិច្ចសន្យាមកបំពេញតម្រូវការ ដើម្បីជួយឱ្យអង្គភាពរបស់គេមានភាពបត់បែន និងឆ្លើយតបទៅនឹងតម្រូវការរបស់ពលរដ្ឋបានល្អជាងមុន។

---

៧៧ ពន្ធរួមដែលត្រូវបានផ្ទេរពីខេត្តទៅស្រុក/ក្រុងគឺមានចំនួន ៥០%ស្មើគ្នាសម្រាប់ស្រុក/ក្រុងទាំងអស់ ហើយចំនួន៥០%ផ្សេងទៀតត្រូវបានគណនាដោយផ្អែកលើចំនួនប្រជាជនក្នុងស្រុក/ក្រុងនីមួយៗ។ រូបមន្តនេះចំណេញជាងសម្រាប់ក្រុងតូចៗ ពីព្រោះថា តម្លៃលេខសរុបនៃចំណែករួមស្មើគ្នាឃើញថាខ្ពស់បើប្រៀបទៅនឹងចំនួនប្រជាជនតិច។ ដោយសារចំណាយរបស់ស្រុក/ក្រុងភាគច្រើនត្រូវបានធ្វើទៅលើបុគ្គលិក និងចំណាយផ្នែករដ្ឋបាល វាមានន័យថាក្រុងតូចៗមានចំនួនបុគ្គលិកច្រើនជាងសម្រាប់ពលរដ្ឋម្នាក់ក្នុងមូលដ្ឋាន កាលណាប្រៀបធៀបជាមួយក្រុងធំៗ។

**តារាង ២.១៖** ភាពខុសៗគ្នានៃចំណាយជាក់ស្តែង(ជាប្រាក់រៀល)របស់បណ្តាក្រុង ខណ្ឌ រាជធានីភ្នំពេញ សម្រាប់ពលរដ្ឋម្នាក់ៗ ក្នុងឆ្នាំ២០១៦

| ក្រុង | ប្រជាជនក្នុងឆ្នាំ២០១៦ | ចំណាយសម្រាប់ពលរដ្ឋម្នាក់ (២០១៦) |
| --- | --- | --- |
| តោខ្មៅ | ៧៦៧៣៣ | ២៨២៧១ |
| ព្រះសីហនុ | ៧៨៣៨០ | ២៧៦១២ |
| សិរីសោភ័ណ | ៩១១៥៨ | ៣០៧០៧ |
| បាត់ដំបង | ១៥៥៨៤ | ២៥៤២៤ |
| សៀមរាប | ២៣០១៥៧ | ២២៩៩៧ |
| ចំនួនមធ្យមភាគរបស់ទីប្រជុំជនខេត្ត ១៩ផ្សេងទៀត | ៣៧៩០៤ | ៤១៣៣៨ |
| ចំនួនមធ្យមភាគរបស់ខណ្ឌទាំង ១២ ក្នុងក្រុងភ្នំពេញ | ១២០៦១២ | ៥៤១៥៧ |
| ក្រុងភ្នំពេញ | ១៤៤៧៣៤០ | ៣៤២៥២២ |
| បញ្ជីចំណាយតាមផ្នែក | | |
| ចំនួនមធ្យមភាគសម្រាប់មនុស្សម្នាក់ សម្រាប់ស្រុក(ជនបទ) ទាំងអស់ | អត់មាន | ៧៨១២ |
| ចំនួនមធ្យមភាគសម្រាប់មនុស្សម្នាក់ សម្រាប់ខេត្តទាំងអស់ (លើកលែងតែរាជធានីចេញ) | អត់មាន | ២៤០៦៦ |

*ប្រភព៖ ធនាគារអភិវឌ្ឍន៍អាស៊ី (Jonathan Dunn). 2016. TA 8159-CAM: Decentralized Public Service and Financial Management Sector Development Project. Subnational Fiscal Data Base for Cambodia. Phnom Penh.*

ដើម្បីឆ្លើយតបទៅនឹងវិសមធម៌យេនឌ័រ នៅក្នុងចំណោមបុគ្គលិក «យុទ្ធសាស្រ្តសម្រាប់លើកកម្ពស់ស្រ្តីនៅក្នុងតំណែងគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ» (Strategy to Promote Women in SNA Management Positions) ដែលត្រូវបានអនុម័តកាលពីខែមេសា ឆ្នាំ២០១៧ ស្នើឱ្យប្រើប្រព័ន្ធកូតា និងការរៀបចំផែនការសន្តតិកម្ម(ការបន្តវេន) ជាមធ្យោបាយសម្រាប់ឈានទៅសម្រេចគោលដៅឱ្យមានស្រ្តីយ៉ាងហោចណាស់ចំនួន ២៥% នៅក្នុងតំណែងគ្រប់គ្រងរដ្ឋបាលថ្នាក់ស្រុក/ក្រុង ត្រឹមឆ្នាំ២០១៨។ បច្ចុប្បន្ននេះ ស្រ្តីកាន់តំណែងជាអភិបាលស្រុកមានចំនួនមិនដល់ ៤%ទេ ប៉ុន្តែកិច្ចខិតខំរបស់ក្រសួងមហាផ្ទៃបានធ្វើឱ្យមានចំនួនស្រ្តីកាន់តំណែងជាអភិបាលរងស្រុករហូតដល់ទៅ ៣០% ដែលច្រើនគួរឱ្យកត់សម្គាល់។

ដើម្បីផ្តល់សមត្ថភាពមានលក្ខណៈប្រមូលផ្តុំ និងកែលម្អប្រសិទ្ធផលការងារផ្តល់សេវាសាធារណៈ រដ្ឋាភិបាលបានចាប់ផ្តើមបង្កើត «ការិយាល័យច្រកចេញចូលតែមួយ» ក្នុងឆ្នាំ២០១៨។ ខណៈដែលការិយាល័យមានគោលដៅធ្វើឱ្យសេវារដ្ឋបាល ជាមូលដ្ឋាន (ឧ. លិខិតបញ្ជាក់ការអនុញ្ញាតផ្សេងៗ) កាន់តែងាយស្រួលសម្រាប់ពលរដ្ឋទទួលបាន តួនាទីរបស់រដ្ឋបាលក្រុងគឺរៀបចំផែនការ និងគ្រប់គ្រងការអភិវឌ្ឍនៃនគរូបនីយកម្មក្នុងរយៈពេលយូរអង្វែងទៅមុខ។ គិតមកត្រឹមចុងឆ្នាំ២០១៧ ការិយាល័យច្រកចេញចូលតែមួយ៥២កន្លែងបានដាក់ឱ្យដំណើរការ ដោយយ៉ាងហោចណាស់ក្រុងមួយមានការិយាល័យមួយ។ ការអង្កេតបែបគុណភាពលើអភិបាលកិច្ច ដែល គ.ជ.អ.ប បានធ្វើក្នុងឆ្នាំ២០១៧ រកឃើញថា ការិយាល័យច្រកចេញចូលតែមួយទទួលបានការទុកចិត្តពីសំណាក់ប្រជាជន ដោយវាបានផ្តល់សេវាដល់អ្នកប្រើប្រាស់តាមរបៀបមួយមានមេត្រីភាព លក្ខណៈអាជីព និងតម្លាភាព។ ការផ្តល់សេវាមានភាពលឿនជាងប្រៀបទៅនឹងសេវាដែលផ្តល់ដោយមន្ទីរខ្សែបណ្តោយរបស់ក្រសួង (API, 2012)។ ប៉ុន្តែ និរន្តរភាពរបស់ការិយាល័យច្រកចេញចូលតែមួយ នៅតែចោទជាបញ្ហានៅឡើយ ដោយចំណូលដែលប្រមូលបានពីការផ្តល់សេវាមិនទាន់ទាំងគ្រប់គ្រាន់សម្រាប់ទូទាត់ថ្លៃចំណាយលើប្រតិបត្តិការ នៅ

ឡើយទេ។ ផែនការ «ផអ៣ទី៣» រួមមានការវាយតម្លៃរកមើលលទ្ធភាពផ្ទេរការិយាល័យច្រកចេញចូលតែមួយ ឱ្យទៅនៅក្រោមអាជ្ញាធរថ្នាក់ក្រោមជាតិវិញ ជាមធ្យោបាយមួយសម្រាប់ធានាឱ្យមាននិរន្តរភាពរបស់វាទៅថ្ងៃមុខ។ ផែនការនេះក៏មានគោលដៅបង្កើនទ្វេដងដែរ នូវចំនួនមនុស្សមកប្រើប្រាស់សេវារបស់ការិយាល័យច្រកចេញចូលតែមួយ និងការធ្វើការពង្រីកថែមទៀតចំនួនសេវាដែលត្រូវផ្តល់ ពី២៣២ប្រភេទ ឱ្យទៅដល់២៥៥ប្រភេទ។

មតិតបរបស់ពលរដ្ឋ អំពីកម្រិតពេញចិត្តជាមួយសេវាផ្តល់ដោយស្រុក/ក្រុង រួមមានដូចជាការសាងសង់ផ្លូវ ការអភិវឌ្ឍរៀបចំផែនការ និងសេវាផ្សេងៗទៀត មានភាពប្រសើរឡើងចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦។ ការអង្កេតអភិបាលកិច្ចឆ្នាំ២០១៦ រកឃើញថា លេខតម្លៃមធ្យមភាគទូទៅនៃភាពពេញចិត្តជាមួយការផ្តល់សេវាគ្រប់ប្រភេទ បានហក់ឡើងពីពិន្ទុទាប ៤៨,៦៤ (ក្នុងពិន្ទុ១០០) ទៅដល់ ៥៦,៥២ ដែលត្រូវជាកំណើន ១២,៥៤%។ សូមមើលនៅខាងក្រោមការពន្យល់លម្អិតអំពីការដាក់ពិន្ទុភាពពេញចិត្តតាមប្រភេទសេវា (តារាង ២.២)។ ដើម្បីពង្រឹងការឆ្លើយតបរបស់សេវាក្រុងទៅប្រជាពលរដ្ឋ គ.ជ.អ.ប នឹងរៀបចំ ហើយចាក់ចេញវិធីសាស្ត្រគណនេយ្យភាពសង្គមថ្មីមួយទៀត ដោយធ្វើបច្ចុប្បន្នភាពវាពីលើវិធីសាស្ត្រក្នុងពេលបច្ចុប្បន្ន ដែលបានអនុវត្តក្រោមផែនការអនុវត្តសម្រាប់គណនេយ្យភាពសង្គម (ISAF) នៅតាមឃុំ សាលារៀន មណ្ឌលសុខភាព ក៏ដូចជាបទពិសោធន៍នៃគម្រោង «លើកកម្ពស់ការចូលរួមរបស់ពលរដ្ឋ នៅក្នុងការអភិវឌ្ឍប្រជាធិបតេយ្យ» (Promoting Citizen Engagement in Democratic Development/PROCEED) ដែលអនុវត្តដោយអង្គការ PACT ដែលក្នុងនោះមាន តារាងពិន្ទុសហគមន៍ថ្នាក់ស្រុក/ក្រុង (មើលប្រអប់ ២.៤) ផងដែរ។ បន្ថែមពីលើការលើកកម្ពស់ការយល់ដឹងសាធារណៈ អំពីការផ្តល់សេវារបស់ក្រុង និងអំពីការផ្តល់មតិតបវិញអំពីការផ្តល់សេវាទាំងនោះ បណ្តាក្រុងគួរតែពិចារណាផងដែរនូវការប្រើប័ណ្ណស្រង់យោបល់របស់ពលរដ្ឋ (citizen report cards) ដែលអាចសុំពលរដ្ឋឱ្យផ្តល់មតិអំពីប្រភេទសេវាដែលបានផ្តល់នៅកម្រិតក្រុង ឬការធ្វើអធិការកិច្ចសង្គមលើអង្គភាពផ្តល់សេវានៅកម្រិតក្រុង ដូចជាអ្នកម៉ៅការប្រមូលសំរាម អ្នកម៉ៅការផ្គត់ផ្គង់ទឹកនិងថែទាំអនាម័យ មធ្យោបាយដឹកជញ្ជូនសាធារណៈ ជាដើម។ បណ្តាក្រុងអាចត្រូវបានលើកទឹកចិត្តថែមទៀតឱ្យបំពេញមុខងារបានកាន់តែប្រសើរឡើងតាមរយៈការដាក់ចេញ និងការប្រើប្រាស់សមាសភាគគុណផលការងារមួយនៃហិរញ្ញប្បទានដែលផ្តល់តាមមូលនិធិស្រុក/ក្រុង (មានរៀបរាប់លម្អិតនៅខាងក្រោម)។ កិច្ចខិតខំក្នុងពេលថ្មីៗរបស់គ.ជ.អ.ប ក្នុងការពង្រឹងប្រព័ន្ធអធិការកិច្ចលើអនុលោមភាព ជាចំណុចចាប់ផ្តើមមួយសម្រាប់ការបង្កើតប្រការលើកទឹកចិត្តក្នុងការបំពេញមុខងារដូចគ្នានឹងក្របខណ្ឌវាយតម្លៃរបស់មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ (SNIF) ដែរ។

**តារាង ២.២៖** កម្រិតភាពពេញចិត្តជាមួយការផ្តល់សេវារបស់ស្រុក/ក្រុង

| ប្រភេទសេវា | តម្លៃលេខមធ្យមភាព (២០១៣) | តម្លៃលេខមធ្យមភាព (២០១៦) | % កើនរវាង ២០១៣-២០១៦ |
|---|---|---|---|
| ការសាងសង់ផ្លូវ | ៥២,៣៩ | ៥៧,០៥ | ៨,៩០% |
| ការសាងសង់ប្រឡាយស្រោចស្រព | ៤៤,៤២ | ៥១,៩២ | ១៦,៨៧% |
| ការរៀបចំផែនការអភិវឌ្ឍន៍ | ៥៣,៥៤ | ៥៩,៨៣ | ១១,៧៥% |
| ភាពស្អាត និងអនាម័យ | ៥២,២៩ | ៥៨,៦៣ | ១២,១២% |
| ការសម្របសម្រួលដោះស្រាយវិវាទ | ៥៦,៥៥ | ៦១,២៣ | ៨,២៨% |
| ការផ្គត់ផ្គង់ទឹក | ៤៩,៩០ | ៥៩,៣២ | ១៨,៨៧% |
| ការគ្រប់គ្រងសំណល់រឹង | ៤០,៨៣ | ៥២,៧៧ | ២៩,២៦% |
| សេវាអភិវឌ្ឍន៍ធុរកិច្ច | ៣៩,២០ | ៥១,៣៩ | ៣១,១០% |

*ប្រភព៖ ការអង្កេតអភិបាលកិច្ច ២០១៦, លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ខែមិថុនា ឆ្នាំ២០១៧។*

**ប្រអប់ ២.៥៖** គម្រោងសាកល្បងប្រើតារាងសហគមន៍ដាក់ពិន្ទុក្រុមប្រឹក្សាស្រុក/ក្រុង របស់អង្គការ PACTs

តារាងពិន្ទុសហគមន៍គឺជាឧបករណ៍មួយដែលបានរៀបចំឡើងដើម្បីបង្កើនការចូលរួមរបស់ពលរដ្ឋ នៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាស្រុក/ក្រុង និងដើម្បីធ្វើអត្តសញ្ញាណផ្នែកនានាសម្រាប់កែលម្អនៅក្នុងការផ្ដល់សេវា។ អ្នកចូលរួមមានសមាជិកក្រុមប្រឹក្សាស្រុក/ក្រុង និងក្រុមប្រឹក្សាភិបាល អង្គការសហគមន៍មូលដ្ឋាន ពលរដ្ឋក្នុងមូលដ្ឋាន (ជាមធ្យម ១៥០នាក់ក្នុងមួយឃុំ ឬសង្កាត់ ហើយ ៥០%ជាស្ត្រី យុវជន និងជនងាយរងគ្រោះ) សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់។ ដ្យាក្រាមខាងលើបង្ហាញជំហានសំខាន់ៗនៅក្នុងដំណើរការបំពេញតារាងពិន្ទុ រួមមានសហគមន៍ និងក្រុមប្រឹក្សាដាក់ពិន្ទុខ្លួនឯង ការជួបប្រជុំ និងការធ្វើផែនការសកម្មភាពសម្រាប់យកទៅអនុវត្ត។




ក្រុមប្រឹក្សាដាក់ពិន្ទុវាយតម្លៃខ្លួនឯង ប្រជុំពិភាក្សាគ្នា និងផែនការសកម្មភាពសម្រាប់ការអនុវត្ត។

### ២.២.៤ ការផ្តល់ហិរញ្ញប្បទាន

ខណៈដែលស្រុកនិងក្រុងជាចំណុចដៅនៃកិច្ចខិតខំធ្វើវិមជ្ឈការមុខងារចេញពីថ្នាក់ក្រសួង រដ្ឋបាលថ្នាក់ស្រុកនិងក្រុងនៅតែទទួលបានហិរញ្ញប្បទានតិចជាងថ្នាក់ខេត្ត និងថ្នាក់ឃុំ/សង្កាត់ទៅទៀត។ ដូចបានបង្ហាញជូនរួចហើយនៅក្នុងរូបភាព ២.២ ស្រុកនិងក្រុងទើបតែនឹងចាប់ផ្តើមធ្វើប្រតិបត្តិការចំណាយ នៅក្នុងឆ្នាំ ២០១២ ទេ ហើយក្នុងពេលដែលពួកគេចាយតិចជាងឃុំនិងសង្កាត់មែន ការចំណាយទាំងនោះកើនឡើងយ៉ាងឆាប់រហ័សគួរសម នៅក្នុងអត្រាធម្មតាមួយ គឺ៤០% ក្នុងមួយឆ្នាំ។ ដូចមានបង្ហាញជូននៅក្នុងតារាង ២.៣ខាងក្រោម កញ្ចប់ចំណាយរបស់ស្រុក/ក្រុង គឺទៅលើប្រាក់ខែ និងថ្លៃចំណាយរដ្ឋបាល ធ្វើឱ្យនៅសល់ថវិកាតិចណាស់សម្រាប់ការអភិវឌ្ឍ និងការវិនិយោគផ្សេងៗ។

**រូបភាព ២.២៖** ចំណាយជាក់ស្តែងសរុប (ជាប៊ីលានរៀល) នៅថ្នាក់ក្រោមជាតិ ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៥




*ប្រភព៖ ធនាគារអភិវឌ្ឍន៍អាស៊ី (Jonathan Dunn). 2017. TA 81-59-CAM: Decentralized Public Service and Financial Management Sector Project. Draft Annual Report on Sustainable Administrative Finance. Phnom Penh.*

**តារាង ២.៣៖** ការចំណាយជាក់ស្តែងរបស់ថ្នាក់ក្រោមជាតិ តាមប្រភេទ គិតជាមធ្យមភាគ(%) រវាងឆ្នាំ២០១៤-២០១៦

| ប្រភេទចំណាយ | ឃុំ និងសង្កាត់ (%) | ស្រុក ក្រុង ខណ្ឌ (%) | ខេត្ត និង ភ្នំពេញ |
|---|---|---|---|
| បៀវត្ស និងប្រាក់ឧបត្ថម្ភ | ៤២ | ៤៥ | ៤,៧ |
| ការអភិវឌ្ឍ (ទ្រព្យមូលធន និងការថែទាំ) | ៥០,៧ | ៩,៦ | ៧៥,៤ |
| រដ្ឋបាល (ទំនិញ និងសេវា) | ៧,៣ | ៣០,៩ | ១២,២ |
| ការផ្ទេរ និងការឧបត្ថម្ភធន[៧៨] | - | ១៤,២ | ៧,៧ |
| **សរុប** | ១០០ | ១០០ | ១០០ |

*ប្រភព៖ ធនាគារអភិវឌ្ឍន៍អាស៊ី (Jonathan Dunn). 2016. TA 8159-CAM: Decentralized Public Service and Financial Management Sector Development Project. Subnational Fiscal Data Base for Cambodia. Phnom Penh.*

---

៧៨ ការផ្ទេរ និងការឧបត្ថម្ភធនត្រូវបានផ្ទេរពីថ្នាក់រដ្ឋភិបាលមួយទៅឱ្យថ្នាក់រដ្ឋបាលមួយទៀត ដូចជាការផ្ទេរពីខេត្តទៅឱ្យស្រុកក្រុង និងពីស្រុកក្រុងទៅឱ្យឃុំសង្កាត់។ ការផ្ទេរទាំងនេះត្រូវបានចាត់ទុកថាជាចំណាយសម្រាប់ថ្នាក់រដ្ឋបាលនីមួយៗដែលធ្វើការផ្ទេរហិរញ្ញប្បទាន។ ហិរញ្ញប្បទានផ្ទេររួមមានចំណូលពន្ធលម្អិតដែលហូរពីថ្នាក់ខេត្តទៅថ្នាក់ស្រុកក្រុង និងថ្នាក់ឃុំសង្កាត់។

**ហិរញ្ញប្បទានសម្រាប់ក្រុងមានប្រាំប្រភេទ៖** ការផ្ទេរគ្មានលក្ខខណ្ឌ, ចំណូលមិនជាប់ពន្ធ, ការផ្ទេរមានលក្ខខណ្ឌនិងគ្មានលក្ខខណ្ឌពីខេត្ត, ការផ្ទេរមានលក្ខខណ្ឌ, និងមូលនិធិពីដៃគូអភិវឌ្ឍន៍សម្រាប់គម្រោង។ បច្ចុប្បន្ននេះ រដ្ឋបាលថ្នាក់ក្រោមជាតិមិនអាចទៅខ្ចីបុលពីហិរញ្ញិកផ្តល់កម្ចីជាលក្ខណៈសម្បទាន ឬជាលក្ខណៈពាណិជ្ជកម្ម បានទេ ដូច្នេះ ការជាប់បំណុលហិរញ្ញប្បទានមិនមែនជាជម្រើសមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។ ភាគច្រើននៃចំណូលសម្រាប់ស្រុក និងក្រុងនៅក្រៅភ្នំពេញ មានប្រភពមកពីស្រុក និងមូលនិធិស្រុក/ក្រុង។ ក្រៅពីនេះមាន ការផ្ទេរគ្មានលក្ខខណ្ឌបន្ថែមទៀតពីរថ្នាក់ខេត្តទៅឱ្យថ្នាក់ស្រុកនិងក្រុង ដែលភាគច្រើនចេញពីចំណូលពន្ធរួម[៧៩]។ រវាង ឆ្នាំ ២០១៤ និង ២០១៦ ប្រហែល ៩៣%នៃចំណូលសរុបរបស់ស្រុកក្រុង និងខណ្ឌ បានមកពីការផ្ទេរពីថ្នាក់ជាតិ ភ្នំពេញ និងថ្នាក់ខេត្ត។ នៅពេលដែលស្រុកនិងក្រុង កាលពីពេលថ្មីៗនេះ ចាប់ផ្តើមទទួលបានប្រយោជន៍ពីកិច្ចចាត់ចែងចែករំលែកចំណូលពន្ធ ស្រុកនិងក្រុងអត់ទាន់បានទទួលការចាត់ប្រភេទប្រភពចំណូលពន្ធណាមួយសម្រាប់ខ្លួននៅឡើយទេ។ តារាង ២.៤ បង្ហាញប្រភេទនៃចំណូលដែលក្រុងនីមួយៗទទួលបាន ក្នុងអំឡុងឆ្នាំ២០១៧។ DMF មានឈ្មោះពេញថា មូលនិធិស្រុកក្រុង ហើយ CSF មានឈ្មោះពេញថា មូលនិធិឃុំសង្កាត់។ ចំណូលក្នុងមូលដ្ឋាន (LocalRev) គឺជាប្រភេទចំណូលមិនជាប់ពន្ធដែលក្រុងជាអ្នកប្រមូល។ មូលនិធិជាប់លក្ខខណ្ឌ(CondFund) សំដៅលើហិរញ្ញប្បទានជាប់លក្ខខណ្ឌសម្រាប់ការគ្រប់គ្រងសំណល់។ មូលនិធិបម្រុង (Reserved Fund) សំដៅលើអតិរេកថវិកាពីឆ្នាំមុនដែលបន្តមកដល់ឆ្នាំបច្ចុប្បន្ន។ រូបភាព ២.៣ ខាងក្រោម ពន្យល់ប្រភេទផ្សេងៗគ្នារបស់ការផ្តល់ហិរញ្ញប្បទាន និងប្រភេទមុខងារដែលត្រូវបានកំណត់សម្រាប់ធ្វើហិរញ្ញកិច្ច។

**តារាង ២.៤៖** ចំណូលរបស់ក្រុងទៅតាមប្រភេទ (២០១៧)

| ក្រុង | ចំណូលថវិកាឆ្នាំ២០១៧ | | | | | |
|---|---|---|---|---|---|---|
| | មូលនិធិ ស្រុក/ក្រុង | ចំណូល ក្នុងមូលដ្ឋាន | មូលនិធិជាប់ លក្ខខណ្ឌ (គ្រប់គ្រងសំណល់) | មូលនិធិ ឃុំ/សង្កាត់ | មូលនិធិបម្រុង (អតិរេកថវិកាពីឆ្នាំមុន) | សរុប |
| ស៊ីរីសោភ័ណ | ៧៦៤,៧៣ | ៤០៣,៣១ | ៣៩៨ | ១៦៩១,៤៨ | ១៨០,៩៦ | ៣៣៨៤,៤៨ |
| ប៉ោយប៉ែត | ៧៧៩,៩០ | ១០១៣,១ | ៤០២ | ១០៧០,៤៥ | - | ៣២៦៥,៤៥ |
| បាត់ដំបង | ១០១១,៨២ | ៤៥៦,៣៣ | ៥៧០ | ២៥៣០,៧១ | ១៩,៨៥ | ៤៥៨៨,៧១ |
| កំពង់ចាម | ៦២៣,៩៤ | ១៥០,០៦ | ២៦១ | ៩៦១,៦៧ | - | ១៩៩៦,៦៧ |
| កំពង់ឆ្នាំង | ៦១២,៧២ | ៥៥,៨៩ | ២៦៧ | ៨៥៨,៦៨ | ១០,៣៩ | ១៨០៤,៦៨ |
| ច្បារមន | ៦៨៥,២១ | ១២៣,៣១ | ២៨៧ | ១ ២៥៧,២៥ | ២៧,៤៨ | ២៣៨០,២៥ |
| ស្ទឹងសែន | ៨៩៤,៧៨ | ៧០,២២ | ៣១០ | ១៩៦៣,៤៧ | - | ២៧៣៨,៤៧ |
| កំពត | ៦២៧,៥១ | ១៩២,២៤ | ២៥៣ | ៨៦៧,៤៤ | ១៩,២៥ | ១៩០៩,៤៤ |
| តាខ្មៅ | ៧១៥,០៨ | ១៣២,៩២ | ២៥៩ | ១ ៣៣៥,៥៦ | - | ២៥៤២,៥៦ |
| ខេមរភូមិន្ទ | ៦៥៦,៦៤ | ១៧៥,៣៦ | ២៣០ | ៥៩៩,២៨ | - | ១៦៦១,២៨ |
| ក្រចេះ | ៦១៤,៧៧ | ៩៦,២៣ | ២៣៨ | ៨៤៤ | - | ១៧៩៣ |
| សែនមនោរម្យ | ៥៣៥,៥៨ | ៦០,២៤ | ១៩៤ | ៦០៩,១៨ | - | ១៣៩៩,១៨ |
| ព្រះវិហារ | ៤៩៦,៨៦ | ៦៥,១៤ | ២១៤ | ៥២៣,៩៧ | - | ១២៩៩,៩៧ |

៧៩ ការផ្ទេរចំណូលពន្ធរួមទាំងនេះអនុលោមតាម ប្រកាសស្តីពីចំណូលពន្ធរួមរវាងរដ្ឋបាលរាជធានី/ខេត្ត ជាមួយរដ្ឋបាលស្រុក/ក្រុង/ខណ្ឌ និងរដ្ឋបាលឃុំ/សង្កាត់ ដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាលពីខែធ្នូ ឆ្នាំ២០១៧។

| | | | | | | |
|---|---|---|---|---|---|---|
| ព្រៃវែង | ៥៨០,៤៩ | ៧០,៧ | ២២៤ | ៥៨៦,៣៧ | ១៤,៨១ | ១៤៧៦,៣៧ |
| ពោធិសាត់ | ៨១១,៩០ | ១៥០,១ | ៣៣២ | ១៦៣៤,៣៥ | - | ២៩២៨,៣៥ |
| បានលុង | ៦៣៤,៧៦ | ៩៤,២៤ | ២៣៩ | ៧៨៩,២៤ | - | ១៧៥៧,២៤ |
| សៀមរាប | ១១៣៤,១១ | ១ ០០០,៨៩ | ៧៧០ | ៣៣០០,៦៣ | - | ៦ ២០៥,៦៣ |
| ព្រះសីហនុ | ៧៧៥,១៣ | ២៦០,៥៨ | ៣៦៤ | ១១៤០,៧៥ | ៦៩,២៩ | ២៦០៩,៧៥ |
| ស្ទឹងត្រែង | ៦០៨,៨០ | ៦៦,៧៨ | ២៣៧ | ៧៣៧,៤៩ | ៣៤,៤២ | ១៦៨៤,៤៩ |
| ស្វាយរៀង | ៧៣៨,៦៦ | ១០០,២៦ | ២៧៨ | ១៣៤៥,៨៥ | ៥៥,០៨ | ២៥១៧,៨៥ |
| បារិត | ៦៥៤,៤៧ | ១៤០,៤១ | ២៦០ | ៩៨៧,៦០ | ២៧,១២ | ២០៦៩,៦០ |
| ដូនកែវ | ៦៨០,៧១ | ១០០,០៨ | ២៧១ | ៩០២,៥០ | ៣០,២១ | ១៩៨៤,៥០ |
| សំរោង | ៦៦២,៥៧ | ៥៥,៧៥ | ៣៣០ | ១៤៦៨,៣៣ | ៦,៦៨ | ២៥២៣,៣៣ |
| កែប | ៥៣៦,០៤ | ៤០,៩៨ | ២០៩ | ៤៨២,៥៩ | ៦,៩៨ | ១២៧៥,៥៩ |
| ប៉ៃលិន | ៦១៥,២៨ | ៩០,៧២ | ២៤៥ | ៩៣២,១៨ | ០ | ១៨៨៣,១៨ |
| ស្ទួង | ៥៧១,៩៣ | ១០០,០៧ | ២៥៨ | ៦៥៨,៦៨ | ២ | ១៥៩០,៦៨ |
| សរុប (លានរៀល) | ១៨០២៤,៣៩ | ៥២១៦,០៩ | ៨០០០ | ២៩៥២៩,៧០ | ៥០៤,៥២ | ៦១២៧៤,៧០ |
| សរុប (លានដុល្លារអាមេរិក) | ៤,៤៥ | ១,២៩ | ១,៩៨ | ៧,២៩ | ០,១២ | ១៥,១៣ |
| % | ២៩,៤២% | ៨,៥១% | ១៣,០៦% | ៤៨,១៩% | ០,៨២% | ១០០% |

*ប្រភព៖ ទិន្នន័យទទួលបានពីគ.ជ.អ.ប យោងតាមថវិកាជាតិឆ្នាំ ២០១៧*

**រូបភាព ២.៣៖** ទំនាក់ទំនងរវាងប្រភេទនៃការផ្តល់មូលនិធិ និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ




*ប្រភព៖ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ៖ សេចក្តីថ្លែងការណ៍គោលនយោបាយជាគោលការណ៍ណែនាំសម្រាប់ភាគីទាំងអស់ សម្រាប់វគ្គពាក់កណ្តាលទី២ នៃកម្មវិធីជាតិ ១០ឆ្នាំ - ឆ្នាំ២០១៧។*

ការផ្ទេរគ្មានលក្ខខណ្ឌពីរដ្ឋាភិបាលថ្នាក់ជាតិមានចំណូលក្រុងមួយភាគធំ ដែលជាចម្បងចេញមកពីមូលនិធិស្រុក-ក្រុង។ តាំងតែពីមូលនិធិស្រុក-ក្រុង (មានមូលនិធិសម្រាប់ទាំងក្រុង ទាំងស្រុក) ត្រូវបានបង្កើត ធនធានរបស់មូលនិធិនេះបានកើនទាំងក្នុងន័យចំនួនដាច់ខាត (ពី ១៤,៤លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៤ ដល់ ៣៣,៤លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧) និងទាំងក្នុងន័យជាភាគរយធៀបទៅនឹងចំណូលចរន្តរបស់ឆ្នាំមុនៗ (ពី ០,៨% ទៅ ១%)។ អនុក្រឹត្យមួយដែលត្រូវបានចុះហត្ថលេខានៅខែមេសា ឆ្នាំ ២០១៨ កន្លងទៅថ្មីៗនេះ ស្តីពី «ការផ្ទេរធនធានពីថវិកាជាតិទៅឱ្យមូលនិធិស្រុក-ក្រុង» បានកំណត់កាតព្វកិច្ចរដ្ឋាភិបាលឱ្យដំឡើងភាគរយដែលត្រូវបានរំលែកទៅឱ្យមូលនិធិស្រុក-ក្រុង ពី ១% នៃចំណូលប្រចាំ ទៅដល់ ១,៦% នៅឆ្នាំ២០២៤។ ខាងក្រោម តារាង ២.៥ ជាការប៉ាន់ទុកនៃការដំឡើងចំនួនថវិកាក្នុងមូលនិធិស្រុក-ក្រុង រហូតដល់ឆ្នាំ២០២៤ ផ្អែកលើកំណើនដែលបានកំណត់រួចហើយនៅក្នុងអនុក្រឹត្យស្តីពីការផ្ទេរទៅឱ្យមូលនិធិស្រុក-ក្រុង។ ក្នុងរយៈពេលបីឆ្នាំខាងមុខ ចំនួនសរុបដែលនឹងមាននឹងកើនជិតទ្វេដង សម្រាប់យកទៅដំឡើងចំនួនផ្ទេរទៅឱ្យមូលនិធីស្រុក/ក្រុង។ ប៉ុន្តែ ភាគច្រើននៃមូលនិធិទាំងនេះនៅតែទំនងជាត្រូវបានគេបង្វែរចេញពីចំណាយលើបៀវត្ស និងលើផ្នែករដ្ឋបាល។ គោលដៅរបស់ផែនការ «ផអ៣ទី៣» គឺដើម្បីបង្កើនសមាសភាគអភិវឌ្ឍន៍របស់មូលនិធិស្រុក-ក្រុង ជាភាគរយនៃចំណូលប្រចាំ (និងជាភាគរយនៃចំណាយរបស់មូលនិធិស្រុក-ក្រុងជារួម) ពីកម្រិតបច្ចុប្បន្នដែលមានតិចជាង ០,៣% ឱ្យទៅដល់ ០,៥% ក្នុងឆ្នាំ២០២០។ យ៉ាងណាក្តី គ្រោងការនេះបានជួបការលំបាកដោយសារតែមានការដំឡើងប្រាក់បៀវត្សរបស់បុគ្គលិករាជការ និងភាគរយនឹងថ្កល់ (ថេរ)មួយដែលត្រូវបានកំណត់រួចមកហើយសម្រាប់ចំណាយផ្នែករដ្ឋបាល យោងទៅលើចំណាយលើបៀវត្ស។

**តារាង ២.៥៖** ការប៉ាន់ទុកជាមុននូវតម្រូវការមូលនិធិសម្រាប់ស្រុក/ក្រុង ឆ្នាំ២០១៨-២០២៤

**ការប៉ាន់ទុកជាមុននូវតម្រូវការមូលនិធិសម្រាប់ស្រុក/ក្រុង (២០១៨-២០២៤)**

ឯកតា៖ លាន

| ឆ្នាំ | ចំណូលក្នុងស្រុកប៉ាន់ស្មាន | % | ចំនួន (រៀល) | ចំនួន (USD) |
|---|---|---|---|---|
| ២០១៨ | ១៧៤៦០០០៦ | ១% | ១៥៥០១៥ | ៣៨,២៨ |
| ២០១៩ | ១៩៩០៤៤០៧ | ១,១% | ១៩២០៦០ | ៤៧,៤២ |
| ២០២០ | ២២៦៩១០២៤ | ១,២% | ២៣៨៨៥៣ | ៥៨,៩៨ |
| ២០២១ | ២៥៨៦៧៧៦៧ | ១,៣% | ២៩៤៩៨៣ | ៧២,៨៤ |
| ២០២២ | ២៩៤៨៩២៥៥ | ១,៤% | ៣៦២១៤៩ | ៨៩,៤២ |
| ២០២៣ | ៣៣៦១៧៧៥០ | ១,៥% | ៤៤២៣៣៩ | ១០៩,២២ |
| ២០២៤ | ៣៨៣២៤២៣៥ | ១,៦% | ៥៣៧៨៨៤ | ១៣២,៨១ |

*ប្រភព៖ តួលេខប៉ាន់ស្មានផ្តល់ដោយ គ.ជ.អ.ប ដោយយោងតាមប្រកាសឆ្នាំ២០១៨ និងថវិកាជាតិ ២០១៧។*

ស្រុក និងក្រុង អត់មានប្រភពចំណូលពន្ធឬចំណូលមិនមែនពន្ធណាមួយដែលត្រូវបានរដ្ឋាភិបាលចាត់តាំងឱ្យសម្រាប់ខ្លួនទេ យ៉ាងណាក៏ដោយ ចាប់ពីឆ្នាំ២០១៧មក ក្រុង ខណ្ឌ និងសង្កាត់មួយចំនួននឹងរំលែកមួយចំណែកនៃចំណូលពន្ធអចលនទ្រព្យទៅឱ្យស្រុក-ក្រុងផ្សេងទៀត។ ចំណូលពន្ធដារនិងចំណូលមិនមែនពន្ធដារទាំងអស់ត្រូវបានអគ្គនាយកដ្ឋានពន្ធដារ និងចំណូលមិនមែនពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកប្រមូល។

មកទល់ពេលនេះ មានឧទាហរណ៍តែមួយករណីទេស្តីពីការផ្តល់សម្បទានថវិកាមានលក្ខខណ្ឌ ដែលអមជាមួយនឹងមុខងារដែលត្រូវបានផ្ទេរចេញពីថ្នាក់ជាតិ ទៅថ្នាក់ស្រុក/ក្រុង គឺមុខងារគ្រប់គ្រងសំណល់រឹង។ ប្រកាសអន្តរក្រសួងឆ្នាំ២០១៥មួយត្រូវបានចុះហត្ថលេខាស្តីពីការប្រើមូលនិធិសេវាបរិស្ថាន ដោយមានចំនួនបឋម ៥លានដុល្លារអាមេរិក បែងចែកទៅឱ្យក្រុងទាំង ២៦ នៅទូទាំងប្រទេស ដែលក្នុងនោះចំនួនទឹកប្រាក់បឋមសម្រាប់ក្រុងនីមួយៗមានពី ៩៥០០០ដុល្លារអាមេរិក ទៅ ៩០០០០ដុល្លារអាមេរិក អាស្រ័យទៅតាមចំនួនប្រជាជនរបស់ក្រុងនីមួយៗ។ ក្នុងឆ្នាំ២០១៧ ក្រុងនីមួយៗបានចាប់ផ្តើមទទួលហិរញ្ញប្បទាន ២០០០ដុល្លារអាមេរិកក្នុងមួយឆ្នាំ ដើម្បីផ្គត់ផ្គង់ចំណាយផ្នែករដ្ឋបាលនៅក្នុងការអនុវត្តមុខងារថ្មីមួយនេះ។ យ៉ាងណាក៏ដោយ បើទោះជាមុខងារ

ផ្លូវការបានផ្ទេរទៅឱ្យថ្នាក់ស្រុក/ក្រុងរួចហើយក្តី ក៏មូលនិធិនិងការទទួលខុសត្រូវគ្រប់គ្រងកិច្ចសន្យាត្រូវបានរក្សាទុកនៅឯថ្នាក់ខេត្តនៅឡើយ ដូច្នេះបានន័យថា អំណាចថ្មីដែលត្រូវបានផ្ទេរទៅឱ្យស្រុក/ក្រុងនេះមិនទាន់ចូលជាធរមានពេញលេញនៅឡើយទេ។ ថ្នាក់ដឹកនាំក្រុងក៏មានចំណេះដឹងនៅមានកម្រិតនៅឡើយដែរ អំពីការថាតើត្រូវគ្រប់គ្រងសេវានេះដោយរបៀបណា រួមទាំងភាពចាំបាច់លើកកម្ពស់ការយល់ដឹងអំពីសំណល់ ការប្រមូលសំណល់ ការកែច្នៃសំណល់ ការគ្រប់គ្រងទីលានចាក់សំរាម និងប្រតិបត្តិការរបស់ទីលានផង។ (សូមមើលផ្នែកទី ១ សំណល់រឹង)។

មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ (SNIF) ក៏ជាយន្តការផ្ទេរមានលក្ខខណ្ឌមួយដែរ ប៉ុន្តែថវិកាក្នុងមូលនិធិនេះអាចយកទៅប្រើបានតែលើមូលដ្ឋានប្រកួតប្រជែងប៉ុណ្ណោះ សម្រាប់ប៉ុន្មានឆ្នាំដំបូងនៃការអនុវត្តដែលនឹងចាប់ផ្តើមក្នុងឆ្នាំ២០១៨។ SNIF តំណាងឱ្យប្រភពដ៏សំខាន់បំផុតនៃការធ្វើហិរញ្ញប្បទានការអភិវឌ្ឍឬការវិនិយោគសម្រាប់ក្រុង ដែលកញ្ចប់ថវិកាមានជាមធ្យមពី ២៥០០០ដុល្លារអាមេរិក ទៅ ៦០០០០ដុល្លារអាមេរិក ក្នុងមួយឆ្នាំ។ ក្នុងឆ្នាំ២០១៧ ការពិនិត្យឡើងវិញ លើសមត្ថភាពរបស់ស្រុក/ក្រុងចំនួន៤៩ត្រូវបានធ្វើ ហើយជាលទ្ធផលស្រុក/ក្រុងចំនួន១៩ទទួលបានការយល់ព្រមរបស់ក្រុមប្រឹក្សានាយករបស់ SNIF សម្រាប់ការទទួលយកហិរញ្ញប្បទានវិនិយោគនៅក្នុងឆ្នាំ២០១៨។ សមត្ថភាពស្រុក/ក្រុងត្រូវស្ថិតចំណុះក្រោមការត្រួតពិនិត្យរៀងរាល់ឆ្នាំ ដើម្បីវាយតម្លៃកម្រិតអនុលោមភាពរបស់ស្រុក/ក្រុងជាមួយសំណុំលក្ខខណ្ឌភាពពេញសិទ្ធិដែលបានឯកភាពគ្នារួចហើយ សម្រាប់ទទួលបានលទ្ធភាពប្រើប្រាស់ហិរញ្ញប្បទានរបស់ SNIF ។ លក្ខខណ្ឌទាំងនេះមានចែងនៅក្នុងតម្រូវការផ្នែកច្បាប់និងបទបញ្ញត្តិធំៗដែលស្រុក/ក្រុងអាចបានដឹងរួចទៅហើយសម្រាប់ធ្វើការអនុលោមតាម។

ក្រៅពីមូលនិធិដែលមានតាមរយៈប្រព័ន្ធហិរញ្ញវត្ថុអន្តរក្រសួងរដ្ឋបាល ស្រុក/ក្រុងក៏អាចទទួលដែរនូវមូលនិធិពីគម្រោងវិនិយោគជាក់លាក់របស់រដ្ឋាភិបាល រួមទាំងគម្រោងដែលទទួលការឧបត្ថម្ភហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍អន្តរជាតិផង។ ធនធានទាំងនោះត្រូវបានផ្តល់លើមូលដ្ឋានអំណោយសម្បទានតែប៉ុណ្ណោះ ដែលធម្មតាមានជាទៀងទាត់ ហើយមិនអាចបញ្ចូលកិច្ចព្រមព្រៀងខ្ចីបុលផ្ទាល់ ឬកិច្ចព្រមព្រៀងឧបត្ថម្ភធនណាមួយទៅក្នុងនោះបានទេ ដើម្បីខ្ចីប្រាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ពីមុនមកមូលនិធិត្រូវបានផ្តល់ទៅឱ្យគណនីឃុំ/សង្កាត់ សម្រាប់គោលបំណងប្រើប្រាស់ជាក់លាក់ (ដូចជា វិនិយោគបង្កើនភាពធនទៅនឹងការប្រែប្រួលអាកាសធាតុ និងវិនិយោគសង្គម ជាដើម) ហើយវិធីនេះអាចធ្វើជាគំរូសម្រាប់ការធ្វើហិរញ្ញប្បទានផ្ទាល់ទៅឱ្យស្រុក/ក្រុងបាន នៅពេលណាដែលស្រុក/ក្រុងកសាងបានសមត្ថភាពរបស់ខ្លួនដើម្បីអាចចាត់ចែងគ្រប់គ្រងការផ្តល់ហិរញ្ញប្បទានអភិវឌ្ឍន៍កាន់តែធំៗ និងអនុវត្តសកម្មភាពអភិវឌ្ឍន៍ក្រោមហិរញ្ញប្បទាននោះ។

លើកលែងមូលនិធិ SNIF និងគម្រោងដែលទ្រទ្រង់ដោយហិរញ្ញវត្ថុស្រុក/ក្រុងដែលមានក្រសួងថ្នាក់ជាតិជាអ្នកគ្រប់គ្រង ក្រុងនៅមានការខ្វះខាតហិញ្ញប្បទានច្រើនទៀត ដែលចាំបាច់សម្រាប់វិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធក្នុងទីប្រជុំជន មានដូចជាមធ្យោបាយដឹកជញ្ជូន ការគ្រប់គ្រងសំណល់ ផ្លូវ ទឹក និងប្រព័ន្ធលូទឹក ជាដើម។ សូម្បីតែទំហំសម្បទានថវិការបស់មូលនិធិ SNIF ក៏នៅតែមិនទាន់គ្រប់ដែរសម្រាប់ការវិនិយោគធំៗថែមទៀត ជាពិសេសសម្រាប់ក្រុងលំដាប់ទីពីរធំៗ។ ការធ្វើហិរញ្ញប្បទានដោយផ្នែកឯកជន និងការវិភាជន៍ថវិកាជាតិក៏អាចយកទៅប្រើបានដែរសម្រាប់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជាដុំកំភួន ប៉ុន្តែដោយសារការវិនិយោគភាគច្រើនទាំងនេះមានក្រសួងថ្នាក់ជាតិជាអ្នកគ្រប់គ្រងចាត់ចែង តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិច្រើនតែមានកម្រិត រួមទាំងលទ្ធភាពក្នុងការស៊កបញ្ចូលកម្មវិធីវិនិយោគទាំងនោះទៅក្នុងផែនការអភិវឌ្ឍន៍ដែនដីនិងទីប្រជុំជនផង ដែលរដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវប្រើដើម្បីធានាយ៉ាងណាឱ្យក្រុងរបស់ខ្លួនមានការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព។

ដោយសារតែធនធានរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នៅមានកម្រិត ផ្នែកឯកជន ជាពិសេសក្រុមហ៊ុនឯកជនក្នុងស្រុក ក៏អាចដើរតួជាដៃគូមានសក្តានុពលដែរសម្រាប់ក្រុង នៅក្នុងកិច្ចប្រឹងប្រែងឆ្លើយតបទៅនឹងតម្រូវការហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ។ ផ្នែកឯកជនមានភាពសកម្មគួរសមដែរនៅទីក្រុងភ្នំពេញ បើប្រៀបជាមួយក្រុងតូចៗដទៃទៀត (ឧ. ផ្លូវវាងស្រេងដែលពីមុនមានការបង់ថ្លៃសេវាឆ្លងកាត់ និងស្ពានលីយ៉ុងផាត់ភ្ជាប់ផ្លូវជាតិលេខ៥និងលេខ៦)។ ក្នុងដំណើរឆ្ពោះទៅមុខ នៅមានកាលានុវត្តភាពច្រើនទៀតសម្រាប់ធ្វើការសម្របសម្រួលជាមួយផ្នែកឯកជន ដើម្បីធានាយ៉ាងណាឱ្យគម្រោងវិនិយោគណាក៏ដោយត្រូវតែភ្ជាប់ជាមួយ ឬអនុលោមតាមផែនការរៀបចំក្រុង ហើយផែនការនោះក៏ត្រូវយកការវិនិយោគរបស់ផ្នែកឯកជនទៅគិតគូរពិចារណាផងដែរ។ ធ្វើដូច្នេះនឹងជួយធានាឱ្យទទួលបានអត្ថប្រយោជន៍ដែលអាចកើតមានពីភាពជាដៃគូរវាងផ្នែកសាធារណៈនិងឯកជន សម្រាប់ការវិនិយោគ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធក្រុង។

## ២.៣ ការធ្វើផែនការប្រើប្រាស់ដីធ្លីឱ្យមានចីរភាពសម្រាប់ការរីកចម្រើនទីក្រុងមានប្រសិទ្ធផល

### ២.៣.១ សេចក្តីផ្តើម

ជារួម ប្រទេសកម្ពុជានៅមានកិច្ចការច្រើនទៀតដែលត្រូវធ្វើក្នុងផ្នែកនគរូបនីយកម្ម។ កង្វះផែនការរៀបចំក្រុងមានលក្ខណៈគ្រប់ជ្រុងជ្រោយមួយ ធ្វើឱ្យបណ្តាទីក្រុងគ្មានលទ្ធភាពរត់ឱ្យទាន់ល្បឿននៃការពង្រីកមាឌរបស់ទីប្រជុំជនទេ ដែលជាលទ្ធផលធ្វើឱ្យក្រុងលាតសន្ធឹងខ្វះសណ្តាប់ធ្នាប់ កាន់តែកកស្ទះ និងផ្តល់សេវាក្រុងជាមូលដ្ឋានមិនបានល្អ។ ជំពូកនេះពិនិត្យមើលឧបសគ្គជាមូលដ្ឋានដល់ការអភិវឌ្ឍ និងការអនុវត្តផែនការប្រើប្រាស់ដីធ្លីនៅតាមតំបន់ក្រុងលំដាប់ទីពីរ ពិសេសបញ្ហាសមត្ថភាពបច្ចេកទេសទាប កង្វះការផ្តល់ហិរញ្ញប្បទាន ការសម្រេចថ្នាក់ជាតិទល់នឹងការសម្រេចថ្នាក់ក្រុង និងអវត្តមានរបស់បរិស្ថាននិយតកម្មខ្លាំងក្លាស្វាហាប់មួយ។ ករណីសិក្សាជាច្រើននៃការរៀបចំផែនការក្រុងនៅក្រុងបាត់ដំបង - ដែលជាទូទៅត្រូវបានគេចាត់ទុកថា ជាការអនុវត្តដ៏ប្រសើរជាងគេនៅក្នុងប្រទេសកម្ពុជា - និងការរីកចម្រើនយ៉ាងឆាប់រហ័សនៃទីក្រុងតំបន់ឆ្នេរក្រុងព្រះសីហនុ កាន់តែធ្វើឱ្យគេមើលឃើញបានកាន់តែជ្រៅទៅលើកត្តានានាដែលជះផលប៉ះពាល់ទៅលើដំណើរការនគរូបនីយកម្ម។ របាយការណ៍អមមួយទៀតរបស់ធនាគារពិភពលោកដែលមានចំណងជើងថា Urban Development in Phnom Penh (2017) ពិភាក្សាបញ្ហាជាក់លាក់ជាច្រើនដែលទាក់ទិនទៅនឹងការងារនគរូបនីយកម្មនៅទីក្រុងភ្នំពេញ។

### ២.៣.២ ប្រព័ន្ធរៀបចំផែនការជាតិ

មានប្លង់ធំពីរប្រភេទដែលត្រូវបានក្រុងរៀបចំឡើង - ប្លង់រូបវន្ត/ប្លង់ភូមិសាស្ត្រ (physical/spatial plans) និងផែនការការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ ក្រោមការណែនាំនិងត្រួតពិនិត្យរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គោលបំណងនៃប្លង់ភូមិសាស្ត្រ គឺធ្វើការសម្របសម្រួលគោលនយោបាយ និងសកម្មភាពនានាដែលមានផលប៉ះពាល់ទៅលើការរៀបចំភូមិសាស្ត្រ (spatial organization) របស់ក្រុង។ នៅក្នុងដំណើការដោយឡែកមួយទៀត ដែលស្ថិតក្រោមការដឹកនាំនិងត្រួតពិនិត្យរបស់ក្រសួងផែនការ ដោយមានការសម្របសម្រួលជាមួយក្រសួងមហាផ្ទៃ ផែនការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកំណត់អត្តសញ្ញាណបញ្ហាប្រឈមមួយចំនួនចំពោះការអភិវឌ្ឍនៅកម្រិតក្រុង ផ្អែកលើព័ត៌មានធាតុចូលតាមលំដាប់ពីក្រោមឡើងលើ ដែលពលរដ្ឋនិងក្រុមប្រឹក្សាឃុំបានផ្តល់ និងផ្អែកលើការណែនាំពីលើចុះក្រោម ពីគោលនយោបាយនិងអាទិភាពពីថ្នាក់ជាតិ និងថ្នាក់ខេត្ត។ ផែនការទាំងនេះដាក់អាទិភាពទៅលើសកម្មភាពដែលក្រុងអាចធ្វើបានក្នុងតួនាទីជាថ្នាក់ដឹកនាំ នៅក្នុងការអនុវត្តរួមគ្នាជាមួយដៃគូ និងអ្នកផ្តល់ហិរញ្ញប្បទានផ្សេងៗ (រួមទាំងមូលនិធិអភិវឌ្ឍន៍មានកម្រិតរបស់ខ្លួនផង)។ អ្វីដែលសំខាន់នោះ គឺឥតមានការធ្វើសមាហរណកម្មផែនការរៀបចំភូមិសាស្ត្រ និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមចូលគ្នាទេ។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលត្រូវបានអនុវត្តតាមរយៈច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ឆ្នាំ២០០៨ ផ្តល់អំណាចខេត្ត ស្រុក ខណ្ឌ និងក្រុង ឱ្យធ្វើផែនការនិងថវិការៀបចំក្រុង និងត្រួតពិនិត្យលើការផ្តល់សេវាសាធារណៈនៅក្នុងដែនយុត្តាធិការរៀងៗខ្លួន[៨០]។ ស្របគ្នានេះដែរ គោលនយោបាយជាតិស្តីពីការរៀបចំប្លង់ភូមិសាស្ត្រ (២០១៣) (National Policy on Spatial Planning - 2013) បញ្ជាក់ប្រាប់អំពីឋានានុក្រមរបស់ផែនការភូមិសាស្ត្រ ពីផែនការយុទ្ធសាស្ត្រនៅថ្នាក់ជាតិ - និងតំបន់ - រហូតដល់ទៅដល់ថ្នាក់ក្រោម រួមទាំងផែនការប្រើប្រាស់ដីធ្លីលម្អិតនៅថ្នាក់ឃុំ-សង្កាត់ ទៀតផង។ នៅថ្នាក់ជាតិ ផែនការថ្នាក់ជាតិ/តំបន់មួយនឹងត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការជាតិសម្រាប់រៀបចំដែនដី និងនគរូបនីយកម្ម (National Committee for Land Management, Urban Panning/NCLMUP) ក្នុងទស្សនវិស័យពេលវេលា២០ឆ្នាំទៅមុខ។ គណៈកម្មាធិការជាតិនេះមានសមាសភាពមកពី ២២ក្រសួង ដោយមានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន។ ផែនការនេះនឹងត្រូវធ្វើបច្ចុប្បន្នភាព ១០ឆ្នាំម្តង។ ក្របខណ្ឌយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុង (National Urban Development Strategy (NUDS) Framework) ក៏កំពុងស្ថិតក្នុងរៀបចំឡើងដែរ ក្នុងគោលដៅធ្វើជាមគ្គុទេសក៍សម្រាប់ការ

៨០ Ministry of Land Management, Urban Planning and Construction. 2016. Introduction to the Cambodian Spatial Planning System. Spatial Planning Series No. 1. https://orbi.uliege.be/bitstream/2268/199639/1/MLMUPC_2016_Introduction-Spatial-Planning-Handbook_ENG_Lowres.pdf

តាក់តែងឡើងនូវយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍទីក្រុង (NUDS) ពេញរូបពេញរាងមួយ ដែលនឹងផ្តោតការយកចិត្តទុកដាក់ជាក់លាក់ទៅលើតម្រូវការនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេដ្ឋកិច្ចទីក្រុង តាមរយៈឧស្សាហភាវូបនីយកម្ម និងទំនើបភាវូបនីយកម្ម ជាកត្តាគន្លឹះក្នុងការទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ។

**រូបភាព ២.៤៖** ឋានានុក្រមរបស់ផែនការភូមិសាស្ត្រនៅកម្ពុជា




*ប្រភព៖ គោលនយោបាយជាតិស្តីពីការរៀបចំប្លង់ភូមិសាស្ត្រ(២០១៣)*

គណៈកម្មាធិការរាជធានី/ខេត្តសម្រាប់រៀបចំដែនដី និងនគរូបនីយកម្ម តាមគោលគំនិត ត្រូវរៀបចំផែនការកម្រិតរាជធានី/ខេត្តក្នុង ៥ឆ្នាំម្តង ប៉ុន្តែ លើកលែងតែទីក្រុងភ្នំពេញចេញ គ្មានផែនការណាមួយត្រូវបានរៀបចំឡើងនៅឡើយទេ នៅថ្នាក់ខេត្ត។ ផែនការថ្នាក់ក្រុង/ស្រុក/ខណ្ឌ ដែលគេច្រើនហៅថា ប្លង់ប្រើប្រាស់ដីធ្លី/ប្លង់គោលប្រើប្រាស់ដីធ្លី (Land Use Plan/Land Use Master Plan) មានទស្សនវិស័យពេលវេលា១៥ឆ្នាំទៅមុខ ដោយមានការគ្រោងធ្វើបច្ចុប្បន្នភាព៥ឆ្នាំម្តង ហើយមានគោលដៅផ្តល់ការតម្រង់ទិសសម្រាប់ការបង្កើតផែនការលម្អិតៗថែមទៀត។ ភាគច្រើននៃក្រុងទាំង ២៦ បានធ្វើសេចក្តីព្រាង និងពិគ្រោះយោបល់ជាមួយផែនការរបស់គេរៀងៗខ្លួន។ មានតែប្លង់គោលរបស់ក្រុងបាត់ដំបងទេដែលទទួលបានការអនុម័តពីរដ្ឋាភិបាលថ្នាក់ជាតិរួចហើយ បន្ទាប់ពីចំណាយពេលរៀបចំអស់ជាច្រើនឆ្នាំក្រោមជំនួយបច្ចេកទេសមកពីបរទេស ដូចមានពិពណ៌នាឲ្យលម្អិតនោះក្នុងផ្នែក ១.៦.៣ និង ១.៦.៤។ នៅលំដាប់ទាបបំផុតនៃការធ្វើផែនការភូមិសាស្ត្រ ផែនការប្រើប្រាស់ដីធ្លីឃុំ/សង្កាត់ ក៏តម្រូវឱ្យមានការគ្រប់គ្រងការប្រើប្រាស់ដីនិងធនធានធម្មជាតិនៅក្នុងរង្វង់ដែនសមត្ថកិច្ចនីមួយៗ ហើយបន្សុីខ្លួនទៅនឹងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ផងដែរ។ បច្ចុប្បន្ននេះ ឥតមានកំណត់ត្រាណាមួយអាចបញ្ជាក់បានអំពីចំនួនផែនការភូមិសាស្ត្រថ្នាក់ឃុំ-សង្កាត់ដែលត្រូវបានរៀបចំរួចហើយទេ។ តារាង ២.៦ សង្ខេបស្ថានភាពការរៀបចំប្លង់ភូមិសាស្ត្រនៅកម្រិតផ្សេងៗគ្នារបស់រដ្ឋាភិបាល។

**តារាង ២.៦៖** ស្ថានភាពនៃការរៀបចំប្លង់ភូមិសាស្ត្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

| ប្រភេទផែនការ | ផែនការភូមិសាស្ត្រ | ស្ថានភាព |
|---|---|---|
| **ថ្នាក់ជាតិ** | គោលនយោបាយជាតិស្តីពីការរៀបចំប្លង់ភូមិសាស្ត្រ | អនុម័តឆ្នាំ២០១៣ |
| | ប្លង់ភូមិសាស្ត្រជាតិ | មិនទាន់មាន |
| **ថ្នាក់តំបន់ទូទៅ** | ប្លង់ភូមិសាស្ត្រតំបន់ | ឧទាហរណ៍តែមួយដែលមានមកទល់ពេលនេះគឺសារាចរស្តីពីការគ្រប់គ្រងតំបន់ឆ្នេរកម្ពុជា (កុម្ភៈ ២០១២) |
| **ថ្នាក់រាជធានី/ខេត្ត** | ការធ្វើប្លង់ប្រើប្រាស់ដីធ្លី និងប្លង់គោលរបស់រាជធានី | ផែនការយុទ្ធសាស្ត្រតម្រង់ទិសរបស់រាជធានីភ្នំពេញ ២០៣៥ ទទួលបានការយល់ព្រមជាគោលការណ៍នៅខែធ្នូ ឆ្នាំ២០១៥ ជាមួយនឹងទស្សនវិស័យ ១៥ឆ្នាំទៅមុខ។ |
| | ប្លង់ភូមិសាស្ត្រខេត្ត | ប្លង់ប្រើប្រាស់ដីធ្លីរបស់ខេត្តមួយចំនួនកំពុងត្រូវបានរៀបចំឡើង ស្របគ្នាជាមួយនឹងប្លង់ប្រើប្រាស់ដីស្រុក-ក្រុង។ សេចក្តីព្រាងកំពុងត្រូវបានធ្វើសម្រាប់ផែនការភូមិសាស្ត្រខេត្ត និងផែនការគ្រប់គ្រងតំបន់ឆ្នេរ ចំនួន ៦។ |
| **ថ្នាក់ក្រុង/ស្រុក/ខណ្ឌ** | ប្លង់ប្រើប្រាស់ដីធ្លីក្នុងទីក្រុង | មកទល់ពេលនេះ មានតែប្លង់ប្រើប្រាស់ដីធ្លីក្រុងបាត់ដំបងទេដែលត្រូវបានរៀបចំ និងទទួលការអនុម័តរួច កាលពីខែធ្នូ ឆ្នាំ២០១៥។ |
| | ប្លង់គោលស្តីពីការប្រើប្រាស់ដីធ្លីស្រុក/ខណ្ឌ | ប្លង់គោលមួយចំនួនត្រូវបានធ្វើសេចក្តីព្រាងរួចហើយ ប៉ុន្តែអត់ទាន់មានមួយណាទទួលបានការអនុម័តនៅឡើយទេ។ ប្លង់ប្រើប្រាស់ដីធ្លីក្រុង/ស្រុក ចំនួន ២៣ កំពុងឆ្លងកាត់ការពិនិត្យ និងបញ្ចប់ក្នុងឆ្នាំ២០១៨ (MLMUPC, 2018)។ នៅសល់១៣ទៀតកំពុងតែស្ថិតក្នុងដំណើរការព្រាង។ |
| **ថ្នាក់ឃុំ/សង្កាត់** | ប្លង់ប្រើប្រាស់ដីធ្លីឃុំ/សង្កាត់ | ការរៀបចំតាក់តែងផែនការទាំងនេះបានចាប់ផ្តើមតាំងពីក្រោយអនុក្រឹត្យមួយបានចូលជាធរមាននៅឆ្នាំ២០០៩ ប៉ុន្តែមកទល់ពេលនេះឥតមានកំណត់ត្រាណាមួយបញ្ជាក់ថាមានផែនការប៉ុន្មានដែលបានរៀបចំរួចហើយ។ |

*ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ២០១៨ (ព័ត៌មានបច្ចុប្បន្នភាពពីគោលនយោបាយជាតិស្តីពីការរៀបចំប្លង់ភូមិសាស្ត្រ)*

នៅក្នុងឆ្នាំ២០១៧ គោលការណ៍ណែនាំថ្មីៗថែមទៀតត្រូវបានអនុម័តសម្រាប់រៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម រួមក្នុងនោះមាន ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំ។ ទីក្រុងនឹងទទួលបានការបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំថ្មីៗនេះនៅក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់ក្នុងឆ្នាំ ២០១៧។ ផែនការនានាដែលបានរៀបចំឡើងតាមវិធីសាស្ត្រចូលរួមនៅថ្នាក់ឃុំ/សង្កាត់ ហើយត្រូវបានក្រុមប្រឹក្សាឃុំ/សង្កាត់អនុម័តល្ហើរួច នឹងបំពេញទៅឱ្យផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្រុង។ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្រុងត្រូវបានលើកយកទៅបង្ហាញ នៅសិក្ខាសាលាសមាហរណកម្មផែនការស្រុក/ក្រុងរៀងរាល់ឆ្នាំ ដែលក្នុងនោះក្រសួងខ្សែបណ្តោយត្រូវបានគេស្នើឱ្យជួយស្វែងរកធនធានចាំបាច់ ហើយដៃគូអភិវឌ្ឍន៍ត្រូវបានលើកទឹកចិត្តឱ្យជួយគាំទ្រដល់សកម្មភាពគម្រោងអភិវឌ្ឍន៍ដោយឡែកៗ។ ដោយសារតែធនធានហិរញ្ញវត្ថុមានកម្រិតសម្រាប់វិនិយោគទៅលើគម្រោងអភិវឌ្ឍន៍នៅថ្នាក់ស្រុក/ក្រុង អាជ្ញាធរក្រុងមានលទ្ធភាពតិចតួចណាស់ ក្នុងការផ្គត់ផ្គង់ហិរញ្ញវត្ថុដល់សកម្មភាពជាអាទិភាពរបស់ខ្លួន។ ផែនការសកម្មភាពធ្វើគណនេយ្យភាពរួម (Joint Accountability Action Plans) ដែលត្រូវបានរៀបចំឡើងដោយពលរដ្ឋនិងអ្នកផ្តល់សេវា នឹងត្រូវបានយកទៅច្របាច់បញ្ចូលក្នុងផែនការរបស់ឃុំនិងស្រុកដែរ។ មកទល់ពេលនេះ ការផ្តោតរបស់ក្របខណ្ឌ ISAF មានទៅលើតំបន់ជនបទ ប៉ុន្តែ ដូចតបានលើកឡើងនៅខាងលើរួចហើយ ការផ្តោតរបស់ក្របខណ្ឌនេះគួរតែត្រូវបានពង្រីកទៅគ្រប់ដណ្តប់លើតំបន់ទីប្រជុំជន និងសេវាជាក់លាក់មួយចំនួនដែលក្រុងជាអ្នកផ្តល់។

### ២.៣.៣ បញ្ហាប្រឈមចំពោះការអភិវឌ្ឍ និងការអនុវត្តផែនការរៀបចំក្រុង

ក្របខណ្ឌរៀបចំផែនការជាតិនៅខ្វះគោលការណ៍ណែនាំច្រើនសម្រាប់បង្កើតផែនការ នៅតាមដែនរដ្ឋបាលផ្សេងៗគ្នា[៨១]។ ឧទាហរណ៍ សេចក្ដីសម្រេចលេខ ៤១ ស្ដីពី «នីតិវិធីលម្អិតសម្រាប់ធ្វើប្លង់គោលប្រើប្រាស់ដីធ្លី និងប្លង់ប្រើប្រាស់ដីធ្លីរបស់ក្រុង ស្រុក ខណ្ឌ» ដាក់ចេញដំណើរការមានប្រាំបួនលំដាប់ ដែលត្រូវអនុលោមតាមនៅថ្នាក់ជាតិ ហើយក្នុងនោះមានការប្រមូលទិន្នន័យនិងការវិភាគ ការកំណត់ចក្ខុវិស័យ ប្លង់ព្រាង កិច្ចពិគ្រោះយោបល់ជាសាធារណៈ និងការកំណត់គម្រោងជាអាទិភាព។ យ៉ាងណាក្ដី នៅមានបញ្ហាប្រឈមច្រើន ទាំងក្នុងការរៀបចំឱ្យបានសម្រេច ទាំងក្នុងការអនុវត្តផែនការទាំងនេះ។ នៅក្នុងជំពូកនេះ ក្រុមការងារយោងជាក់លាក់ទៅលើប្លង់ប្រើប្រាស់ដីធ្លី ដែលមានសក្ដានុពលសម្រាប់ដឹកមុខការអភិវឌ្ឍ និងផ្ដល់មូលដ្ឋានច្បាស់និងប្រកបដោយតម្លាភាពមួយ សម្រាប់យកទៅធ្វើការសេចក្ដីសម្រេចនានាស្ដីពីការអភិវឌ្ឍ។

**សមត្ថភាពបច្ចេកទេសទាប៖** បញ្ហាប្រឈមធំគឺកង្វះផ្នែកសមត្ថភាពបច្ចេកទេស និងកង្វះបុគ្គលិកនៅថ្នាក់ក្រោមជាតិដើម្បីរៀបចំធ្វើប្លង់ប្រើប្រាស់ដីធ្លីលម្អិត។ ភាគច្រើននៃជំនាញអាជីពផ្នែកនេះក្នុងការធ្វើផែនការនគរូបនីយកម្ម នៅតែប្រមូលផ្ដុំគ្នានៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅពេលដែលមន្ទីររបស់ខ្លួននៅថ្នាក់មូលដ្ឋានគ្មានការបំពាក់គ្រឿងសម្ភារគ្រប់គ្រាន់សម្រាប់ធ្វើ និងអនុវត្តផែនការ ដើម្បីយកទៅប្រើជាត្រីវិស័យក្នុងការអភិវឌ្ឍទីក្រុងឱ្យបានសមស្រប។ ដោយទទួលស្គាល់នូវបញ្ហាប្រឈមពិសេសដោយឡែកទាំងនេះដែលបណ្ដាក្រុងជួបប្រទះ ក្រុងភាគច្រើនបានចាប់ផ្ដើមបង្កើតការិយាល័យ «អភិវឌ្ឍន៍ក្រុង» និង «រៀបចំសោភ័ណភាពក្រុង» តាំងពីឆ្នាំ២០០៩មក ប៉ុន្តែការិយាល័យទាំងនេះមានធនធាន និងបុគ្គលិកអាជីពជំនាញតិចតួចណាស់។ ក្នុងចំណោមការទទួលខុសត្រូវផ្សេងទៀត ការិយាល័យទាំងនេះមានគោលដៅអនុវត្តគម្រោងអភិវឌ្ឍន៍ក្រុង ធ្វើការសម្របសម្រួលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លី ត្រួតពិនិត្យសកម្មភាពគម្រោងសាងសង់ និងការធ្វើនគរូបនីយកម្ម។ ការិយាល័យទាំងនេះមានគណនេយ្យភាពចំពោះនាយករដ្ឋបាលសាលាក្រុង និងដើរតួជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាក្រុង និងគណៈអភិបាល។

ជាមធ្យម ការិយាល័យទាំងនោះមានបុគ្គលិកពី ២ ទៅ៤នាក់ ដែលទទួលខុសត្រូវបឋមចំពោះការរៀបចំផែនការ និងឆ្លើយតបចំពោះបញ្ហានានាក្នុងការអភិវឌ្ឍក្រុង។ ជាមួយបុគ្គលិក ៤៣នាក់ ជាមធ្យមក្នុងមួយក្រុង (ក្រុងបាត់ដំបង) បុគ្គលិកភាគច្រើនត្រូវបានរុញឱ្យទៅធ្វើការនៅតាមការិយាល័យប្រាំផ្សេងទៀត (សូមមើលឧទាហរណ៍រចនាសម្ព័ន្ធរៀបចំបុគ្គលិកក្រុងបាត់ដំបងនៅខាងក្រោម) រូបភាព ២.៥។ ដោយសារការបណ្ដុះបណ្ដាល និងបទពិសោធន៍នៅមានកម្រិតរបស់បុគ្គលិកក្នុងអង្គភាពអភិវឌ្ឍន៍ក្រុង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងផ្សេងទៀត បានដើរតួនាទីដោយអត្តន័យសំខាន់នៅក្នុងការរៀបចំប្លង់អភិវឌ្ឍន៍ក្រុង។ ការសិក្សាមួយទៀតមុននេះរបស់ធនាគារពិភពលោកបានរកឃើញថា មានតែពី ១០ ទៅ៥០ភាគរយប៉ុណ្ណោះនៃអ្នកធ្វើប្លង់រៀបចំក្រុង ដែលសាលារាជធានីភ្នំពេញជ្រើសរើសយកមកធ្វើការ មានការបណ្ដុះបណ្ដាលត្រឹមត្រូវផ្នែកធ្វើប្លង់រៀបចំក្រុង[៨២]។ ជារួម សមត្ថភាពរបស់អង្គភាពអភិវឌ្ឍន៍ក្រុងស្ថិតនៅក្រោយឆ្ងាយណាស់ពីភាពចាំបាច់ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមដ៏ច្រើនអនេកនៃដំណើរយ៉ាងលឿនរបស់នគរូបនីយកម្មនាពេលបច្ចុប្បន្ន។

បច្ចុប្បន្ន មានសាលា ឬវគ្គសិក្សាឧត្ដមសិក្សាដោយឡែកៗ ដែលផ្ដោតទៅលើមុខវិជ្ជារៀបចំនិងគ្រប់គ្រងក្រុង ក្នុងកម្រិតសញ្ញាបត្របរិញ្ញាឬអនុបណ្ឌិត។ វគ្គសិក្សាស្ដីពីការធ្វើប្លង់រៀបចំក្រុងត្រូវបានបង្រៀនគ្រាន់តែជាផ្នែកមួយនៃកម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រប៉ុណ្ណោះ ជាពិសេសជាផ្នែកមួយនៃបរិញ្ញាបត្រផ្នែកស្ថាបត្យកម្ម។ ទន្ទឹមគ្នានេះ នៅមានភាពចាំបាច់ខ្លាំងឱ្យមានការបណ្ដុះជំនាញឯកទេសមួយចំនួន ដូចជាមុខវិជ្ជាការកំណត់ផែនទី ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងប្រព័ន្ធស្ទង់ពីចម្ងាយ (GIS and remote sensing) ប្រតិបត្តិការកម្មវិធី CAD operations ការវិភាគទិន្នន័យ ការធ្វើផែនការនិងការគ្រប់គ្រងក្រុង វិស្វកម្មបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន។ នៅក្នុងដើមទសវត្សរ៍ឆ្នាំ ២០០០ ធនាគារពិភពលោកបានផ្ដួចផ្ដើមគំនិតបង្កើតមហាវិទ្យាល័យរៀបចំដីធ្លីមួយនៅក្នុងសកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលជាកម្មវិធីបណ្ដុះបណ្ដាលវែងឆ្ងាយមួយពាក់ព័ន្ធផ្នែកគ្រប់គ្រងដីធ្លី និង

៨១ World Bank. 2017. Urban Development in Phnom Penh. Phnom Penh, Cambodia: World Bank.

៨២ Ibid.

សុរិយោដី។ ពេលនេះ ក្រសួងមហាផ្ទៃកំពុងពិចារណាបង្កើតសាលារដ្ឋបាលមូលដ្ឋានជាតិ (National School of Local Administration/NaSLA) ដែលនឹងជួយបំពេញឱ្យបុគ្គលិកផ្នែករដ្ឋបាលថ្នាក់ក្រោមជាតិនូវការបណ្តុះបណ្តាលឯកទេសដែលគេត្រូវការចាំបាច់សម្រាប់យកទៅបម្រើការងាររបស់ពួកគេ។

**រូបភាព ២.៥៖** រចនាសម្ព័ន្ធរៀបចំក្រុងបាត់ដំបង និងការិយាល័យក្រុង




*ប្រភព៖ គូរឡើងវិញយកលំនាំតាមរចនាសម្ព័ន្ធរៀបចំក្រុងបាត់ដំបង ឆ្នាំ២០១៨។*
*(សម្គាល់៖ លើកលែងតែការិយាល័យបច្ចេកទេសខ្សែបណ្តោយក្រសួងនៅក្នុងប្រអប់គំនូសដាច់ៗនៅខាងឆ្វេងចេញ ក្រុងបាត់ដំបងមានបុគ្គលិកពេញម៉ោង៤៣នាក់ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អាជ្ញាធរក្រុង ក្នុងនោះ ៤នាក់ធ្វើការក្នុងការិយាល័យ «អភិវឌ្ឍន៍ក្រុង»។ ក្នុងរង្វង់រដ្ឋបាលក្រុងទាំងមូល មានបុគ្គលិកតែម្នាក់គត់ (អភិបាលរង) ដែលមានសញ្ញាបត្របរិញ្ញាបត្រផ្នែកស្ថាបត្យកម្មនិងរៀបចំក្រុង។ មិនមែនគ្រប់ក្រុងសុទ្ធតែមានការិយាល័យខ្សែបណ្តោយរបស់ក្រសួងអង្គុយនៅក្នុងរដ្ឋបាលក្រុងទេ។*

ដើម្បីឆ្លើយតបទៅនឹងភាពទន់ខ្សោយក្នុងសមត្ថភាពធ្វើផែនការ ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍នានាបានផ្តល់ជំនួយកសាងសមត្ថភាពតាមទម្រង់ផ្សេងៗ ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ។ ប៉ុន្តែ ជំនួយកសាងសមត្ថភាពទាំងនោះ ជាញឹកញាប់ ច្រើនតែមិនបានធ្វើឱ្យមានឥទ្ធិពលយូរអង្វែងឱ្យហួសពីរយៈពេលអាយុកាលនៃការផ្តល់ជំនួយទេ។ ឧទាហរណ៍ គម្រោងអភិវឌ្ឍន៍សមត្ថភាពមួយនៅឆ្នាំ២០១៥របស់ធនាគារអភិវឌ្ឍន៍អាស៊ី បានផលិតចេញជាឯកសារសម្ភារសម្រាប់ការបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយជាច្រើន ដែលត្រូវបានទទួលការអនុម័តឯកភាពពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងគោលបំណងឈានទៅពង្រឹងសមត្ថភាពនៅក្នុងការរៀបចំប្លង់ ការគ្រប់គ្រង និងការធ្វើអភិបាលកិច្ចទីក្រុង ដើម្បីឱ្យមានការឆ្លើយតបកាន់តែប្រសើរឡើងទៅនឹងតម្រូវការក្នុងមូលដ្ឋាន និងការលូតលាស់យ៉ាងឆាប់រហ័សរបស់នគរូបនីយកម្ម[៤៣]។ មន្ត្រីជាង២០០នាក់មកពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានទទួលការបណ្តុះបណ្តាលជាផ្នែកមួយរបស់គម្រោង ដែលគ្រប់ដណ្តប់ទៅលើប្រធានបទច្រើនមុខ រាប់តាំងពីនីតិវិធីសម្រាប់ការបង្កើតឡើងនូវផែនការថ្នាក់ក្រុង រហូតដល់របៀបគ្រប់គ្រងគម្រោង និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន។ ម៉ូឌុលបណ្តុះបណ្តាលសរុប២១ម៉ូឌុល ត្រូវបានផលិតឡើងដោយគម្រោងនោះ ប៉ុន្តែតាំងតែពីពេលនោះមកមិនទាន់ត្រូវបានគេយក

៤៣ Ministry of Land Management, Urban Planning and Construction. 2015. Training Manuals on The Capacity Development for Urban Management in Cambodia. Phnom Penh, Cambodia: MLUMPC.

ទៅប្រើជាលក្ខណៈប្រព័ន្ធ សម្រាប់បណ្តុះបណ្តាលដល់មន្ត្រីថ្មីៗ ថែមទៀតនៅឡើយទេ។

ស្រដៀងគ្នានេះដែរ នៅឆ្នាំ២០១៦ ទីភ្នាក់ងារសហប្រតិបត្តិការផ្នែកអភិវឌ្ឍន៍នៃប្រទេសអាល្លឺម៉ង់ (Gesellschaft für Internationale Zusammenarbeit/GIZ) បានចងក្រងសៀវភៅក្បួនបីក្បាលស្តីពីការរៀបចំប្លង់ភូមិសាស្ត្រក្នុងប្រទេស ដោយផ្តោតទៅលើការរៀបចំប្លង់ភូមិសាស្ត្រថ្នាក់ខេត្ត ស្រុក និងក្រុង។ ឈរលើបទពិសោធន៍របស់ប្រទេសទីភ្នាក់ងារ GIZ នៅក្នុងការពាក់ព័ន្ធជាមួយទីភ្នាក់ងាររបស់ក្រុងនានា នៅក្នុងប្រទេសអាល្លឺម៉ង់ក្នុងការធ្វើប្លង់ប្រើប្រាស់ដីធ្លី សៀវភៅក្បួនទាំងនោះមានគោលដៅផ្តល់ការណែនាំជាក់ស្តែងមួយជំហានម្តងៗ នៅក្នុងដំណើរការរៀបចំប្លង់។ សៀវភៅក្បួនទាំងនោះមាននៅលើអ៊ិនធឺណិត ប៉ុន្តែមិនដែលត្រូវបានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ យកទៅបោះពុម្ព ឬធ្វើការផ្សព្វផ្សាយឱ្យមន្ត្រីថ្នាក់ក្រោមជាតិយកទៅប្រើប្រាស់ទេ។

### បរិស្ថាននិយតកម្ម និងការឱ្យប្រតិបត្តិតាមច្បាប់នៅខ្សោយ៖

នៅក្នុងករណីដែលមានផែនការរៀបចំក្រុងរួចហើយ គេនៅឃើញមានភាពដាច់ចេញពីគ្នាស្រឡះរវាងអ្វីដែលផែនការបានស្នើឡើង និងភាពជាក់ស្តែងនៃកម្មភាពអភិវឌ្ឍន៍ក្រុងនៅតាមការដ្ឋាន។ មានកត្តាជាច្រើនដែលផ្សំគ្នា រួមទាំងអវត្តមាននៃបរិស្ថាននិយតកម្មនិងការអនុវត្តច្បាប់ដ៏ស្វាហាប់មួយផង។ ជាទូទៅ បទបញ្ញត្តិក្នុងកម្រិតផ្សេងៗគ្នាដើរតួធ្វើអភិបាលកិច្ចទៅលើការអនុវត្តផែនការប្រើប្រាស់ដីធ្លី ដោយក្នុងនោះមានខ្លះជាផែនការកំណត់ដោយច្បាប់ ខណៈដែលផែនការដទៃទៀតមានលក្ខណៈជាឯកសារណែនាំច្រើនជាង សម្រាប់យកទៅពិចារណានៅពេលណាត្រូវធ្វើការវាយតម្លៃគម្រោងអភិវឌ្ឍន៍ថ្មី។ ឧទាហរណ៍ នៅប្រទេសជប៉ុន និងប្រទេសសិង្ហបុរី ការអភិវឌ្ឍទីក្រុងស្ថិតក្រោមការត្រួតត្រារបស់បទបញ្ញត្តិពីរប្រភេទ - ទីមួយ គឺការធ្វើផែនការជំហានដំបូង ឬការអនុញ្ញាតធ្វើការអភិវឌ្ឍ ដែលធានាយ៉ាងណាឱ្យគម្រោងអភិវឌ្ឍន៍ដែលបានស្នើឡើងមានភាពស្របគ្នាជាមួយនឹងផែនការប្រើប្រាស់ដីធ្លី ហើយបន្ទាប់មកទីពីរ គឺការអនុញ្ញាតសាងសង់ចុងខ្សែ (downstream building permissions) ដែលធ្វើនិយតកម្មទៅលើទ្រង់ទ្រាយ និងសុវត្ថិភាពទូទៅនៃរចនាសម្ព័ន្ធសំណង់របស់គម្រោងអភិវឌ្ឍន៍សាងសង់ថ្មី។ នៅក្នុងបរិបទប្រទេសកម្ពុជា គេកម្រឃើញមានការយោងទៅលើផែនការប្រើប្រាស់ដីធ្លីណាស់នៅពេលផ្តល់ការអនុម័តទៅលើសំណើគម្រោងអភិវឌ្ឍន៍ថ្មីៗ ហើយបើទោះជាមានការប៉ុនប៉ងច្រើនត្រូវបានធ្វើដើម្បីរៀបចំការណែនាំស្តីពីកត្តាលម្អិតនៃគម្រោងអភិវឌ្ឍន៍ក្តី មានដូចជាវិធានការត្រួតពិនិត្យលើភាពរយាល និងកម្ពស់របស់សំណង់ជាដើម ការដាក់ឱ្យប្រតិបត្តិតាមវិធានទាំងនោះនៅតែជាបញ្ហាប្រឈមនៅឡើយ។

ច្បាប់ស្តីពីការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្ម ឆ្នាំ១៩៩៤ នៅតែជាច្បាប់មានទំនាក់ទំនងជាគេជាមួយនឹងការរៀបចំផែនការភូមិសាស្ត្រ។ អនុក្រឹត្យលេខ ៨៦ (១៩៩៦) ក៏ផ្តល់ដែរនូវការណែនាំសម្រាប់ការចេញលិខិតអនុញ្ញាតសាងសង់ និងការប្រើប្រាស់ដី (រួមទាំងការត្រួតពិនិត្យលើភាពរយាលរវាងអគារសំណង់) នៅក្នុងតំបន់ទីប្រជុំជន។ ប៉ុន្តែ ច្បាប់ពីឆ្នាំ១៩៩៤ ត្រូវបានតាក់តែងឡើងផ្អែកលើច្បាប់ភូមិបាលឆ្នាំ២០០១។ បច្ចុប្បន្ន ច្បាប់ស្តីពីការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្ម កំពុងត្រូវបានសើរើធ្វើឡើងវិញជាច្បាប់នគរូបនីយកម្ម ឱ្យស្របតាមច្បាប់ភូមិបាលបច្ចុប្បន្នភាព ហើយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏បានខិតខំដែរក្នុងការព្រាងក្រមសំណង់មួយសម្រាប់ត្រួតពិនិត្យលើកម្ពស់អគារដោយផ្តោតទៅលើទីក្រុងភ្នំពេញ។ ទន្ទឹមគ្នានេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងបរិស្ថាន កំពុងពិភាក្សាគ្នាលើគំនិតផ្តួចផ្តើមរួមមួយស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ទីក្រុង។

ស្ថានភាពមិនល្អដោយសារតែអវត្តមាននៃផែនការរៀបចំក្រុង និងក្របខណ្ឌច្បាប់សម្រាប់ទ្រទ្រង់កាន់តែមានសភាពធ្ងន់ធ្ងរថែមទៀត ខណៈដែលខ្វះការចុះសម្រុងគ្នាច្រើនក្នុងការអនុម័តគម្រោងសាងសង់ (មានពិភាក្សាបន្ថែមនៅខាងក្រោម) និងការអនុវត្តពុំទាន់បានល្អនូវគោលការណ៍ណែនាំដែលមានស្រាប់។ នៅក្រុងព្រះសីហនុ ស្ថានភាពបែបនេះបានបង្កឱ្យមានលំនាំគ្មានរបៀបរៀបរយមួយក្នុងការអភិវឌ្ឍទីក្រុង ដោយគម្រោងអភិវឌ្ឍន៍សំណង់ថ្មីៗក្នុងមាត្រដ្ឋាននិងដង់ស៊ីតេផ្សេងៗគ្នាកំពុងតែបង្កើនភាពណែនតាន់តាប់ក្នុងភាគកណ្តាលទីក្រុង និងនៅតាមឆ្នេរសំខាន់ៗមួយចំនួន។ ស្ថានភាពប្រហាក់ប្រហែលគ្នានេះត្រូវបានគេឃើញរួចហើយនៅភ្នំពេញ ដែលកង្វះការប្រតិបត្តិតាមផែនការរៀបចំក្រុង និងភាពធូរលុងនៅក្នុងការតម្រូវឱ្យអនុវត្តតាមក្រមសំណង់ បានបង្កើតឱ្យមានទេសភាពក្រុងមួយដែលលាតសន្ធឹងរកេតរកូតគ្មានសណ្តាប់ធ្នាប់។ ចំពោះមុខល្បឿនលឿនរបស់នគរូបនីយកម្មនៅតាមក្រុងលំដាប់ទីពីរ និងកង្វះផែនការសម្រាប់ដឹកនាំគម្រោងអភិវឌ្ឍន៍ទាំងនោះ គេសង្ឃឹមថាច្បាប់បច្ចុប្បន្នភាពស្តីពីការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្ម និងបទបញ្ញត្តិពាក់ព័ន្ធ នឹងផ្តល់ជាមូលដ្ឋានច្បាប់មួយកាន់តែរឹងមាំថែមទៀតសម្រាប់បណ្តាខេត្ត ទីក្រុង និងក្រុង ដើម្បីយករៀបចំឡើងនូវប្លង់គោល និងប្លង់ប្រើ

ប្រាស់ដីធ្លី សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍកាន់តែប្រសើរឡើង នៅក្នុងដែនដីសមត្ថកិច្ចរបស់ពួកគេរៀងៗខ្លួន។

**តួនាទីផ្ទុយគ្នារវាងថ្នាក់ជាតិ និងថ្នាក់ក្រុង៖** ថ្វីបើកន្លងមកមានកិច្ចប្រឹងប្រែងក្នុងការធ្វើវិមជ្ឈការដំណើរការធ្វើសេចក្តីសម្រេច និងការទទួលខុសត្រូវ និងក្នុងការធ្វើវិសហមជ្ឈការធនធានក្នុងក្រសួងថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨) មែនក្តី ការប្រមូលផ្តុំអំណាចក្នុងការធ្វើសេចក្តីសម្រេចនៅថ្នាក់ជាតិ ពិសេសសម្រាប់គម្រោងអភិវឌ្ឍន៍ធំៗ ក៏ជាឧបសគ្គមិនឱ្យគម្រោងអភិវឌ្ឍន៍សំណង់អាចដំណើរការបាន ស្របទៅតាមផែនការដែលបានគ្រោងទុកឡើយ។ ភស្តុតាងដែលជាការនិទានប្រាប់ក្នុងពេលស្រាវជ្រាវបានឱ្យដឹងថា រដ្ឋបាលថ្នាក់ក្រុងមានឥទ្ធិពលតិចតួចណាស់នៅក្នុងដំណើរការអនុម័តគម្រោងអភិវឌ្ឍន៍ថ្មីៗ ដែលត្រូវការតែអាជ្ញាបណ្ណសាងសង់តែប៉ុណ្ណោះសម្រាប់ចាប់ផ្តើមធ្វើការអភិវឌ្ឍគម្រោង។ គម្រោងសាងសង់មានទំហំផ្ទៃក្រោម ៣០០០ម$^{២}$ (ឬក្នុងតម្លៃទឹកប្រាក់តិចជាង ២លានដុល្លារអាមេរិក) អាចទទួលបានការអនុម័តនៅកម្រិតក្រុង ឬខេត្ត ប៉ុន្តែគម្រោងធំជាងនេះត្រូវការការឯកភាពពីថ្នាក់ជាតិ ឬពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់[៨៤]។

លើសពីនេះ គម្រោងវិនិយោគបរទេសធំៗត្រូវឆ្លងកាត់ការពិនិត្យ និងការអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាមជ្ឈមណ្ឌលសេវាកម្មលើកកម្ពស់ និងសម្រួលការវិនិយោគមកពីក្រៅប្រទេស។ ការសិក្សាលើកមុនរបស់ធនាគារពិភពលោកទៅលើការអភិវឌ្ឍទីក្រុងភ្នំពេញ បង្ហាញឱ្យឃើញថា ការសម្របសម្រួលរវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអាជ្ញាធរពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានមិនសូវជារឹងមាំទេទោះជាមានយន្តការច្រើនស្រាប់ក៏ដោយ ដែលធានាយ៉ាងណាឱ្យទីភ្នាក់ងាររដ្ឋាភិបាលនីមួយៗផ្តល់ការយល់ព្រមរបស់ខ្លួនទៅលើសំណើគម្រោងអភិវឌ្ឍន៍ជាមុនសិន មុននឹងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអនុម័តចុងក្រោយ។ បទពិសោធន៍នៅតាមក្រុងលំដាប់ទីពីរក៏ប្រហាក់ប្រហែលគ្នានេះដែរ។ អត្ថបទមួយរបស់កាសែត Phnom Penh Post កាលពីពេលថ្មីៗនេះបានរាយការណ៍ថា អ្នកលក់ដូរនិងម្ចាស់ហាងរកស៊ីនៅក្នុងតំបន់ផ្ទៃ ៥គ.ម$^{២}$ ជុំវិញឆ្នេរអូរឈើទាលនៅក្រុងព្រះសីហនុ ត្រូវតែរើចេញដើម្បីយកកន្លែងសម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរ ប៉ុន្តែសូម្បីតែមន្ទីរទេសចរណ៍ខេត្តក៏អត់មានព័ត៌មានអំពីគម្រោងនោះ ហើយក៏មិនដឹងថាតើគេប្រុងអភិវឌ្ឍន៍ធ្វើអ្វីដែរ[៨៥]។

**កង្វះហិរញ្ញប្បទាន៖** កង្វះហិរញ្ញប្បទានក៏ជាឧបសគ្គមួយមិនឱ្យគម្រោងអភិវឌ្ឍន៍សំណង់ដំណើរការទៅមុខស្របតាមផែនការដែលបានគ្រោងទុកដែរ។ ប្រកាសមួយស្តីពីការបែងចែកចំណូលមិនមែនពន្ធដារ (ពន្ធអចលនទ្រព្យ) ត្រូវបានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដាក់ចេញ (លេខ ១៤៥៨ ខែធ្នូ ឆ្នាំ២០១៧) ដោយអនុញ្ញាតឱ្យបែងចែក ៣% ទៅឱ្យក្រុង/ស្រុក/ខណ្ឌ និង ១% ទៅឱ្យឃុំ/សង្កាត់។ ចំណែកនៃចំណូលនេះ ប្រហែលជាអាចជួយបំពេញបានដល់តម្រូវការសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងការថែទាំ ប៉ុន្តែហេដ្ឋារចនាសម្ព័ន្ធខ្នាតធំនៅតែត្រូវការមូលនិធិមកពីប្រភពផ្សេងៗទៀតដែរ[៨៦]។ ការពិភាក្សាកាន់តែស៊ីជម្រៅមួយទៀតលើបញ្ហាប្រឈមពាក់ព័ន្ធជាមួយនឹងកង្វះហិរញ្ញប្បទាន ត្រូវបានបង្ហាញជូននៅក្នុងផ្នែក ២.២.៥។

ការដែលការវិនិយោគ បរទេសចេះតែបន្តហូរចូលទៅក្នុងទីក្រុងលំដាប់ទីពីរ បង្កើតឱ្យមានកាលានុវត្តភាពច្រើនសម្រាប់ត្រងយកវិនិយោគិន ឱ្យចូលរួមចំណែកដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន - ឧទាហរណ៍ ដោយតម្រូវឱ្យម្ចាស់អភិវឌ្ឍន៍ការសាងសង់ធ្វើការកែលម្អដល់ផ្លូវនានានៅក្បែរគម្រោង ទេសភាពភ្ជាប់លូបង្ហូរទឹកភ្លៀង ឬលូបង្ហូរទឹកស្អុយ ជាដើម។ ប៉ុន្តែ ជាទូទៅមិនទាន់មានការអនុវត្តរបៀបនេះទេ។ គ្មានបទបញ្ញត្តិណាបញ្ជាក់ឱ្យមានតម្រូវការបែបនេះសម្រាប់ការអភិវឌ្ឍនៅនឹងកន្លែង ឬសម្រាប់ការរួមចំណែកដល់បរិស្ថានទីក្រុង និងពលរដ្ឋមានចំណូលតិចដែរ។ គម្រោងអភិវឌ្ឍន៍សំណង់នីមួយៗអាចសង់ហេដ្ឋារចនាសម្ព័ន្ធសម្រួលខ្លះៗ នៅក្នុងរង្វង់ដែនរបស់ផ្ទៃការដ្ឋានរបស់គេដើម្បីទាក់ទាញអ្នកទិញ ឬដើម្បីគ្រាន់តែបំពេញតម្រូវការរបស់ខ្លួនប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបានគេបង្ខំឱ្យធ្វើការកែលម្អដល់បរិស្ថាននៅជុំវិញការដ្ឋានអភិវឌ្ឍន៍ឡើយ។ ចំណុចនេះជារឿងទូទៅដែលគេជួបប្រទះនៅក្នុងសហគមន៍បុរីជាច្រើននៅទីក្រុងភ្នំពេញ និងនៅតាមទីក្រុងលំដាប់ទីពីរក្នុងប្រទេសកម្ពុជា។

---

៨៤ World Bank. 2017.

៨៥ Sokhorng, Cheng and Robin Spiess (2018). “Evictions sweep away Sihanoukville beach businesses.” The Phnom Penh Post. 8 January 2018. https://www.phnompenhpost.com/business/evictions-sweep-away-sihanoukville-beach-businesses

៨៦ World Bank, 2017.

### ២.៣.៤ ការធ្វើផែនការរៀបចំក្រុងនៅក្រុងបាត់ដំបង និងក្រុងព្រះសីហនុ

ផ្នែកបន្ទាប់ទៅនេះ ពិនិត្យមើលផែនការរៀបចំក្រុងដែលមាននៅក្នុងទីក្រុងលំដាប់ទីពីរចំនួនពីរ - ក្រុងព្រះសីហនុ និងក្រុងបាត់ដំបង - ជាមួយនឹងទស្សនៈធ្វើការវាយតម្លៃស្ថានភាពអនុវត្ត និងលទ្ធភាពថាតើការរៀបចំផែនការនោះមានឥទ្ធិពលកម្រិតណាទៅលើការអភិវឌ្ឍក្រុង។

#### ក្រុងបាត់ដំបង

ក្រុងបាត់ដំបងជាក្រុងមួយក្នុងចំណោមក្រុងពីរតែប៉ុណ្ណោះ ដែលមានប្លង់គោលប្រើប្រាស់ដីធ្លីក្នុងក្រុង ដែលទទួលបានការអនុម័តពីរដ្ឋាភិបាលថ្នាក់ជាតិ ជាមួយគ្នានឹងក្រុងភ្នំពេញដែរ។ ប្លង់គោលនេះជាលទ្ធផលនៃកិច្ចសហការរយៈពេលវែងមួយជាមួយទីភ្នាក់ងារ GIZ និងទីភ្នាក់ងារសេវាអភិវឌ្ឍន៍ប្រទេសអាល្លឺម៉ង់ (German Development Service/DED)។ វាត្រូវបានទទួលការអនុម័តយល់ព្រមនៅឆ្នាំ២០១៥ គឺប្រាំមួយឆ្នាំបន្ទាប់ពីវាត្រូវបានព្រាងចប់សព្វគ្រប់ និង១២ឆ្នាំបន្ទាប់ពីកិច្ចការមួយបានចាប់ផ្តើមនៅឆ្នាំ២០០៣ ជាផ្នែកមួយនៃគំនិតផ្តួចផ្តើមមានលក្ខណៈទូលំទូលាយស្តីពីការគ្រប់គ្រងដីធ្លី។ ប្រៀបជាមួយក្រុងផ្សេងទៀត ក្រុងបាត់ដំបងបានកសាងសមត្ថភាពថ្នាក់មូលដ្ឋានបានច្រើនគួរសមនៅក្នុងការធ្វើផែនការរៀបចំក្រុង ហើយទទួលបានលទ្ធផលជាដុំកំភួនជាច្រើនពីការអភិវឌ្ឍ និងការអនុវត្តផែនការនានាដូចមានពីពណ៌នាជូននៅខាងក្រោម[៨៧]។ គំរូនៃការធ្វើផែនការរៀបចំក្រុងបាត់ដំបងត្រូវបានគេចាត់ទុកជាទូទៅថាជាទម្លាប់អនុវត្តន៍ល្អមួយនៅប្រទេសកម្ពុជា ហើយវិធីសាស្ត្រនិងនីតិវិធីដែលគេបានយកមកប្រើ កន្លងមក ត្រូវបានខេត្តដទៃទៀតទទួលយកទៅធ្វើតាមដែរ មានខេត្តកណ្តាល កំពង់ឆ្នាំង និងតាកែវ។

ប្លង់គោលក្រុងបាត់ដំបង ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍សមាហរណកម្មមួយ ជាមួយនឹងការសម្លឹងមើលទៅ១៥ឆ្នាំខាងមុខ ហើយផ្សំឡើងដោយសមាសភាគដោយឡែកៗពីគ្នា ដូចជា៖ (i) ប្លង់/ផែនការប្រើប្រាស់ដីធ្លី; (ii) ប្លង់/ផែនការហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស; (iii) ប្លង់/ផែនការហេដ្ឋារចនាសម្ព័ន្ធសង្គម និង and (iv) ប្លង់/ផែនការអភិវឌ្ឍន៍លម្អិត[៨៨]។ ប្លង់គោលនេះត្រូវបានបង្កើតឡើងដោយឈរលើចក្ខុវិស័យ ការអភិវឌ្ឍសម្រាប់ឆ្នាំ២០២០ ដែលរួមមានគោលដៅចំនួនប្រាំមួយ ដូចមានបង្ហាញជូននៅក្នុងរូបភាព ២.៦។ កិច្ចការភាគច្រើនដែលត្រូវបានធ្វើដោយទីភ្នាក់ងារ GIZ ផ្តោតទៅលើការបង្កើតប្លង់/ផែនការប្រើប្រាស់ដីធ្លី ដែលបង្ហាញអំពីការបែងចែកតំបន់អនុញ្ញាតឱ្យមានការប្រើប្រាស់ដីធ្លី ផ្អែកលើដីដែលកំពុងតែមានការប្រើប្រាស់ ការអភិវឌ្ឍមានផែនការ និងតម្រូវការដែលបានប្រមើលទុកសម្រាប់ពេលអនាគត។ ការពិពណ៌នាកាន់តែលម្អិតស្តីពីដំណើរការធ្វើផែនការត្រូវបានបង្ហាញជូនក្នុងប្រអប់ ២.៥។

**រូបភាព ២.៦៖** ដ្យាក្រាមនៃចក្ខុវិស័យអភិវឌ្ឍន៍ក្រុងបាត់ដំបងដល់ឆ្នាំ២០២០




*ប្រភព៖ របាយការណ៍បច្ចេកទេសស្តីពីប្លង់ប្រើប្រាស់ដីធ្លីសម្រាប់ក្រុងបាត់ដំបង (២០០៩)*

---

៨៧ Goad, Hallam. 2012. “Growing Pains: Urbanisation and Informal Settlements in Cambodia’s Secondary Cities.” https://data.opendevelopmentmekong.net/dataset/63c328e1-5665-4e8d-8b66-eaca5df94e28/resource/10962a4b-cea7-4ee6-be9a-4d685c81181a/download/STT-ThreeCitiesReport2012Growing-pains.pdf.

៨៨ Master Plan Team Battambang Municipality. 2009. Technical Report on the Land-Use Plan for Battambang Municipality.

បើកាលណានិយាយអំពីឥទ្ធិពលរបស់វាវិញ ប្លង់គោលទីក្រុងបានធ្វើឱ្យមានឥទ្ធិពលទៅលើដំណើរការអភិវឌ្ឍន៍ក្រុងបាត់ដំបងច្រើនយ៉ាង។ វាបានផ្តល់មូលដ្ឋានច្បាស់លាស់មួយដែលទាំងរដ្ឋាភិបាល ទាំងដៃគូអភិវឌ្ឍន៍ យកជាសំអាងសម្រាប់ធ្វើសេចក្តីសម្រេចធ្វើការវិនិយោគទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ ការវាយតម្លៃមួយដែលត្រូវបានធ្វើទៅលើបណ្តាផ្លូវក្នុងក្រុង នៅក្នុងអំឡុងដំណាក់កាលរៀបចំធ្វើផែនការ បង្ហាញថា ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នោះ នៅមិនទាន់គ្រប់គ្រាន់ដើម្បីពេញទៅនឹងតម្រូវការដែលចេះតែកើនឡើងនោះឡើយ ទាំងផ្លូវក្នុងមូលដ្ឋានបម្រើដល់សេចក្តីត្រូវការរបស់សហគមន៍ និងទាំងផ្លូវធំសម្រាប់តភ្ជាប់ជាមួយតំបន់ផ្សេងៗ និងថ្នាក់ជាតិ។ ទីក្រុងមានបញ្ហាកកស្ទះ និងការបំពុលបរិយាកាសកាន់តែអាក្រក់ឡើងៗ ដោយសារតែអត់មានផ្លូវក្រវាត់វាងក្រុង ដែលធ្វើឱ្យចរាចរណ៍មកពីផ្លូវធំពីរឆ្លងកាត់កណ្តាលទីក្រុងផ្ទាល់តែម្តង។ ប្លង់គោល ក៏ដូចជាប្លង់លម្អិតស្តីពីប្រព័ន្ធផ្លូវទៅថ្ងៃអនាគតដែរ បានបញ្ចូលផ្លូវក្រវាត់ដែលមិនទាន់មាននោះព្រមទាំងហេដ្ឋារចនាសម្ព័ន្ធភ្ជាប់ផង ហើយផ្លូវក្រវាត់នោះបានសាងសង់រួចរាល់ហើយស្របទៅតាមផែនការគ្រោងទុក។

ផែនការអភិវឌ្ឍន៍លម្អិត - ជាផែនការត្រួតពិនិត្យដែលបំពេញឱ្យប្លង់មេរបស់ទីក្រុង - ក៏ជះឥទ្ធិពលទៅលើការអភិវឌ្ឍទីក្រុងដែរ។ ផែនការរៀបចំប្រព័ន្ធផ្ទៃបៃតងទៅអនាគត (Future Greenery System plan) ដែលត្រូវបានផ្តើមធ្វើក្រោមកិច្ចសហការជាមួយទីភ្នាក់ងារ GIZ មានគោលដៅធានាយ៉ាងណាឱ្យទីក្រុងនៅរក្សាបានវាលបៃតងនិងលម្អសាធារណៈ បើទោះជាដំណើរការនគរូបនីយកម្មចេះតែបន្តទៅមុខក្នុងល្បឿនយ៉ាងលឿនក៏ដោយ។ ដូចត្រូវបានបង្ហាញជូនក្នុងរូបភាព ២.៧ និងរូបភាព ២.៨ នៅខាងក្រោម ស្ទឹងសង្កែ និងដៃស្ទឹងភ្ជាប់ជាមួយវានោះ ត្រូវបានគេចាត់ទុកថាជាឆ្អឹងខ្នងរបស់នូវបណ្តាញគម្របផ្ទៃបៃតងនៃទីក្រុងដោយមានច្រករបៀងផ្ទៃទេសភាពពណ៌បៃតង បង្កើតបានជាបណ្តាញទីធ្លាសាធារណៈមួយ នៅទូទាំងក្រុងតែម្តង។ ទីវត្តអារាម និងទីធ្លាពណ៌បៃតងសាធារណៈជាច្រើនទៀតនឹងកាន់តែជួយពង្រីកផ្ទៃបៃតងឱ្យកាន់តែធំ អមដោយខ្សែក្រវាត់បៃតងនៅព័ទ្ធជុំវិញស្រទាប់ខាងក្រៅរបស់ទីក្រុង។ ចាប់តាំងពីពេលនោះមក មានដើមឈើជាង ២០០០០ដើម ត្រូវបានគេដាំស្របតាមផែនការរៀបចំប្រព័ន្ធផ្ទៃបៃតងទៅអនាគត ទន្ទឹមគ្នានឹងការបង្កើតសួនច្បារថ្មី និងការកែលម្អសួនច្បារចាស់នៅតាមមាត់ស្ទឹងសង្កែផងដែរ[៨៩]។

៨៩ ការរកឃើញរបស់ក្រុមការងារ។

**រូបភាព ២.៧៖** ប្លង់លម្អិតសម្រាប់រៀបចំប្រព័ន្ធលម្អផ្ទៃបៃតងក្នុងក្រុងបាត់ដំបង




*ប្រភព៖ របាយការណ៍បច្ចេកទេសស្តីពីប្លង់ប្រើប្រាស់ដីធ្លីសម្រាប់ក្រុងបាត់ដំបង (២០០៩)*

**រូបភាព ២.៨៖** ដំណើរការអនុវត្តវិធានការកែលម្អលម្អផ្ទៃបៃតងនៅតាមដងស្ទឹងសង្កែ




*ប្រភព៖ Update on GIZ Land Rights Program (2014)*

ស្រដៀងគ្នានេះ ក្រុងក៏បានចាត់ការការងារធ្វើផែនការអភិវឌ្ឍន៍លម្អិតមួយសម្រាប់បេតិកភណ្ឌសំណង់របស់ក្រុងបាត់ដំបងដែរ ដែលផែនការនេះបំពេញឱ្យការធ្វើអត្តសញ្ញាណកម្មតំបន់ការពារបេតិកភណ្ឌរបស់ប្លង់ប្រើប្រាស់ដីធ្លី ដោយផ្តល់នូវគោលការណ៍ណែនាំលម្អិតសម្រាប់ការពារ និងពង្រឹងបេតិកភណ្ឌស្ថាបត្យកម្ម។ ត្រង់

នេះ ជាសមាសភាគសំខាន់មួយនៃកិច្ចប្រឹងប្រែងរបស់ក្រុងដើម្បីអភិវឌ្ឍខ្លួនឱ្យទៅជាទីក្រុងបេតិកភណ្ឌ វប្បធម៌ និងទេសចរណ៍ ដែលជាផ្នែកមួយនៃចក្ខុវិស័យការអភិវឌ្ឍន៍ របស់ខ្លួនសម្រាប់ឆ្នាំ២០២០។ ក្រុងបាត់ដំបងមានអគារបេតិកភណ្ឌប្រមាណជា ៨០០អគារ នៅក្នុងភាគកណ្តាលរបស់ទីក្រុង ប៉ុន្តែ អគារទាំងនោះបានបាត់បង់លក្ខណសម្បត្តិដោយឡែកនៃស្ថាបត្យកម្មអង្គរ និងស្ថាបត្យកម្មសម័យអាណានិគមបារាំងជាបណ្តើរៗហើយ ក្រោមឥទ្ធិពលនៃការរីកលូតលាស់យ៉ាងលឿនរបស់ទីក្រុង ដូចធ្លាប់មានរួចមកហើយនៅតាមទីក្រុងជាច្រើនទូទាំងពិភពលោក។ ជាធម្មតា អគារទាំងនេះត្រូវបានគោះរើចេញសម្រាប់សង់អគារទំនើបវិញ ដែលច្រើនតែមានលក្ខណៈឆ្លងទៅនឹងទិដ្ឋភាព និងទ្រង់ទ្រាយជាប្រពៃណីរបស់ផ្នែកស្នូលនៃទីក្រុង។ ដើម្បីឆ្លើយតបទៅនឹងការវិវត្តបែបនេះ ក្រុងការងាររៀបចំប្លង់គោលបានធ្វើការសិក្សាជាច្រើនទៅលើអគារបេតិកភណ្ឌដែលនៅមានស្រាប់ ធ្វើសកម្មភាពយុទ្ធនាការផ្សព្វផ្សាយ និងផ្តល់ការណែនាំស្តីពីការប្រព្រឹត្តទៅលើគ្រោងសំណង់បេតិកភណ្ឌទាំងនោះ ក៏ដូចជាការអភិវឌ្ឍសាងសង់អគារថ្មីជាមួយនឹងការយល់ដឹងអំពីបេតិកភណ្ឌនៅក្នុងកណ្តាលទីក្រុងផងដែរ។

**រូបភាព ២.៩៖** គោលការណ៍ណែនាំសម្រាប់ការការពារបេតិកភណ្ឌក្រុង




*ប្រភព៖ របាយការណ៍បច្ចេកទេសស្តីពីប្លង់ប្រើប្រាស់ដីធ្លីសម្រាប់ក្រុងបាត់ដំបង (២០០៩)*

ប្រៀបជាមួយទីក្រុងផ្សេងៗទៀត ក្រុងបាត់ដំបងសម្រេចបានជោគជ័យគួរឱ្យកត់សម្គាល់នៅក្នុងការរៀបចំប្លង់គោលក្រុងរបស់ខ្លួន និងនៅក្នុងការកសាងសមត្ថភាពធ្វើផែនការរៀបចំក្រុងនៅតាមថ្នាក់មូលដ្ឋាន។ យ៉ាងណាក៏ដោយ នៅមានបញ្ហាប្រឈមច្រើនទៀតដើម្បីឈានទៅអនុវត្តផែនការឱ្យបានពេញលេញនិងមានចីរភាព។ ដោយសារតែត្រូវការពេលយូរទម្រាំនឹងវាទទួលបានការយល់ព្រម ប្លង់គោល (២០២០) នេះ នៅពេលឆាប់ៗខាងមុខ នឹងតម្រូវឱ្យធ្វើបច្ចុប្បន្នភាព ដើម្បីដើរឱ្យទាន់សភាពការណ៍នៃល្បឿនរបស់នគរូបនីយកម្ម។ ក្រុងបាត់ដំបងបានទាក់ទាញចំណាប់អារម្មណ៍កាន់តែច្រើន ពីសំណាក់អ្នកវិនិយោគលើអចលនទ្រព្យ ដោយសារតម្លៃដីនៅទាបគួរសមនៅឡើយ ជាពិសេសសម្រាប់ការអភិវឌ្ឍគម្រោងសាងសង់បុរី។ គម្រោងអភិវឌ្ឍន៍ទាំងនោះបានចាប់ផ្តើមលេចរូបរាងនៅក្នុងផ្ទៃទេសភាពរបស់ក្រុង នៅក្នុងរបៀបមួយគ្មាននិយតភាព ដែលជាតេស្តមួយដល់ការអនុវត្តផែនការប្រើ

ប្រាស់ដីធ្លី និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ ឱ្យបានទាន់ពេលវេលា។ ហើយខណៈដែលយន្តការត្រួតពិនិត្យការអភិវឌ្ឍនៅលំដាប់ចុងខ្សែដើម្បីធ្វើនិយតកម្មទៅលើទ្រង់ទ្រាយ និងដង់ស៊ីតេរបស់អគារ កំពុងស្ថិតក្រោមការរៀបចំបង្កើតនៅឡើយ យន្តការត្រួតពិនិត្យទាំងនេះ ដាច់ខាត នឹងតម្រូវឱ្យមានក្របខណ្ឌនិយតកម្មអមជាមួយថែមទៀត សម្រាប់យកទៅអនុវត្តឱ្យអ្នកអភិវឌ្ឍន៍គម្រោងសាងសង់អនុលោមតាម។

**ប្រអប់ ២.៥៖** ការកសាងសមត្ថភាពយូរអង្វែងសម្រាប់ការរៀបចំប្លង់ក្រុង - ករណីក្រុងបាត់ដំបង

ការព្រាងប្លង់ប្រើប្រាស់ដីធ្លីក្រុងបាត់ដំបង ចំណាយពេលជិតប្រាំមួយឆ្នាំទើបចប់រួចរាល់ ហើយជាដំណើរការដែលមានការពាក់ព័ន្ធគ្រប់ជ្រុងជ្រោយមួយជាប្រចាំជាមួយអ្នកពាក់ព័ន្ធជាច្រើន។ រូបភាពនៅខាងក្រោមបង្ហាញយ៉ាងទូលំទូលាយនូវជំហានដែលបានធ្វើ ផ្ដើមចេញពីដំណាក់កាលចូលរួមរៀបចំ និងការប្រមូលទិន្នន័យទូលំទូលាយ រហូតដល់ការធ្វើវិភាគ ការធ្វើផែនការសេណារីយោ ការព្រាងប្លង់រួមស្ដីពីការប្រើប្រាស់ដីធ្លី និងការរៀបចំផែនការអភិវឌ្ឍន៍កាន់តែលម្អិត និងទៅតាមផ្នែកជាក់លាក់ផង។

**រូបភាព ប្រអប់** ២.៥ក៖ ជំហានពាក់ព័ន្ធនៅក្នុងការរៀបចំបង្កើតប្លង់ប្រើប្រាស់ដីធ្លីក្រុងបាត់ដំបង




*ប្រភព៖ យកលំនាំពីរបាយការណ៍បច្ចេកទេសស្ដីពីប្លង់ប្រើប្រាស់ដីធ្លីសម្រាប់ក្រុងបាត់ដំបង (២០០៩)*

នៅក្នុងជំហានដំបូងនៃការពាក់ព័ន្ធធ្វើការជាមួយទីភ្នាក់ងារ GIZ (កាលនោះជា DED) ក្រុងបាត់ដំបងគ្មានបទពិសោធន៍ស្តីពីការធ្វើផែនការរៀបចំក្រុងពីមុនមកទេ។ ការកសាងសមត្ថភាពបច្ចេកទេចាំបាច់ត្រូវបានធ្វើឡើងសឹងតែពីបាតដៃទទេ ហើយគេត្រូវប្រមែប្រមូលព័ត៌មានដើមគ្រាសិន យកមកតម្រៀប និងវិភាគ នៅក្នុងការរៀបចំឈានទៅបង្កើតប្លង់ប្រើប្រាស់ដីធ្លីមួយ។ ឧទាហរណ៍ ក្នុងនោះរួមមានការសិក្សាស្ទង់មើលផ្លូវដែលមានស្រាប់ក្នុងក្រុង និងការវាយតម្លៃសមត្ថភាពទ្រទម្ងន់បានរបស់បណ្តាញផ្លូវក្នុងក្រុង ក្នុងទំនាក់ទំនងទៅនឹងតម្រូវការរបស់នគូបនីយកម្ម។ កិច្ចការឆ្លុះបញ្ចាំងបូកសរុប និងវិភាគស្រដៀងគ្នានេះត្រូវបានធ្វើទៅលើផ្នែកហេដ្ឋារចនាសម្ព័ន្ធដទៃទៀតក៏ដូចជាទៅលើប្រភេទនៃការប្រើប្រាស់ដីធ្លីផ្សេងៗគ្នាដែរ។

កិច្ចការនេះត្រូវបានធ្វើដោយក្រុមការងារពហុផ្នែកមួយក្រុម ក្រោមការណែនាំរបស់អ្នកជំនាញមកពីទីភ្នាក់ងារ GIZ និងគណៈកម្មាធិការមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលមួយក្រុម។ ក្រុមការងារស្នូលមួយសម្រាប់រៀបចំប្លង់គោលរបស់ស្រុក (District Master Plan Team) ត្រូវបានបង្កើតឡើង ដោយមានសមាសភាពបុគ្គលិកបច្ចេកទេស ១០នាក់ មកពីមន្ទីរក្រុងនិងមន្ទីរខេត្ត។ សមាជិកមួយចំនួនរបស់ក្រុមការងារធ្លាប់បានទទួលការបណ្តុះបណ្តាលលើមុខវិជ្ជាប្រព័ន្ធព័ត៌មានភូមិសាស្ត្រ វិស្វកម្ម និងស្ថាបត្យកម្ម ប៉ុន្តែអ្នកនៅសល់ពីនោះអត់ដែលធ្លាប់មានបទពិសោធន៍ទាក់ទងទៅនឹងការធ្វើផែនការទេ។ ក្រុមការងារនេះធ្វើការជាមួយគ្នាបីថ្ងៃក្នុងមួយសប្តាហ៍ ដើម្បីបង្កើតប្លង់ប្រើប្រាស់ដីធ្លីដោយមានការចូលរួមជាប្រចាំរបស់មន្ត្រីរដ្ឋាភិបាល និងសាធារណជន ដើម្បីចែករំលែកការរកឃើញបឋម និងអនុសាសន៍គ្នា ហើយដើម្បីប្រមូលមតិតបសម្រាប់យកទៅពិភាក្សារៀបចំប្លង់ជាបន្តទៅទៀត។

សេចក្តីព្រាងចុងក្រោយនៃប្លង់ប្រើប្រាស់ដីធ្លី ត្រូវបានបង្កើតឡើងដោយផ្អែកទៅលើកំណើនសន្ទត់ក្នុងអត្រា ២,៥% ដែលជាសេណារីយោមួយក្នុងចំណោមសេណារីយោបីដែលក្រុមការងារប្លង់គោលប្រើប្រាស់ដីធ្លីយកមកពិចារណា។ សេចក្តីព្រាងនេះបានកំណត់អត្តសញ្ញាណការប្រើប្រាស់ដីធ្លី ១៤ប្រភេទ និងធ្វើការបញ្ជាក់ជាក់លាក់អំពីតំបន់ការពារពិសេសសម្រាប់បេតិកភណ្ឌ សម្រាប់ការផ្តល់លំនៅដ្ឋានតម្លៃទាប និងសម្រាប់ការពារបរិស្ថាន។ របាយការណ៍បច្ចេកទេសគ្រប់ជ្រុងជ្រោយមួយអមនឹងប្លង់នោះ ហើយក្នុងនោះរួមមានព័ត៌មានវិភាគហេដ្ឋារចនាសម្ព័ន្ធ និងប្រភេទដីប្រើប្រាស់ផ្សេងៗគ្នា ព្រមទាំងជំហានថែមទៀតដែលត្រូវប្រកាន់យកដើម្បីបង្កលក្ខណៈឱ្យមានការអនុវត្តប្លង់ប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព។

**រូបភាព ប្រអប់** ២.៥ខ៖ ប្លង់ប្រើប្រាស់ដីធ្លីរបស់ក្រុងបាត់ដំបងរហូតដល់ឆ្នាំ២០២០




*ប្រភព៖ របាយការណ៍បច្ចេកទេសស្តីពីប្លង់ប្រើប្រាស់ដីធ្លីសម្រាប់ក្រុងបាត់ដំបង (២០០៩)*

មានមេរៀនមួយចំនួនដែលគេអាចរៀនសូត្របានពីបទពសោធន៍ក្រុងបាត់ដំបង ក្នុងការបង្កើតប្លង់គោលក្រុង។

- **ការកសាងសមត្ថភាពតាមរយៈការបណ្ដុះបណ្ដាលនៅនឹងការងារផ្ទាល់៖** ក្រុមការងារប្លង់គោលស្រុក ទទួលបានអត្ថប្រយោជន៍ពីឱកាសបានចូលរួមជាផ្នែកមួយនៃដំណើការធ្វើផែនការប្រើប្រាស់ដីធ្លីទាំងមូល។ ខណៈដែលសកម្មភាពកសាងសមត្ថភាពច្រើនតែចប់នៅត្រឹមដំណាក់កាលរៀបចំចក្ខុវិស័យជាយុទ្ធសាស្ត្រ ឬពឹងផ្អែកខ្លាំងទៅលើអ្នកពិគ្រោះយោបល់មកពីខាងក្រៅឱ្យជួយបង្កើតប្លង់គោល ការចូលរួមរបស់ទីភ្នាក់ងារ GIZ បានរក្សាឱ្យមានការផ្ដោតការយកចិត្តទុកដាក់ទៅលើការកសាងសមត្ថភាពធ្វើផែនការរៀបចំក្រុងនៅកម្រិតមូលដ្ឋាន តាមរយៈការបណ្ដុះបណ្ដាលនៅនឹងការងារផ្ទាល់ជាបន្តបន្ទាប់។ ធ្វើដូច្នេះជួយឆ្លើយតបទៅនឹងការខ្វះខាតជំនាញបច្ចេកទេសនៅថ្នាក់ក្រុង - ដែលជាបញ្ហាប្រឈមធំមួយក្នុងការធ្វើផែនការរៀបចំក្រុងជាលក្ខណៈប្រព័ន្ធមួយ ដែលត្រូវបានរដ្ឋាភិបាលថ្នាក់ជាតិបន្តលើកឡើងមកទល់បច្ចុប្បន្ននេះ។

- **ការបង្កើតក្រុមការងាររៀបចំប្លង់គោលស្រុកមានលក្ខណៈអន្តរមុខវិជ្ជានិងពហុវិស័យមួយ៖** ក្រុមការងារស្នូលរៀបចំប្លង់គោលមានសមាសភាពជាមន្ត្រីជាន់ខ្ពស់ មកពីមន្ទីរក្រុង និងខេត្ត រួមទាំងមន្ទីរផែនការ មន្ទីរសាធារណការ និងមន្ទីរបរិស្ថានដែរ។ មុននឹងចាប់ផ្ដើមមានការរៀបចំផែនការ វាជារឿងទូទៅហើយដែលមន្ទីរផ្សេងៗគ្នាមានអន្តរកម្មតិចតួចបំផុតជាមួយគ្នាទៅវិញទៅមក ប្រសិនបើគេធ្លាប់មានមែននោះ។ អាស្រ័យហេតុនេះ អភិក្រមពហុវិស័យគឺមានភាពចាំបាច់ណាស់នៅពេលនោះ ដើម្បីធ្វើការវិភាគមួយឱ្យបានហ្មត់ចត់អំពីសេចក្ដីត្រូវការដីធ្លីក្នុងពេលបច្ចុប្បន្ន និងទៅពេលអនាគត និងដើម្បីវាយតម្លៃបញ្ហាប្រឈមក្នុងការអភិវឌ្ឍនានាដែលក្រុងបានជួបប្រទះ។ នៅពេលដែលការកសាងសមត្ថភាពពេលនោះផ្ដោតភាគច្រើនទៅលើតែថ្នាក់ក្រុង ក្រុមការងារធ្វើប្លង់គោលក៏ខិតខំដែរធ្វើយ៉ាងណាឱ្យអ្នកធ្វើសេចក្ដីសម្រេចថ្នាក់ខ្ពស់របស់រដ្ឋាភិបាល បានមកចូលរួមពាក់ព័ន្ធនៅក្នុងដំណាក់កាលសំខាន់ៗក្នុងការផ្ដល់មតិតប ឬធ្វើសេចក្ដីសម្រេចិត្ត ដូចជានៅក្នុងសិក្ខាសាលាដែលសេចក្ដីព្រាងផែនការត្រូវបានចែកជូនដើម្បីធ្វើការពិនិត្យ។

- **ការចាប់យកអភិក្រមបែបផែនចូលរួម៖** ដំណើរធ្វើផែនការមានការពិគ្រោះយោបល់ទៀងទាត់ជាមួយមន្ត្រីរដ្ឋាភិបាល និងសាធារណជន។ ដោយសារតែមិនសូវមានការស្គាល់អំពីគោលគំនិតប្លង់គោល ចាំបាច់ត្រូវមានកិច្ចប្រឹងប្រែងច្រើនដើម្បីចែករំលែកគោលបំណងនៃការរៀបចំផែនការតាំងពីដំណាក់កាលដំបូងឱ្យហើយ ហើយតាមរយៈនេះដំណើការមួយដែលមានអន្តរកម្មយ៉ាងសកម្មក្នុងការចែករំលែកសេចក្ដីព្រាងគ្នាទៅវិញទៅមក ត្រូវបានយកមកប្រើនៅក្នុងតាក់តែងរៀបចំផែនការ។ សំខាន់ វេទិការៀបចំប្លង់គោលមួយត្រូវបានបង្កើតឡើងសម្រាប់ប្រមែប្រមូលមតិតប ដោយមានការចូលរួមរបស់មនុស្សពី ៦០ ទៅ ៧០នាក់ មកពីក្នុងចំណោមសាធារណជន និងវិស័យឯកជន។ លក្ខណៈអន្តរវិស័យរបស់វេទិកានេះ បានជួយធានាយ៉ាងណាឱ្យអ្នករៀបចំបានស្ដាប់ឮទស្សនៈមកពីគ្រប់ជ្រុងទាំងអស់ ដែលជាការគិតគូរមួយសំខាន់នៅក្នុងបរិបទដែលមានភាពជំពាក់ទាក់ទងស្មុគស្មាញវែងឆ្ងាយរបស់ប្លង់គោលថ្មី។

- **ការកសាងប្លង់គោលមួយមានភាពជាក់លាក់សមតាមភាពជាក់ស្ដែងនៃក្រុងបាត់ដំបង៖** សម្ភាសន៍ជាមួយអ្នកជំនាញជាច្រើនដែលពាក់ព័ន្ធនៅក្នុងការងាររៀបចំប្លង់គោលនេះ បានលាតត្រដាងឱ្យដឹងថា កត្តាគន្លឹះមួយសម្រាប់នាំទៅរកជោគជ័យក្នុងកិច្ចការនេះគឺការកសាងប្លង់មួយដែលមានលក្ខណៈសមស្របសម្រាប់ក្រុងបាត់ដំបង សមតាមសភាពការណ៍នៃកម្រិតសមត្ថភាពបច្ចេក ទេសដែលក្រុងមានស្រាប់។ ការចូលពាក់ព័ន្ធនេះសង្កត់ធ្ងន់ទៅលើការកសាងមូលដ្ឋានគ្រឹះរឹងមាំមួយ ដើម្បីអនុវត្តការធ្វើផែនការរៀបចំក្រុងជាមួយនឹងទស្សនៈព្យាយាមរក្សាឥទ្ធិពលរបស់វា តាមរយៈការផ្ដល់ការណែនាំនៅក្នុងរបាយការណ៍បច្ចេកទេសសម្រាប់សកម្មភាពដែលត្រូវបន្តធ្វើ ទៅមុខទៀត។

*ប្រភព៖ ព័ត៌មានដែលក្រុមការងារប្រមូលបានតាមរយៈសម្ភាសន៍ជាមួយអ្នកជំនាញរបស់ទីភ្នាក់ងារ GIZ និងព័ត៌មានដែលត្រូវបានដកស្រង់ចេញពីរបាយការណ៍បច្ចេកទេសស្ដីពីប្លង់ប្រើប្រាស់ដីធ្លីសម្រាប់ក្រុងបាត់ដំបង (២០០៩)។*

## ក្រុងព្រះសីហនុ

យោងតាមប្រវត្តិកន្លងមក ក្រុងព្រះសីហនុធ្លាប់មានប្លង់អភិវឌ្ឍន៍ក្រុងមួយចំនួន ក្នុងនោះមានប្លង់របស់លោកស្ថាបត្យករ វណ្ណ មូលីវណ្ណ (១៩៥៩), ប្លង់របស់ Ariston-ACER (ក្រុមហ៊ុនម៉ាឡេស៊ី) (១៩៩៥), ប្លង់អភិវឌ្ឍន៍ក្រុងព្រះសីហនុរបស់រាជរដ្ឋាភិបាលកម្ពុជា (២០០៣), ប្លង់អភិវឌ្ឍន៍តំបន់ស្ទឹងហាវ (២០០៣), ប្លង់របស់ក្រុមហ៊ុន Vinci (ក្រុមហ៊ុនបារាំង) (២០០៦), និងសេចក្ដីព្រាងប្លង់គោលរបស់ក្រុងព្រះសីហនុ (ជាផ្នែកមួយនេះ ផែនការអភិវឌ្ឍន៍តំបន់ឆ្នេរខាងត្បូង) ដែលទទួលបានការគាំទ្រពីអង្គការ JICA ជាផ្នែកមួយនៃយុទ្ធសាស្ត្របែបសមាហរណកម្មថ្នាក់ជាតិសម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរ និងការរៀបចំប្លង់គោល (២០១០)[៩០]។ សេចក្ដីព្រាង ប្លង់គោលដែលមានការជួយឧបត្ថម្ភរបស់អង្គការ JICA ដូចមានបង្ហាញជូនក្នុងរូបភាព ២.១០ គឺជាប្លង់ចុងក្រោយគេបង្អស់ ហើយមានភាពគ្រប់ជ្រុងជ្រោយជាងគេដែលមានមកទល់សព្វថ្ងៃនេះដែរ ក៏ប៉ុន្តែ តាំងតែពីឆ្នាំ២០១០នោះមក សកម្មភាពអភិវឌ្ឍន៍គ្មាននិយតភាពច្រើនណាស់បានកើតឡើងព្រោងព្រាត ហើយអាស្រ័យហេតុនេះ ភាគច្រើននៃទិន្នន័យ និងអនុសាសន៍នៅក្នុងសេក្ដីព្រាងប្លង់គោលនេះប្រហែលក្លាយទៅជាព័ត៌មានចាស់ហួសសម័យទៅហើយ។

ប្លង់គោលនេះមានចក្ខុវិស័យដល់ឆ្នាំ២០៣០ ដោយគ្របដណ្ដប់លើទិដ្ឋភាពជាច្រើន មានយុទ្ធសាស្ត្រសេដ្ឋកិច្ច-សង្គម យុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្ម គោលគំនិតផែនការប្រើប្រាស់ដីធ្លី សំណើប្រព័ន្ធ ដឹកជញ្ជូន សេវាទឹកភ្លើង និងផែនការហេដ្ឋរចនាសម្ព័ន្ធ។ ប្លង់នេះត្រូវបានកសាងឡើងនៅជុំវិញក្រុងព្រះសីហនុជាច្រកទ្វារឆ្លងកាត់សម្រាប់ការប្រមូលផ្ដុំ និងការធ្វើពាណិជ្ជកម្មអន្តរជាតិ និងជាមូលដ្ឋានយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចមួយនៅជុំវិញយុទ្ធសាស្ត្រតម្រង់ទិសសម្រាប់ការនាំចេញ (តំបន់សេដ្ឋកិច្ចពិសេស) ការវិនិយោគលើធនធាន និងឧស្សាហកម្មយកកសិកម្មជាមូលដ្ឋាន ការកែច្នៃកសិផល និងផលនេសាទសមុទ្រ និងវិស័យទេសចរណ៍។ យុទ្ធសាស្ត្រដែលបានស្នើឡើង បានដាក់ការសង្កត់ធ្ងន់ទៅលើការអភិរក្ស/ការការពារបរិស្ថាននិងជីវៈចម្រុះដល់តំបន់ដីសម្បទានខ្នាតធំដែលបានផ្ដល់ឱ្យផ្នែកឯកជន តំបន់ទឹកសាប និងតំបន់ព្រៃការពារជាដើម។ សកម្មភាពអភិវឌ្ឍន៍ត្រូវបានហាមឃាត់នៅភាគនិរតីរបស់ក្រុង (ជាតំបន់ឆ្នេរខ្សាច់)។ ផ្លូវរថភ្លើងត្រូវបានស្ដារឱ្យដំណើរការឡើងវិញហើយដើម្បីបម្រើសេវាដល់ការដឹកទំនិញធំៗមកនិងពីក្រុងភ្នំពេញ។ ផ្លូវជាតិលេខ៤នឹងទុកសម្រាប់បម្រើដល់ការមកដល់របស់ភ្ញៀវ និងចរាចរណ៍រថយន្ត។

នៅកម្រិតក្រុង ផែនការប្រើប្រាស់ដីធ្លីមួយកំពុងត្រូវបានព្រាង (ជំហានទី៣ ក្នុងវដ្ដផែនការមាន៩ជំហាន) ហើយត្រូវបានគេរំពឹងទុកថានឹងព្រាងចប់រួចរាល់នៅមុនការបោះឆ្នោតជាតិ ក្នុងខែកក្កដា ឆ្នាំ២០១៨។ ដោយមានស្ថាបត្យករ/អ្នកគូរប្លង់តែពីរនាក់ធ្វើការក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ការរៀបចំផែនការនេះត្រូវពឹងផ្អែកខ្លាំងទៅលើការជួយគាំទ្រពីសំណាក់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ តួនាទីរបស់ «ផ្នែកអភិវឌ្ឍន៍ក្រុង» នៅក្នុងការធ្វើផែនការនៅមានកម្រិត ឬសឹងតែគ្មានតែម្ដង សំខាន់មកពីគ្មានធនធាន (ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស)។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានអនុម័តលើសារាចរមួយស្ដីពីការអភិវឌ្ឍន៍តំបន់ឆ្នេរ ដែលហាមឃាត់ការចាប់យកដីឬឆ្នេរខ្សាច់ខុសច្បាប់ បានកំណត់ឱ្យមានរយាលគម្លាតរវាងសំណង់ និងតម្រូវឱ្យមានការអនុញ្ញាតសិនមុននឹងធ្វើការសាងសង់។ សារាចរស្ដីពីការអភិវឌ្ឍតំបន់ឆ្នេរបានផ្ដល់វេទិកាល្អមួយសម្រាប់ធ្វើការត្រួតត្រាពិនិត្យលើដង់ស៊ីតេ និងកម្ពស់របស់សំណង់អគារ។ គណៈកម្មាធិការអ្នកពាក់ព័ន្ធចម្រុះថ្នាក់ខេត្តមួយបានបង្កើតឡើងដើម្បីជំរុញការអនុវត្តបទបញ្ញត្តិធ្វើផែនការនេះ ប៉ុន្តែប្រសិទ្ធភាពរបស់វានៅតែរឿងមួយគួរឱ្យឆ្ងល់ខ្លាំងនៅឡើយ។ ថ្មីៗនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងរដ្ឋាភិបាលកូរ៉េ តាមរយៈទីភ្នាក់ជំនួយ KOIKA បានរួមគ្នាផ្ដើមសហការលើគម្រោង “Smart City” មួយ ដោយជួយដល់ក្រុងព្រះសីហនុនៅក្នុងការធ្វើប្លង់គោលសម្រាប់ស្រុកស្ទឹងហាវ ក្រុងព្រះសីហនុ និងតំបន់នៅជុំវិញកំពង់ផែ។ អាជ្ញាធរមានផែនការនឹងបញ្ចូលឃុំពីរទៀត គឺឃុំរាម និងបិតត្រាង ក្នុងស្រុកព្រៃនប់ ទៅក្នុងដែនសមត្ថកិច្ចរបស់ក្រុងព្រះសីហនុវិញ។

---

៩០ Korea, 2017.

**រូបភាព ២.១០៖** សេចក្តីព្រាងប្លង់គោលរបស់ទីភ្នាក់ងារ JICA សម្រាប់ក្រុងព្រះសីហនុ




*ប្រភព៖ JICA, The Study on National Integrated Strategy of Coastal Area and Master Plan of Sihanoukville for Sustainable Development, 2010.*

## ២.៣.៤ សន្និដ្ឋាន

ប្រឈមជាមួយនឹងការរីកចម្រើនយ៉ាងលឿនរបស់នគូបនីយកម្ម បញ្ហាសម្រាប់ទីក្រុងទាំងអស់ គឺត្រូវប្រឹងឱ្យហួសពីការអភិវឌ្ឍតាមលំនាំដោយអន្លើ(គ្មានលក្ខណៈជាប្រព័ន្ធ) ដែលកំពុងតែរីកខ្លាំងឡើងៗ ដោយឈានទៅធ្វើឱ្យមានកំណើនប្រកបដោយចីរភាពយូរអង្វែង ទ្រទ្រង់ដោយផែនការរៀបចំក្រុងដែលមានស្វាហាប់ និងភាពអនុវត្តបានក្នុងស្ថានភាពជាក់ស្តែង។ នេះគឺជាចំណោទស្រាប់ក្រុងភ្នំពេញ និងក្រុងលំដាប់ទីពីរ។ បញ្ហាប្រឈមដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងផ្នែកនេះ - រួមមានការវិនិយោគមិនគ្រប់គ្រាន់ទៅលើហេដ្ឋារចនាសម្ព័ន្ធ សមត្ថភាពបច្ចេកទេសទាប កង្វះភាពច្បាស់លាស់របស់តួនាទីនិងការទទួលខុសត្រូវ បរិស្ថាននិយតកម្មខ្សោយ និងការខ្វះខាតរបស់ហិរញ្ញប្បទាន - បានធ្វើឱ្យការងារធ្វើផែនការរៀបចំក្រុងដើរយឺត នៅពីក្រោយសកម្មភាពអភិវឌ្ឍន៍ក្រុងនៅប្រទេសកម្ពុជា ជាជាងដឹកមុខសកម្មភាពទាំងនោះ។ ដរាបណាដែលការអភិវឌ្ឍក្រុងចេះតែបន្តវិវត្តតាមបែបខ្វះនិយតភាព គោលគំនិតនៃការអភិវឌ្ឍតាមផែនការជាលក្ខណៈប្រព័ន្ធមួយនឹងមានហានិភ័យ រហូតដល់អាចធ្វើឱ្យវាប្រាស់ចាកបន្តិចម្តងៗពីភាពជាក់ស្តែងនៃកិច្ចការអភិបាលកិច្ចទីក្រុង[៩១]។ ដោយសារតែមានភ័ស្តុតាងតិចតួចឬក៏គ្មានសោះតែម្តងថា តើការរៀបចំផែនការល្អមួយអាចនាំមកនូវអត្ថប្រយោជន៍ដល់ក្រុងបានដូចម្តេចខ្លះ ភាពចាំបាច់ដែលគេធ្លាប់យល់ឃើញសម្រាប់ការធ្វើផែនការរៀបចំក្រុង និងចំណាប់អារម្មណ៍នៅក្នុងការកសាងសមត្ថភាព ក៏កាន់តែមានថមថយសារៈសំខាន់បន្តិចម្តងៗទៅដែរ។

---

៩១ Goad, 2012.

ផ្នែកទី ៣

# កាលានុវត្តភាពសម្រាប់ឈានទៅសម្រេចឱ្យបានពេញលេញនូវសក្តានុពលរបស់នគូបនីយកម្ម



## ៣.១ សេចក្តីផ្តើម

សក្តានុពលសេដ្ឋកិច្ចរបស់ទីក្រុងមួយចំនួនក្នុងប្រទេសកម្ពុជា ផ្តល់កាលានុវត្តភាពច្រើនដល់កំណើនសេដ្ឋកិច្ច ភាពប្រកួតប្រជែង និងការកាត់បន្ថយភាពក្រីក្រ ទៅថ្ងៃអនាគត។ ប៉ុន្តែទន្ទឹមគ្នានេះ បញ្ហាប្រឈមនានាពាក់ព័ន្ធទៅនឹងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ការធ្វើផែនការនិងការគ្រប់គ្រងក្រុង និងការធ្វើហិរញ្ញប្បទាន ជាឧបសគ្គដល់កាលានុវត្តភាពទាំងនោះទៅវិញ។

ការបង្កើតឱ្យបាននូវមជ្ឈមណ្ឌលក្រុងនៃកំណើនសេដ្ឋកិច្ច ដែលមានមេត្រីភាពដល់ការរស់នៅ មានចីរភាព និងភាពបរិយាប័ន្ន នឹងដើរតួជាស្នូលសម្រាប់ការអភិវឌ្ឍរបស់កម្ពុជា ទៅពេលអនាគត។ គ្មានប្រទេសណាមួយដែលបានក្លាយជាប្រទេសមានចំណូលមធ្យម ដោយមិនបានឆ្លងកាត់ការធ្វើនគូនីយកម្មទេ ហើយមាគ៌ាដែលការធ្វើនគូបនីយកម្មដើរតាមនោះ អាចទទួលឥទ្ធិពលវិជ្ជមានច្រើនពីការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព ការធ្វើផែនការរៀបចំក្រុងនិងប្រើប្រាស់ដីធ្លី សមត្ថភាពរបស់រដ្ឋបាលមូលដ្ឋាន ការពង្រឹងសមត្ថភាពស្ថាប័ន និងការពង្រីកឱកាសសម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍក្រុង។ ការធានាយ៉ាងណាឱ្យមានអភិក្រមបរិយាប័ន្នក៏មានសារៈសំខាន់ខ្លាំងដែរ ដើម្បីកុំឱ្យក្រុមពលរដ្ឋមានចំណូលទាបនៅដាច់ឆ្ងាយក្រោយគេខ្លាំងពេក។

ផ្នែកខាងក្រោមៗបន្តទៅនេះ លើកឡើងនូវសំណុំអនុសាសន៍គោលនយោបាយអាទិភាពសម្រាប់ការធ្វើនគូនីយកម្ម ដែលជាតម្រូវការចាំបាច់សម្រាប់តំបន់ទីប្រជុំជនទាំងអស់។ អនុសាសន៍គោលនយោបាយទាំងនេះ នឹងត្រូវបានអមដោយអនុសាសន៍ជាក់លាក់ច្រើនទៀត ស្របទៅតាមប្រភេទរបស់ក្រុងនៅកម្ពុជា -- ក្រុងច្រករបៀងសេដ្ឋកិច្ចក្នុងតំបន់, ទីក្រុងច្រកឆ្លងកាត់, ក្រុង/ទីប្រជុំជនតាមព្រំដែន និងក្រុងរាជធានី -- និងឧទាហរណ៍នៃអភិក្រមផ្សេងៗសម្រាប់យកទៅអនុវត្ត។ ដោយសារក្រុងមានទំហំទ្រង់ទ្រាយខុសៗគ្នាច្រើន (ទំហំ ទិសដៅសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រ

និងលទ្ធភាពចេញចូល ធនធានធម្មជាតិ កម្រិតចំណូល ប្រវត្តិប្រព័ន្ធនយោបាយ សមត្ថភាពស្ថាប័ន និង ស្វ័យភាព ជាដើម) អភិក្រមឆ្ពោះទៅធ្វើការវិនិយោគ និងការជួយឧបត្ថម្ភ ចាំបាច់ត្រូវតែរៀបចំតម្រូវទៅតាមភាពចាំបាច់ជាក់លាក់ផ្សេងៗគ្នាដែរ។

## ៣.១.១ អាទិភាពសម្រាប់ពង្រឹងការអភិវឌ្ឍទីក្រុងរបស់កម្ពុជា

ជម្រើសគោលនយោបាយដែលបានដាក់ចេញ នៅក្នុងរបាយការណ៍ Urban Development in Phnom Penh, 2017 របស់ធនាគារពិភពលោក ជារួម មានសង្គតិភាពជាមួយនឹងភាពចាំបាច់របស់បណ្ដាទីក្រុងដែរ ហើយនឹងតម្រូវឱ្យមានការយកចិត្តទុកដាក់ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ខេត្ត និងទាំងថ្នាក់មូលដ្ឋាន។ អនុសាសន៍ទាំងនេះត្រូវបានយកលំនាំតាមរបាយការណ៍កាលពីពេលថ្មីៗមួយ និងត្រូវបានសង្ខេបជូននៅក្នុងតារាង ៣.១ ហើយក្នុងនោះមានអនុសាសន៍បន្ថែមមួយចំនួនទៀត ដែលកើតចេញពីការវិភាគទូលំទូលាយបន្តិចដោយបញ្ចូលទីក្រុងលំដាប់ទីពីរទៅក្នុងនោះផង។ ខណៈដែលជម្រើសគោលនយោបាយភាគច្រើនមានភាពទូលំទូលាយ ពួកវាសុទ្ធតែជាអាទិភាពជាសារវន្តសម្រាប់ការធ្វើនគរូបនីយកម្មប្រកបដោយចីរភាព និងប្រកបដោយបរិយាប័ន្ន។ តារាងនេះបង្ហាញផងដែរនូវការធ្វើអាទិភាពជាក់លាក់មួយចំនួនសម្រាប់ទីក្រុងទាំងបួនប្រភេទ។ ប៉ុន្តែ ភាគច្រើនអាទិភាពជាសារវន្តនោះ ដូចជាការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព ការពង្រឹងស្ថាប័ននិងការផ្ដល់ហិរញ្ញប្បទាន និងការធានាឱ្យមានអភិក្រមបរិយាប័ន្ន សុទ្ធតែជាភាពចាំបាច់សម្រាប់ឈានទៅសម្រេចឱ្យបានពេញលេញ នូវសក្ដានុពលនៃនគរូបនីយកម្មនៅតាមតំបន់ក្រុងទាំងអស់។

**តារាង ៣.១៖** សេចក្ដីសង្ខេបអនុសាសន៍គោលនយោបាយអាទិភាព

| ផ្នែកគោលនយោបាយ | អនុសាសន៍ | ក្របខណ្ឌពេលវេលា (ខ(ខ្លី), ម (មធ្យម), វ (វែង)) | រាជធានី | ទីក្រុងច្រកឆ្លងកាត់ | ទីក្រុងច្រករបៀងសេដ្ឋកិច្ចក្នុងតំបន់ | ទីក្រុង/ទីប្រជុំជនតាមព្រំដែន |
|---|---|---|---|---|---|---|
| | | | មានទំនាក់ទំនងសារៈសំខាន់ខ្ពស់សម្រាប់ទីក្រុងតាមប្រភេទជាក់លាក់ | | | |
| ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព | • បង្កើនការវិនិយោគលើផ្នែកហេដ្ឋារចនាសម្ព័ន្ធអាទិភាព៖ បណ្ដាញផ្លូវក្រុង លូបង្ហូរទឹកនិងប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធប្រព្រឹត្តិកម្មទឹកស្អុយនិងទឹកកង្វក់ ការគ្រប់គ្រងសំណល់រឹង លំនៅដ្ឋានតម្លៃសមរម្យអាចជាវបាន និងការកែលម្អតាមសហគមន៍<br>• ផ្ដើមបង្កើតអភិក្រមចម្រុះសម្រាប់ធ្វើឱ្យភូមិដ្ឋានមានភាពរស់រវើកឡើងវិញ នៅតាមតំបន់យុទ្ធសាស្ត្ររបស់ក្រុងធំៗ<br>• ធានាឱ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងការធ្វើអាទិភាព និងរៀបចំគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធ | ម/វ<br>ខ<br>ខ | | | | |
| លើកកម្ពស់អភិក្រមតាមដែនដីសម្រាប់ក្រុងច្រករបៀងសំខាន់ៗ | • ពង្រឹងពង្រីកការតភ្ជាប់បណ្ដាញគមនាគមន៍រវាងទីក្រុង និងក្នុងរង្វង់ទីក្រុង ដើម្បីបង្កើនភាពប្រកួតប្រជែងរបស់ទីក្រុង តាមរយៈការវិនិយោគលើបណ្ដាញហេដ្ឋារចនាសម្ព័ន្ធមានប្រសិទ្ធផល។<br>• ចាប់យកអភិក្រមតាមដែនដីជាមួយនឹងទស្សនៈពង្រាយជាយុទ្ធសាស្ត្រនូវហេដ្ឋារចនាសម្ព័ន្ធសម្រាប់ជំរុញឱ្យមានកំណើនប្រកបដោយបរិយាប័ន្ននិងប្រកបដោយចីរភាព។ | ខ/ម<br>ម/វ | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ពង្រឹងស្ថានប័ន និងការផ្ដល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍក្រុង | • ស្រាយបំភ្លឺតួនាទីនិងការទទួលខុសត្រូវរវាងមន្ទីរខ្សែបណ្ដោយក្រសួងនិងរដ្ឋបាលមូលដ្ឋាន ដើម្បីធានាយ៉ាងឱ្យការធ្វើផែនការរៀបចំក្រុង និងការផ្ដល់សេវាត្រូវបានច្របាច់ចូលគ្នា និងមានចីរភាព<br>• ធ្វើការកសាងសមត្ថភាពជាតម្រូវការចាំបាច់សម្រាប់ស្ថាប័នថ្នាក់មូលដ្ឋាន រួមទាំងសមត្ថភាពបច្ចេកទេស និងសមត្ថភាពអនុវត្តផែនការ<br>• ធ្វើឱ្យមានភាពប្រសើរឡើងក្នុងការសម្របសម្រួលរវាង និងនៅតាមក្រុងពាក់ព័ន្ធ ពិសេសសម្រាប់ក្រុងធំៗ (ដូចជាក្រុងភ្នំពេញនិងតំបន់ជុំវិញ) នៅលើការងារហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងការផ្ដល់សេវា<br>• សម្របក្របខណ្ឌផ្នែកច្បាប់ ផ្នែកនិយតកម្ម និងផ្នែកពង្រឹងការអនុវត្តច្បាប់សម្រាប់ការអភិវឌ្ឍទីក្រុងជាមួយការធ្វើផែនការរៀបចំក្រុង (មើលខាងក្រោម)<br>• ផ្ដល់ក្របខណ្ឌសារពើពន្ធមួយមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានតម្លាភាព និងអាចព្យាករបាន សម្រាប់បណ្ដាទីក្រុង<br>• សិក្សារកលទ្ធភាពអភិក្រមថ្មីៗឈានទៅពង្រឹងវិសាលភាព ប្រសិទ្ធភាព និងគណនេយ្យភាពនៅក្នុងការប្រើប្រាស់ហិរញ្ញប្បទានក្រុង៖<br>➢ ចាប់ផ្ដើមផ្ទេរសម្បទានជាប់លក្ខខណ្ឌទៅឱ្យគណនីក្រុងសម្រាប់បម្រើដល់មុខងារដែលត្រូវបានធ្វើវិមជ្ឈការ ដោយផ្ដើមពីការអនុវត្តតាមការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើសម្បទានសម្រាប់កិច្ចការសំណល់រឹង<br>➢ ការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គមទៅលើក្រុមប្រឹក្សាទាំងអស់ក្រុង និងដាក់ឱ្យប្រើ ប័ណ្ណស្រង់យោបល់របស់ពលរដ្ឋ សម្រាប់ក្រុងធំៗមួយចំនួនសិន<br>➢ ដាក់ឱ្យប្រើ សម្បទានបំពេញមុខងារ (performance grants) ជាផ្នែកមួយនៃការផ្ទេររបស់មូលនិធិស្រុក/ក្រុង<br>• សិក្សាលទ្ធភាពប្រើយន្តការយកពន្ធលើផលចំណេញពីការកើនតម្លៃដីដោយសារការបំពាក់ហេដ្ឋារចនាសម្ព័ន្ធ (Land Value Capture) សម្រាប់ផ្ដល់ហិរញ្ញប្បទានឱ្យទីក្រុង<br>• ពង្រីកឱ្យបានអតិបរមានូវសក្ដានុពលសម្រាប់ប្រមូលចំណូលពីប្រភពរបស់ខ្លួន<br>• ដាក់ចេញឱកាសច្រើនថែមទៀតសម្រាប់ពង្រីកឱ្យបានអតិបរមានូវហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ តាមរយៈការចូលរួមរបស់ផ្នែកឯកជន | ខ<br>ម<br>ម<br>ម/វ<br>ម<br>ខ/ម<br>ខ/ម<br>ខ<br>ខ/ម | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ធ្វើឱ្យប្រសើរដល់ការបង្កើត និងការអនុវត្តផែនការរៀបចំក្រុង | • ពង្រឹងបណ្ដាញទំនាក់ទំនងរវាងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីជាអំណោយផលដល់ការអភិវឌ្ឍមានភាពសម្របសម្រួលកាន់តែប្រសើរឡើង<br>• កសាងសមត្ថភាពថ្នាក់មូលដ្ឋាន ដើម្បីយករៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធនិងប្លង់ប្រើប្រាស់ដីធ្លីមានលក្ខណៈសម្របសម្រួលនិងប្រកបដោយចីរភាព ក្នុងនោះមានផែនការជាដំណាក់កាលសម្រាប់ការវិនិយោគ និងការអនុវត្ត ផងដែរ<br>• ដាក់ចេញច្បាប់និងក្រមចាំបាច់ថែមទៀតដើម្បីសម្រួលដល់ការអនុវត្តប្លង់ប្រើប្រាស់ដីធ្លីលម្អិត<br>• បញ្ចូលវិធានការភាពធន់នៅក្នុងការធ្វើផែនការរៀបចំក្រុងដើម្បីកាត់បន្ថយហានិភ័យ<br>• បង្កើតក្របខណ្ឌសម្រាប់ការប្រមូល ការចែករំលែក និងការវិភាគទិន្នន័យក្រុង | ខ<br><br>ម<br><br>ម/វ<br><br>ខ<br>ខ/ម | | | | |
| ធានាឱ្យមានអភិក្រមបែបរិយាប័ន្ន | • ធានាយ៉ាងណាឱ្យការវិនិយោគលើហេដ្ឋរចនាសម្ព័ន្ធប្រកបដោយចីរភាពបានទៅដល់ជនក្រីក្រ<br>• ធានាយ៉ាងណាឱ្យអត្ថប្រយោជន៍សេដ្ឋកិច្ចបានទៅដល់សេដ្ឋកិច្ចក្នុងមូលដ្ឋាន (ផ្លូវដឹកជញ្ជូនរវាងទីក្រុង ការបណ្ដុះបណ្ដាលការងារ)<br>• បង្កើនការបណ្ដុះបណ្ដាលការងារ សហគ្រាសខ្នាតតូច និងកម្មវិធីផ្សេងទៀត សម្រាប់ជនក្រីក្ររស់នៅតាមទីក្រុង<br>• ពង្រីកការចូលរួមរបស់សហគមន៍តាមរយៈការបង្កើនការចូលពាក់ព័ន្ធរបស់សហគមន៍នៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចលើការប្រើមូលនិធិឃុំ/សង្កាត់។ | ខ<br>ខ<br><br>ខ<br><br>ខ | | | | |

*ប្រភព៖ សង្ខេបចេញពីរបាយការណ៍ World Bank 2017, Phnom Penh Urban Development, World Bank Team.  ខ-រយៈពេលខ្លី (១៨ខែ), ម-រយៈពេលមធ្យម (២ ទៅ ៥ឆ្នាំ), វ-រយៈពេលវែង (៥ឆ្នាំឡើងទៅ)*
*រាជធានី៖ ភ្នំពេញ*
*ទីក្រុងច្រកឆ្លងកាត់៖ ភ្នំពេញ សៀមរាប ព្រះសីហនុ*
*ទីក្រុងច្រករៀងសេដ្ឋកិច្ចក្នុងតំបន់៖ បាត់ដំបង កំពង់ចាម ស៊ីសុផុន កំពង់ឆ្នាំង កំពត កែប និងផ្សេងទៀត*
*ទីក្រុង/ទីប្រជុំជនតាមព្រំដែន៖ ប៉ោយប៉ែត បាវិត*

## ៣.២ ការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព

ឤភាពចាំបាច់ផ្នែកហេដ្ឋារចនាសម្ព័ន្ធអាទិភាពមួយចំនួន ត្រូវបានកំណត់អត្តសញ្ញាណរួចហើយ នៅក្នុងជំពូកទី ២ ដើម្បីធ្វើឱ្យប្រសើរនូវលទ្ធភាពទទួលបានសេវាជាមូលដ្ឋាន និងគុណភាពរបស់វា នូវលក្ខខណ្ឌនៃជីវភាពរស់នៅ បង្កើតការងារ លើកកម្ពស់ភាពបរិយាប័ន្ន និងធានាយ៉ាងណាឱ្យមានចីរភាពនិងភាពធន់។ នៅក្នុងចំណោមការវិនិយោគទាំងនោះមាន តម្រូវការចាំបាច់ឱ្យមានផ្លូវគមនាគមន៍រវាងទីក្រុង និងក្នុងរង្វង់ទីក្រុង បណ្ដាញលូបង្ហូរទឹកនិងប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធប្រព្រឹត្តិកម្មទឹកស្អុយនិងទឹកកង្វក់ ការគ្រប់គ្រងសំណល់រឹង ការផ្គត់ផ្គង់ទឹកស្អាត លំនៅដ្ឋានតម្លៃសមរម្យអាចជាវបាន ការកែលម្អសហគមន៍ ជាពិសេសនៅតាមតំបន់មានចំណូលទាប។ ដោយសារតែធនធានហិរញ្ញវត្ថុនៅមានកម្រិត និងកង្វះសមត្ថភាព សំខាន់ណាស់ដែលការវិនិយោគទាំងនេះមានការបែងចែកជាលក្ខណៈយុទ្ធសាស្ត្រ - ទាំងទៅតាមផ្នែក ទាំងទៅតាមភូមិសាស្ត្រ - ដើម្បីធានាឱ្យមានកំណើនប្រកបដោយចីរភាព បរិយាប័ន្ន មានភាពធន់ និងមានភាពប្រកួតប្រជែងនៅទូទាំងប្រទេសកម្ពុជា។ សម្រាប់តំបន់យុទ្ធសាស្ត្រខ្លះនៅក្នុងប្រទេស ការវិនិយោគទៅលើបណ្ដាញផ្លូវគមនាគមន៍រវាងទីក្រុងដោយប្រើអភិក្រមអភិវឌ្ឍន៍តាមយុត្តាធិការដែនដី អាចជួយលើកស្ទួយឱ្យមានឱកាសច្រើនថែមទៀតសម្រាប់កំណើន និងភាពប្រកួតប្រជែង។

ដូចបានរៀបរាប់ជូនរួចហើយនៅក្នុងផ្នែក ១.២ លទ្ធផលវិភាគសន្ទស្សន៍ EPI បង្ហាញឱ្យឃើញ កន្សោមទីក្រុងតំបន់នៅទូទាំងប្រទេសកម្ពុជា ដែលមានសក្ដានុពលសេដ្ឋកិច្ចខ្លាំង តាមរយៈការវាស់វែងលទ្ធភាពចូលដល់ទីផ្សារ បណ្ដាញភ្ជាប់ផ្លូវដឹកជញ្ជូនដល់ស៊ីតេសេដ្ឋកិច្ច កម្រិតនគរូបនីយកម្ម និងមូលធនមនុស្ស។ កន្សោមតំបន់របស់ក្រុង/ស្រុកមានសក្ដានុពលខ្ពស់ដែលត្រូវបានកំណត់ដោយសន្ទស្សន៍ EPI គឺមានរាជធានីភ្នំពេញនិងតំបន់ជាប់ជាយក្រុង (រួមមានខណ្ឌទាំងអស់ក្នុងក្រុងភ្នំពេញ ក្រុងច្បារមន និងស្រុកមួយចំនួនរបស់ខេត្តកណ្ដាល និងស្រុកមួយចំនួនទៀតក្នុងខេត្តព្រៃវែង); នៅប៉ែកអាគ្នេយ៍ (មានស្រុកមួយចំនួនក្នុងខេត្តតាកែវ), ប៉ែកឆ្នេរខាងត្បូង (ស្រុកមួយចំនួនរបស់ខេត្តកោះកុង ព្រះសីហនុ និងកែប), ប៉ែកពាយ័ព្យ (មានស្រុកមួយចំនួនរបស់បាត់ដំបង សៀមរាប ស៊ីសោភ័ណ និងប៉ោយប៉ែត), ប៉ែកកណ្ដាល (ស្រុកមួយចំនួនរបស់ក្រុងកំពង់ចាម កំពង់ឆ្នាំង ពោធិសាត់ និងស្ទឹងសែន), និងប៉ែកឧត្តរ និងប៉ែកឦសាន (មានស្រុកមួយចំនួនរបស់ក្រុងក្រចេះ ព្រះវិហារ រតនគីរី និងក្រុងស្ទឹងត្រែង)។ លើសពីនេះ ផ្នែក ១.៣ បានចាត់ចំណាត់ថ្នាក់ទីក្រុងលំដាប់ទីពីរធំៗ (ដែលជាក្រុងមានសក្ដានុពលសេដ្ឋកិច្ចខ្ពស់ដែរនៅក្នុងកន្សោមតំបន់) ជាបួនប្រភេទ អាស្រ័យទៅតាមមុខងាររបស់វា៖ ទីក្រុងច្រករបៀងសេដ្ឋកិច្ចក្នុងតំបន់, ទីក្រុងច្រកឆ្លងកាត់, ទីក្រុង/ទីប្រជុំជនតាមព្រំដែន, និងទីក្រុងរាជធានី។ សំខាន់ត្រូវទទួលស្គាល់មុខងារ និងភាពខ្លាំងរបស់ទីក្រុងនីមួយៗដើម្បីយកទៅពង្រីកបន្ថែម កាលណាធ្វើការកំណត់អត្តសញ្ញាណហេដ្ឋារចនាសម្ព័ន្ធធំៗ និងការវិនិយោគជាលក្ខណៈយុទ្ធសាស្ត្រអាទិភាព។

## ៣.៣ លើកកម្ពស់ការអភិវឌ្ឍដែនដីដោយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ឱ្យមានរបាយជាលក្ខណៈយុទ្ធសាស្ត្រ ទាំងនៅតាមវិស័យ និងទាំងនៅតាមភូមិសាស្ត្រ

ទីក្រុងលំដាប់ទីពីរធំៗទាំងអស់ក្នុងប្រទេសកម្ពុជា សុទ្ធតែស្ថិតក្នុងទីតាំងជាលក្ខណៈយុទ្ធសាស្ត្រ ក្នុងច្រករបៀងសេដ្ឋកិច្ចប៉ែកខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ ដែលតភ្ជាប់ផ្ទៃក្នុងរបស់ប្រទេសផង និងប្រទេសទាំងមូលទៅនឹងទីផ្សារអន្តរជាតិសំខាន់ៗនៅជិតខាងផង មានប្រទេសឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។ ដោយភ្ជាប់ខ្លួនជាមួយប៉ូលសេដ្ឋកិច្ចសំខាន់តាមរយៈបណ្ដាញហេដ្ឋរចនាសម្ព័នមានប្រសិទ្ធផល ច្រករបៀងសេដ្ឋកិច្ចរបស់កម្ពុជាបានពង្រឹងដល់ការសម្រួលផ្នែកពាណិជ្ជកម្មរវាងតំបន់ (សកល) និងពង្រីកតម្លៃបន្ថែមដល់ខ្សែចង្វាក់តម្លៃ ហើយទន្ទឹមគ្នានោះរួមចំណែកដល់ការអភិវឌ្ឍក្នុងផ្ទៃក្នុងតំបន់ (ក្នុងមូលដ្ឋាន) តាមរយៈសេដ្ឋកិច្ចមាត្រដ្ឋាន និងបែបរិយាប័ន្ន។ យ៉ាងណាក៏ដោយ ភាគច្រើននៃបណ្ដាញដឹកជញ្ជូនតាមច្រករបៀងសេដ្ឋកិច្ចរបស់កម្ពុជា គឺមានតែមួយបែបទេ គឺបណ្ដាញផ្លូវគោក។ បណ្ដាញផ្លូវជាតិបានឆ្លងកាត់ការស្ដារហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍច្រើនគួរឱ្យកត់សម្គាល់ ក្រោមជំនួយមកពីធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងារជំនួយអូស្ត្រាលី ប្រទេសជប៉ុន ប្រទេសចិន ប្រទេសកូរ៉េ ប្រទេសថៃ និងតួអង្គជាច្រើនក្នុងផ្នែកឯកជន។ បន្ថែមលើនេះ ការស្ដារឡើងវិញនូវបណ្ដាញផ្លូវរថភ្លើងនៅតាមច្រករបៀងសេដ្ឋកិច្ចក៏កំពុងតែដំណើរការដែរ តាមរយៈជំនួយពី

ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងារជំនួយអូស្ត្រាលី។ ប៉ុន្តែ ផ្ទុយទៅវិញ បណ្តាញភ្ជាប់ផ្លូវគមនាគមន៍រវាងទីក្រុងនៅមានឧបសគ្គច្រើនសម្រាប់ឱ្យបណ្តាក្រុងឈានទៅសម្រេចសក្តានុពលសេដ្ឋកិច្ចរបស់ខ្លួនបាន។ ការកើនឡើងច្រើនសន្ធឹកសន្ធាប់នៃចំនួនយានយន្តចុះបញ្ជី សមត្ថភាពរបស់បណ្តាញផ្លូវនៅមានកម្រិត និងកង្វះមធ្យោបាយដឹកជញ្ជូនសាធារណៈនិងមធ្យោបាយផ្សេងៗទៀត បានរួមចំណែកដល់ការកកស្ទះចរាចរណ៍នៅតាមទីក្រុងធំៗក្នុងប្រទេសកម្ពុជា។ សំខាន់ណាស់ដែលត្រូវមានការពង្រឹងសមត្ថភាពថែមទៀតដល់បណ្តាញផ្លូវដឹកជញ្ជូនរវាងទីក្រុង និងក្នុងរង្វង់ទីក្រុង និងលទ្ធភាពចូលដល់ទីផ្សារ និងការចល័តទីបានងាយស្រួល។

ចំពោះមុខតម្រូវការចាំបាច់ធំ និងធនធាននៅមានកម្រិត - ទាំងធនធានហិរញ្ញវត្ថុ ទាំងកង្វះសមត្ថភាព - ជាអនុសាសន៍ កម្ពុជាគួរតែរៀបចំយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីសម្រួលដល់ការធ្វើអាទិភាព និងការបែងចែកការវិនិយោគឱ្យមានការអភិវឌ្ឍប្រកបដោយតុល្យភាពនៅតាមដែនដី និងនៅតាមតំបន់។ ក្របខណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍទីក្រុង (NUDS Framework) បានរំលេចឡើងនូវភាពចាំបាច់ឱ្យមាន «ការអភិវឌ្ឍនៅទូទាំងថ្នាក់ជាតិនិងថ្នាក់តំបន់ និងតម្រូវការឱ្យមានកិច្ចសហប្រតិបត្តិការក្នុងរៀបចំផែនការ និងកត្តានានា (រួមមានការសម្របសម្រួលក្នុងការរៀបចំផែនការរវាងតំបន់ឬទីក្រុងជិតខាងគ្នា និងការបែងចែកការងារនិងចំនួនប្រជាជន)» ដោយក្នុងនោះមាន «គោលគំនិតទូលំទូលាយនៃការខណ្ឌចែកដែនដីជាតិឱ្យទៅជាតំបន់អភិវឌ្ឍន៍ដោយឡែកៗ (តំបន់កសិកម្ម ទេសចរណ៍ ឧស្សាហកម្ម តំបន់សេដ្ឋកិច្ចពិសេស និងតំបន់តាំងទីលំនៅ) និងតំបន់ការពារ (ឧទ្យានជាតិ តំបន់បម្រុងធម្មជាតិ តំបន់អភិរក្សជីវៈចម្រុះ ព្រមទាំងតំបន់អភិរក្សបេតិកភណ្ឌ និងវប្បធម៌ ផងដែរ)»[៩២]។ ផែនការអភិវឌ្ឍន៍ដែនដីមួយ (ដែលបច្ចុប្បន្នមិនទាន់មាននៅឡើយទេ) អាចផ្តល់មូលដ្ឋានសម្រាប់កំណត់អត្តសញ្ញាណហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដែលត្រូវការចាំបាច់ដើម្បីបង្កើនឱ្យបានអតិបរមានូវច្រករបៀងផ្លូវដឹកជញ្ជូន និងពង្រីកការអភិវឌ្ឍសេដ្ឋកិច្ច។ លទ្ធផលវិភាគសន្ទស្សន៍ EPI បានឱ្យដឹងថា ការចាប់ផ្តើមដាក់រៀបទីក្រុងជាកន្សោម ដែលអាចនឹងទទួលអត្ថប្រយោជន៍ពីការធ្វើសហកម្មទាំងនេះ កើតចេញមកពីយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមដែនដី និងតាមតំបន់។

**ប្រអប់ ៣.១៖** ការប្រើអភិក្រមអភិវឌ្ឍន៍ដែនដី

ការអភិវឌ្ឍដែនដីធ្លាប់ត្រូវបានគេចាត់ទុកថាជាអភិក្រមអភិវឌ្ឍន៍មានប្រសិទ្ធភាពមួយ នៅកម្រិតផ្សេងៗគ្នា។ នៅថ្នាក់ជាតិ ការអភិវឌ្ឍដែនដីអនុញ្ញាតឱ្យរដ្ឋាភិបាលថ្នាក់ជាតិផ្តង់ការអភិវឌ្ឍទៅលើតំបន់ណាដែលនៅមានភាពអន់ថយជាងគេ ហើយដែលជាទីកន្លែងរស់នៅរបស់ជនក្រីក្របំផុត និងសហគមន៍ដែលត្រូវបានផាត់ឱ្យនៅក្រៅដំណើរការអភិវឌ្ឍ។ នៅថ្នាក់ក្រោមជាតិ រដ្ឋបាល (ខេត្ត) អាចធ្វើការពូនផ្តុំថាមពលចូលគ្នាពីការអភិវឌ្ឍនៅតាមច្រករបៀង តំបន់ និងពីការរួមគ្នាចងក្រងជាកន្សោមថ្មីសម្រាប់បង្កើតឱកាសការងារឱ្យបានច្រើន។ នៅថ្នាក់មូលដ្ឋាន រដ្ឋបាល (ទីក្រុង ក្រុង និងស្រុក) អាចមានលទ្ធភាពលៃលកជាមួយបញ្ហាប្រឈមនៃការអភិវឌ្ឍនានា ដែលហៀរឆ្លងព្រំដែនសមត្ថ«កិច្ចរដ្ឋបាល»របស់ខ្លួន មានដូចការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់ទីក្រុងធំៗជាដើម។ ការប្រើទស្សនវិស័យអភិវឌ្ឍដែនដីធ្វើឱ្យគោលនយោបាយអភិវឌ្ឍន៍មានការសម្របសម្រួលគ្នា នៅពេលណាមានអន្តរាគមន៍ជាលក្ខណៈអន្តរវិស័យ និងសម្រាប់ជួយឱ្យការវិនិយោគមានការរៀបចំតម្រូវឱ្យបានកាន់តែល្អស្របតាមធនធាន និងឧបសគ្គក្នុងមូលដ្ឋាន។

អភិក្រមដែនដីត្រូវបានគេយកទៅប្រើតាមរយៈការអភិវឌ្ឍច្រករបៀង អមជាមួយនឹងការវិនិយោគ ដើម្បីជំរុញកំណើនទេសចរណ៍សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងមូលដ្ឋាននៅប្រទេសហ្សកហ្ស៊ី និងតាមរយៈការវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបវន្ត និងជំនួយបច្ចេកទេសនៅក្នុងការពង្រឹងបរិស្ថានធុរកិច្ចក្នុងតំបន់អន់ថយនៃភាគខាងលើរបស់ប្រទេសអេហ្ស៊ីប ដើម្បីជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ច។

*ប្រភព៖ World Bank, 2012, Kakheti Regional Development Project, and World Bank, 2016, Upper Egypt Local Development PforR*

៩២ NUDS Framework (Draft), 2015.

## ៣.៤ ការពង្រឹងស្ថាប័ន និងហិរញ្ញប្បទាន

ការវាយតម្លៃនៅក្នុងរបាយការណ៍នេះ បានរកឃើញបញ្ហាប្រឈមសំខាន់ៗសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីយកទៅលៃលកជាមួយដំណើរនគរូបនីយកម្មយ៉ាងលឿន និងដើម្បីធានាយ៉ាងណាឱ្យមានការអភិវឌ្ឍក្រុងប្រកបដោយចីរភាព នៅក្នុងដែនដីសមត្ថកិច្ចរៀងៗខ្លួន។ ជាទូទៅ មានភាពចាំបាច់ជាអាទិភាពក្នុងការស្រាយបំភ្លឺតួនាទី និងការទទួលខុសត្រូវរវាងមន្ទីរខ្សែបណ្តោយរបស់ក្រសួង និងរដ្ឋបាលមូលដ្ឋាន ដើម្បីធានាយ៉ាងណាឱ្យការធ្វើផែនការរៀបចំក្រុង និងការផ្តល់សេវា ត្រូវបានសមាហរណកម្មចូលគ្នា និងមានចីរភាព។ ចំណុចនេះនឹងតម្រូវឱ្យមានការកសាងសមត្ថភាពសម្រាប់ស្ថាប័នថ្នាក់មូលដ្ឋាន ទាំងសមត្ថភាពបច្ចេកទេស និងទាំងសមត្ថភាពអនុវត្ត។ នៅថ្នាក់ក្រុងជាពិសេសសម្រាប់ភ្នំពេញ នៅមានឱកាសច្រើនទៀតដើម្បីធ្វើឱ្យមានការសម្របសម្រួលកាន់តែប្រសើរជាងមុន លើការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្រុងសំខាន់ៗ និងការផ្តល់សេវា នៅក្នុងរង្វង់និងរវាងក្រុងដែលមានការពាក់ព័ន្ធ។

ចំពោះហិរញ្ញប្បទានសម្រាប់ការរៀបចំក្រុង ក្របខណ្ឌសារពើពន្ធមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានតម្លាភាព និងអាចព្យាករបាន គឺជាចំណុចចាប់ផ្តើមមួយដ៏មានសារៈសំខាន់សម្រាប់ទីក្រុង។ គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលថ្នាក់ជាតិក្នុងផ្ទេរមូលនិធិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺស្រុកនិងក្រុង តាមរយៈការផ្ទេរមូលនិធិស្រុក/ក្រុង ជាឈ្នាន់ឈានឡើងទៅពង្រឹងសមត្ថភាពរបស់ស្រុក/ក្រុង សម្រាប់ការងាររៀបចំផែនការនិងការអនុវត្ត; ការផ្តល់សេវា និងការបង្កើតហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ចាំបាច់សម្រាប់ពលរដ្ឋក្នុងមូលដ្ឋាន; និងជាការធានាយ៉ាងណាឱ្យមានការអភិវឌ្ឍក្រុង និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ផ្នែកជាក់លាក់ ដែលអាចបង្កើនការផ្តល់ហិរញ្ញប្បទាន និងគណនេយ្យភាពឱ្យកាន់តែប្រសើរថែមទៀតនោះ ពិសេសសម្រាប់បណ្តាក្រុងលំដាប់ទីពីរ រួមមាន៖

ក. ចាប់ផ្តើមផ្ទេរសម្បទានជាប់លក្ខខណ្ឌ ទៅឱ្យគណនីក្រុងសម្រាប់បម្រើដល់មុខងារដែលត្រូវបានធ្វើវិមជ្ឈការ ដោយផ្តើមពីការអនុវត្តតាមការគ្រប់គ្រងសំណល់រឹង។ មកទល់ពេលនេះ មូលនិធិទើបតែកំពុងត្រូវបានផ្ទេរទៅឱ្យបណ្តាក្រុងសម្រាប់មុខងារតែមួយគត់ គឺមុខងារគ្រប់គ្រងសំណល់រឹង។ ដើម្បីបំពេញមុខងារមួយនេះ ក្រុងចាប់ផ្តើមទទួលបានហិរញ្ញប្បទានចំនួន ២០០០ដុល្លារអាមេរិក ក្នុងមួយឆ្នាំ។ ប៉ុន្តែ មូលនិធិសម្រាប់បង់ថ្លៃឱ្យអ្នកម៉ៅការសេវាគ្រប់គ្រងសំណល់រឹងនេះ នៅមិនទាន់ត្រូវបានគេផ្ទេរទៅឱ្យក្រុងយកទៅប្រើប្រាស់នៅឡើយទេ។ រដ្ឋបាលថ្នាក់ខេត្តនៅតែបន្តគ្រប់គ្រងកិច្ចសន្យាទាំងនេះនៅឡើយ។ មូលនិធិទាំងនេះចាំបាច់ត្រូវទៅនៅក្រោមការគ្រប់គ្រងរបស់ក្រុងវិញ ដើម្បីឱ្យពួកគេមានគណនេយ្យភាពចំពោះគុណភាពរបស់សេវាដែលត្រូវបានផ្តល់។ ហេតុនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គួរតែចាប់ផ្តើមបញ្ជាឱ្យមូលនិធិដែលបានបែងចែករួចសម្រាប់ធ្វើហិរញ្ញប្បទានការគ្រប់គ្រងសំណល់រឹង ទៅដាក់ក្នុងគណនីស្រុកវិញ។ ផ្ទុយមកវិញ រដ្ឋបាលថ្នាក់ខេត្តគួរផ្តល់ការបណ្តុះបណ្តាលដល់បណ្តារដ្ឋបាលស្រុកក្នុងការគ្រប់គ្រងកិច្ចសន្យាសេវាសំណល់រឹង រួមទាំងការធ្វើលទ្ធកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុផងដែរ។ ដោយសារតែស្រុកមានគណនីស្រាប់ហើយ មូលនិធិទាំងនោះអាចផ្ទេរពីថ្នាក់ខេត្តរឹងបានមកស្ថិតនៅក្រោមការកាន់កាប់របស់រដ្ឋបាលក្រុងហើយ គេគួរបង្វែរការយកចិត្តទុកដាក់ទៅលើសេវាដទៃទៀតដែលទទួលបានការឯកភាពជាមួយក្រសួងខ្សែបណ្តោយ និងដែលត្រូវបានគូសបញ្ជាក់ជាក់លាក់នៅក្នុង «ផអ៣ទី៣» រួចហើយ។ សេវាទាំងនោះគួរត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង មានដូចជាការអប់រំមុនកម្រិតបឋម ការគ្រប់គ្រងមណ្ឌលកុមារកំព្រា ការគ្រប់គ្រងសួន និងតំបន់ការពារ ជាដើម។ កាលណាមុខងារទាំងនេះត្រូវបានផ្ទេរចេញ មូលនិធិក៏ត្រូវទៅតាមវាពីក្រោយដែរ។ ប្រអប់ ៣.២ ផ្តល់ឧទាហរណ៍មួយស្តីពីការថាតើប្រទេសហ្វីលីពីនរៀបចំរចនាសម្ព័ន្ធសមាហរណកម្មខ្សែបណ្តោយរបៀបណា សម្រាប់ការងារផ្តល់សេវា។

**ប្រអប់ ៣.២៖** ការធ្វើវិមជ្ឈការមុខងារផ្ដល់សេវាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅប្រទេសហ្វីលីពីន តាមរយៈអភិក្រមសមាហរណកម្មខ្សែបណ្ដោយ

ផែនការអភិវឌ្ឍន៍ប្រទេសហ្វីលីពីន ២០១៧-២០២២ (The Philippine Development Plan/PDP) 2017-2022) គឺជាផែនការរយៈពេលមធ្យមដំបូងគេដែលផ្ដើមចេញពីចក្ខុវិស័យរយៈពេលវែង និងរបៀបវារៈសេដ្ឋកិច្ច-សង្គមរបស់ប្រទេសនេះ។ PDP មានគោលដៅ «ចាក់គ្រឹះរឹងមាំមួយសម្រាប់កំណើនសេដ្ឋកិច្ចដែលកាន់តែមានភាពបរិយាប័ន្ន សង្គមមួយដែលមានការជឿទុកចិត្តនិងភាពធន់ខ្ពស់ និងសម្រាប់លើកកម្ពស់សេដ្ឋកិច្ចមួយឈរលើចំណេះដឹង និងមានសមត្ថភាពប្រកួតប្រជែងនៅលំដាប់សកលបាន» ដោយមានមូលដ្ឋានលើសសរស្តម្ភបី៖ (i) ពង្រឹងរចនាសម្ព័ន្ធរៀបចំសង្គម; (ii) កាត់បន្ថយវិសមភាព; និង (iii) បង្កើនសក្ដានុពលកំណើន។

ការពន្លឿនការអភិវឌ្ឍលើហេដ្ឋារចនាសម្ព័ន្ធត្រូវបានគេចាត់ទុកថាជាការចាំបាច់ នៅក្នុងការឈានទៅសម្រេចគោលដៅរបស់ PDP ឱ្យបាន។ ការពង្រាយជាលក្ខណៈយុទ្ធសាស្ត្រនូវហេដ្ឋារចនាសម្ព័ន្ធ - ទាំងតាមផ្នែក និងទាំងតាមភូមិសាស្ត្រ - ត្រូវបានគេយល់ថាជាសារៈសំខាន់ជាសារវន្តសម្រាប់នាំឱ្យមានកំណើនប្រកបដោយបរិយាប័ន្ន និងការអភិវឌ្ឍប្រកបដោយចីរភាព។ ជាមួយនឹងកំណើនឆាប់រហ័សរបស់ប្រជាជន និងនគរូបនីយកម្ម និងស្របតាមយុទ្ធសាស្ត្រភូមិសាស្ត្រជាតិ (National Spatial Strategy/NSS), PDP សង្កត់ធ្ងន់លើភាពចាំបាច់ឱ្យមានការវិនិយោគកាន់តែជាយុទ្ធសាស្ត្រជាងមុនទៅលើហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសសម្រាប់វិនិយោគលើបណ្ដាញផ្លូវគមនាគមន៍ ដូចជាផ្លូវដឹកជញ្ជូន និងប្រព័ន្ធទូរគមនាគមន៍ ដើម្បីតភ្ជាប់តំបន់ដែលនៅមានភាពអន់ថយ ជាមួយមជ្ឈមណ្ឌលសេដ្ឋកិច្ចតំបន់ ដែលស្ថិតនៅក្រៅតំបន់រដ្ឋធានីជាតិ (National Capital Region/NCR)។ លើសពីនេះ PDP ក៏បញ្ជាក់ ដែរថានឹងមានការបំពេញបន្ថែមវិធីច្រើនទៀត សម្រាប់ការធ្វើហិរញ្ញប្បទានសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ - មានការផ្ដល់មូលនិធិក្នុងស្រុក ការផ្ដល់មូលនិធិជំនួយបរទេស និងគម្រោងផ្សេងទៀតនៅក្រោម PPP។ ជាការសម្រួលដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព PDP លើកទឹកចិត្តឱ្យមាន PPP ច្រើនទៀត ឱ្យមានការរៀបចំផែនការល្អជាងមុនស្របតាមប្លង់ប្រើប្រាស់ដីធ្លី និងផែនការអភិវឌ្ឍន៍តំបន់ បង្កើនសមត្ថភាពអនុវត្តគម្រោង និងការគ្រប់គ្រងទ្រព្យសកម្មកាន់តែរឹងមាំឡើង។

PDP ២០១៧-២០២២ សម្របខ្លួនជាមួយនឹងឯកសារ NSS ដែលទទួលស្គាល់តួនាទីរបស់ក្រុងថាជាម៉ាស៊ីនកំណើនសេដ្ឋកិច្ច ហើយរំលេចភាពចាំបាច់របស់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីតភ្ជាប់តំបន់ដែលនៅអន់ថយ ជាមួយមជ្ឈមណ្ឌលកំណើនសេដ្ឋកិច្ច។ NSS មានសមាសភាគបី៖ (i) ការផ្ដុំតាមតំបន់ជាមួយកំណើននៅតាមមជ្ឈមណ្ឌលធំៗ; (ii) ភ្ជាប់បណ្ដាញគមនាគមន៍; និង (iii) កាត់បន្ថយភាពងាយរងគ្រោះ។ NSS បានដាក់ចេញបញ្ជី និងមុខងាររបស់មជ្ឈមណ្ឌលក្រុងធំៗ មជ្ឈមណ្ឌលតំបន់ និងមជ្ឈមណ្ឌលអនុតំបន់ ដែលតម្រូវឱ្យមានយុទ្ធសាស្ត្រផ្សេងៗគ្នា។

នៅក្នុងការកសាងរចនាសម្ព័ន្ធក្នុងស្រុក រដ្ឋាភិបាលហ្វីលីពីនបានសង្កត់ធ្ងន់ថា «រដ្ឋាភិបាលមូលដ្ឋានគួរទទួលបានការពង្រឹងអំណាចឱ្យក្លាយជាដៃគូមានសមត្ថភាពក្នុងការអភិវឌ្ឍ» ដោយដឹងថា រដ្ឋាភិបាលមូលដ្ឋានដឹងច្បាស់ជាងគេអំពីបញ្ហានៅតាមមូលដ្ឋានរបស់ខ្លួន ហើយដូច្នេះពួកគេស្ថិតនៅក្នុងស្ថានភាពមួយល្អជាងគេក្នុងការស្វែងរកដំណោះស្រាយដល់បញ្ហាឱ្យបានជាបន្ទាន់ និងមានប្រសិទ្ធភាព។ ក៏ប៉ុន្តែ នៅមានការកត់សម្គាល់ដែរថា រដ្ឋាភិបាលមូលដ្ឋាននៅពឹងអាស្រ័យខ្លាំងនៅឡើយលើការផ្ទេរហិរញ្ញវត្ថុផ្ទៃក្នុងរដ្ឋាភិបាល ហើយគ្មានលទ្ធភាពក្នុងការបង្កើតប្រភពចំណូលឱ្យបានគ្រប់គ្រាន់ និងក្នុងការផ្ដល់សេវាជាមូលដ្ឋាននៅក្រោមអាណត្តិរបស់ខ្លួនទេ។ ទោះជាយ៉ាងដូច្នេះក្ដី រដ្ឋាភិបាលថ្នាក់ជាតិនៅតែមានការប្ដេជ្ញាចិត្តពង្រឹងសមត្ថភាពរដ្ឋាភិបាលមូលដ្ឋាន ដើម្បីឱ្យពួកគេក្លាយខ្លួនជាខ្សែជួរទីមួយក្នុងការផ្ដល់សេវាដល់ពលរដ្ឋ តាមរយៈកម្មវិធីនានា ដូចជា កម្មវិធីជំនួយសម្រាប់ក្រុងខ្វះការអភិវឌ្ឍ (Assistance for Disadvantaged Municipalities/ADM) និងកម្មវិធីស្ដារសម្បទាផ្លូវក្នុងខេត្ត (KALSADA) នៅក្រោមលក្ខខណ្ឌមួយ គឺរដ្ឋាភិបាលមូលដ្ឋានត្រូវប្រកាន់ខ្ជាប់ស្តង់ដាអភិបាលកិច្ចល្អ ប្រឹងបង្កើនចំណូលពីប្រភពផ្ទៃក្នុងរបស់ខ្លួនឱ្យបានខ្ពស់ និងមានសមត្ថភាពរឹងមាំឡើងក្នុងការផ្ដល់សេវា។

*ប្រភព៖ World Bank, Philippines Urbanization Review II: Policy Note on Local Governance and Service Delivery - Assessment of the Assistance to Disadvantaged Municipalities (ADM) Program*

ខ. អនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម (SAF) ទៅលើក្រុមប្រឹក្សាក្រុងទាំងអស់ និងដាក់ឱ្យប្រើ«ប័ណ្ណស្រង់យោបល់របស់ពលរដ្ឋ» (Citizen Report Card/CRC) នៅតាមក្រុងធំៗជាងគេមួយចំនួន។ ដើម្បីអនុវត្តកម្មវិធីក្របខណ្ឌគណនេយ្យភាពសង្គម ឱ្យមានប្រសិទ្ធភាព ឧបករណ៍ដែលអង្គការ PACT បានសាកល្បងធ្វើ អាចត្រូវបានយកមកពិនិត្យ និងរៀបចំឡើងវិញដើម្បីបង្កើតថ្មីសម្រាប់យកមកវាយតម្លៃ (បានន័យថា តាមរយៈការផ្តល់ព័ត៌មានសាធារណៈថ្មី និងតារាងពិន្ទុសហគមន៍)។ ដោយសារតែមានក្រុមការងារមួយរួចហើយជួយគាំទ្រដល់ គ.ជ.អ.ប ក្នុងការអនុវត្ត SAF នៅខាង «ផ្នែកផ្គត់ផ្គង់» ឧបករណ៍ទាំងនោះអាចបង្កើតបានដោយមិនបាច់ចំណាយពេលមិនយូរទេ ហើយដាក់ចេញឱ្យប្រើប្រាស់ជាជំហានៗរហូតដល់ចុងឆ្នាំ២០១៨។ ក្រៅពីការវាយតម្លៃសេវារបស់ក្រុមប្រឹក្សាក្រុង គេអាចដាក់ឱ្យប្រើ «ប័ណ្ណស្រង់យោបល់របស់ពលរដ្ឋអំពីសេវាពហុមុខ» ថ្មីមួយទៀត ដោយផ្អែកលើគំរូដែលគេធ្លាប់បានយកទៅប្រើមានជោគជ័យនៅក្នុងប្រទេសនានា ដូចជាប្រទេសឥណ្ឌា (រដ្ឋ បេងហ្គាល័រ) និងប្រទេសកេនយ៉ា ជាដើម។ ប័ណ្ណស្រង់យោបល់នេះ អាចមានសេវាមូលដ្ឋានច្រើនមុខដែលផ្តល់ដោយអ្នកផ្តល់សេវាច្រើនអង្គភាព ដូចជាផ្នែកផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រងសំណល់រឹង ផ្នែកគ្រប់គ្រងទឹកស្អុយ ផ្នែកគ្រប់គ្រងចរាចរណ៍ ផ្នែកអគ្គិសនី ផ្នែកសុខាភិបាល ផ្នែកអប់រំ ជាដើម។ ឧបករណ៍ CRC មួយអាចរៀបចំបង្កើតឡើងបាន នៅក្នុងក្របខណ្ឌរបស់កម្មវិធីការងារ SAF នៅក្នុងឆ្នាំ២០១៨ ឬឆ្នាំ២០១៩ ហើយដាក់ចេញឱ្យប្រើប្រាស់នៅតាមក្រុងលំដាប់ទីពីរ ចំនួនពីរ ឬបី សិន ដើម្បីបង្ហាញឱ្យឃើញអំពីអត្ថប្រយោជន៍របស់វា ហើយបន្ទាប់មកទើបយកទៅពង្រីកទៅដល់ក្រុងផ្សេងទៀត ប្រសិនបើមានចំណាប់អារម្មណ៍ច្រើន និងបើសិនជាអភិក្រមនេះបញ្ជាក់ថាមានប្រសិទ្ធភាព។ លទ្ធផលដែលបានពីការប្រើ CRC នឹងអនុញ្ញាតឱ្យបណ្តាក្រុងចាប់បង្ខំអ្នកផ្តល់សេវាទាំងនោះឱ្យមានគណនេយ្យភាព ចំពោះគុណភាពនៃសេវារបស់ខ្លួន បាន។

គ. ដាក់ឱ្យប្រើសម្បទានហិរញ្ញវត្ថុផ្អែកលើគុណផលការងារជាផ្នែកមួយនៃការផ្ទេរមូលនិធិស្រុក/ក្រុង និងបង្កើនទំហំទឹកប្រាក់ផ្ទេររបស់មូលនិធិនេះ។ ការប្រើថវិកាសម្បទានផ្អែកលើគុណផលការងារនៅក្នុងប្រទេសផ្សេងទៀត (មានប្រទេសអ៊ូហ្គង់ដា ប្រទេសចិន ប្រទេសនេប៉ាល់ ជាដើម) បានបង្ហាញថាជាមធ្យោបាយមានប្រសិទ្ធភាពមួយ ក្នុងការលើកទឹកចិត្តដល់ក្រុងឱ្យបំពេញមុខងារបាន និងលើសពីស្តង់ដាអប្បបរមាទៅទៀត ហើយអាចឱ្យគេយកទៅប្រើធ្វើការកំណត់កម្រិតគោលសម្រាប់វាស់វែងការបំពេញមុខងារសម្រាប់ក្រុងទាំងអស់ទៀតផង[៩៣]។ លក្ខខណ្ឌវិនិច្ឆ័យនៃការបំពេញមុខងារអាចទាញចេញពីវិធីសាស្ត្រវាយតម្លៃ ដែលត្រូវបានយកមកប្រើសម្រាប់មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ (SNIF) ដើម្បីកំណត់មើលថា តើបណ្តាស្រុក/ក្រុងត្រៀមខ្លួនរួចហើយឬនៅដើម្បីទទួលយកកញ្ចប់មូលនិធិកាន់តែធំសម្រាប់ការអភិវឌ្ឍ ទៅប្រើក្នុងការវិនិយោគសេដ្ឋកិច្ចក្នុងមូលដ្ឋាន។ ឧបករណ៍វាយតម្លៃ និងផ្ទៀងផ្ទាត់ អាចបង្កើតបានរួមគ្នារវាង គ.ជ.អ.ប និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយយកទៅសាកល្បងនិងអនុវត្តជាជំហានៗ ជាផ្នែកមួយនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ។ ដើម្បីអនុញ្ញាតឱ្យមានការវិនិយោគគម្រោងអភិវឌ្ឍន៍កាន់តែមានអត្ថន័យខ្លាំងឡើង ហើយដោយឈរនៅលើបទពិសោធន៍របស់មូលនិធិ SNIF ដែលត្រូវបានគេរំពឹងថានឹងមានបរិមាណកើនឡើងតាមរយៈការអនុវត្តក្នុងឆ្នាំ២០១៨ មូលនិធិច្រើនថែមទៀតនឹងមានសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធខ្នាតមធ្យមដល់ធំ ដែលត្រូវបានបណ្តាក្រុងធ្វើអាទិភាព ហើយដែលបានប្រឡូកក្រុងឱ្យចូលពាក់ព័ន្ធកាន់តែសកម្មនៅក្នុងការរៀបចំរចនាបថ ការកសាង និងការថែទាំសេវា និងហេដ្ឋារចនាសម្ព័ន្ធ។ ដើម្បីប្រើប្រាស់មូលនិធិទាំងនេះឱ្យមានប្រសិទ្ធភាព ការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពគឺជាភាពចាំបាច់ ក៏ដូចជាការធ្វើឱ្យសាមញ្ញដែរនូវបទបញ្ញត្តិហិរញ្ញវត្ថុ និងជួយដល់បណ្តាក្រុងឱ្យពង្រីកបញ្ជីវាយនាមសកម្មភាពវិនិយោគរបស់ខ្លួនឱ្យកាន់តែមានលក្ខណៈឆ្លើយតបខ្លាំងឡើងទៅនឹងសេចក្តីត្រូវការក្នុងមូលដ្ឋាន។ ប្រអប់ ៣.៣ ពិពណ៌នាបទពិសោធន៍នៃការផ្តល់សមត្ថភាព និងការលើកទឹកចិត្តដល់រដ្ឋាភិបាលមូលដ្ឋានសម្រាប់ធ្វើឱ្យសម្រេចលទ្ធផលតាមរយៈកម្មវិធីនៅប្រទេស តង់ហ្សានី និង អ៊ូហ្គង់ដា។

---

៩៣ សូមមើល “Performance-Based Grant Systems Concept and International Experience” (UNCDF, 2010) សម្រាប់ឧទាហរណ៍ស្តីពីប្រព័ន្ធផ្តល់សម្បទានផ្អែកលើគុណផលការងារ។ ថ្វីបើការប្រើប្រការលើកទឹកចិត្តនៅក្នុងការផ្ទេរហិរញ្ញវត្ថុរវាងរដ្ឋបាលកម្រិតខុសៗគ្នាមិនមែនជារឿងថ្មីក៏ដោយ ការច្របាច់បញ្ចូលជាលក្ខណៈប្រព័ន្ធជាផ្នែកមួយស្នូលមួយនៃដំណើរការបែងចែកសម្បទាន គឺជាការអនុវត្តមួយថ្មីៗនេះ។ ប្រទេស អ៊ូហ្គង់ដា ជាអ្នកច្នៃប្រតិដ្ឋប្រើប្រព័ន្ធនេះមុនគេ ហើយឥឡូវនេះមានយ៉ាងហោចណាស់ប្រទេស ១៥ ទៀតដែលចាប់ផ្តើមប្រើអភិក្រមផ្តល់សម្បទានផ្អែកលើគុណផលការងារនេះដែរ ជាការសាកល្បងក៏មាន និងនៅកម្រិតជាតិទាំងមូលក៏មាន។

**ប្រអប់ ៣.៣៖** ការពង្រឹងសមត្ថភាពរដ្ឋាភិបាលមូលដ្ឋានដើម្បីបំពេញមុខងារវិមជ្ឈការ តាមរយៈការផ្តល់សម្បទានហិរញ្ញវត្ថុផ្អែកលើគុណផលការងារ នៅប្រទេសតង់សានី និងប្រទេសអ៊ូហ្គង់ដា

តម្រូវការមានកាន់តែច្រើនឡើងសម្រាប់ឱ្យមានកម្មវិធីអភិវឌ្ឍន៍ដែលផ្តល់លទ្ធផលមានចីរភាព និងពង្រឹងស្ថាប័ន នៅក្នុងពេលដែលបណ្តាប្រទេស និងរដ្ឋាភិបាលកាន់តែមានការអភិវឌ្ឍទៅមុខ និងភាពចាស់ទុំ។ កម្មវិធីដើម្បីលទ្ធផល (Program-for-Results/PforR) ត្រៀមខ្លួនសម្រាប់តម្រូវការបែបនោះ ដោយប្រើស្ថាប័ននិងដំណើរការក្នុងប្រទេសខ្លួន ហើយភ្ជាប់ការបញ្ចេញមូលនិធិដោយផ្ទាល់ជាមួយនឹងការសម្រេចបានផលជាក់លាក់របស់កម្មវិធី ហើយធ្វើដូច្នេះ វាជួយកសាងសមត្ថភាពនៅក្នុងប្រទេស និងពង្រីកប្រសិទ្ធភាពនិងប្រសិទ្ធផលរបស់ហិរញ្ញប្បទាន ក្នុងការឈានទៅសម្រេចបានលទ្ធផលរបស់កម្មវិធីជាដុំកំភួន និងប្រកបដោយចីរភាព។ គម្រោងមានឈ្មោះដូចជា Tanzania Urban Local Government Strengthening Program (ULGSP) និង Uganda Support to Municipal Infrastructure Development (USMID) បានប្រើប្រាស់កម្មវិធី PforR ប្រកបដោយជោគជ័យ ដើម្បីផ្តល់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ទន្ទឹមគ្នានឹងការពង្រឹងសមត្ថភាពរបស់រដ្ឋាភិបាលមូលដ្ឋាននៅក្នុងការគ្រប់គ្រងសារពើពន្ធ និងគណនេយ្យភាព។

ជាមួយនឹងភាពបត់បែនបានសម្រាប់ធ្វើការបែងចែកហិរញ្ញវត្ថុ ការសង្កត់ធ្ងន់របស់គុណផលការងារ និងគណនេយ្យភាពរបស់រដ្ឋាភិបាលមូលដ្ឋាន បានជះឥទ្ធិពលជាវិជ្ជមានដោយធ្វើឱ្យរដ្ឋាភិបាលមូលដ្ឋានកាន់តែបង្ហាញឱ្យគេឃើញនូវលទ្ធភាពរបស់ខ្លួនក្នុងការផ្តល់សេវាទីក្រុង។ សម្រាប់ករណីកម្មវិធី PforR នៅប្រទេសអ៊ូហ្គង់ដា សមាសភាគពីររបស់គម្រោងទទួលបានការសង្កត់ធ្ងន់នៅក្នុងអំឡុងពេលអនុវត្ត ដើម្បីធានាឱ្យមានប្រសិទ្ធភាព និងតម្លាភាពរបស់ដំណើរការ៖ i) ការកសាងសមត្ថភាពសម្រាប់រដ្ឋាភិបាលមូលដ្ឋានឱ្យមានលទ្ធភាពឆ្លើយតបទៅនឹងយន្តការលើកទឹកចិត្តគុណផលការងារ និង ii) ការវាយតម្លៃឯករាជ្យលើគុណផលការងារប្រចាំឆ្នាំ ដើម្បីកំណត់ការបញ្ចេញថវិកាសម្បទានទៅឱ្យរដ្ឋាភិបាលមូលដ្ឋាន។

សៀវភៅណែនាំការវាយតម្លៃគុណផលការងារ (Performance Assessment Manual/PAM) ត្រូវបានគេផលិតឡើងហើយយកទៅផ្សព្វផ្សាយដើម្បីជួយសម្រួលឱ្យមានប្រតិបត្តិការប្រកបដោយប្រសិទ្ធផលនិងប្រសិទ្ធភាពរបស់ប្រព័ន្ធផ្តល់សម្បទានក្រុងផ្អែកលើគុណផលការងារ (Urban Performance Grant System) និងរបស់ដំណើរការវាយតម្លៃ។ សៀវភៅណែនាំនេះធានាយ៉ាងណាឱ្យក្រុមប្រឹក្សាក្រុងទាំងអស់បានជ្រាបជាមុនអំពីដំណើរការ ដើម្បីផ្តល់កិច្ចប្រឹងប្រែងរបស់ពួកគេទៅលើការកែលម្អគុណផលការងាររបស់ស្ថាប័នឱ្យកាន់តែប្រសើរ និងទៅលើការប្រើប្រាស់កម្មវិធីហិរញ្ញវត្ថុសម្បទានឱ្យមានប្រសិទ្ធភាព។ លើសពីនេះទៅទៀត ក្រុមវាយតម្លៃគុណផលការងារមកពីខាងក្រៅ (Performance Assessment Teams/PATs) ដែលមានសមាសភាពជាអ្នកជំនាញមកពីផ្នែក i) រៀបចំក្រុង/ទីប្រជុំជន, ii) លទ្ធកម្ម, iii) គ្រប់គ្រងហិរញ្ញវត្ថុ និងគៀរគរចំណូលរបស់រដ្ឋាភិបាលមូលដ្ឋាន, iv) វិស្វកម្មស៊ីវិល/ហេដ្ឋារចនាសម្ព័ន្ធ, v) ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម, និង vi) ពង្រឹង និងកសាងសមត្ថភាពស្ថាប័ន ត្រូវបានបង្កើតឡើងដើម្បីធ្វើការវាយតម្លៃគុណផលការងារប្រចាំឆ្នាំ (Annual Performance Assessment/APA) របស់បណ្តារដ្ឋាភិបាលមូលដ្ឋានដែលបានចូលរួមនៅក្នុងកម្មវិធីនេះ។

*ប្រភព៖ World Bank, Philippines Urbanization Review II: Policy Note on Local Governance and Service Delivery - Assessment of the Assistance to Disadvantaged Municipalities (ADM) Program*

ខណៈដែលតួនាទីរបស់ផ្នែកឯកជនក្នុងការផ្តល់ហិរញ្ញប្បទាន រៀបចំក្រុងនៅកម្ពុជានៅមានកម្រិតនៅឡើយ សំខាន់គេត្រូវ សិក្សាលទ្ធភាព និងសហការជាមួយផ្នែកឯកជននៅតាមតំបន់ ដែលអាចឱ្យគេបង្កើនដល់អតិបរមានូវធនធានហិរញ្ញវត្ថុ បច្ចេក វិទ្យា និងបទពិសោធន៍នៅក្នុងការរៀបចំក្រុង។ គេអាចតម្រង់ ទិសដៅនៃការកៀរគរផ្នែកឯកជនមកចូលរួម ទៅលើក្រុងមួយ ចំនួនដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ ដូចជាក្រុងភ្នំពេញ ក្រុង សៀមរាប ក្រុងបាត់ដំបង និងក្រុងព្រះសីហនុ ដែលជាចំណាប់ អារម្មណ៍ខ្លាំងរបស់ផ្នែកឯកជនស្រាប់ ទាំងសម្រាប់ការវិនិយោគ ក្នុងស្រុក និងការវិនិយោគអន្តរជាតិ តាមរយៈបរិស្ថានធុរកិច្ចរឹងមាំ ធនធានទេសចរណ៍ កំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេស របស់ ទីក្រុងនោះ។ សេវាទឹកភ្លើង និងហេដ្ឋារចនាសម្ព័ន្ធក្រុង និង សេវាដទៃទៀតដែលកំពុងដំណើរការបានល្អនិងរកផលចំណេញ បាន អាចធ្វើឯកជនភាវូបនីយកម្ម ឬផ្តល់ស្វ័យភាព ស្រដៀងគ្នា នឹងគំរូរបស់រដ្ឋាករទឹករាជធានីភ្នំពេញ។ គួរតែមានកិច្ចសន្ទនា ជាមួយភាគីពាក់ព័ន្ធផ្នែកឯកជនឱ្យបានញឹកញាប់ នៅកម្រិត បច្ចេកទេស ដើម្បីស្វែងយល់អំពីឧបសគ្គដល់ការចូលរួមពាក់ព័ន្ធ របស់ពួកគេ និងអំពីសមត្ថភាពចាំបាច់ដែលផ្នែកឯកជន ឬជំនួយ បច្ចេកទេស អាចជួយបំពេញបន្ថែមឱ្យបាន។

ក្រៅពីនេះ សំខាន់ត្រូវពង្រឹងនិងសម្របខ្លួនក្របខណ្ឌច្បាប់ និយតកម្ម និងការអនុវត្តច្បាប់សម្រាប់ការរៀបចំក្រុងជាមួយការ អភិវឌ្ឍ ដើម្បីធានាយ៉ាងណាឱ្យគម្រោងអភិវឌ្ឍខ្នាតធំរបស់ផ្នែក ឯកជនមានគណនេយ្យភាពចំពោះការអភិវឌ្ឍរបស់ពួកគេ និង ដើម្បីឱ្យប្រាកដថាពួកគេនឹងមិនរួមចំណែកជាអវិជ្ជមានថែមទៀត ទៅលើភាពតានតឹង និងសម្ពាធដែលបណ្តាទីក្រុងកំពុងតែជួប ប្រទះស្រាប់ឡើយ។ ការអភិវឌ្ឍអចលនទ្រព្យគ្មានការត្រួតត្រាបាន ថ្មីៗនេះនៅទីក្រុងភ្នំពេញ និងក្រុងព្រះសីហនុបាននិងកំពុងបន្ថែម សម្ពាធទៅលើហេដ្ឋារចនាសម្ព័ន្ធ ដែលកំពុងតែរងសម្ពាធស្រាប់ របស់ក្រុង ដែលបណ្តាលឱ្យភាពណែនតានតាប់ និងការផ្តល់សេវា ដែលមានគុណភាពក្រោមស្តង់ដាស្រាប់ កាន់តែមានសភាពយ៉ាង យ៉ឺនជាងមុនទៅទៀត។ សំខាន់គឺថា កត្តាអវិជ្ជមានមកពីក្រៅ និង ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច-សង្គមពីសំណាក់គម្រោងអភិវឌ្ឍន៍របស់ ផ្នែកឯកជន មានការឆ្លើយតបឱ្យបានសមស្រប និងមានការ ទទួលខុសត្រូវ។ នៅពេលណាមានក្របខណ្ឌច្បាប់ និយតកម្ម និងការអនុវត្តច្បាប់ហើយ បណ្តាក្រុងអាចចាប់ផ្តើមសិក្សារកមើល យន្តការផ្តល់ហិរញ្ញប្បទានសម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដូចជាយន្តការ «ការទារថ្លៃពីម្ចាស់គម្រោងអភិវឌ្ឍន៍ និងថ្លៃសេវា ផលប៉ះពាល់» “developer exactions and impact fees” ដែលអាចត្រូវបានរៀបចំឡើង ដើម្បីឱ្យការរីកលូតលាស់របស់ នគរូបនីយកម្មអាច «បង់ថ្លៃលើការលូតលាស់របស់ខ្លួន» “pay its way” ដោយតម្រូវឱ្យម្ចាស់គម្រោងសាងសង់បង់ថ្លៃសេវា សម្រាប់ការពង្រីកសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធ ដែលកំណើន នគរូបនីយកម្មតម្រូវឱ្យមានជាចាំបាច់ (សូមមើលសេចក្តីពិស្តារ នៅក្នុងប្រអប់ ៣.៤ ស្តីពីយន្តការយកពន្ធលើផលចំណេញពីការ កើនតម្លៃដីដោយសារការបំពាក់ហេដ្ឋារចនាសម្ព័ន្ធ (Land Value Capture Schemes)។

ទីក្រុងមានលក្ខណៈប្រកួតប្រជែងជាច្រើន ធ្លាប់ប្រើយន្តការ LVC នេះ និងយន្តការធ្វើហិរញ្ញប្បទានក្រុងផ្សេងទៀត ដើម្បី បង្កើតមូលនិធិសម្រាប់យកទៅផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធ (ដូចជា បណ្តាញគមនាគមន៍ក្រុងជាដើម)។ ទីក្រុងភ្នំពេញ និងទីក្រុងមួយ ចំនួនដែលកំពុងមានការលូតលាស់យ៉ាងលឿន មានលក្ខខណ្ឌ ដែលអាចដាក់ចេញយន្តការ LVC នេះបាន ដោយក្នុងនោះមាន កំណើនសេដ្ឋកិច្ចរឹងមាំ ចំណូលកើនឡើងពីវិស័យអចលនទ្រព្យ ចំនួនយានយន្ត និងការកកស្ទះកាន់តែច្រើន ដែលទាំងអស់នេះជា កត្តាដែលអាចរួមចំណែកដល់ការឡើងថ្លៃដីនៅជុំវិញតំបន់មាន ហេដ្ឋារចនាសម្ព័ន្ធប្រសើរជាងមុន។ បើសិនជាត្រូវបានយកទៅ រៀបចំតម្រូវឱ្យល្អទៅតាមបរិបទក្នុងស្រុក យន្តការ LVC មាន សក្តានុពលក្លាយជាឧបករណ៍យុទ្ធសាស្ត្រសំខាន់មួយនៃការធ្វើ ហិរញ្ញប្បទានដល់ទីក្រុង ក្នុងប្រទេសកម្ពុជា[៩៤]។ ក្នុងការធ្វើដូច្នេះ សំខាន់បទបញ្ញត្តិ និងការរឹតបន្តឹងការអនុវត្តច្បាប់លើសកម្មភាព នគរូបនីយកម្ម និងសកម្មភាពអភិវឌ្ឍន៍ ត្រូវមានការពង្រឹង ឡើងដើម្បីធានាយ៉ាងណាឱ្យការអភិវឌ្ឍសាងសង់ខ្នាតធំរបស់ផ្នែក ឯកជន មានលក្ខណៈស្របជាមួយនឹងទស្សនវិស័យអភិវឌ្ឍន៍ និង ផែនការប្រើប្រាស់ដីធ្លីរបស់ទីក្រុង និងជាមួយបទបញ្ញត្តិ ឬក្រម នានាពាក់ព័ន្ធនគរូបនីយកម្ម។

---

៩៤ World Bank, Financing Transit-Oriented Development with Land Values - Adapting Land Value Capture in Developing Countries, 2015.

**ប្រអប់ ៣.៤៖** ឧទាហរណ៍ជាសកលស្តីពីយន្តការយកពន្ធលើផលចំណេញពីការកើនតម្លៃដីដោយសារការបំពាក់ហេដ្ឋារចនាសម្ព័ន្ធ (Land Value Capture Schemes)

មានយន្តការ និងបច្ចេកទេសជាច្រើនត្រូវបានគេយកទៅប្រើដើម្បីត្រេងយកតម្លៃដីក្នុងក្រុង ដើម្បីយកទៅជួយទ្រទ្រង់ដល់ហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រុង។ ខណៈដែលទីក្រុងនៅអាស៊ីបានរៀនសូត្រដកពិសោធន៍បានច្រើនពីយន្តការ «កែសម្រួលដីធ្លី» (land readjustment schemes) ពីប្រទេសជប៉ុន និងប្រទេសកូរ៉េ ទីក្រុងនៅតាមប្រទេសអាមេរិកឡាទីនបង្កើតយន្តការ «ពន្ធលើផលចំណេញពីការកើនតម្លៃដី» (ដោយសារការវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធ) (contribución de valorización/betterment levies) របស់ខ្លួនចេញដោយផ្ទាល់ពីគោលការណ៍ដែលមាននៅក្នុងច្បាប់របស់អេស្ប៉ាញ ហើយប្រទេសឥណ្ឌាបង្កើតគោលការណ៍ស្តីពីចលនារបស់ទីក្រុងដោយផ្អែកលើច្បាប់របស់ចក្រភពអង់គ្លេស។ សំខាន់ គួរតែសិក្សាមើលយន្តការ LCV ផ្សេងៗគ្នា ហើយយកវាមករៀបចំឱ្យបានសមស្របតម្រូវទៅនឹងបរិបទនិងភាពចាំបាច់របស់កម្ពុជា។

- ពន្ធលើផលចំណេញពីការកើនតម្លៃដី៖ យន្តការនេះចាប់យកផ្នែកណាមួយនៃតម្លៃដីដែលកើនផលចំណេញដោយសារតែមានការវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធក្បែរដីនោះ ដោយកំណត់យកពន្ធ ឬថ្លៃសោហ៊ុយតែមួយលើក ទៅលើតម្លៃផលចំណេញរបស់ដី (ឧទាហរណ៍: យន្តការ Contribución de Valorización នៅប្រទេសកូឡុមប៊ី)។

- ការលក់ដីរបស់អ្នកអភិវឌ្ឍន៍ដី (Developer Land Sales)៖ យន្តការនេះតម្រូវឱ្យអ្នកអភិវឌ្ឍន៍តាមអនុផ្នែករបស់ដីធ្លី សង់ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងផ្នែករបស់ខ្លួន ហើយស្តារការចំណាយនោះមកវិញតាមរយៈការលក់ដី។ នៅពេលដែលវិសាលភាពនៃគម្រោងអភិវឌ្ឍន៍ថ្មីៗកាន់តែរីកធំឡើងៗ គោលនយោបាយនេះ បង្វែរចំណែកមួយកាន់តែធំជាងមុននៃការវិនិយោគសរុបលើហេដ្ឋារចនាសម្ព័ន្ធទៅខាងផ្នែកឯកជនវិញ (ឧទាហរណ៍៖ គម្រោង Orestad New Town និងការភ្ជាប់ខ្សែរថភ្លើងក្រោមដីនៅទីក្រុង កូប៉ិនហាក ប្រទេសដាណឺម៉ាក)។

- យន្តការយកពន្ធពីការលក់ដីពាក់ព័ន្ធគម្រោង (Value Capture via Project-Related Land Sales)៖ យន្តការនេះពាក់ព័ន្ធការលក់ដីដែលតម្លៃរបស់វាបានកើនដោយសារការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ឬដោយសារការកែសម្រួលក្នុងការបែងចែកតំបន់។ បើសិនជាផ្នែកសាធារណៈជាម្ចាស់កម្មសិទ្ធិលើដីនោះ គេអាចធ្វើឱ្យការវិនិយោគនោះបង្កើតអត្ថប្រយោជន៍ផ្ទៃក្នុងខ្លួនឯងបាន ហើយទាញយកផលចំណេញតាមរយៈការលក់ដី (ឧទាហរណ៍៖ ការវិនិយោគលើសំណង់ផ្លូវហាយវ៉េ និងលើហេដ្ឋារចនាសម្ព័ន្ធនៅប្រទេសចិន)។

- ការលក់សិទ្ធិនៃការអភិវឌ្ឍដីធ្លី (Sale of Development Rights)៖ យន្តការនេះអនុញ្ញាតឱ្យអាជ្ញាធរសាធារណៈលក់សិទ្ធិអភិវឌ្ឍន៍ដីធ្លីជាជម្រើសជំនួសឱ្យការលក់ដី ដើម្បីទាញយកផលតម្លៃកើន (incremental value) ដែលកើតមកពីការវិនិយោគសាធារណៈលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ សិទ្ធិអភិវឌ្ឍន៍មានពីរចំណាត់ថ្នាក់៖ គឺសិទ្ធិបំប្លែងដីជនបទឱ្យក្លាយជាទីប្រជុំជន និងសិទ្ធិធ្វើការសាងសង់ក្នុងទំហំដង់ស៊ីតេធំមួយ ដែលធម្មតាអាចអនុញ្ញាតឱ្យធ្វើបានក្រោមវិធានបែងចែកតំបន់ ឬបទបញ្ញត្តិកម្រិតកម្ពស់របស់សំណង់ (ឧទាហរណ៍៖ ការលក់សិទ្ធិបន្ថែមក្នុងការសាងសង់នៅទីក្រុង សាវប៉ាវឡូនៃប្រទេសប្រេស៊ីល និង ទីក្រុងតូក្យូនៃប្រទេសជប៉ុន)។

- ការទារថ្លៃពីម្ចាស់គម្រោងអភិវឌ្ឍន៍ និងថ្លៃសេវាផលប៉ះពាល់ (Developer Exactions and Impact Fees)៖ ខុសពីយន្តការ LVC យន្តការនេះលៃលកបញ្ហាធ្វើហិរញ្ញប្បទានដោយមើលពីជ្រុងនៃតម្លៃរបស់ការអភិវឌ្ឍវិញ។ វាជាយន្តការតម្រូវឱ្យបង់ថ្លៃមុនតែមួយលើក ដែលមានគោលបំណងស្តារមកវិញនូវថ្លៃចំណាយលើហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធជាមួយនឹងកំណើនរបស់ទីក្រុង។ ការទារថ្លៃពីម្ចាស់គម្រោងអភិវឌ្ឍន៍ តម្រូវឱ្យអ្នកអភិវឌ្ឍន៍គម្រោងសង់ហេដ្ឋារចនាសម្ព័ន្ធផ្ទៃក្នុង ដោយប្រើចំណាយផ្ទាល់ខ្លួន ដើម្បីបំពេញតាមស្តង់ដាអភិវឌ្ឍន៍ ឬឱ្យបង់ថ្លៃលើសមាសភាគផ្សំហេដ្ឋរចនាសម្ព័ន្ធ ដែលអាជ្ញាធរសាធារណៈបានផ្តល់ជូន។ ថ្លៃសេវាផលប៉ះពាល់ ត្រូវបានរៀបចំឡើងដើម្បីស្តារមកវិញនូវចំណាយផ្នែកខាងក្រៅលើហេដ្ឋារចនាសម្ព័ន្ធ ដែលបណ្តាលមកពីគម្រោងអភិវឌ្ឍន៍ថ្មី (ឧទាហរណ៍: ទីក្រុងនៅសហរដ្ឋអាមេរិក និងទីក្រុងមុមបៃ ប្រទេសឥណ្ឌា)។

- ការគ្រប់គ្រងទ្រព្យសកម្មដីធ្លី (Land Asset Management)៖ យន្តការនេះអនុញ្ញាតឱ្យអាជ្ញាធរសាធារណៈធ្វើការដោះដូរទ្រព្យសកម្មដីធ្លី ជាមួយទ្រព្យសកម្មជាហេដ្ឋារចនាសម្ព័ន្ធ ក្នុងករណីដែលបញ្ជីសមតុល្យរបស់ស្ថាប័នសាធារណៈផ្ទុកច្រើនដោយសម្បត្តិជាដីក្រុង និងអចលនទ្រព្យផ្សេងទៀត ប៉ុន្តែទីក្រុងដែលមានអចលនទ្រព្យទាំងនោះ ជួបការខ្វះខាតខ្លាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធទៅវិញ។ អាជ្ញាធរសាធារណៈអាចលក់ ឬដាក់ជួលដីកម្មសិទ្ធិសាធារណៈបាន ហើយប្រើប្រាស់ចំណូលដែលប្រមូលបានដើម្បីផ្គត់ផ្គង់ហិរញ្ញវត្ថុដល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ។ ជាជាងការប្រើប្រាស់ឧបករណ៍ធ្វើហិរញ្ញប្បទានដីធ្លីដើម្បីផ្គត់ផ្គង់ហិរញ្ញវត្ថុដល់គម្រោងវិនិយោគដោយឡែកៗ ស្ថាប័នសាធារណៈអាចធ្វើការកែតម្រូវបញ្ជីសមតុល្យ ដោយសម្រួលឡើងវិញនូវសមាសភាគរួមរបស់ទ្រព្យសកម្មដែលជាកម្មសិទ្ធិកាន់កាប់សាធារណៈ (បង្កើនទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងបន្ថយទ្រព្យសកម្មដីធ្លី) (ឧទាហរណ៍៖ New York World Trade Center, Cape Town Waterfront, Istanbul Municipal Bus Station, and Metro Manila former US Military Compound)។

*ប្រភព៖ World Bank, Public-Private Infrastructure Advisory Facility, Unlocking Land Values to Finance Urban Infrastructure, 2017.*

## ៣.៤ ធ្វើឱ្យប្រសើរឡើងនូវការធ្វើផែនការប្រើប្រាស់ដីធ្លីប្រកបដោយចីរភាពសម្រាប់ការរីកចម្រើនទីក្រុងមានប្រសិទ្ធផល

នគរូបនីយកម្មតាមបែបសមាហរណកម្មល្អ និងផ្អែកលើភ័ស្តុតាង អាចជួយធានាឱ្យមានការរៀបចំក្រុងប្រកបដោយប្រសិទ្ធផល និងច្របាច់ទិដ្ឋភាពរបស់ចីរភាពនិងភាពធន់ចូលគ្នា ដែលអាចនាំមកនូវកំណើនសេដ្ឋកិច្ចកាន់តែខ្ពស់ និងបង្កើនភាពងាយស្រួលរស់នៅបានសម្រាប់ពលរដ្ឋក្នុងទីក្រុង។ ការធ្វើអាទិភាពសមាហរណកម្មនៃដំណើរការរៀបចំផែនការគឺជាសារៈសំខាន់មួយពិសេសសម្រាប់កម្ពុជា នៅក្នុងបរិបទបច្ចុប្បន្ននេះដែលដំណើរការរៀបចំផែនការប្រព្រឹត្តទៅនៅកម្រិតច្រើនផ្សេងៗគ្នា ហើយមិនសូវមានការសម្របសម្រួលបានល្អ។ យ៉ាងណាក៏ដោយ នៅមានឱកាសច្រើនដើម្បីពង្រឹងតំណភ្ជាប់ទំនាក់ទំនងរវាងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការធ្វើសមាហរណកម្មខ្សែបណ្ដោយ ដើម្បីកសាងសមត្ថភាពថ្នាក់មូលដ្ឋានឱ្យចេះបង្កើនផែនការប្រើប្រាស់ដីធ្លីមានចីរភាពនិងការសម្របសម្រួលគ្នា និងផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ រួមទាំងផែនការជាដំណាក់កាលៗសម្រាប់ធ្វើការវិនិយោគនិងអនុវត្តផង។ ច្បាប់និងក្រមច្រើនទៀតជាតម្រូវការចាំបាច់សម្រាប់សម្រួលការអនុវត្តផែនការលម្អិតប្រើប្រាស់ដីធ្លី ដែលក្នុងនោះគួរមានវិធានការភាពធន់នៅក្នុងការធ្វើផែនការរៀបចំក្រុងដើម្បីកាត់បន្ថយហានិភ័យ កសាងនិងរឹតបន្តឹងការអនុវត្តគោលការណ៍ណែនាំត្រួតពិនិត្យគម្រោងអភិវឌ្ឍន៍ និងក្រមសំណង់ដែរ។ ក្របខណ្ឌមួយគួរត្រូវបានបង្កើតឡើងសម្រាប់ប្រមូល ចែករំលែក និងវិភាគទិន្នន័យអំពីទីក្រុង។ សំណុំអនុសាសន៍ជាក់លាក់ជាច្រើនសម្រាប់រាជធានីភ្នំពេញ ដែលកំពុងប្រឈមជាមួយនឹងភាពស្មុគស្មាញថែមទៀត នៅក្នុងការរៀបចំផែនការនគរូបនីយកម្មនៅក្នុងតំបន់ជាយក្រុងដែលមានពហុយុត្តាធិការ ត្រូវបានស្នើឡើងនៅក្នុងរបាយការណ៍ស្រដៀងគ្នាមួយទៀត (សូមមើល Urban Development in Phnom Penh)[៩៥]។

ក. ពង្រឹងតំណភ្ជាប់ការទាក់ទងរវាងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីអនុញ្ញាតឱ្យមានការអភិវឌ្ឍទីក្រុងកាន់តែមានភាពសម្របសម្រួលល្អឡើង។ រដ្ឋបាលថ្នាក់ក្រោមជាតិមានការទទួលខុសត្រូវចំពោះការបង្កើតផែនការប្រើប្រាស់ដីធ្លីរបស់ខ្លួន ប៉ុន្តែសេចក្តីសម្រេចលើការប្រើប្រាស់ដីធ្លីត្រូវបានធ្វើនៅឯកម្រិតផ្សេងទៅវិញ អាស្រ័យទៅតាមទំហំរបស់គម្រោងអភិវឌ្ឍន៍ថ្មីនីមួយៗ។ ខណៈដែលមានយន្តការច្រើនសម្រាប់ផ្ទៀងផ្ទាត់ និងសម្របសម្រួលគ្នាក្នុងចំណោមស្ថាប័ននៅកម្រិតផ្សេងៗគ្នា ក៏ពិតមែន - ឧទាហរណ៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមច្បាប់ ត្រូវអនុម័តលើសំណើគម្រោងអភិវឌ្ឍន៍តែនៅក្រោយពេលមានការឯកភាពពីគ្រប់ស្ថាប័នពាក់ព័ន្ធរួចប៉ុណ្ណោះ - គេនៅតែមិនទាន់ច្បាស់ទេថាយន្តការទាំងនេះ ពិតជាបានយកទៅអនុវត្តប្រកបដោយប្រសិទ្ធភាពឬអត់។ កង្វះសមត្ថភាពរបស់ហេដ្ឋារចនាសម្ព័ន្ធក្នុងការដើរឱ្យទាន់ល្បឿននៃការ

៩៥ World Bank, 2017, Urban Development in Phnom Penh.

អភិវឌ្ឍ គឺជានិមិត្តហេតុឱ្យដឹងថាខ្វះសង្គតិភាពរវាងផែនការគម្រោងអភិវឌ្ឍន៍ និងកំណើនហេដ្ឋារចនាសម្ព័ន្ធ។ ដើម្បីឱ្យមានការអភិវឌ្ឍក្រុងកាន់តែមានភាពសម្របសម្រួលជាងនេះ តំណភ្ជាប់ការទាក់ទង និងដំណើរការផ្តល់ការអនុម័តសំណើគម្រោងភអភិវឌ្ឍន៍ថ្មីៗ គួរតែត្រូវបានរឹតបន្តឹងឱ្យរឹងមាំឡើង។

ខ. កសាងសមត្ថភាពថ្នាក់មូលដ្ឋានឱ្យចេះធ្វើផែនការប្រើប្រាស់ដីធ្លីមានចីរភាព និងមានការសម្របសម្រួលគ្នា និងផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ។ ទាំងនៅថ្នាក់រាជធានីភ្នំពេញ ទាំងនៅថ្នាក់ក្រុងលំដាប់ទីពីរ នៅមានការខ្វះសមត្ថភាពសម្រាប់ធ្វើផែនការប្រើប្រាស់ដីធ្លីដែលអាចយកទៅអនុវត្តបាន ដោយពេលនេះការងាររៀបចំផែនការកំពុងតែស្ថិត នៅដាច់ឆ្ងាយពីក្រោយល្បឿន និងវិសាលភាពនៃកំណើននគរូបនីយកម្មបាត់ទៅហើយ។ ប្រព័ន្ធចម្រុះមួយស្តីពីការប្រើប្រាស់ដីធ្លីនិងធ្វើផែនការហេដ្ឋារចនាសម្ព័ន្ធ នឹងជួយឱ្យបណ្តាទីក្រុងមានលទ្ធភាពប្រសើរឡើង នៅក្នុងការអភិវឌ្ឍខ្លួនតាមរបៀបមានចីរភាព។ ដោយមានការអនុវត្តល្អក្នុងការធ្វើផែនការរៀបចំក្រុងបាត់ដំបងជាឧទាហរណ៍ស្រាប់ ទីក្រុងនានាអាចសិក្សាមើលអំពីការចាត់ចែងបែបប្រទាក់ក្រឡាគ្នានៅក្នុងផែនការរៀបចំក្រុងបាត់ដំបងដើម្បីដកស្រង់បទពិសោធន៍ ជាពិសេសនៅក្នុងការបង្កើតដំណើរការពិគ្រោះយោបល់ធ្វើផែនការមួយមានភាពរស់រវើកការធ្វើសមាហរណកម្មតម្រូវការប្រើប្រាស់ដីធ្លីជាលក្ខណៈពហុវិស័យ និងការធ្វើផែនការតាមវិស័យជាក់លាក់ ដូចជាសម្រាប់សួន និងរមណីយដ្ឋានបេតិកភណ្ឌវប្បធម៌ ជាដើម។ ឧទាហរណ៍ បទពិសោធន៍របស់ក្រុងបាត់ដំបងកំពុងត្រូវបានរៀនសូត្រដកស្រង់នៅតាមខេត្តមួយចំនួនហើយ មានដូចជាខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង និងខេត្តតាកែវ។ ដោយគ្រាន់តែប្រើឯកសារសម្ភារដែលត្រូវបានបង្កើតឡើង នៅក្នុងកម្មវិធីគាំទ្រដោយអ្នកផ្តល់ជំនួយមុនៗ - មានធនាគារអភិវឌ្ឍន៍អាស៊ី និងទីភ្នាក់ងារ GIZ - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចដាក់ចេញកម្មវិធីបណ្តុះបណ្តាលជាលក្ខណៈប្រព័ន្ធមួយ សម្រាប់បុគ្គលិកអភិវឌ្ឍន៍ទីក្រុងនៅថ្នាក់មូលដ្ឋានទាំងអស់ ដើម្បីបង្កើតឱ្យមានការយល់រួមគ្នាមួយ អំពីប្រព័ន្ធធ្វើផែនការនៅមូលដ្ឋាន ព្រមទាំងដំណើរការសម្រាប់ធ្វើផែនការនៅមូលដ្ឋានផងដែរ។ ចុងបញ្ចប់ ខណៈដែលការបណ្តុះបណ្តាល នៅនឹងការងារមានសារៈសំខាន់មែនហើយសម្រាប់ការកសាងសមត្ថភាពធ្វើផែនការ ការបង្កើតកម្មវិធីលំដាប់ទីបីដោយផ្តោតលើផ្នែកនគរូបនីយកម្មនិងធ្វើរចនាប័ទ្មទីក្រុង ក៏នឹងជួយបង្កើតឱ្យមានជាក្រុមអ្នកបច្ចេកទេសមួយជាស្រេចសម្រាប់ធ្វើការក្នុងវិស័យនេះ។ ដោយឃើញថាទីក្រុងជាច្រើននៅកម្ពុជាមានហានិភ័យដោយសារទឹកជំនន់ ការមានអភិក្រមមួយសម្រាប់ធ្វើផែនការរៀបចំក្រុងដែលមានព័ត៌មានគ្រប់គ្រាន់អំពីហានិភ័យ អាចនឹងជួយសម្រាលផលប៉ះពាល់ពីហានិភ័យនេះបាន។ ប្រទេសវៀតណាមអាចផ្តល់ឧទាហរណ៍គួរឱ្យចាប់អារម្មណ៍មួយ អំពីអភិក្រមដែលអាចយកទៅកែសម្រួលតម្រូវតាមបរិបទប្រទេសកម្ពុជាបាន (ប្រអប់ ៣.៥)។

គ. បង្កើតក្របខណ្ឌមួយសម្រាប់ការប្រមូល ចែករំលែក និងវិភាគទិន្នន័យ។ ផែនការល្អគ្រប់ជ្រុងជ្រោយគួរត្រូវបានតាក់តែងឡើងជាមួយការយល់ឃើញអំពីភាពចាំបាច់របស់ទីក្រុង នាពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគត។ ដើម្បីសម្រេចកិច្ចការនេះបាន ទិន្នន័យពាក់ព័ន្ធទិដ្ឋភាពច្រើនបែបនៃជីវិតក្នុងទីក្រុង - មានទិន្នន័យផ្នែកប្រជាសាស្ត្រ ការផ្តល់សេវា កំណើនសេដ្ឋកិច្ច កម្មសិទ្ធិដីធ្លី និងសេចក្តីត្រូវការប្រើប្រាស់ដីធ្លី - ត្រូវតែមានការប្រមូលនិងវិភាគជាលក្ខណៈប្រព័ន្ធ នៅក្នុងជំហានដំបូងនៃដំណើរការធ្វើផែនការរៀបចំក្រុង។ ទិន្នន័យនេះគួរត្រូវដាក់ឱ្យភ្នាក់ងារផ្សេងៗរបស់រដ្ឋាភិបាលចូលទៅប្រើប្រាស់បាន ដើម្បីឱ្យគេមានទស្សនៈគ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយអំពីសេចក្តីត្រូវការរបស់ទីក្រុង។ ក្រសួងរៀចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ និងជាមួយបណ្តារដ្ឋបាលក្រុង អាចដឹកនាំការងារបង្កើតក្របខណ្ឌមួយ សម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធទិន្នន័យភូមិសាស្ត្រក្រុង (Municipal Spatial Data Infrastructure) - ហេដ្ឋារចនាសម្ព័ន្ធនេះ អាចបញ្ចូលការបង្កើតប្រព័ន្ធស្តង់ដាសម្រាប់គ្រប់គ្រងទិន្នន័យ និងការបង្កើតក្របខណ្ឌស្ថាប័នសម្រាប់ការចែករំលែកទិន្នន័យ ព្រមទាំងការកសាងសមត្ថភាពបច្ចេកទេសដែរ - និងសម្រាប់ធ្វើការវិភាគទិន្នន័យនៅក្នុងដំណើរការធ្វើផែនការរៀបចំក្រុង។ កិច្ចការនេះជាសិលាគ្រឹះចាំបាច់បំផុតសម្រាប់ឈានទៅបង្កើតផែនការក្រុងមួយដែលមានលក្ខណៈរស់រវើកស្វាហាប់ ហើយវានឹងមានសារៈសំខាន់ពាក់ព័ន្ធមិនមែនសម្រាប់តែនៅក្នុងការរៀបចំផែនការប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងការអភិវឌ្ឍហេដ្ឋារចនាម្ព័ន្ធ និងក្នុងការផ្តល់សេវានៅតាមផ្នែកពហុវិស័យផងដែរ។ ប្រអប់ ៣.៦ ពិពណ៌នាលម្អិតអំពីកិច្ចខិតខំបែបនេះនៅក្នុងប្រទេសសិង្ហបុរី ដែលអាចយកមកអនុវត្តប្រកបដោយប្រសិទ្ធភាពនៅក្នុងប្រទេសកម្ពុជាបាន។

**ប្រអប់ ៣.៦៖** បទពិសោធន៍ប្រទេសសិង្ហបុរីក្នុងការរៀបចំនគូបនីយកម្មដោយផ្អែកលើទិន្នន័យ

ការវិភាគទិន្នន័យភូមិសាស្ត្រមានសក្តានុពលអត្ថប្រយោជន៍ច្រើនយ៉ាង និងអាចជួយដល់ការធ្វើសេចក្តីសម្រេចផ្អែកលើព័ត៌មានគ្រប់គ្រាន់តាមច្រើនបែបទៀតផង។ នៅប្រទេសសិង្ហបុរី អ្នកធ្វើផែនការនគូបនីយកម្មទាញអត្ថប្រយោជន៍ពីទិន្នន័យ និងឧបករណ៍វិភាគ ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវរបៀបធ្វើសេចក្តីសម្រេចអំពីការប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដីធ្លី ទាំងក្នុងរយៈពេលខ្លីដល់មធ្យម ក៏ដូចជានៅក្នុងធ្វើផែនការរយៈពេលវែងដែរ។ កិច្ចការនេះអាចធ្វើទៅបានដោយមានការគាំទ្រមុះមុតពីរដ្ឋាភិបាលចំពោះការធ្វើស្តង់ដានីយកម្មការប្រមូលទិន្នន័យភូមិសាស្ត្រ និងការចែករំលែកទិន្នន័យជាមួយទីភ្នាក់ងារផ្សេងទៀតរបស់រដ្ឋាភិបាល ព្រមទាំងការគាំទ្រឱ្យមានការវិនិយោគលើការកសាងសមត្ថភាពរបស់អ្នកធ្វើផែនការ ទៀតផង។

នៅអាជ្ញាធរអភិវឌ្ឍន៍ទីក្រុងឡើងវិញ (Urban Redevelopment Authority/URA) ដែលជាឧបករណ៍វិភាគផ្ទៃក្នុងដែលគេស្គាល់ថាជា ePlanner ធ្វើសមាហរណកម្មទិន្នន័យមកពីប្រភពផ្សេងៗគ្នាសម្រាប់វិភាគ និងធ្វើបទបង្ហាញ។ ជាឧបករណ៍ដែល URA បង្កើតក្នុងស្ថាប័នរបស់ខ្លួន ePlanner ប្រមូលព័ត៌មានមកពីសំណុំទិន្នន័យជាង ៩០សំណុំផ្សេងគ្នា ហើយឧបករណ៍នេះត្រូវបានយកទៅប្រើនៅតាមស្ថាប័នជាង ២៥ របស់រដ្ឋាភិបាល ដើម្បីផ្តល់ព័ត៌មានដល់ការផ្តល់សេវា និងធ្វើផែនការហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ ដូចជាការសង់មជ្ឈមណ្ឌលថែទាំកុមារ ជាដើម។ តម្រូវការចំពោះមជ្ឈមណ្ឌលបែបនេះមានខុសៗគ្នាពីទីប្រជុំជនមួយទៅទីប្រជុំជនមួយទៀត អាស្រ័យលើចំនួនហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់សេវាដែលមានស្រាប់ និងស្ថានភាពប្រជាសាស្ត្រនៅក្នុងភូមិសាស្ត្រនីមួយៗ។ ដោយលាយព័ត៌មានប្រជាសាស្ត្រជាមួយទិន្នន័យនៅលើបញ្ជីរង់ចាំ និងចំនួនដែលនៅទំនេរ ePlanner អាចបង្ហាញទាំងទីតាំង និងទាំងស្ថានភាពធ្ងន់ធ្ងរនៃភាពខ្វះខាតដែលកំពុងតែកើតមាន។ ត្រង់នេះចង្អុលប្រាប់អំពីកន្លែងដែលហេដ្ឋរចនាសម្ព័ន្ធទ្រទ្រង់សេវាមានតម្រូវការចាំបាច់ជាបន្ទាន់ ជួយក្រុមប្រឹក្សារៀបចំលំនៅដ្ឋាន និងការអភិវឌ្ឍ (Housing & Development Board) ឱ្យគិតគូរបញ្ចូលការផ្តល់មជ្ឈមណ្ឌលថែទាំកុមារ ទៅក្នុងគម្រោងអភិវឌ្ឍន៍នាពេលខាងមុខ។ អ្នកធ្វើផែនការក៏អាចកំណត់ផងដែរថា តើមានវិធានការបន្ទាន់ចាំបាច់ថែមទៀតឬទេ ដូចជាការបំប្លែងអគារអចលនទ្រព្យរបស់រដ្ឋឱ្យទៅជាមជ្ឈមណ្ឌលថែទាំកុមារ ជាដើម។

**រូបភាព ៣.១៖** ការវិភាគភូមិសាស្ត្រសម្រាប់ការផ្តល់មជ្ឈមណ្ឌលថែទាំកុមារ



*ប្រភព៖ Urban Redevelopment Authority, Singapore.*

ការវិភាគភូមិសាស្ត្រប្រហាក់ប្រហែលគ្នានេះក៏អាចធ្វើបានដែរសម្រាប់ការផ្តល់សេវាមុខផ្សេងទៀត ដូចជាឧទ្យាន និងលំហផ្ទៃបៃតងជាដើម។ ដោយតែងតែគិតពីគុណផលការងារជានិច្ច - នៅប្រទេសសិង្ហបុរី គោលដៅត្រឹមឆ្នាំ២០៣០ គឺធ្វើយ៉ាងណាឱ្យ ៩០%នៃលំនៅដ្ឋានទាំងអស់ស្ថិតនៅចម្ងាយពីឧទ្យានមួយដែលគ្រាន់តែដើរ ១០នាទី ដល់ - អ្នកធ្វើផែនការប្រើការវិភាគភូមិសាស្ត្រ ដើម្បីកំណត់តំបន់ណាដែលបច្ចុប្បន្នមិនទាន់ត្រូវតាមគោលដៅ ហើយអាចធ្វើអាទិភាពរៀបចំឱ្យមានលំហផ្ទៃបៃតងនៅតាមចំណុចទាំងនោះ។

សម្រាប់សេណារីយោវែងឆ្ងាយទៅមុខ អ្នកធ្វើផែនការរបស់ URA មានកម្មវិធី GEMMA ឬ (GIS-Enabled Mapping, Modelling and Analysis) សម្រាប់វិភាគទិន្នន័យ។ កម្មវិធីនេះអនុញ្ញាតឱ្យអ្នកធ្វើផែនការបង្កើតសេណារីយោប្រើប្រាស់ដីធ្លីផ្សេងៗគ្នាជាយុទ្ធសាស្ត្រមានសក្តានុពលកំណើនសម្រាប់ទីក្រុង ហើយពួកគេអាចធ្វើការវាយតម្លៃបានផងដែរអំពីផលប៉ះពាល់របស់សេណារីយោទាំងនោះទៅលើបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ ដោយសហការគ្នាជាមួយទីភ្នាក់ងារផ្សេងទៀតរបស់រដ្ឋ។ ឧទាហរណ៍ ប្រសិនបើមានគម្រោងវិនិយោគសាធារណៈសង់អគារលំនៅដ្ឋានថ្មីមួយ គេត្រូវពិនិត្យមើលថាតើមានតម្រូវការហេដ្ឋារចនាសម្ព័ន្ធផ្លូវសំខាន់ៗអ្វីខ្លះ ហើយថាតើទាំងអស់នេះនឹងមានផលប៉ះពាល់ទៅលើកម្រិតសូរសព្ទនៅក្នុងសហគមន៍ដូចម្ដេចដែរ? តាមរបៀបនេះ អ្នកធ្វើផែនការមានការយល់ឃើញពេញលេញអំពីភាពជំពាក់ទាក់ទងគ្នានៅក្នុងការប្រើប្រាស់ដីធ្លីបែបផ្សេងៗទៅថ្ងៃមុខ ហើយមានព័ត៌មានចាំបាច់នៅក្នុងដៃសម្រាប់ធានាយ៉ាងណាឱ្យហេដ្ឋារចនាសម្ព័ន្ធ មានការអភិវឌ្ឍនៅក្នុងវិសាលភាព និងល្បឿនមួយដែលអាចទ្រទ្រង់បានពេញលេញដល់ការប្រើប្រាស់ទៅថ្ងៃមុខ។ ការពិចារណាអំពីឱកាស ការដោះដូររវាងតម្លៃត្រូវបង់និងផលទទួលបានមកវិញ និងអំពីការចំណាយ នៅក្នុងសេណារីយោខុសៗគ្នា អាចនាំមកនូវលទ្ធផលកាន់តែល្អ នៅក្នុងការភ្ជាប់ការប្រើប្រាស់ដីធ្លីជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។

*ប្រភព៖ Centre for Livable Cities (2016), Urban Redevelopment Authority (2016).*

បង្កើត និងដាក់ឱ្យអនុវត្តតាមនូវគោលការណ៍ត្រួតពិនិត្យគម្រោងអភិវឌ្ឍន៍ និងក្រមសំណង់។ បើទោះជាមានផែនការគ្រប់ជ្រុងជ្រោយហើយក្ដី ក្របខណ្ឌស្ថាប័នទ្រទ្រង់ការអភិវឌ្ឍដីធ្លីឱ្យស្របតាមផែនការ ក៏ត្រូវតែមានដែរ។ ក្រៅពីផែនការប្រើប្រាស់ដីធ្លី គោលការណ៍ណែនាំសម្រាប់ត្រួតពិនិត្យគម្រោងអភិវឌ្ឍន៍ ជួយតម្រែតម្រង់ទិដ្ឋភាពបរិស្ថានសំណង់អគារ ដោយវាធ្វើនិយតកម្មទៅលើទ្រង់ទ្រាយ និងដង់ស៊ីតេរបស់អគារ ប្រភេទប្រើប្រាស់ក្នុងអគារ ព្រមទាំងទំនាក់ទំនងផ្នែកស្ថានភាពភូមិសាស្ត្ររវាងអគារ និងបរិស្ថានជុំវិញដែរ - ឧទាហរណ៍ ចម្ងាយនៃភាពរយាលរវាងអគារ និងផ្លូវ។ ក្នុងគោលដៅនេះ ជាអនុសាសន៍ ស្ថាប័នដូចជាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងបរិស្ថាន គួរធ្វើការជាមួយគ្នាឆ្ពោះទៅបង្កើតសំណុំនៃគោលការណ៍ណែនាំសម្រាប់ត្រួតពិនិត្យគម្រោងអភិវឌ្ឍន៍មួយមានតម្លាភាព ដែលអាចយកទៅអនុវត្តបាននៅក្នុងភាពជាក់ស្ដែង។

## ៣.៦ ធានាឱ្យមានអភិក្រមបែបបរិយាប័ន្ន

របាយការណ៍នេះ មិនបានគ្រប់ដណ្ដប់ដោយផ្ទាល់លើបញ្ហាបរិយាប័ន្ននៅឡើយទេ ប៉ុន្តែ បើទោះជានគរូបនីយកម្មនាំមកនូវអត្ថប្រយោជន៍ច្រើនក៏ដោយ សម្ពុរីកចម្រើនលឿនរបស់ទីក្រុងក៏អាចធ្វើឱ្យបញ្ហាវិសមភាព កាន់តែមានសភាពធ្ងន់ធ្ងរថែមទៀត ប្រសិនបើវាគ្មានការរៀបចំផែនការ និងការគ្រប់គ្រងឱ្យបានល្អ។ របាយការណ៍ផ្សេងៗទៀតរបស់ធនាគារពិភពលោក តួយ៉ាង របាយការណ៍ East Asia Cities: Expanding Opportunities for the Urban Poor គ្របដណ្ដប់លើបញ្ហាទាំងនេះ ដោយពិនិត្យមើលពីជ្រុងទស្សនៈបរិយាប័ន្នផ្នែកសេដ្ឋកិច្ច ភូមិសាស្ត្រ និងសង្គម។ កង្វះការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ការងារ និងសេវាអាចធ្វើឱ្យវិសមភាពកាន់តែមានគម្លាតធំឡើង ហើយអាចបង្កឧបសគ្គដល់កំណើនសេដ្ឋកិច្ច និងនាំឱ្យមានការប្រេះឆាក្នុងសង្គមទៀតផង។ ដើម្បីឆ្លើយតបទៅនឹង ឬបញ្ចៀសបញ្ហាទាំងនេះ មានកិច្ចការច្រើនដែលបណ្ដាទីក្រុងអាចធ្វើបាន។ អភិក្រមទាំងឡាយ ដូចគ្នានឹងអនុសាសន៍ផ្សេងទៀតដែរ គួរត្រូវបានសម្រួលឱ្យត្រូវទៅតាមភាពចាំបាច់របស់ក្រុងនីមួយៗ ស្របនឹងប្រភេទរបស់ក្រុងដែលបានលើកមកបង្ហាញនៅខាងលើរួចហើយ។

ឧទាហរណ៍ ក្រុងតូចៗតាមព្រំដែន ក្រុងច្រកឆ្លងកាត់ ឬក្រុងច្រករបៀងសេដ្ឋកិច្ចតំបន់ដែលអាចរីកធំលឿន អាចនឹងទទួលអត្ថប្រយោជន៍ពីការវិនិយោគទៅលើលំនៅដ្ឋានមានតម្លៃសមរម្យដែលគ្រោងសម្រាប់កំណើនទៅថ្ងៃអនាគត ប្រៀបជាមួយនឹងរាជធានីដែលចាំបាច់ត្រូវផ្ដោតជាពិសេសលើការអភិវឌ្ឍមធ្យោបាយដឹកជញ្ជូន ដើម្បីឱ្យពលរដ្ឋប្រើសម្រាប់ស្វែងរកការងារ និងលើការធ្វើឱ្យប្រសើរនៅកន្លែងណាដែលមិនទាន់មានលទ្ធភាពទទួលបានសេវាជាមូលដ្ឋាន។ ទីក្រុងលំដាប់ទីពីរ ដូចជាក្រុងសៀមរាប និងក្រុងព្រះសីហនុ មានចលករជំរុញកំណើនសេដ្ឋកិច្ចខ្លាំង រួមមានធនធានផ្នែកទេសចរណ៍ កំពង់ផែអន្តរជាតិ តំបន់សេដ្ឋកិច្ចពិសេស និង កាស៊ីណូ ប៉ុន្តែ ភាគច្រើននៃអត្ថប្រយោជន៍សេដ្ឋកិច្ចមិនទាន់បានធ្លាក់ទៅដល់ថ្នាក់មូលដ្ឋានទេ។ ឧទាហរណ៍ ខណៈដែលតំបន់សេដ្ឋកិច្ចនៅកម្ពុជាទទួលបានជោគជ័យក្នុងការបង្កើតការងារដោយដើរតួនាទីជាតំបន់កែច្នៃផលិតផលសម្រាប់នាំចេញ

តំបន់សេដ្ឋកិច្ចពិសេសទាំងនោះមានចំណងទាក់ទងខ្សោយណាស់ជាមួយសេដ្ឋកិច្ចក្នុងស្រុក។ បន្ថែមលើការវិនិយោគលើមធ្យោបាយដឹកជញ្ជូនក្នុងរង្វង់ទីក្រុង សំខាន់ដែរដែលត្រូវធានាយ៉ាងណាឱ្យមានការវិនិយោគច្រើនទៀតទៅលើផ្នែកសេវា ដើម្បីលើកស្ទួយទីផ្សារក្នុងស្រុក ព្រមទាំងពង្រឹងផងដែរដល់ការិយាល័យសេវាច្រកចេញចូលតែមួយ ដើម្បីធ្វើឱ្យសេវាមូលដ្ឋានផ្នែករដ្ឋបាលងាយរកបាន ហើយមានប្រសិទ្ធផល សម្រាប់ពលរដ្ឋ និងសហគ្រាសខ្នាតតូចនិងមធ្យម។

សូចនាករមួយក្នុងចំណោមសូចនាករស្នូលរបស់ EPI គឺ មូលធនមនុស្ស - ការវិនិយោគលើគុណភាពនៃការអប់រំសម្រាប់ទាំងអស់គ្នា និងលើការបណ្តុះបណ្តាលការងារ អាចជួយធានាឱ្យមានកម្លាំងពលកម្មមានជំនាញល្អ ដែលជាការចាំបាច់សម្រាប់វិស័យឧស្សាហកម្មនៅក្នុងទីក្រុង។ មានឧទាហរណ៍ច្រើនអំពីកម្មវិធីមានជោគជ័យ ដែលមានគោលដៅលើកកម្ពស់បរិយាប័ន្នសម្រាប់ជនក្រីក្រក្នុងទីក្រុងនៃតំបន់អាស៊ីបូព៌ា ដែលត្រូវបានចងក្រងទុក ហើយអាចមានប្រយោជន៍សម្រាប់យកមកសិក្សា នៅក្នុងបរិបទរបស់កម្ពុជា[៩៦]។

## ៣.៧ សំណើកម្មវិធីដើម្បីធ្វើអាទិភាពការអភិវឌ្ឍក្រុង

ករណីសម្រាប់វិនិយោគក្នុងទីក្រុង ត្រូវបានលើកយកមកបង្ហាញទូលំទូលាយជាសកល ហើយវាមានសារៈសំខាន់ស្មើគ្នាជាមាគ៌ាមួយសម្រាប់នាំឱ្យមានកំណើន និងកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា។ ការរីកចម្រើននគរូបនីយកម្មរបស់កម្ពុជាដែលស្ថិតនៅដំណាក់កាលដំបូងនៅឡើយ បានក្លាយជាមុខប្រសព្វសំខាន់មួយសម្រាប់ធានាឱ្យមានការត្រៀម ហើយជាស្រេចនូវសមាសភាគចាំបាច់ធំៗ សម្រាប់រៀបផែនការ កសាង និងថែទាំក្រុង។ សក្តានុពលសេដ្ឋកិច្ចរបស់ក្រុងជាក់លាក់មួយចំនួនរួមទាំងក្រុងនៅតាមច្រករបៀងសេដ្ឋកិច្ចផង ត្រូវបានលើកមកគូសបញ្ជាក់នៅក្នុងរបាយការណ៍នេះ ហើយវាបង្ហាញថាក្រុងមួយចំនួនមានសក្តានុពលខ្ពស់សម្រាប់ទទួលបានកំណើនទៅថ្ងៃអនាគត។ ភ័ស្តុតាងជាសកលក៏បង្ហាញដែរនូវសារៈសំខាន់នៃការវិនិយោគលើការពង្រឹងសមត្ថភាពស្ថាប័នឱ្យបានរឹងមាំ សម្រាប់ការរៀបចំផែនការ ការផ្តល់ហិរញ្ញប្បទាន និងការគ្រប់គ្រងនគរូបនីយកម្ម ដោយវាអាចជួយកាត់បន្ថយបានច្រើននូវបញ្ហាកកស្ទះ ការរាលដាលសំណង់ជម្រកអនាធិបតេយ្យ ការបំពុលបរិស្ថានវិសមភាព និងឧក្រិដ្ឋកម្ម។

ជាមួយនឹងតម្រូវឱ្យមានការវិនិយោគ និងជំនួយបច្ចេកទេសច្រើនសន្ធឹកសន្ធាប់ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងរបាយការណ៍នេះ កម្មវិធីរបស់ធនាគារពិភពលោកមួយដែលកំពុងតែដំណើរការសម្រាប់ពង្រឹងការអភិវឌ្ឍនគរូបនីយកម្ម នៅកម្ពុជាទំនងជាអាចជួយបំពេញបន្ថែមដល់កិច្ចប្រឹងប្រែងនានាដែលកំពុងតែធ្វើ។ វិធីជាក់លាក់សម្រាប់ធ្វើឱ្យមានគម្រោងបែបនោះកំពុងស្ថិតក្រោមការពិភាក្សាគ្នានៅឡើយ ប៉ុន្តែយ៉ាងណាក៏ដោយ តាមការប្រមើលទុក កម្មវិធីនេះនឹងជួយបង្កឱ្យមានបរិស្ថានអំណោយផលមួយ សម្រាប់ការធ្វើហិរញ្ញប្បទានដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធក្រុងប្រកបដោយចីរភាពនិងមានភាពធន់ ដោយធ្វើអាទិភាពតម្រូវការហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងសមត្ថភាពរបស់ស្ថាប័នក្នុងការរៀបចំផែនការ ការផ្តល់ហិរញ្ញវត្ថុ និងការអនុវត្ត។ ការពិនិត្យទូទៅដោយសង្ខេបមួយលើសកម្មភាពបច្ចុប្បន្នរបស់ដៃគូអភិវឌ្ឍន៍នៅក្នុងផ្នែកនគរូបនីយកម្ម ព្រមទាំងគំរូគម្រោងមានសក្តានុពលផ្អែកលើបទពិសោធន៍ ដែលមានស្រាប់របស់ធនាគារពិភពលោកត្រូវបានលើកយកមកពិភាក្សាក្នុងផ្នែក ៣.៧.១ និង ៣.៧.២ ខាងក្រោម។

### ៣.៧.១ សកម្មភាពរបស់ដៃគូអភិវឌ្ឍន៍

បច្ចុប្បន្ន មានដៃគូអភិវឌ្ឍន៍មួយចំនួនដែលសកម្មនៅក្នុងការគាំទ្រដល់ការអភិវឌ្ឍទីក្រុង តាមរយៈជំនួយបច្ចេកទេសឬគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដូចមានសង្ខេបជូននៅខាងក្រោម។ ភាគច្រើននៃដៃគូអភិវឌ្ឍន៍មិនបានកំណត់ជាក់លាក់លើ ការអភិវឌ្ឍនគរូបនីយកម្មថាជាផ្នែកវិនិយោគមួយទេ ហើយពួកគេក៏មិនផ្តោតលើទីក្រុងលំដាប់ទីពីរថាជាមូលបទមួយសម្រាប់ការធ្វើហិរញ្ញប្បទានដែរ។ មានតែវិទ្យាស្ថានកំណើនបៃតងសកល (GGGI) ទេដែលផ្តោតយ៉ាងច្បាស់ទៅលើតម្រូវការចាំបាច់ ដោយឡែករបស់ក្រុងលំដាប់ទីពីរ ក្នុងដំណាក់កាលទី២ នៃកម្មវិធីអភិវឌ្ឍន៍នគរូបនីយកម្មបៃតង (Green Urban Development) របស់គេ។ យ៉ាងណាក៏ដោយ មានការវិនិយោគច្រើនគួរសមដែរលើហេដ្ឋារចនាសម្ព័ន្ធដែលស្ថិតក្នុងតំបន់ភូមិសាស្ត្ររបស់ក្រុងលំដាប់ទីពីរ ហើយវាធ្វើឱ្យមានការយល់ដឹងអំពីកិច្ចខិតខំបច្ចុប្បន្ន ដើម្បីជួយឱ្យបណ្ដា

៩៦ See World Bank, 2017, East Asia Cities: Expanding Opportunities for the Urban Poor.

ក្រុងក្នុងប្រទេសកម្ពុជា អាចសម្រេចសក្តានុពលរបស់ខ្លួនបានពេញលេញ[៩៧]។

ទន្ទឹមគ្នានឹងកម្រិតខ្ពស់នៃភាពចាំបាច់ឱ្យមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធក្រុង និងសកម្មភាពដែលកំពុងតែដំណើរការរបស់ដៃគូអភិវឌ្ឍន៍មួយចំនួន កម្មវិធីណាមួយក៏ដោយដែលស្នើឡើងដោយធនាគារពិភពលោកនឹងតម្រូវឱ្យមានការសម្របសម្រួលយ៉ាងស្វាហាប់ជាមួយម្ចាស់ជំនួយឯទៀត។ នៅពេលដែលមានវេទិកាជាច្រើនសម្រាប់ចែករំលែកព័ត៌មាន និងពិភាក្សាបញ្ហាធំៗក្នុងចំណោមដៃគូអភិវឌ្ឍន៍នៅតាមវិស័យនានា ដូចជាទឹក សុខភាព និងអនាម័យ ដីធ្លីនិងអភិបាលកិច្ចថ្នាក់ក្រោមជាតិ ហើយមែនក៏ដោយ វេទិកាដោយឡែកមួយសម្រាប់តែបញ្ហាវិស័យនគរូបនីយកម្មនៅមិនទាន់បង្កើតបាននៅឡើយទេ។ ការបង្កើតនូវវេទិកាប្រភេទនេះ - ដែលមានសក្តានុពលអាចពាក់ព័ន្ធទាំងដៃគូអភិវឌ្ឍន៍ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសាធារណការ និងដឹកជញ្ជូនឱ្យចូលរួមជាមួយគ្នា - គឺជាជំហានចាប់ផ្តើមសំខាន់មួយឆ្ពោះទៅបង្កើតកម្មវិធីប្រតិបត្តិការមួយ ដែលពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយនូវសេចក្តីត្រូវការជាយុទ្ធសាស្ត្រ និងការងាររបស់អ្នកផ្តល់ជំនួយឯទៀត។ ភាពជាដៃគូក៏អាចត្រូវបានយកមកគិតគូរដែរនៅត្រង់ណាដែលអាទិភាពមានភាពស្របគ្នា ឧទាហរណ៍ ការផ្តល់មូលនិធិសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាចត្រូវបានយកទៅអនុវត្តដោយអ្នកផ្តល់ជំនួយមួយ ហើយការអភិវឌ្ឍស្ថាប័នដោយអ្នកផ្តល់ជំនួយមួយទៀត។

**ធនាគារពិភពលោក៖** ក្រោយពីមានសកម្មភាពជាមធ្យមអស់មួយរយៈ ហើយបន្ទាប់ពីដាក់ចេញកម្មវិធីវិនិយោគថ្មីនៅឆ្នាំ២០១៦មក ធនាគារពិភពលោកបានផ្តោតការផ្តល់ហិរញ្ញប្បទានរបស់ខ្លួនទៅលើផ្នែកកសិកម្ម នេសាទនិងអភិវឌ្ឍន៍ជនបទ សុខាភិបាល អប់រំ ការគ្រប់គ្រងហានិភ័យ និងការកែលម្អគុណភាពផ្លូវជាតិ។ គម្រោងមួយមានឈ្មោះថា Livelihood Enhancement and Association of the Poor (LEAP) កំពុងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនៅភ្នំពេញ និងសៀមរាប (ភាគច្រើនជាផ្លូវជនបទ) ដើម្បីបង្កើនការតភ្ជាប់ផ្លូវធ្វើដំណើរ និងលទ្ធភាពចូលទៅរកសេវាបាន។ គម្រោងមួយចំនួនដែលនឹងដាក់ឱ្យអនុវត្តនាពេលឆាប់ៗនេះ មានគម្រោងកែលម្អស្ថានភាពផ្លូវជាតិលេខ៤ (ដែលភ្ជាប់ទីក្រុងភ្នំពេញជាមួយខេត្តព្រះសីហនុ ឆ្លងកាត់ក្រុងច្បារមន) និងការពង្រីកបណ្តាញប្រព័ន្ធទឹកនិងអនាម័យនៅក្រុងសៀមរាប សែនមនោរម្យ (ខេត្តមណ្ឌលគិរី) និងនៅកន្លែងដទៃទៀត។ គម្រោងវិនិយោគលើការអភិវឌ្ឍនគរូបនីយកម្មមួយកក៏ត្រូវបានប្រមើលទុកហើយដែរ ប៉ុន្តែមិនទាន់ចាប់ផ្តើមធ្វើផែនការលម្អិតនៅឡើយទេ។ តាមពិត របាយការណ៍នេះជាការរួមចំណែកដល់ការឱ្យនិយមន័យរបស់គម្រោងណាមួយបែបនោះ នៅថ្ងៃមុខ។

**ធនាគារអភិវឌ្ឍន៍អាស៊ី៖** មួយភាគធំនៃការវិនិយោគរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលើការអភិវឌ្ឍនគរូបនីយកម្មក្រុងលំដាប់ទីពីរ គឺមានលើផ្នែកការគ្រប់គ្រងទឹក រួមមានការផ្គត់ផ្គង់ទឹកស្អាត អនាម័យ ប្រព័ន្ធការពារទឹកជំនន់ និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកង្វក់ (ដូចជានៅក្រុងប៉ោយប៉ែត បាត់ដំបង បាវិត ព្រះសីហនុ កំពត ជាដើម)។ ក្រៅពីនោះមានគម្រោងវិនិយោគខ្នាតមធ្យមមួយចំនួនទៀត លើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន រួមមានផ្លូវនៅក្រុងបាវិត និងផែនៅក្រុងកំពត។ នៅមានគម្រោងនឹងមកដល់មួយចំនួនដែលផ្តោតលើ «ទីក្រុងច្រករបៀង» និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ប៉ុន្តែហេដ្ឋារចនាសម្ព័ន្ធ និងទីតាំងជាក់លាក់នឹងត្រូវបានកំណត់តាមក្រោយ។ កម្មវិធីវិនិយោគបន្ថែមទៀតកំពុងតែដំណើរការនៅក្នុងការគ្រប់គ្រងសំណល់រឹងនៅក្រុងកំពត និងការគ្រប់គ្រងបរិស្ថាននៅក្រុងកំពង់ឆ្នាំងនិងពោធិសាត់។ ការវិនិយោគទាំងអស់នេះត្រូវបានតម្រង់ទៅថ្នាក់ខេត្ត ប៉ុន្តែហាក់ដូចជាផ្តោតទៅលើមជ្ឈមណ្ឌលរបស់ខេត្ត/ក្រុងរបស់ខេត្តច្រើន ដោយសារទីនេះប្រមូលផ្តុំហេដ្ឋារចនាសម្ព័ន្ធធំៗ។ បន្ថែមពីលើការវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ធនាគារអភិវឌ្ឍន៍អាស៊ីក៏បានផ្តល់ជំនួយបច្ចេកទេសដែរដល់ក្រុងមួយចំនួន ក្រោមកម្មវិធីឈ្មោះថា «ការអភិវឌ្ឍសមត្ថភាពសម្រាប់គ្រប់គ្រងនគរូបនីយកម្ម» "Capacity Development for Urban Management" ដែលមានសង្ខេបជូនខ្លីនៅក្នុងផ្នែក ២.៣ រួចហើយ។

**ទីភ្នាក់ងារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (JICA)៖** ជាង២៥ឆ្នាំកន្លងមកនេះ ទីភ្នាក់ងារ JICA បានធ្វើការវិនិយោគច្រើនសន្ធឹកសន្ធាប់ទៅលើផ្នែកហេដ្ឋារចនាសម្ព័ន្ធទីក្រុង។ នៅភ្នំពេញ ប្រព័ន្ធមធ្យោបាយដឹកជញ្ជូនត្រូវបានធ្វើការកែលម្អឡើងវិញតាមរយៈការសង់ស្ពានធំមួយឆ្លងទន្លេមេគង្គ ការគ្រប់គ្រងចរាចរណ៍ ប្រព័ន្ធដឹកជញ្ជូនសាធារណៈ និងកំពង់ផែទីក្រុងភ្នំពេញ។ បណ្តាញចែកចាយអគ្គិសនី បណ្តាញផ្គត់ផ្គង់ទឹក និងប្រព័ន្ធបង្ហូរទឹកស្អុយ ក៏ទទួលបានការកែលម្អច្រើនដែរតាមរយៈជំនួយរបស់

៩៧ ខណៈដែលមានការវិនិយោគសាធារណៈនិងផ្នែកឯកជនផ្សេងទៀតដែលផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាក្នុងក្រុងលំដាប់ទីពីរ អ្នកពាក់ព័ន្ធគម្រោងវិនិយោគទាំងនោះមិនត្រូវបានសម្ភាសន៍នៅក្នុងវិសាលភាពរបស់ការសិក្សានេះទេ។

ទីភ្នាក់ងារនេះ។ ក្រៅពីក្រុងភ្នំពេញ ទីភ្នាក់ងារ JICA បានផ្តល់ការគាំទ្រហិរញ្ញវត្ថុដល់ការរៀបចំ «ការសិក្សា ស្តីពីយុទ្ធសាស្ត្រសមាហរណកម្មជាតិសម្រាប់តំបន់ឆ្នេរ និងប្លង់គោលសម្រាប់ការអភិវឌ្ឍក្រុងព្រះសីហនុប្រកបដោយចីរភាព» (Study On National Integrated Strategy Of Coastal Area And Master Plan Of Sihanoukville For Sustainable Development) ដែលជាលទ្ធផលនាំឱ្យមានការវិនិយោគច្រើនគួរសមដើម្បីពង្រីកសមត្ថភាពរបស់កំពង់ផែក្រុងព្រះសីហនុ និងតំបន់សេដ្ឋកិច្ចពិសេសនោះក្បែរនោះ។ ក្រុងលំដាប់ទីពីរមួយចំនួនបានទទួលរួចហើយ ឬក៏នឹងទទួលបានអត្ថប្រយោជន៍ពីការស្តារឡើងវិញ និងការបង្កើនគុណភាពរបស់បណ្តាញផ្លូវដឹកជញ្ជូនជាពិសេសនៅក្រុងបាត់ដំបង សិរីសោភ័ណ ប៉ោយប៉ែត កំពង់ចាម និងសៀមរាប។ គម្រោងមួយចំនួនបានធ្វើការវិនិយោគដែរទៅលើការកែលម្អនិងការបង្កើនសមត្ថភាពរបស់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដោយផ្តង់ការយកចិត្តទុកដាក់ពិសេស ទៅលើក្រុងសៀមរាប កំពង់ចាម និងបាត់ដំបង។

**មូលនិធិអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសហប្រតិបត្តិការកូរ៉េ (ECDF)៖** ភាគច្រើននៃការវិនិយោគរបស់មូលនិធិ EDCF គឺមានទៅលើផ្នែកបណ្តាញផ្លូវជាតិ ហើយក្នុងចំណោមនោះមានគម្រោងតែមួយគត់ដែលកំពុងតែដំណើរការជាមួយការផ្តោតខ្លាំងទៅលើក្រុងលំដាប់ទីពីរ តាខ្មៅ គឺការបង្កើនសមត្ថភាពប្រព័ន្ធលូបង្ហូរទឹកស្អុយក្នុងក្រុងនោះ។

**ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD)៖** ជាប្រវត្តិកន្លងមក ទីភ្នាក់ងារ AFD បានធ្វើការផ្តល់ជំនួយដល់ផ្នែកផ្គត់ផ្គង់ទឹកស្អាតនៅទីក្រុងភ្នំពេញ។ បច្ចុប្បន្ន ទីភ្នាក់នេះមានគម្រោងទឹកស្អាត និងអនាម័យមួយចំនួនកំពុងត្រូវបានអនុវត្តធ្វើនៅក្រុងសៀមរាប ក្រុងបាត់ដំបង ក្រុងកំពង់ចាម និងក្រុងព្រះសីហនុ។ នៅក្នុងវិស័យអភិវឌ្ឍន៍ក្រុង AFD បានផ្តល់ជំនួយហិរញ្ញវត្ថុដល់គម្រោងមួយនៅក្រុងសៀមរាប ដើម្បីរៀបចំបង្កើតឧបករណ៍សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនូវតំបន់អង្គរ-សៀមរាប នៅក្នុងបរិបទមួយដែលលំហូរចូលរបស់ភ្ញៀវទេសចរ និងការពង្រីកនគរូបនីយកម្មកំពុងតែមានសម្ពុះហក់ឡើងខ្លាំង។ នៅទីក្រុងភ្នំពេញ AFD បានផ្តល់ហិរញ្ញវត្ថុដល់ការជួសជុលស្តារឡើងវិញ និងដល់ការធ្វើកំណែទម្រង់របៀបគ្រប់គ្រងផ្សារថ្មី។ ជាមួយគ្នានេះដែរ AFD កំពុងតែសម្ពោធគម្រោងសិក្សាលទ្ធភាពមួយស្តីពី «ការអភិវឌ្ឍប្រកបដោយចីរភាពនៃទីក្រុងកម្ពុជា៖ ការអនុវត្តគម្រោងក្រុងមានបរិយាប័ន្នសម្រាប់ក្រុងលំដាប់ទីពីរ ចំនួន៣ (បាត់ដំបង កំពត និងក្រចេះ/ឆ្លូង)»។

